គ្រួមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀមប្រពៃណី ចេះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនឥន្ទ្រទេវន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ ភៅ-សុំម អ្នកត្រួតត្រា
សិស្សនៅសាលាបាលីជាន់ខ្ពស់

មាតិកា

ផ្នែកអក្សរសាស្ត្រ		ទំព័រ
លោកគ្រូ លីលស់វ៉ែរ អ៊ិត-ហ្វាក់	សរសើរព្រះស្មឹ	៣៦៩
ឃុនឥន្ទ្រទេវន្ត្រី ញ៉ុក-ថែម	កុលាបប៉ែលិខ (តទៅក)	៣៧៧
អ្នកនាងញ៉ាវង្សាសារពេជ្ជ (ឧទ)	លោកនេយ្យពាក្យកាព្យ (តទៅក)	៤០៣
ផ្នែកសាសនា		
ព្រះពោធិព្រះគុណ ព្រះពុទ្ធឃោសាចារ្យ (ជ. ណាត)	អំពីបុណ្យប្លូងាសពលោកគ្រូចៅអធិការវត្តកោធិព្រឹក្ស	៤០២
ដំណឹងអំពីក្រសួងធម្មការ	អំពីតាំងចៅអធិការថ្មី	៤០៥
ហ្វឺនចណ្ណាគរក្ស ប៊ុ-ប៉	អំពីពិធីបុណ្យប្លូងាព្រះសព សម្តេចឧទ្ទេសវេទាចារ្យ (ស៊ុក)	៤០៦

ឆ្នាំទំរង់ទី ១៩ — លេខ ៧ ខែសីហា ១៩៤៣ — ដំឡៃដាក់: ១ ឆ្នាំ ១០ រៀល ។

អរិយសច្ចវិភាវនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនឥន្ទមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ ភៅ-សុំម អ្នកគ្រូពត្រ
សិស្សនៅសាលាថាលីជាន់ខ្ពស់

មាតិកា

ផ្នែកអក្សរសាស្ត្រ		ទំព័រ
លោកគ្រូ សីលសំវរ អ័ត-ហ្កាក់	សរសើរព្រះរស្មី	៣៦៩
ឃុនឥន្ទមន្ត្រី ញ៉ុក-ថែម . . .	កុលាបប៉ែលិខ (តទៅក)	៣៧៧
អ្នកនាងញ៉ាវង្សាសារពេជ្ជ (ឧង)	លោកនេយ្យភាក្យភាក្យ (តទៅក)	៤០៣
ផ្នែកសាសនា		
ព្រះពោធិព្រះគុណ ព្រះពុទ្ធឃោសាចារ្យ (ជ. ណាត)	អំពីបុណ្យប្រគាសនៈលោកគ្រូហើយអធិការវត្តកោធិព្រឹក្ស	៤១២
ដំណឹងអំពីក្រសួងធម្មការ . . .	អំពីតាំងហើយអធិការថ្មី	៤១៥
ក្រើនពណ្ណនាការ ប៊ូ-ប៊ុ	អំពីពិធីបណ្ឌប្រគាព្រះសង្ឃ សម្តេចមង្គលទេពាចារ្យ (ស៊ុក)	៤១៦

ឆ្នាំទំរង់ទី ១៩ — លេខ ៧ ខែស៊ីយេត ១៩៤៣ — ដំឡៃជាវ: ១ ឆ្នាំ ១០ រៀល ។

KAMBUJASURIYĀ

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Khun Nibandhamantri Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Kao-Sim, Surveillant général de l'Ecole Supérieure de Pāli.

TABLE DES MATIÈRES

Partie littéraire

		Pages
Achar Ith-Hak.....	Les 6 rayons de la puissance bouddhique. Poème ancien.....	369
Khun Nibandhamantri Nhok-Thèm.....	Kolap — Pailin. Roman (suite).....	377
Feu l'Oknha Vongsasarpejna Nong.....	Lokaneyya. Poème (suite).....	403

Partie religieuse

Vénérable Préas Buddhaghosachar Chuon-Nath.....	La crémation du Chau-Athikar de Vat Bodhipruks.....	412
Communiqué du département des cultes...	Nomination de nouveaux Chau-Athikar.....	415
Meun Pannanuraks Bou-Po.....	La crémation du Samdach Mangoladebachar (Souk).....	416

លោកគ្រូសីលសំវរ អ័ត-ហាក់ បម្លងពីប្បាប់ថាស់

ការបស់ការណា តែងពីកាលណាពុំគ្រាន់ ។

អហំ រែកញ្ចុំ ខុនបង្គំបង្គាប់កាយ ហត្ថាតាំងពីរថ្វាយ ប្រណម្យ
ខ្ចីកដល់ព្រះគុណ ។ សម្មាសម្ពុទ្ធស្ស កាលស្តេចគ្រាស់ព្រះមាន
បុណ្យ ឡើងគង់បិតរលើម- ណ្ឌលខែនទិព្វតែវតេជ្រមណី ។ បញ្ចេញ
ព្រះឆព៌ណ្ណ - រង្សីកាន់ខាល់ទិសទី អញ្ចុំសូមអតី- ភាពបង្គំសូមពណិនា ។
សរសើរព្រះរស្មី ព្រះជិនស្រីសម្ពុទ្ធ ចេញចែងដោយវាចា សូត្រសរ-
សើរតាមនិពាន ។ បពិត្រអើយរស្មី ព្រះជិនស្រីដ៏ខ្ពង់ញាណ ថ្កុំ-
មួយព័ណ៌មែនមាន- មានសម្បុរខ្ចីខែណា ។ រស្មីទាំងនោះមិញ សឹងចាក
ចេញពីនខា ព្រះហស្តព្រះសាស្តា ពីនខាថ្កុំវិសេស ។ សម្បុរគ្រ-
ហមផ្កៅ ប៉ាដូចខ្ចូវផ្កាចម្បាទេស ដូចជ្រាំខ្ចីនវិសេស ដូចខន់ដែងអ្នក
ដុសមាត់ ។ រស្មីគំរប់ពីរ មួយនោះទំាងចេញថ្នាត់ ពីពណ្ណរោមរ-
ត្ន សម្បុរលឿងដូចផ្កាយព្រឹក ។ ដូចផ្ទៃរត្នវិស័យ ស្រស់ថ្លៃពៃ
ល្អពន្លឺក ភ្លឺផ្ទៃគ្រឡេកភ្លឺក រុងរឿងរស្មីចាំងឡាយ ។ រស្មីគំរប់ ៣
ចាកចេញពីព្រះកេសកាយ ពីរោមនេត្រធ្វើលធ្លាយ ចេញពីរោមព្រះ
កៅណ្ឌ[1] ។ ចេញពីព្រះរោមកាយ ព័ណ៌តែងតាយល្អខ្ចីវែណ្ឌ ព័ណ៌

. ១ រោមចិញ្ចើម ។

ដូចផ្កាអញ្ចឹន ផ្កាត្រកៀតផ្កាទីលុបឬល ។ ព័ណ៌ដូចស្វាយកន្ទុំ ស្រស់បញ្ចំទឹមទិម្មល ដូចផ្ទៃកេមសោតសល់ នៃកន្ទុយក្អែកណា ។ រស្មីជាគំរប់- ជួនចេញសព្វព្រះកាយ រស្មីលឿនដូចផ្កា កណ៌តាវហែជុំជិត ។ រស្មីគំរប់ជុំ ចាកនេត្រស្តាំស្តេចស្តែងពិត រុងរឿនវង្សីសិទ្ធ ហើយចេញភិព្រះវន្តា ។ នោះសំដីសម្បុរស សុទ្ធល្អះល្អហាកដូចផ្កាខ្ទួនស្រីរៃសណា ពុំនោះដូចឰដ៏សង្ខសត្វ ។ រស្មីត្រប់ជុំមួយ ចាកព្រះឧណ្ណាលោមត្នៃ កេមកែវព្រះតក្កិកូត្រៃយ៍ ព័ណ៌ផ្កាយព្រឹកព្រោងព្រាតព្រាយ ។ មានឆព័ណ្ណរង្សី ព្រះរស្មីព័ណ៌ពណ្ណកាយ ក្រហមក៏ឆើតឆាយ លើសអស់ពាំងក្រហមផង ។ បើលឿងក៏លឿងស្រស់ល្អលើសអស់ពាំងលឿងហោង បើខៀវខៀមបំព្រឺ ល្អកន្ទុងខៀវពាំងខ្ចាយ ។ បើសក៏សស្រស់ ល្អលើសអស់សសម្ភាយ ព័ណ៌អនក៏ឆើតឆាយល្អល្អះល្អាយលើសអនផង ។ ឯព័ណ៌ដូចផ្កាយព្រឹក ភ្លឺផ្ទេកភ្លឺកចាស់ណាស់ហោង ហាក់សែងសូរ្យសាយសង្ឃ ត្រប់ជុំមួយព័ណ៌រស្មី ។ រៃលង់ពង់ពេនពាក់ ធ្លាយធ្លៀលធ្លាក់អង្គដ៏នស្រី ត្រឿនៗ ទៅមកនៃ ពុំមានអន់តាប់សៅហ្មង ។ ឧទ្ធាយសាយអណ្តែត សាត់ត្រសែតទៅមកហោង ត្រសាយសឹងត្រសង សឹងហាក់ត្រាស់សឹងហាក់ស្តើង ។ សំយោគចាកសំយុង ចុះជុំមគ្គសិទ្ធហាក់ឆ្លើង [illegible] ជាដុំសិនជាកន់ ។ អណ្តែតត្រសែតសាត់ លឿនខ្ពស់ក្តត់តណ្តោលវង់

អាកាសវេហាសង្គមំ សំនៅមុខសំនៅត្រកាយ ។ ច្រវាត់ឆ្វាត់ឆ្វៀលឆ្វាក់ សឹងច្រពាក់ច្រពូនដោយ ឆ្វាស់ឥណ្ឌាគ្នាមុខត្រកាយ សឹងច្រលួកច្រឡំភាយ ។ បពិត្រអើយវេស្ស ខ្ញុំវេទមន្តថ្លៃសាត់មុនឆ្ងាយ វេស្សលឿនជវជាយ ត្រសែតសាត់តាមដោយត្រកាយ ។ វេស្ស្រពាមហោះ ភ្លើងផ្លុះផ្លោះទៅបណ្តាយ ឯអន្ទាយដោយត្រកាយ ទៅបណ្តាយបន្ទាប់ខ្ញុំត ។ ខើបវេស្សផ្លុកភ្លើត ដូចផ្កាយព្រឹកផ្លេវផ្លុះផ្លេវត បណ្តាយបន្ទាប់ខ្ញុំត ដោយចំពួកឥណិទ័នៃ ។ វេស្សលឿនោះមិញ សឹងចេះបញ្ជាឆ័ន្ទសំដីទៅនឹងខ្ញុំវេទមន្តថ្លៃ ថាហៃវេស្សខ្ញុំវេអើយ ។ ចូរអ្នកនឹងឈប់ទៅ អញនឹងទៅមុខអ្នកអើយ វេស្សខ្ញុំវេហាក់ឆ្លើយ ប៉ដូចអ្នកចេះស្រដី ។ ថាហៃវេស្សលឿន បុណ្យអ្នកឆ្លើងដូចម្តេចនៃ ក៏អ្នកនឹងវិលវៃ ទៅជាមុនអញនេះណា ។ ឯអញនេះច្បាកដ កាលពង្សពុទ្ធចាប់ជាតា ក្នុងវង្សឆត្តក ឈ្មោះព្រះបាទស្រីពិភស្ត ។ កាលនោះឯអគ្គមន្ត ខតបក្ខិន្ទ្រិយ៍ខ្ញុំផ្លុះឈ្ងា ៤ (១) យល់ក្សត្រិយ៍ស្រីពិភស្ត ព្រះឥន្ទអគ្គិទេវតាឣ ។ ៤ ព្រាហ្មណ៍ចាស់ព្រឹទ្ធ ដល់ពោធិសូមទេព្រះ តាំងពីរសោតភជា ទ្វៀលព្រះនេត្រឲ្យទានព្រាហ្មណ៍ ។ ដូច្នេះខើបបុណ្យយើង សម្ភារថ្លើងកើតឡើងតាម ជាវេស្សខ្ញុំវេភ្លាម ទៅជាមុនអស់តាំងអ្នក ។ បពិត្រអើយវេស្សព្រហមត្រែហោះហើយហាក់ ចេះស្តាំវៃប្រែត្រឡប់ ថាហៃវេស្សលឿនអើយ ។

---

១ មើលបាលី ជាក់-ទិន "ភ្លែក" មានន័យ ដូចគ្នានឹង "ឥន្ទ្រិយគឺភ្លែក" ។

ម្តេចអ្នកទៅមុនយើង បុណ្យអ្នកថ្លើងម្តេចអ្នកអើយ ពំណាំលឿងពុំលង់
ឡើយ ហាក់ស្តីឆ្នើយតួងចរចា ។ ថាហៃព្រះស្តេ្ច ក្រហមក្រៃយើងនេះ
ណា កាលអង្គពង្សពុទ្ធ ចាប់ជាតិជាវៃបណ្ឌិត ។ កាលនោះអង្គឥន្ទអគ្គ
ថ្លៃមួយអ្នកមកទទ្ងិត ជាជាងវៃបណ្ឌិត គាសោចអ្នកឲ្យជាងខន ។
ភយដំផ្តុំផែងជាយ ក្តែងក្តួចក្តាយជាទាសហោង អម្រិទ្ធឥន្ទូជាងខន ឲ្យ
អ្នកបិទព្រះពុទ្ធរូប ។ សម្តាយើងដូច្នេះ ទើបយើងនេះចាប់ជាតិជួប
ដោយបុណ្យបិទពុទ្ធរូប ពំណាំយើងលឿងយើងទៅមុន ។ បពិត្រ
អើយកាលនោះនៃ ព្រះស្តេ្ចសុទ្ធសុិន យល់ក្រហមទៅមុន សសុទ្ធ
សុិនហាក់ចេះស្តី ។ ស្តេ្ចក្រហមអើយ នៃអ្នកអើយឈប់សិនៃ បុណ្យ
អ្នកម្តេចអ្នកថ្លៃ ក៏អ្នកទៅជាមុខយើង ។ ស្តេ្ចក្រហមហាក់ បីដូចអ្នកចេះ
ស្តីឡើង សអើយឯបុណ្យយើង កាលព្រះអង្គទ្រង់ក្នងភព ។ ភលវដ្ត-
សង្ឃភក កាលនោះណាអ្នកសម្តគ ចាប់ជាតិជាមាណព ឈ្មោះបទុម-
កុមារ ។ មានកាលនា ១ ថ្ងៃ ពស់តិសៃក្រែទាំមាគា បទុមកុមារ យក
តាំបិតមកពុះទ្រូង ។ អ្នកហើយអ្នកណាកែក អ្នកគាត់យកតែបេះដូង ផ្សំថ្នាំ
មើលម្តាយហោង ម្តាយក៏តង់ដីរិតទៅ ។ ទើបយើងកើតក្រែងក្រម
ពំណាំក្រហមដូច្នេះកូវ បុណ្យរបើងថ្លើងសន្ធៅ យើងទៅមុនអ្នកគគាត ។

កាលនោះឯងវេស្ស័ ក្រុហ្មមនៃអនហង្សជាតក[1] អណ្តែតដាលយលាត ហាក់ស្តើងទ្វើយទៅនឹងសរ ។ ចាំហៃព្រះវេស្ស័ សសុទ្ធថ្ងៃម្តេចអ្នកតំ ទៅមុខយើងនេះជា - រមែងអ្នកនោះតើដូចម្តេច ។ កាលនោះវេស្ស័ស ហាក់ទ្វើយតមួយរំពេច បុណ្យយើងនេះកាលស្តេច ចាប់ជាតិជាវេស្សន្តរ ។ ស្តេចទ្រង់ព្រះសទ្ធា មានដំណើរទ្រង់ត្រេកអរ ឲ្យទានដ៏វិស មួយទៅព្រាហ្មណ៍នៅភូគ្រាំស្លែ[2] ។ សម្ភារយើងសម្ភព តើតជ្រុំជ្រុះព្រួតាមនិ-ការ វេស្ស័ភ្លឺខ្ចុះឈ្វាស សសុទ្ធស្ទឹងមុនគគ៌ត ។ បពិត្រអើយកាលនោះក៏ វេស្ស័ល្អដូចផ្កាយព្រឹក សម្បុរភ្លឺពន្លឺក ចេះស្រដីនឹងក្រុហ្ម ។ នឹងលឿងអនហង្សថ្លាខ ថាអ្នកឃ្លាតហោះច្រលម ទៅមុនយើងនេះល្មម នឹងបុណ្យអ្នកនោះឬម្តេច ។ វេស្ស័ព័ណ៌ ៤ ថាន ហាក់ទ្វើយថ្លានមួយរំពេច បុណ្យយើងនេះកាលស្តេច ជាវិជ្ជាធរពោធ ។ អ្នកថាន តារសាច់អ្នក ឲ្យទានយក្សបិសាចស៊ី សម្ភារបុណ្យថាមី ដូច្នេះទើបយើងតើតជា ។ វេស្ស័ក្រុហ្មលឿង អនហង្សថាខដោយវាស្នា សំណូមសូមថ្លាថ្នូ ទើបទៅជាមុនអ្នកហោង ។ ហើយមានព្រះវេស្ស័ មួយថ្លាវៃក្រស្រស់ចំព្រង ដូចផ្កាយផ្កែវត្តហោង ហោះត្រសងទៅជាមុន ។ វេស្ស័ព័ណ៌ប្លួនថាន ដូចហាក់មានវិញ្ញាណគន់ ហាក់ស្តីថាអ្នកមុន បុណ្យ

---

១ មើលថា ហង់-ស្សាត, « ដើងហង្ស » ពីសម្បុរក្រហមខ្លួចសម្បុរដើងហង្ស (ត្រដើងក្វាន) ។ (២) ពលិង្គវាស្ត្រ

អ្នកតែដូចម្តេចខ្លះ ។ ស្មើតំណាក់ផ្កាយត្រីក ភ្លឺផ្កេកភ្លឺតែត្រឿនរះ ដ៏ដូច
ចន្ទចែងជ្រះ ចរចាចែងចេះស្រស់ ។ ថាកាលតុន្តឹរ ស្តេចអាទ្ធាល
ចាប់ដាតី ជាសោមបណ្តាតថ្ងៃ ម្ហូបនោះនៃមានចិត្តកាត់ ។ ដំឡាសា-
ណាណ៌ធំ ចិត្តចង់ប៉ំពេញគាខក្តាត់ ឥន្ធូតង្គ្រែងង៉ំបង្កាត់ ក្លៀងភ្លឺជាក់អ្នក
អធិដ្ឋាន ។ ចូលកន្លែងក្លៀងនោះណា សាច់ឆ្អឹងអារជាក់ឲ្យគាន ហេតុតែ
បុណ្យយើងមាន ទើបកើតជាតំណាក់ផ្កាយត្រីក ។ ឋានត្រអើយវាស្មើ ធរឿរ
ភ្លឺផ្កេកភ្លឺក ហាក់នាំគ្នាតតឹក ហោះរង្គៀតង្កែផកទៅឯក្រោម ។ ចុះដល់
ឫស្សរដែនកំព ឃល់តាន្ធឹកពន្ធឺត្រម ជាឃដុំរឡើងខ្សោម ដល់អរូប-
ព្រហ្មាយ ។ អណ្តាប់សង្ខាង់តន់ ដល់អនន្តបត្រក់ឡឆ្វាយ ភ្លឺដាល
ជាសសត្វសាយ ឃល់សត្វកុំសត្វសារតោ ។ សត្វជ្រោះសត្វច្រកល្អក
សត្វឈូងឆកតែពែកគ្រាមលើ ដ៏ណាសូរ្យចន្ទដើរ ចែងតាន្ធឹតុំបានដល់ ។
ស្មើព្រះខ្ញង់ញាណ ភ្លឺសភ្ញាខសត្វមណ្ឌល សត្វដែនសត្វក្រែលំ
សត្វរូងន្នេសត្វទានា ។ ឋានត្រអើយគាលតម្លែង ស្តេចសម្តែងព្រះដ៏-
ហាវ្យ កត្រែកជាអស្ចារ្យ ប្រថពីញ៉ាវន្ធត់ ។ ពុះពោរជាវដន់ដែង
បៃតងជាតែឆ្ងាមហាសមុទ្រ សុមេរុក៏ត្រាមទ្រុង ឆ្នូលំពោនពោរពន់
ពាស ។ ទាំងសត្វតូរ្យតន្ត្រី លាន់ឮតីកេះរៀងរាស ប្រដុំចង្កើតាស ថ្វាយ
បូជាព្រះទសពល ។ ទាំងរូបត្រាល្ហ(១) ទាំងរោគាភ៌ថ្វាយទ្រង់ ព្រះឥន្ទ

---

១ មើលថា រូបត្រាល្ហ ត្រូវមាន "ព្រហ្មាខរូប" ។

សោតមកគាល់ កាលព្រះអង្គខ្ញុំជាដំហរ្យ ។ ថវាញ្ជួរស្នែ
ព័ណិច្រមច្រុយល្បីអស្ចារ្យ តើតដោយរំខ្ញុំជាដំហរ្យ មានអាតារល្អ
ចំពោះ ។ ទុអស់យើងពាល់គ្នា ពាន់ជាតិពីកាលនោះ ម្តេចឡើយ
អត្តិសោះ មកពាន់តែព្រះសាស្តា ។ ខ្ញុំធម៌ ៩ ហ្មឺន បួនពាន់ច្រើន
ជម្ម្តន្ត្រា ខ្លះរៀនជាពិស្តារ ខ្លះរៀនជាសង្ខេបពាន ។ តែកាលពុទ្ធុប្បាទ
ជិតនឹងចូលព្រះនិព្វាន ខ្ញុំបើកឋនូលប្តាន ឆ្លុះនឹងអង្គអនុជា ។ អា-
ឧទ្ទូអនុជទៅ ចូរអ្នកនៅឋន្តិចរ៉ា តថាគតជាក ចាកឋោលចាចូលនិព្វាន ។
បើឥតនឹងអញទៅ ព្រះពុទ្ធនៅអំពាសមាន ចូរចាកុំថាគ្មាន ព្រះពុទ្ធ
ឡើយកុំណាចា ។ ធម៌ពាន់ ៩ ហ្មឺន ៤ ពាន់ច្រើនវៃគណាស់ណា ខុក
តាន់អង្គតថា- តតទ្ធូន្តានច្រៀសសក្ខសល់ ។ ទុអស់យើងពាល់គ្នា រក
រៀនរ៉ាឲ្យចានដល់ ឲ្យស្គាល់កុំឲ្យសល់ អង្គព្រះពុទ្ធគ្រប់ព្រះអង្គ ។
ឲ្យស្គាល់ទូវព័ណិនៃ ព្រះរស្មីព្រះពុទ្ធពង្ស ទំរៀនកុំបង្អង់ សូត្រសរ-
សើរសេព្វវេលា ។ អ្នកនោះឯងនឹងបាន ដៀសចាកឋានចតុព- ចាយចាប
លែងជាតា ចាប់ជាតិទៅសួគ៌សុខសល់ ។ សម្បត្តិសម្បុរបុណ្យ ច្រើន
អនន្តអនេកស្តល់ សោយភោជ្យឥតអំពល់ លើសាកលជម្ពូទ្វីប ។ មាន
ទ្រព្យកប់ពាន់ហ្មឺន ចរិការច្រើនចានសោយសេព សម្បត្តិបុណ្យជន្មដ៏ឥត
ដកឋដល់កាលកិរិយា ។ រូបនោមរោមព័ណិពេញ ជាសំឡាញ់អស់

ទេវតា មានវិជ្ជាចេស្តា ឈ្នះសត្រូវទិសទាំង ១០ ។ សោយបុណ្យជាន
សព្វកាល មិនដែលស្គាល់គប់ប្រសព្វ ទុក្ខសោកភេគតារគត ភ័យតិត
ភូមិចតុរបាយ ។ តេជះបុណ្យជាម៉ែ ស្គាល់ស្មើព័ណ៌ពណ្ណរាយ ដឹងឆ
ល័ក្ខណ៍ឆ្បើសាយ សូត្រសរសើរសព្វវេលា ។ តាលសូត្រឲ្យតាំងចិត្ត ឲ្យ
ប្រព្រឹត្តហ្មូច្យា ប្រព្រឹត្តបានហើយណា អ្នកនោះបានឧទ្ទិភ្ជាន
ហោង ។

ចប់សរសើរព្រះរស្មីតៃប៉ុណ្ណោះ ។

ឃុនធិពន្ធមន្ត្រី ញ៉ុក–ថែម រៀបរៀង (តទៅ)

មុខគួរឲ្យអនិច្ចាដល់ចៅចិត្រ៍ អុដថ្ងៃដែលក់អង្គុយកុកមើលពន្លឺភ្លើងធ្វើក្អែកភ្លឺ។ ដែលភ្លើងកំពុងឆេះត្រលប់ទៅជាផេះ ឯគំនិតចេះតែគិតផ្សេង។ អណ្តែតអណ្តង់ទៅតាមអារម្មណ៍របស់ចិត្ត ឃើញដកដង្ហើមធំម្តង ប្រហែលដូចជាចង់ដកទុក្ខធំ ដែលតប់នៅក្នុងទ្រូងឲ្យផុះភ្លាត់ទៅខ្លះ។ ការធ្វើយ៉ាងនេះ ជាការយោបល់មនុស្សដែលមានទុក្ខធ្ងន់ក្នុងទ្រូង តែទុក្ខសោកក្រហល់ក្រហាយរបស់បុរសកំឡោះ។ ដូចជាចៅចិត្រនេះ គង់មិនមានអ្វីក្រៅពីសេចក្តីស្នេហាប្រដិព័ទ្ធ ចំពោះរូបស្ត្រីក្រមុំណាមួយប៉ុណ្ណោះ ប៉ុន្តែសេចក្តីស្រឡាញ់ស្នេហារបស់ចៅចិត្រនេះខុសខ្លង់គ្នាឆ្ងាយណាស់ ហាក់ដូចឈោងដៃចាប់ផេះផ្កាយលើមេឃ ឥឡូវនេះចៅចិត្រទទួលសន់គួថា ខ្លួនចាប់ចិត្តស្នេហាលើរូបនាងនារី ដែលជាចៅហ្វាយក្រមុំរបស់ខ្លួន ពុកជាមិនសមរម្យគ្នាយ៉ាងណាក៏ដោយ ក៏ចៅចិត្រយល់ថា សេចក្តីស្រឡាញ់ស្នេហារបស់បុរសស្លូតត្រង់លោកនេះ មិនមានកំរិតកំណត់ព្រំប្រទល់ដូចម្តេចឡើយ ដូច្នេះហើយបានជាចៅចិត្រចង់ឈោងដៃបេះផ្កាកុលាបមែលមិននេះ តែមកនឹកគិតថាខ្លួនដៃខ្លី មិនគួរគប្បីស្រាវឆ្ងល់ឡើយ ទុំដំនាំឲ្យកើតទុក្ខគោមនស្សក្រៃលែងទៅជា

ស្រឡាញ់បងចិត្តឥតប្រយោជន៍ នឹកមកដល់ពីមុននេះ ចៅចិត្តក៏ដកដង្ហើមធំម្តង។ ចារឹមយ៉ាងនេះអស់ទៅ ហូតយកចារឹមយ៉ាងទៀតមកជក់ដិតអស់តាក់តណ្តាល ឯគំនិតក៏បេះតែគិតទៅ។ យ៉ាងលង្ខន់លង្ខោចតែម្នាក់ឯង; ចំណែកខាងនាងវិញ និយាយសាសំតូជាមួយនឹងបាឡាត់ស្រុតនោះ ហាក់ដូចជាត្រូវចិត្តគំនិតគ្នាណាស់ ។

ចៅចិត្តបានឃើញកិរិយាដូច្នេះ ក៏នឹកឥច្ឆាឈ្នានីសសោកចាឡាត់យ៉ាងលើសលន់ មើលទៅគេតាំងពីនោក់ស្រុះស្រួលគ្នាល្អណាស់ដូចជាគេរៀបចូនមួយ ប្រហែលជាគេស្រឡាញ់គ្នាច្រើនហើយទេដឹង ? មែនហើយ ! បាឡាត់នេះគាត់ទៅលីវថែមទាំងមានទ្រព្យធនត្រាន់បើផង ហើយរូបឆោមសោភទៀតក៏មិនជាអាក្រក់ប៉ុន្មាន នាងនារីគង់ប្រថុយស្រឡាញ់គេរួចទៅហើយ ចុះចំណែកខាងអញ ? មានសភាពដូចម្តេច ? នាងនារីមានសភាពដូចម្តេច ? នៅខ្ជិនខ្ជិលសាបជាងគ្នាឆ្ងាយណាស់ បើខុកជានាងនារីនឹកស្រឡាញ់អញវែរ ក៏គង់មិនហ៊ានប្រថុយរេ វែគ្រងខ្លួចក្តើរឈ្មោះរវើរគ្រកូលបេះនាង ព្រោះអាត្មាអញខានហ៊ានត្រឹមកម្មករ ហើយជាកម្មកររបេះនាងទៀតផង តើអាត្មាអញតូចតាបវាំងបុណ្យស័ក្តិ ទាំងទ្រព្យធន ទាំងរបរកេស៊ុ ដូច្នេះអាត្មាអញមិនគួរជាបង្គត់ស្រឡាញ់នាងទេ ដូចមានភាសិតបុរាណបង្គែងខុកថា "ខ្លួនជាបក្សីតោង

ដៃខ្ញុំកុំឈោង ប្រាថ្នាចង់ភ្ជាប់" ។ ចៅចិត្តគិតមកដល់ត្រណោះ ស្រាប់តែកើតគំនិតមួយជាដែកនឹងគំនិតមុនថា ធម្មតាសេចក្តីស្នេហាស្រឡាញ់នេះមិនមានកំរិតជាន់ថ្នាក់អ្វីឡើយ ប្រុស-ស្រីគ្រប់រូបគេអាចស្រឡាញ់គ្នាបានតាមចិត្តស្ម័គ្រចស់ខ្លួន សេចក្តីសំខាន់បំផុតស្រេចនៅលើម្ចាស់ខ្លួនខាងស្រីទេតើ! លុះចៅចិត្តគិតដូច្នេះហើយ ក៏ដកដង្ហើមវែងម្តងដើម្បីឲ្យធូរទ្រូងចិត្ត ។

សូរស្បែកជើងដើរតន្ទ្រឹនចូលមកជិត ចៅចិត្តក៏ក្រឡេកមើលទៅឃើញនាងនារី កាន់កាំភ្លើងខ្ញីមួយនៅក្នុងដៃមកផង ហើយសួរថា "មិនចាន់ឆ័ុយដេកទេឬចិត្ត ?

ចៅចិត្តញញឹមហើយថា "ខ្ញុំក៏មិនចាន់ឆ័ុយទេ, ឃុន, នៅវេលានេះមិនចាន់ជាយប់ផ្លែប៉ុន្មានទេ តែនៅតណ្តាលព្រៃ ម៉ោលទៅឃើញហាក់ដូចជាយប់អធ្រាត្រណាស់ទៅហើយ!

នារី- "ស្រួលហើយ, ចិត្ត, បើមិនចាន់ឆ័ុយនៅចាំយាមទៅសិនចុះ ហ៎! យកកាំភ្លើងនេះទុកបង្ការខ្លួន បើឆ័ុយដេកវេលាណាទៅជាស់សោកបាត្បាត់ឲ្យមកនៅចាំយាមដំណួសវិញ" ។

ចៅចិត្តទទួលយកកាំភ្លើងមកហើយ ក៏សួរទៅនាងវិញថា " ចុះឃុនឆ័ុអញ្ជើញទៅសម្រាន្តឥឡូវឬ ?

នាវ៉ាញាក់មុខហើយថា "ខ្ញុំគិតដេកតាំព្រលប់បន្តិច ដ្បិតអស់កំ-ឡាំងគាំងពីថ្ងៃមកហើយ" ។

ចិត្រ_. "ឃុនទឹកភ្លាចទេ ការដែលមកនៅស្នាក់ក្នុងវត្តស្អាត់ជ្រុះ?

នាងញាក់ស្មាម្ខាងថា "ខ្ញុំក៏ទឹកភ្លាចខ្លះដែរ តែមិនសូវជាច្រើនប៉ុន្មានទេ" ។

ចិត្រ_. "បើដូច្នេះ សូមឃុនមេត្តានៅកំដរខ្ញុំបានបន្តិចសិនចុះ" ។

នាវ៉_. "ចុះអ្នកឯងឆ្ងាយណាស់ឬ ចិត្រ?

ចិត្រ_. "សូមទោស, ខ្ញុំបានមិនជាឆ្ងាយណាស់ណាទេ ប៉ុន្តែឆ្ងាយព្រឹកអង្គុយឆក់ជ្រុលដេកលក់ទៅនាំឲ្យខូចការធំ!

នាងនាវ៉ានៅតែសួរ ទើបចៅចិត្រកេងបាយដ្តើមនិយាយឡើងមុនថា "ចុះឃុនទឹកទៅផ្ទះវិញឬទេ?

នាវ៉_. "ខ្ញុំទឹកដល់ផ្ទះច្រើន, ចិត្រ, ព្រោះមិនមានចាស់ទុំនៅចាំផ្ទះសោះម្យ៉ាយ" ។

ចិត្រ_. "ព្រឹកស្អែកនេះគង់តែបានទៅដល់ផ្ទះទាំងអស់គ្នា" ចៅចិត្រនិយាយបន្តិច។ ស្ទើរតែមិនឮហើយបា ... បើយប់នេះ ខ្ញុំខានវេបុរេះបរមកតាមផ្លូវនេះទេ, ខ្ញុំបានទឹងត្រែកពីយប់ចេញដើរទៅ

ម្រហែលជាថ្ងៃរសៀល តង់រៀមមកទួលឃុនត្រឡប់ដល់ផ្ទះទាំងអស់គ្នាមិនខាន" ។

នារី_. "ដើរទៅរួចឬចិត្ត? ដាំតង្កូវតាំងនេះទៅផ្ទះយើងវាយក្រលវែរ មិនមែនដិតទេ" ។

ចិត្ត_. "ទុកដាក់ទៅរួចឬមិនរួច ក៏ខ្ញុំចាត្រូវតែទៅ, បើខ្ញុំចាមិនទៅទេ, មុខជានាំគ្នាដេកផ្ទះរនៅថ្ងៃនេះ ជាច្រើនយប់ទៅទៀតមិនខាន; ន! ន្ទុះហ្ន៎! ឃុន, ព្រះចន្ទ្រនឹងភ្លាយភ្លឺច។ នៅទាំងគ្នានោះល្អមើលណាស់ ឃុនគាប់ចិត្តនឹងធម្មជាតិនោះដែរឬទេ? ឯខ្ញុំចាចូលចិត្តណាស់!

នាងនារីសំឡឹងមើលទៅតាមដៃដែលចៅចិត្តចង្អុលថ្កាប់ ព្រមទាំងចិត្តគំនិតក៏រីករាយទៅជាមួយផង តែឮរនេះនាងបាត់ស្លប់ខ្ចឹមចៅចិត្តហើយដែរជាមានសេចក្តីពេញចិត្តថែមទៀតផង ។ ចៅចិត្តជាប្រុសតំណើរដំបូង ដែលធ្វើឲ្យនាងមានចិត្តគំនិតយ៉ាងចំឡែកប្លែកជាងពីមុន ។ មក ឯកំឡាំងរបើងរឹងរូសរបស់នាងក៏ថយខ្សោយបុះទៅជាលំជាប់ តែឮរចិត្តនាងដែរជាខន់ក្ងន់ស្ងន់ណែ្លដូចជាត្រមួនត្រូវកំដៅថ្ងៃ ។

_ ចៅចិត្តសំឡឹងមើលដួងចន្ទ្រដោយអាការស្ងប់ស្ងៀម តែខាងក្នុងចិត្តដូចជាអណ្តែតអណ្តូងយ៉ាងចំឡែក ក្នែកក៏មើលធម្មជាតិដ៏ល្អល្អះនៅខាងមុខ ហាក់ដូចជាមិនដឹងខ្លួនថា នាងនារីដែលជាកុលាបត្រពុំត្រហ្មាចារ នៅក្បែរខ្លួនឡើយ ។

កាលនាងយើញចៅចិត្រនៅសំងំស្ងៀមឈឹងដូច្នោះ ហើយឮសួរ
ដកដង្ហើមវែងម្តងៗ ទើបនាងសួរឡើងៗ ថា "តើតនុក្ខអីចិត្ត ?

ចិត្រ- "ជាទ, ខ្ញុំជាទកើតសេចក្តីអផ្សុកយ៉ាងចំឡែក !

នាងនាវិញញឹមបន្តិចៗ ហើយសួរថា "ចុះម៉េចក៏អផ្សុក ទឹក
ក្រមុំស្រុកសង្កែឬ ?

ចៅចិត្រសើចយ៉ាងសោកក្រៃហើយថា "ស្រុកសង្កែឬឃុន,
ខ្ញុំជាទឥតចិត្តទឹកនាចន្តិចឡើយ តាមរាយពិតនោះ វាជាស្រុកស្រណុក
សប្បាយសម្រាប់អ្នកមានធនធាន ឯអ្នកទីទាល់ក្រដូចរូបខ្ញុំជាទនេះ មិន
មានអ្វីនាំឲ្យជាប់ចិត្តបន្តិចឡើយ" ។

នាវីសើចហើយសួរទៀតថា " ចុះស្រុកចម្ប៉ីលិនេះ តាំងពីចិត្រ
មកទៅ តើនាំឲ្យជាទសុខកាយសប្បាយចិត្តជាងនៅស្រុកសង្កែឬ ?

ចិត្រ "ជាទ, ចម្ប៉ីលិនឲ្យសេចក្តីសុខដល់ខ្ញុំជាទច្រើនៗ ដល់ទៅ
ទឹកចង់ផ្ទៃដីដ្ឋានៅទីនេះតែម្តង !

នាវី-" ចុះខណៈនេះអ្នកឯងនឹកនាណា ជាន់ជាមានទឹកមុខក្រៀម
ក្រំតាំងម្ល៉េះ ?

កាលនាងនាវីផ្លាស់សព្ទថ្នាំ "ចៅចិត្រ" មកជា "អ្នក" ទេដូច្នេះ
ដើរឲ្យចិត្រក្រសឹកមើលមុខមាងនាវីសឹងតាល់តែនាវីដាក់មុខចេញ
ថែរម៉េលស្ទៅនៅចំពោះមុខ ។

ចិត្ត- "ឃុនប្រើពាក្យថា "ខ្ញុំក" ជំនួសចិត្តនោះ ដូចជាខ្ពស់ពេក សម្រាប់ខ្ញុំណាស់; សូមឲ្យឃុនមានប្រសាសន៍ដូចមុនល្អជាង!

នារីសើមមួយស្រមក់ហើយពោលថា "ខ្ញុំគាប់ចិត្តប្រើពាក្យនេះជាង, វាមិនខ្ពស់ហួសទេ, ជាពាក្យសុភាពគួរសមហើយ" -

ចៅចិត្តសើម ទើបនាងនារីនិយាយតទៅទៀតថា "អ្នកឯងមិនទាន់ឆ្លើយពាក្យសួរបស់ខ្ញុំនៅឡើយ ខ្ញុំសួរថាខៅបបែលិនឲ្យសេចក្តីសុខអ្វីដល់អ្នកឯងខ្លះ ?

ចិត្ត- "ឲ្យច្រើនយ៉ាងណាស់ឃុន !

នារី- "អើ! ចុះអ្វីខ្លះ ?

ចិត្ត-,, ឲ្យមានបារម្ភធ្វើការរកស៊ីដោយសុចរិត, ធម្មជាតិដ៏ស្រស់-បស់គួរជាទីត្រេកត្រអាល, ខ្យល់អាកាសក៏ល្អ, សេចក្តីសុខ ឥស្សរភាពនឹង . . ."

នារី- "នឹងអ្វីទៀត ? (នាងឈ្ងោកសួរ) ។

ចៅចិត្តសំឡឹងមើលមុខនាង ដោយមានសេចក្តីប៉ុនប៉ងអ្វីមួយនៅខាងក្នុងដួងចិត្ត ហើយនិយាយខ្សាវៗ ស្ទើរជាខ្សឹបថា "នឹងសេចក្តីស្រឡាញ់ស្នេហា !

នារី- "សេចក្តីស្រឡាញ់ ! នាងផ្ទួនពាក្យឡើងខ្ចីតមុខក្រហមត្រឡឹងៗ ។

ចិត្រ- "ខានក្រែងស, សេចក្តីស្នេហាបងសំខ្ញុំចាខជាសេចក្តី
ស្នេហាដ៏បរិសុទ្ធពិតក្រៃពេកជណាស់ ហើយជាស្នេហាដែលខ្ញុំមកើតឡើង
ជាដំបូងបង្អស់ក្នុងជីវិតរបស់ខ្ញុំចាខនេះផង" ។

នាងនារីហាក់ដូចជាដឹងដល់ដួងចិត្តរបស់ចៅចិត្រដែរ តែធ្វើពើជា
ឥតដឹង ឥតយល់អ្វីដល់តិចឡើយ ហើយសួរគេទៅទៀតថា "អ្នកឯង
ស្រឡាញ់ខរណា ?

ចិត្រ- "ខ្ញុំស្រឡាញ់ស្រីម្នាក់" ។

នារី- "ខ្ញុំដឹងហើយថាស្រឡាញ់ស្រី តែស្រីខោះនៅឯណា ?
ឈ្មោះអ៊ា ឬមួយនាងម៉ាយ៉ុង កូនក្រមុំតាម៉ងយ៉ុក មេអណ្តូងត្បូងមួយ
នៅខាងជើងផ្ទះយើងខោះ ? នាងថាហើយក៏សើចយ៉ាងស្រួល ។

ចិត្រ- "គ្រវីក្បាលជំទួសពាក្យតប" ។

នារី- "អើ, យ៉ាងចឹងនាងណាអេះ ឬមួយនាងព្រហ្មកូនក្រមុំ
តាសុខ ?

ចៅចិត្រក៏គ្រវីក្បាលទៀតជាសេចក្តីបដិសេធថាមិនមែនទាំងអស់ ។

នាងនារីញញឹមស្រួលដោយទឹកអស់សំណើចទើងចៅចិត្រហើយ
ថា "អេ ! ប្រហែលជាអាម៉ួយកូនចៅសេងលក់ទឹកកកមកមុខផ្ទះយើង
ខេដឹង ?

ចៅចិត្តគ្រីក្សាលខៀតហើយថា "ខុសពាំងអស់ ស្ត្រីដែលខ្ញុំបានស្រឡាញ់នោះ មានថ្នាក់ជាន់ដោយឡែកពីគ្នាទីណាខ្ញុំបាន នាងមានឋានៈខ្ពង់ខ្ពស់ជាងខ្ញុំបានច្រើន ពាំងកិត្តិយស ពាំងទ្រព្យសម្បត្តិវង្សត្រកូល ខ្ពស់ពាល់តែខ្ញុំបានឈោងគោងចៅមិនដល់ឡើយ ហេតុនេះហើយបានជាខ្ញុំបានដំពាក់ថា សេចក្តីស្នេហារបស់ខ្ញុំបាននេះច្រើហួសខំណាយលស់សប្តិ ទំនងត្រឡប់ក្លាយទៅជារឿងពិតមិនបានឡើយ" ។

កាលបើនាងបានឮសំដីចៅចិត្តនិយាយយ៉ាងត្រង់ត្រមែត្រមៃដោយអស់សង្ឃឹមក្នុងចិត្តដូច្នោះហើយ បេះដូងរបស់នាងក៏ណែនតានតឹងក្នុងទ្រូងជាខ្លាំង នាងចង់តែសុំលន់តួច្រាប់ដោយត្រង់ៗថា "នាងក៏ស្រឡាញ់ចៅចិត្តជាខ្លាំងដែរ; តែអនិច្ចាខ្លួនជាស្ត្រីនិយាយសំដីដូច្នេះសមគួរហើយឬ? ឯសំដីចៅចិត្តត្រង់ៗ ម៉ាត់ នាងស្តាប់បានពាំងអស់ឥតមានខ្វះកន្លះត្រង់ណាមួយម៉ាត់ ដូរតែខ្លួននាងមានវ័យចំរើនធំហើយ មិនមែនក្មេងតូចដែលនឹងលែងចេះដោះគាលណា ប៉ុន្តែការនេះវាហ៊ាសពេកណាស់; ទុ! ពុទ្ធោ! ពុទ្ធោ! អើយ! ទំនងបញ្ហេញច្រាប់រួសពន់ដួចម្តេចបាន, ក្នុងថ្ងៃណាមួយ, ចិត្តគង់បានដឹងថា នារីឥតស្អប់ខ្ពើមទេ ថែមពាំងមានចិត្តស្នេហាស្រឡាញ់ខៀតផង មិនឥឡូវតែឡើយ ជាវេលាយូរថ្ងៃ-ខែណាស់មកហើយ ។

ឯក្ងើនក្តក់ក៏លេតសូទ្យឈើនៅ សូរសេតូសក្ងៃយំឮលាន់រំពង
ព្រៃ មាន់ព្រៃក៏មមើរជាវគ្នាក្រតើស្ងាត់ ទឹកសន្សើមក៏ជ្រុះស្រក់ចុះពី
ស្លឹកឈើមិនដាច់សូរ ហើយមើលឃើញសក្សុសនៅបុងស្មៅ ខ្យល់
ត្រជាក់បក់មកត្រូវកន្ទេងកាយ នាំឲ្យបុរសស្តីចាំងពីមោត់រាំងខ្លាំងឡើង ក្តុ
ខ្ពស់ត្រដែតនៅខាងមុខ ត្រង់កណ្តាលពន្លឺដួងចន្ទនោះហាក់ដូចអសុរ.
កាយ នៅចាំយាំវក្សាព្រៃត្រឹកក្បាដ៏ស្ងាត់ជ្រៀបនោះ ។ ចៅចិត្រសុះ
ក្រោកឡើងពត់ខ្លួនជ្រាណឲ្យបាត់ពេលស្រពន់ ដែលគ្រាអង្គុយនិយាយ
មនជាវេលាយូរហើយដកដង្ហើមធំ ។

ចិត្រ— "យប់ជ្រៅណាស់ហើយ, អញ្ជើញឃុនៅសម្រាន្តឯ
វេយន្តជាមួយនឹងលោកឪពុកចុះ ខ្ញុំបាទនៅចាំយាមសូមកុំព្រួយឲ្យសោះ!

នាវ— "ចុះអ្នកឯងមិនខាន់ងុយដេកទេឬ? នាងក្រោកឡើងដើរ
ទៅហើយជាកមកញញឹមបន្តិច ។

ចិត្រ— "ខ្ញុំបាទមិនខាន់ងងុយទេ, អញ្ជើញឃុនៅសម្រាន្តចុះ
កុំបីមានសេចក្តីព្រួយក្តួចក្តីឲ្យសោះ អ្នកដែលចូលមកធ្វើអន្តរាយដល់
ឃុនបាននោះ លុះត្រាតែខ្ញុំបាទស្លាប់ទៅជាមុនស្រេចហើយ ។ណ:
ទេះខ្ញុំបាទនឹងយកជីវិតរក្សាការពារអន្តរាយគ្រប់ទិស សូមឲ្យឃុនសម្រាន្ត
ជាសុខចុះ" ។

នាងនារីជាកម្មករៅរកៅចិត្តម្ខាងទៀត ព្រោះបានឮសំឡេងស្រែកហៅ ដោយសួរសំឡេងកិតក័យតក្តមា ។

"ឃុនានារី" ចៅចិត្តស្រែកហៅហើយគ្រាកឈរឡើងសំឡឹងៅខាងមុខ លើកដៃចង្អុលបង្ហាញឱ្យនាងមើលតាមដៃហើយថា "ឃើញទេឃុន! ខ្ទុះហ្នឹងខ្វីក្តើងអ្វីចំឡែកណាស់!

នាងនារីសំឡឹងមើលតាមដៃដែលគេចង្អុលប្រាប់ ក៏ឃើញពន្លឺក្តើងដូច្នោះមែន នៅចម្ងាយជាង ១ គីឡូម៉ែត្រ នាងទំសង្កេតមើលៅកាន់តែឃើញពន្លឺគប់ក្តើងនោះច្បាស់ឡើង។ ហើយដើរសំដៅចូលមកកាន់តែជិតឡើង ។ នាងមានសេចក្តីភ័យខ្លាចយ៉ាងខ្លាំងញាប់ញ័រអស់សព៌ាង្គកាយ ព្រោះមិនដឹងជាមានហេតុល្អអាក្រក់ដូចម្តេច នាងសុះៅចាប់ដៃចៅចិត្តជាប់ដោយឥតដឹងខ្លួនបន្តិចសោះ ។

ចៅចិត្តចែកគ្រាប់កន្ត្រកាំក្តើងរួចស្រេច ប្រាប់នាងនារីឱ្យៅជាស់លោកហ្នឹងនឹងលោកថា ឡាត់ឯងវិញន្ត មួយស្របក់ជនចាំង ៣ នាក់ត្រឡប់មកវិញត្រមគ្នា ។

លោកហ្នឹងសួរយ៉ាងសស្មើតសស្លក់ថា "តើតអ្វី: ចៅចិត្ត?

ចៅចិត្តចង្អុលៅពន្លឺក្តើងដែលកំពុងតែចូលជិតមក។ ត្រប់។ ណ: ហើយថា "ពានក្រោស! សូមពិនិត្យមើលគប់ក្តើងខ្ទុះ មិនពាន់ដឹងជាអ្វីទេ!

"ប្រពៃហើយដាពួកចោរទេដឹង? លោកបាឡាត់និយាយទៀងមុនគេ។

"ប្រពៃហើយដាពួកចោរមែន! ចៅចិត្តថាផ្លូន។ តាលចៅចិត្តនិយាយដូច្នេះហើយ ហ្លួងវាតនសម្បត្តិនឹងលោកបាឡាត់ក៏នាំគ្នាត់ទៅឯរថយន្តរកបានដែករំលែរថយន្តមួយម្នាក់ សម្រាប់ប្រើជាអាវុធបង្ការខ្លួន។

ឯនាងនាញ៉ែរខ្លួនចំប្រប់ដូចជាកូនសត្វ ឈរនៅក្បែរចៅចិត្ត។ ចាប់ដៃនាងជាប់ហើយប្រាប់ថា "ឃុនកុំតក់ស្លុតឲ្យសោះធ្វើចិត្តឲ្យក្លាហានទៀង, ឃុនក្មេចពាក្យដែលខ្ញុំបានសន្យានឹងឃុនហើយឬ?

នាងមិនតបដូចម្តេចទៀយ គ្រាន់តែចាប់ដៃជាប់, ចៅចិត្តប្រុងខ្លួនយ៉ាងអង់អាចអង់ចាំពេលវេលា ដែលនឹងមានមកដល់ឥឡូវ។ នោះដាពេលវេលាដែលមិនទាន់ដឹងដាមានហេតុគេដូចម្តេចតើតទៀងនៅឯណ:នោះទេ។

នៅទីបំផុតនោះ ស្រាប់តែឮសំឡេងស្រែកហ៊ោកងរំពង គាកណ្តាលព្រៃស្ងាត់នាំឲ្យដឹងថា ពួកចោរនោះមានចំនួនច្រើនណាស់ ហើយឮសូរកាំភ្លើងច្រើនណាត់ប៉ាញ់ដម្រង់មក មានគ្រាប់កាំភ្លើងខ្លះធ្លាក់នៅខាងមុខចៅចិត្តក៏មាន។

អ្នកទាំង ២ គឺលោកហ្លួងនឹងលោកបាឡាត់ឃើញគ្រាយៅយកថយន្តដាគ្រឿងកំបាំងអន្តរាយ ហ្លួងវាតនសម្បត្តិខុសដាចាស់ហើយក៏ពិតមែន តែនៅមានស្មារតីហ៊ាស្មគ្នងរំណាស់ សមជាបុរសជាត ឯលោក

ចាំឡាត់ស្ងន់សសើតសសក់ ទំលូនចូលទៅនៅខាងត្រែមវេយន្ត ឯ
ខាងនារីមិនព្រមឃ្លាតឆ្ងាយពីចៅចិត្រឡើយ នៅតែចាប់ដៃជាប់ស្អិត
ក្នុងខណៈនោះ ចៅចិត្រអែបបំពាំងខ្លួនទឹងដើមស្រឡៃធំ ១ ដើម ។

ស្រួសំឡេងហ៊ោគឹកកងរំពងនោះគាន់តែជិតមក។ ចៅចិត្រទាំងឆ្មា
យ៉ាងណែនផ្តងកាំភ្លើងប្រុងស្មារតីយ៉ាងអង់អាច ដៃម្ខាងចាប់ដៃនារីជាប់
ដៃម្ខាងទៀតកាន់កាំភ្លើង ត្រៀមខ្លួនចាំតទល់នឹងសត្រូវ ដើម្បីការពារ
ស្រីជាទីស្រឡាញ់ពេញចិត្តរបស់ខ្លួន ជីវិតខ្លួននឹងអ្នកទាំងអស់គ្នា ។

ពួកមហាចោរក៏ចាញ់កាំភ្លើងគ្រាប់ច្រាយមកចាចសាចដូចជាគ្រាប់
ភ្លៀង តែឥតត្រូវពាងកាយនរណាមួយឡើយ ព្រោះទីនោះជាទីងងឹត
ស្ទុះចាក់ក្អែកពុំយល់ ចំណែកខាងពួកចោរមានគប់ភ្លើងភ្លឺសន្ធោពេញ
ទាំងព្រៃ ដូច្នេះបានជាគ្រាប់កាំភ្លើងដែលចៅចិត្រចាញ់ទៅគ្មានខុស ១
គ្រាប់ ចោរខ្លះចាក់ដៃ, ខ្លះចាក់ជើង, ខ្លះដួលចង្អើរទៅក៏មាន តែគ្រាប់
កាំភ្លើងមានតិចពេក បានជាមិនអាចទំងប្រហារចោរដែលមានចំនួនច្រើន
នោះ ឲ្យមានជ័យជំនះបានឡើយ ។

ចៅចិត្រទំតស៊ូយ៉ាងក្លាហាន ដើម្បីការពារជីវិតខ្លួននឹងជីវិតស្រី
ស្នំឡាញ់របស់ខ្លួន ដោយអង់អាចឥតខ្លាចស្ងាប់បន្តិចឡើយ ។

ហេតុគេទៅដែលមុខគួរឲ្យស្ងប់ស្ងែងនេះ នៅមិនទាន់ដឹងជាខាង
ណាចាញ់ឈ្នះនៅឡើយ ពួកចោរខ្មែរជាគ្រូគ្រាប់ដួលទៅជាច្រើន

នាក់ហើយក៏ដោយ ក៏ឥតរួញភយរត្រាយម្បីយ មានតែរុំកបួលមក
ថែមកាន់តែច្រើនឡើង។ ហើយបួលជិតមក។ ឥតឈប់ឈរ កាន់តែ
ជិតបួនខ្លួនត្រប់។ ខណៈ។

ទៅចំត្រៃមកទុបក្រសោបនារីជាប់ ហើយនិយាយខ្សឹបប្រាប់
នឹងត្រចៀកថា "ត្រាប់តាំកូដ៏នៅសល់តែមួយត្រាប់ទេ, ឃុននារី! ខ្ញុំបាទ
សូមលន់តួដំបងឃុនដោយស្មោះត្រង់ថា ខ្ញុំបាទមានចិត្តស្រឡាញ់ឃុន
ក្រៃលែងជាងជីវិតរបស់ខ្ញុំបាទទៅទៀត; ដ្បិតក្នុងខណៈនេះពេលវេលា
កាន់តែជិតដល់ទីបំផុតហើយ ខ្ញុំបាទនឹងត្រាំលាក់ឃ្លៅទៀតពុំបាន,
ព្រោះអាសោនៃជីវិតខ្ញុំបាទ កាន់តែបួលទៅជិតដល់ស្រុកភ្នែបហើយ
ឃុននារី, ខ្ញុំបាទត្រូវតែស្លាប់ក្នុងត្រានេះហើយ! មើលចុះពួកកង្គ្រេច
ណាស់! ឥតដឹមនឹងទុកជីវិតខ្ញុំបាទឲ្យរស់នៅទេ ឯត្រាប់តាំកូដ៏ ១ ត្រាប់នេះ
ខ្ញុំបាទនឹងបេញ្ចូតទល់តារោឃុន ដោយយកជីវិតខ្ញុំបាទបេញ្ចូរជំនួស
សូមឲ្យឃុនរត់ទៅតួនចុះ ខ្ញុំបាទនៅតស៊ូនឹងពួកវា" ។

ទៅចំត្រសំដែងកិរិយាសោកស្តាយស្រណោះអាឡោះអាល័យយ៉ាងខ្លាំង ហើយសួរបញ្ជាក់ថែមទៀតថា "ស្រឡាញ់បងទេ, នារី?

នារី "ចាំ! ស្រឡាញ់ ចិត្ត, ខ្ញុំស្រឡាញ់ចិត្តរបស់នារីតែមួយនេះ
ជាបណ្តូលចិត្តរបស់នារី! ពាក្យនិយាយទាំងនេះក្តែតដោយសេចក្តីត្រេកអរ
យ៉ាងលើសកម្រិត ។

ចិត្ត "ស្រឡាញ់ខ្ញុំ ន! បណ្ដូលដំរីតរបស់បង! តែប៉ុណ្ណោះវៀម ឆ្នេចតែកស្ងាប់ជាសុខរហើយឬអ្ហូនមាសព្រលឹង!

នៅវេលាដែលនារីងាកទៅពួនទឹងគល់ស្រឡៃវិញ; ចៅចិត្តក៏ដំ-រង៉ាំកូដងបាញ់តទល់ទឹងពួកចោរ ស្រាប់តែឮសូរស្រែកយ៉ូយឡែង ដោយឈឺចាប់យ៉ាងខ្លាំង, ចៅចិត្តយកដៃទុបដើមទ្រូង; នារីឃើញដូច្នោះក៏ញ័រខ្លួនត់ចាំងខ្លួនឬណា ។

ចៅចិត្តវែស្រែកប្រាប់នារីថា "ខ្ញុំត្រូវគ្រាប់របស់ចៅរហើយឃុនា-រី! វែស្រែកថ្ងូរតែកងំពងំក ហើយមានឈាមហូរចេញពីខ្លួនគ្រហមច្រាល ហើយប្រាប់ថា "ឃុនារីកុំនៅ, រត់! រត់ជាប្រញាប់ ទើបផុតអំពីកណ្ដាប់ដៃពួកចោរ"; នាងទើបតែងើបពីគល់ស្រះឡៅ ស្រាប់តែឮសូរប៉ុង! ប៉ុង! ជារច្រើនណាត់បាញ់មកទៀត ទើបនាងមុជក្បាលពួនទៅគល់ស្រះឡៅទៅវិញ ឯចៅចិត្តក៏ដួលសន្ធប់ដេកលើផ្ទៃផែនដី នៅត្រង់តន្លែងនោះឯង ។

វគ្គទី ៥

កើតសេចក្ដីស្នេហាក្រោយឧប្បត្តិហេតុ

មានពន្ធឺឆ្ងុះចាំងមកស្រទន់ៗ នៃអរុណដែលទើបរះឡើងពីទិសបូព៌ា នោះ មានព័ណ៌ភ្លឺច្រាលឆ្លុះជាសំបុរមាសយ៉ាងល្អ ហើយចាំងចូលមក

តាមចន្លោះបង្អួចនឹងចន្លោះទ្វារ, វេលានោះមានសត្វចាបតូច ។ ពីរបីហ៊ោរ
ទ្រៀលគ្នាត់ខ្ទះស្ងាបលេងយ៉ាងក្សេមក្សាន្ត ឥតមានព្រួយអំពល់វល់
នឹងសេចក្តីទុក្ខសោកបស់អ្នកឯណាឡើយ, ហ៊ោរកំសាន្តចិត្តនៅ
កណ្តាលខ្យល់ ដែលតំពុងបក់មកវិលៗ ក្នុងពេលព្រឹកព្រហាម ហើយ
ស្រែកហ៊ោកញ្ជ្រៀវទៅតាមភាសាសត្វ ។ ឯចៅចិត្រវិបត្តិភ្ញាក់ស្មារតី
ឡើងហើយស្រែកថ្ងូរដោយសេចក្តីឈឺចាប់យ៉ាងខ្លាំង ហើយបើកភ្នែកក្រ-
ឡេកមើលទៅជុំវិញបន្ទប់ដេក រួចសំឡឹងទៅនឹងរូបស្ត្រីត្រកុំដ៏មាន
រូបឆោមស្រស់បស់ម្នាក់ដែលអង្គុយនៅក្នុងបន្ទប់បស់ខ្លួន. ទើបចៅចិត្រ
ហាមាត់ឡើងប្រឆ្នងនឹងនិយាយទៅ តែនាងជណ្តើមនិយាយឡើងមុនថា
"ចិត្រ ចិត្រលើកហើយឬ? នាងសួរដោយសំដីខន់ផ្អែមល្ហែម ។

ចៅចិត្រសួរនាងថា "ខ្ញុំបានទៅឯណា, ឃុនទាវ, ចុះហេតុដូចម្តេច
បានជាខ្ញុំបានមិនស្ងាប់?

នាងតបថា "ចិត្រមិនស្ងាប់ទេ, ចិត្រចាំមិនបានទេឬ? ទីនេះជា
បន្ទប់បស់ចិត្រឯងនឹងតែគេបានកែប្រែឲ្យបានស្រួល ដើម្បីឲ្យមានអាកាស
ល្អឡើង" ។

ភ្លាំរំលេកទៅនឹងដបថ្នាំចោលភ្នែកអូបឈ្ងុយឈ្ងប់ពេញចាំងលើង
ចន្លប់ នាងក៏កិលចូលមកជិតអ្នកជម្ងឺហើយសួរថា "ពិសាបបាយ្តទេចិត្រ?

នាយចិត្តគ្រីមុខយ៉ាងសន្សឹមៗ ហើយថា "អរគុណច្រើន ឃុន
នារី, ខ្ញុំចង់ដឹងថា ខ្ញុំបានត្រឡប់មកដល់ទីនេះបានដោយហេតុយ៉ាង
ណា ? ហើយពួកចោរទៅឯណាអស់ទៅ ?

នាងនារីញញឹមប៉ៃប្រហើយថា "តើយ៉ាងអ៊ីចេះ នៅវេលាដែល
ចិត្តត្រូវចោរចាញ់ដួលសន្លប់ទៅនោះ ស្រាប់តែលេចតាសុនចរវាយខ្ពប
មួយធំមកតាមយើងហើយមានគ្នាទៅច្រើនផង គាត់ថ្កាប់ថា យើញពួក
យើងចាត់ទៅយូរពេក គាត់មានសេចក្តីព្រួយបារម្ភក្រែងមានគ្រោះថ្នាក់
តាមផ្លូវ ទើបគាត់សុំខ្លីរវាយខ្ពមុងដ៏ថោងយកទៅខួលយើងស្រាប់តែចរ
ទីងពួកយើងកំពុងចម្បាំងនឹងពួកចោរ ហើយគាត់ជួយស្រែកហោចង្អើល
ពួកចោរ ចាល់តែពួកចោរវត់ខ្ចាត់ខ្ចាយចូលព្រៃអស់ទៅ ទើបពួកយើង
នាំគ្នាលើកចិត្តជាក់រវាយខ្ពមកផ្ទះនេះ ហើយលោកឪពុកឲ្យមនុស្សទៅ
អញ្ជើញគ្រូពេទ្យមកពិនិត្យអាការរបួសរបស់ចិត្ត" ។

នាយចិត្តដកដង្ហើមធំដោយអាការធូរក្នុងទ្រូងជាច្រើន សំឡឹង
មើលដៃកក្តែរបស់នារី ហើយពោលថា "ខ្ញុំបានគួរតែស្លាប់នៅក្នុងព្រៃ
នោះប្រសើរជាង មិនគួរនាំខ្ញុំបានមកទីនេះទេ; ដ្បិតនៅទីនេះខ្ញុំបានមុខ
ជាស្លាប់ដោយអាការក្រិចក្តីមិនខាន" ។

នារី "ចុះហេតុម្តេចបានជាចិត្តនិយាយយ៉ាងហ្នឹង ? គ្មាននរណា
ចិត្តអាក្រក់ដល់ទៅបណ្តោយឲ្យស្លាប់ដូច្នោះទេ, ចិត្តដឹងទេ, ឥឡូវនេះ

អ្នកណា ។ គេក៏ស្រឡាញ់ចិត្តខាំងអស់គ្នា, លោកឪពុកមានប្រសាសន៍ថា
បើចិត្តសះជាហើយ លោកនឹងតាំងឲ្យជាអ្នកត្រួតត្រាមើលអណ្តូងត្បូង
ខាំងអស់ដំបូងខ្លួនលោក មើលទៅដូចជាលោកពេញចិត្តនឹងចិត្តគាន់
តែច្រើនឡើង ! " ។

ទៅចិត្តស្ងៀមទៅមួយស្របក់ទើបមើលមុខនារីដោយអាការសោក ។
ថា " នារី, ឃុនទៅចាំសំដីខ្ញុំបានឬទេ, កាលគ្រានិយាយគ្នា
ត្រាមដើមស្រល្អៅក្នុងយប់នោះ ?

នារីញញឹមយ៉ាងស្រស់ខ្ចីហើយថា " ចាំ, ចាំបានខាំង
អស់គតក្តៅមួយម៉ាត់ឡើយ ! ចុះហេតុអ្វីក៏សួរដូច្នេះ ?

ទៅចិត្តងាកបែរខ្លួនផ្លែងបន្តិចហើយថា "ទេ, ឃុន, តាមដោយពិត
ខ្ញុំបានមិនគួរនិយាយចេញមកសោះ តែដែលហ៊ាននិយាយដូច្នោះក្នុង
វេលានោះ ព្រោះគិតជាស្រេចថា មុខជាគ្មានដំរិតរស់នៅក្នុងលោកតទៅ
ទៀត តែឥឡូវនេះបែរជាមិនស្លាប់ នេះហើយដែលធ្វើឲ្យខ្ញុំបានត្រឡប់
ក្រៃក្នុងទុក្ខគ្រាតែអស់ដំរិតមិនខាន . . . ! " ។

នារីយកដៃបិទមាត់ទៅចិត្តជាប្រញាប់ហើយថា " គ្មាននរណា
ចិត្តអាក្រក់ធ្វើបាបចិត្តឲ្យបានសេចក្តីវេទនាដូច្នោះទេ មនុស្សល្អយ៉ាងនេះ
តើនរណាស្អប់ ចិត្តមិនដឹងទៀតឬទេថា នារីស្រឡាញ់ចិត្តរបស់នារី
យ៉ាងអស់ពីចិត្ត ! " ។

ចៅចិត្តញញឹមហើយថា "ដឿ, ដឿអស់ពីពោះប៉ុន្តែនឹងមានប្រយោជន៍អ្វី កាលបើហានៈរបស់យើងខ្ញុំសត្វាធ្លាយណាស់ហាក់ដូចជាមេឃនឹងដី!" ។

នាងនារីនៅតែស្ងៀម ។

ចៅចិត្តនិយាយតទៅទៀតថា "ខ្ញុំជាមនុស្សក្លៀវក្លាឃុន, ដូចពាក្យចំនៀមថា "ខ្លុះកញ្ចក់មិនមើលស្រមោលច្បាណា ជាំដើងក្រាមមិនប្រមាណខ្នាំង" ហេតុតែអន្ទះអន្ទែងដែងបុណ្យកុំឲ្យសំណាងនេះហើយនឹងនាំឲ្យមានគ្រោះថ្នាក់ដល់ខ្លួនមិនខាន ដូចបុរាណថា "ដៃខ្លីចំប្រក់ទុបក្តុំ" មានតែនាំឲ្យត្រៀមកែចិត្តឥតប្រយោជន៍ដកថយដល់ក្បែរដីវិត មកតែអំពីមានគំនិតឥតកំណើតដូចខ្លួនខ្ញុំនេះឯង' ថាហើយក៏ដកដង្ហើមធំដោយអាការអស់សង្ឃឹម ។

នារីសំឡឹងមើលមុខដោយចិត្តអាណិតអាសូរ ហើយនិយាយថា "ពុទ្ធោ! គិតច្រើនហួសប្រមាណតែខ្លួនឯង, នារីជ្រាបហើយថា ស្នេហាញ៉ាំងអស់ពីចិត្តក៏នៅតែមិនដឿទៀត ចុះឲ្យនារីធ្វើដូចម្តេច? នារីព្រមតាមគ្រប់យ៉ាង, មិនមានអ្វីក្នុងលោកនេះមកកំចាត់សេចក្តីតាំងចិត្តរបស់នារីបានឡើយ, នារីស្រឡាញ់ចិត្តតែម្នាក់នេះឯងមិនមានបុរសជាគំរប់ពីរទៀតទេ, នារីមិនត្រូវការអ្វីដទៃទៀតទាំងអស់ ត្រូវតែសេចក្តីស្រឡាញ់ដ៏ស្មោះត្រង់ចរិសុទ្ធរបស់ចិត្តប៉ុណ្ណោះ" ។

ចិត្ត "មែនឬនាវ៉ែ? ញញឹមយ៉ាងរួសរាយ ។

នាវ៉ "ពុទ្ធោ! នៅតែមិនដឿឹងទេឬ? នាងនិយាយដោយសេចក្តីគោរមនស្សអន់ចិត្ត ។

ចៅចិត្តចាប់ពាក្យដៃនាងនាវ៉មកថើបយ៉ាងស្នេហាអស់ពីចិត្ត នាងនាវ៉ក៏ដាប់មុខនៅទីឯទ្រូងរបស់ប្រុសសំឡាញ់ សេចក្តីស្នេហាដែលកប់ពុតតែកក់ចិត្តមកជាយូរលង់ភ្លាយផ្សាយច្រាបគ្នាទៅវិញទៅមកដោយពិតត្រង់តាំងអស់ ពីដើមមកនាងនាវ៉ធ្លាប់មើលងាយប្រមាទចៅចិត្តហើយស្អប់ចៅចិត្ត តែនៅទីបំផុតនេះប្រែជាស្រឡាញ់គេវិញ ហើយជាសេចក្តីស្នេហាស្រឡាញ់យ៉ាងបរិសុទ្ធស្មោះត្រង់ខ្ពង់ខ្ពស់ផ្អែមត្រជាក់ ចេញមកពីបេះដូងដែលថ្លាផូរផង់ឆ្អាប់ឱនឥតមានចាស់ពុំបន្ទុំចិត្តឡើយ ។

នៅទុកាសដែលកំពុងក្រមុំកំពុងនិយាយចរចាសារសួរយ៉ាងក្តៅក្តៅនោះ ស្រាប់តែពួកសូរដើងមនុស្សខ្សឹងដណ្តើរមក ទើបនាងនាវ៉បើកទ្វារចេញទៅខួលលោកហ្វូងគេនសម្បត្តិនឹងគ្រូគេឲ្យ ដនតាំងពីរក៏ដើរចូលទៅកន្លងបន្ទប់ចៅចិត្តៗធ្វើអាការហាក់ដូចជាខឹងគ្រោកម្ល៉ង តែលោកហ្វូងលើកដៃហាមថា "កុំគ្រោក, ដេកតាមសប្បាយចុះ" ហើយងាកទៅសួរគ្រូគេឲ្យថា "ថ្ងៃនេះ អាការពេគដូចម្តេចខ្លះ លោកគ្រូ?

លោកគ្រូគេឲ្យចាប់ដៃអ្នកជម្ងឺត្រួតសព្វគ្រប់ហើយ ទើបនិយាយថា

គ្រាន់បើឡើងច្រើន ព្រោះគាប់តាំងតែដើលចោរចាញ់គ្រប់គ្រងពុតតែខ្លែងសំខាន់ៗតាំងអស់" ។

លោកហ្លួងនិយាយថា "គ្រោះល្អណាស់! ខ្លួនខ្ញុំនឹងកូនខ្ញុំ ប្រសិនបើមិនបានចៅចិត្តជួយការពារក្នុងគ្រានោះទេ មិនដឹងជាដូចម្តេចទេ ចុះប៉ុន្មានថ្ងៃទៀតទើបបានសះជា លោកគ្រូ?

លោកគ្រូពេទ្យសំឡឹងមើលនាងនារី ហើយញញឹមនិយាយថា "ខ្ញុំបានគិតថា បើមានអ្នកថែរក្សាដម្បីចំណាប់ចំនួនថ្ងៃបន្តិចទៀតនឹងសះជាឆាប់ហ៊ាសមិនខាន តែវេលានេះគោងឲ្យអ្នកជម្ងឺដេកឲ្យស្រួលមែនគ្រាន់ឲ្យមុខរបួសសះល្អសិន" ។

ឯនាយចិត្តសំដែងសេចក្តីអរគុណដល់លោកហ្លួងនឹងគ្រូពេទ្យហើយលោកទាំងពីរនាក់ក៏នាំគ្នាដើរចេញទៅ ឯហ្លួងគេនសម្បត្តិដាកមកច្រាប់ចៅចិត្តថា "តាំងអំពីថ្ងៃនេះទៅ ខ្លួនជាចៅចិត្តសះជាខ្លួនហើយ ក៏មិនច្រាប់ទៅធ្វើការនៅអណ្តូងត្បូងដូចមុនៗទៀតទេ ខ្ញុំតាំងឲ្យអ្នកឯងជាជំនួយខ្ញុំត្រួតត្រាមើលអស់តាំងអណ្តូងត្បូង ដែលពួកកម្មករជីកមកតាំងប៉ុន្មានរៀបចំតាមប្រពៃទេបសិនត្បូង មិនច្រាប់ទៅធ្វើការធ្ងន់ដូចសព្វដងទេ គ្រែងនាំឲ្យជម្ងឺរើឡើងវិញ" រួចលោកគ្រូពេទ្យនឹងហ្លួងគេនសម្បត្តិនាំគ្នាដើរចុះពីផ្ទះនោះទៅ ។

ដោយហេតុនាងនាវ័យកចិត្តទុកជាក់ថែរក្សាគ្នាជាលក្ខណៈមួយដោយផ្ទុតផ្ទង់ ដម្ងីចៅចិត្រទើបមានអាការៈគ្រាន់បើខ្លួនជាលំដាប់ ហើយនៅទីបំផុតក៏បានសះជាដូចប្រកតិ ថៃមាំងឥឡូវនេះមិនបាច់ចេញទៅដឹកគ្រួងបែកញើសតាងទឹកដូចពីមុនទៀតផង គ្រាន់តែជួយចាត់ចែងក្តៅបញ្ជឹតគ្រួងដែលពួកកម្មករដឹកបានមកពីអណ្តូងផ្សេងៗ ព្រមាំងបើកប្រាក់ឈៃឲ្យពួកកម្មករទើបនាំឲ្យចៅចិត្របានសេចក្តីសុខខ្លាំងទៀតជាច្រើន សុខាំងកាយសុខាំងចិត្ត គឺថាស្រុកបម៉ៃលិនទុកដូចជាស្ថានសួគ៌របស់ចៅចិត្រតែម្តង ហើយគេតែងតែគិតជានិច្ចថា ខ្ញុំតាំងខ្លួនប្រាណឲ្យបានខ្ជាប់ខ្ជួនគ្រាតែដល់ខួរវ័យបំផុតនៃជីវិតនៅទីនេះ ។

ថ្ងៃនេះអាកាសធាតុស្រឡះល្អ មានខ្យល់បក់រំគើយៗ ល្មមតែត្រជាក់ស្រួល នាវីបបួលចៅចិត្រចុះទៅអង្គុយនិយាយគ្នានៅក្នុងសួនច្បារគ្រាយផ្ទះស្តាប់សូរសេពួចកក្រាបកន្ត្រៃស្រែកយំតាមតាសារបស់ពួក ជាទីកំសាន្តចិត្តរបស់អ្នកដែលមានមេត្រីរស់ជាមួយគ្នា ។

ចៅចិត្រនិយាយតបៗ កាលឃើញនាងនាវីនោះស្ងៀមថា "នាវី" ។

នាវី- "ចា៎ះ" នាងញញឹមយ៉ាងខ្ទន់ក្តួនហើយថា "នៅជាមួយខ្ញុំឯចិត្រយ៉ាងនេះ នាវីមានសេចក្តីសុខយ៉ាងលើសលន់តែម្តង!"

គេញញឹមប៉ៃប្រហើយថា "មិនខឹងនាសោះឡើយ ទៅតាបម៉ៃលិនគ្រង់ប្រាសប្រាណបងដល់ម្ល៉េះទេ" នាងធ្វើជាសំឡក់តាមមាយា

ស្ត្រីហើយស្រែដាថា "ដឹងថាគេស្រឡាញ់ខ្លួនបន្តិច ក៏តាំងអួតយ៉ាងសំបើមតែម្តងណ៎ះ ។

ចិត្រ "ចុះនាវីស្អប់បងណាស់ឬអី?

នាវី "ស្អប់ណាស់" នាងតបចាក់បណ្តើយ ។

ចៅចិត្រញញឹមប៉ប្រឹមហើយថា "បើស្អប់បងណាស់ម៉េចក៏មិនខុកចោលឲ្យស្ងាប់នៅក្នុងរៃព្នុះនៅ?

នាងវែរមកសំឡក់ហើយថា "ដោយគេអាណិតបន្តិចទេតើ កុំអីគាត់ផ្តុំខ្យុកក្នុងរៃព្នុះទៅហើយ ។

ស្ងៀមតាំងអស់គ្នាទៅ ១ ស្រចក់ ចៅចិត្រក៏ចាប់ទំយាយឡើងមុនថា "អើ! នាវី លោកឥឡូវបានដឹងរឿងព័ត៌មានរបស់យើងខ្លះដែរឬទៅឡើយទេ?

នាវី_ "មិនទាន់ដឹងទេ"

ចិត្រ_ "បើលោកដឹងមុខជាលោកធ្វើទោសបំបះបងដូចម្តេចមិនដឹងទេ, បងព្រួយចិត្តណាស់!

នាវី_ "រឿងនេះខ្ញុំដឹងមិនដល់ទេ ព្រោះលោកមិនដែលក្តុំទំយាយដូចម្តេចសោះឡើយ" ។

ចៅចិត្រទំយាយដោយទឹកមុខស្រពោនថា "ប្រសិនបើលោកដឹងមុខជាវេញបងឲ្យចេញព័ផ្ទះនេះជាមិនខាន' ។

នារីសំឡក់ដាក់ចៅចិត្តម្ចងទៀតហើយថា "ខ្ញើមសំដីបងឯងណាស់បងចិត្ត, លោកឪពុកមិនមែនចិត្តអាក្រក់ដល់ម្ល៉េះទេ លោកចាស់ទុំហើយ តែងតែស្គាល់ប្លន់អំណាចរសេចក្តីស្នេហាចាស់លាស់ជាងក្មេងៗទៅទៀត" ។

ចិត្ត- "ឯបងជាមនុស្សកំសត់ទុគ៌តឥតទ្រព្យសម្បត្តិពាំងកំរែកំព្រាបង មានតែដីតែនឹងកង្កាយប៉ុណ្ណោះ" ។

នារី- "ប៉ុណ្ណឹងក៏ល្មមគ្រប់គ្រាន់ហើយ" ។

ចិត្ត- "គ្រប់គ្រាន់តែចំពោះប្អូននារីប៉ុណ្ណោះ" ។

នារី- "ទោះបីលោកឪពុកក៏មិនត្រូវការអ្វីទៀតដែរ" ។

ចិត្ត- "ចុះប្អូននារី, ដឹងចិត្តលោកបានឬ?

នារី- "ចាំ:, ដឹងខ្លះដែរ ធម្មតាឪពុកនឹងកូនដែលនៅជាមួយគ្នាជាយូរអែវធ្លឹងមកហើយ តែងតែដឹងគ្នាខ្លះមិនខាន កុំថាគ្រាន់តែដឹងចិត្តលោកឪពុកម្នាក់ឡើយសូម្បីតែ..."

ចិត្ត- "ចិត្តរបស់បង ប្អូននារីក៏ដឹងច្បាស់អស់ដែរ" (ទៅចិត្តនិយាយបញ្ចប់ប្រយោគ) ។

នារីសំឡក់ហើយថា "ដឹងខ្លួនទេ, បងឯងប៉ុនកុហកលេងមួយ?

ចិត្ត- "បងកុហកប្អូនដូចម្តេចខ្លះ? (ធ្វើមុខដូចជាឆ្ងល់ណាស់)

នារី- "កុំធ្វើតៅឡើយ លោកពូកូនសិស្សសាលាវត្ត" ។

ចិត្រ- "ក៏បងរៀនសាលាវគ្គមែននេះណា" ។

នារី- "ចុះសាលាវគ្គគេមានរៀនដល់ប្រវត្តិពង្សាវតារលោក, ភូមិសាស្ត្រ រិទ្យាសាស្ត្រទំនើបថ្មីដែរឬ ?

ចិត្រ-"ទេ" (ឆ្លើយធ្វើមុខព្រងើយ) ។

នារី- "ទេ" នាងផ្ញើនពាក្យហើយថា "តែខ្ញុំបាននេះយើញសៀវភៅអស់នេះនៅតងចន្ទប់បងរបស់បងឯង, ហើយមានស៊ុកញ្ជោឈ្មោះបងឯង ជាអក្សរបារាំងផង ។

ចៅចិត្រមិនឆ្លើយគាន់តែញញឹម ។

នារី- "ប៉ុន្តែភូតដួចសព្វថ្ងៃ, នេះនែបងចិត្រ ! បុះគាលណាខើបបងឯងចោលនិស្ស័យចចេសដើរូសចេញ ប៉ើនៅតែកុហកខ្ញុំទៀត ខ្ញុំនឹងខឹងច្រើនតែម្តង" ។

ចៅចិត្រទិតចូលទៅកាន់តែដិតហើយថា "ប្អូននារីហ៊ានខឹងនឹងសង្សារកំសត់បានឬ?

"មិនដឿនឹងលមើលក៏បាន នារីអាចនឹងស្អប់ប៉ុន្តែនឹងស្រឡាញ់ក៏បាន" ។

ចៅចិត្រសើចយ៉ាងសប្បាយចិត្តហើយថា "បងគំដឹងថាប្អូននារីមិនស្អប់បងទេ" ។

នារី-" ចុះហេតុអី ?

ចំត្រៃ- "តើប្អូននារីច្បាប់ថា ស្រឡាញ់បងដែរមែនទេ?

នារីលូកដៃមួលក្អៅចៅចំត្រៃខាល់តែស្រែក, ទើបនាយចំត្រៃតបត្រៃ-សោចដៃនារីហើយគោលថា "ម្តងណោះបងលែងកុហកប្អូនទៀតហើយ ដ្បិតត្រៃយ៉ាងត្រៃបំប្រការយើងបានដឹងគ្នាច្បាស់លាស់ហើយមែនទេប្អូននារី?

នាងសំឡឹងមើលមុខគេដោយមេត្រីចិត្ត ហើយផ្ញាស់ទំយាយពីរឿងផ្សេងៗថា "អើ, បងចំត្រៃ, ឥឡូវនេះគ្មូនរបស់យើងដូចម្តេចខ្លះ?

ចៅចំត្រៃឆ្លើយថា "ឥឡូវចំរើនឡើនច្រើន អណ្តូងគ្មូនទឹសខាងកើតដឹកបានគ្មូនទឹកឆម្ងាជាង ១០ គ្រាប់ អណ្តូងខាងលិចដឹកបានគ្មូនទឹកយ៉ាងល្អ ៦-៧ គ្រាប់ ឥឡូវគ្មូនទាំងអស់របស់យើងមានចំនួនជាង ២០០ គ្រាប់ ប៉ុន្តែតៅដំរៀបមាណជាងមួយហ្មឺនរៀល" ។

ក្រមុំតំឡោះទាំងពីរនិយាយសំណេះសំណាលសារសេងគ្នាតៅវិញតៅមកយ៉ាងក្រៀមក្រាន្តស៊ីងតោរតេញដោយសេចក្តីស្នេហា ក្នុងគ្រានោះនេត្តទំកនាអំពីសេចក្តីលំបាកក្នុងការចិញ្ចឹមដំរីតបន្តិចទៀយ តែតែសប្បាយរីករាយក្នុងការផ្តួកផ្តិតសម្រួលកាយសម្រួលចិត្តតៅតាមព្រះប្បាទិយៃនៃត្រៃតាមទេពជាម្ចាស់ ដែលធ្វើមានឫទ្ធិជាពន្ធឹកសៅដួងចិត្តនៃត្រៃប្តូរតំឡោះតំរ៉ីឡាយក្នុងលោកិយនេះ ។

អ្នកទកញ្ញារំឭកសារពេជ្ជ (ឆង) រៀបរៀង

(តទៅ)

ព្រះពង្សវោធ- សត្វអ្នកនាំនី- ពានទើបថ្វាយថ្វាប់ ថាវៃហេ-ព្រក្ស ចូរអ្នកស្តែងស្តាប់ ចង់ចិត្តចាំចាប់ តិតគុណាពុទ្ធរ័ត្ន ។ ន័យនេះអញឯង ចរចាថាយចែង សង្ខេបពេកក្តាត់ ម៉ើន់ឯចែងជា ពិស្តារបរមត្ថ ក្រែក្រតន់តិត ឥតឯទុបមា ។ អប្បមេយ្យា តុទ្ធគុណោ គុណព្រះពុទ្ធជា អនន្តគុណាតាប់ រៀងកប់គណនា ពុំបានបទថ្វា- លើលោកពិស្តារ ។ ទេព្តាស្តែងស្តាប់ ពាក្យពីរោះតាប់ ចូលចិត្តត្រអាល ធ្វាស់ធ្វើយទៀតទៅ ថាចៅរកចារ្យ ចូរថ្លែងកិច្ចការ ពីពុទ្ធគុណាតាប់ ។ ចែងចាយសាយសត្វ សេចក្រែចក្រាន់ក្រែប់ ឲ្យអញស្តែងស្តាប់ អ្នកឮខ្មោះហើយ ធ្វាស់ធ្វើយរឹងមាប់ ថាអញថ្វាយថ្វាប់ រៃបរៀបទុបមា ។ សំដែងសណ្តាប់ ទំពានបច្ចាស់បច្ចាប់ ពុំមានបទថ្វា- លើលោកកម្រៃក្រាស់ក្រតណា លុះលោកត្រាស់ជា ព្រះពុទ្ធប្រៃពៃ ។ ទើបលោកសំដែង សណ្តាប់ចាយចែង គុណព្រះពុទ្ធថ្លៃ ថ្កានបទព្រះអង្គ ខ្ញែសខ្ញង់ញាណញ្ញេយ្យ ជវ័នវង់វៃ ចាយចែងតម្រៃ ។ ទេព្តាធ្វើយទៅ បើខ្មោះចូរចៅ រួសរកនិរវត៌ តែដើមបរបាន ទំពានយើងឃាត់ តំបត្តូចតាមក្រ

ទុកតែធម៌ប្រៀនប្រដៅណា ។ ព្រះសោធិសត្វ ឆ្លាស់ឆ្លើយរឹងថ្នាត់ បើអ្នកចង់ បាន ស្តែងស្តាប់ឲ្យជាក់ ចូរអ្នកប្រុងប្រៀណ តាក្យទាំងនេះបាន បុណ្យ ជាមិនា ។ អញនឹងសំដែង និទានចាយចែង ជាបទអក្ខរ ប្លាប់មួយ ប្រការដ ដោយបទគាថា ៨ ឯងនៃចែងជា បួនបទបាលី ។ ឥ តោវោ ថា រីព្រះតថា- គតជាមេត្រី ព្រះអង្គឯងជា ពង្សាជាតិ នៃអ្នកប្រាជ្ញពី មុនបកមែនមាន ។ ព្រះដំណើរនោះ ប្រាថ្នាស្ម័គ្រស្មោះ ខៀងខៅ ខំភ្លាន គុណតាប់មេត្រី ស្វែងកំពីឲ្យបាន ប្រយោជន៍សត្វប្រាណ សត្វ សោយសុខា ។ មួយព្រះអង្គឲ្យ សព្វសត្វបានដោយ បំណងប្រាថ្នា ឲ្យអរិយផល ដូចដល់ស្រោតា សកិទាគា អរហត្តមគ្គផល ។ មួយតីព្រះអង្គ ប្រសើរខ្ពើសខ្ពង់ បុណ្យបញ្ញាតាល ទាំង ៦ ហាន ចំពូញាណយង់យល់ សុះសព្វការគល់ ពិតពុំកំបាំង ។ មួយតីព្រះអង្គ តិតការចំណង់ ស្រេរឹតពុំកង់ រិះរកគល់កិច្ច ផ្តិលផ្តាច់ខោះខាំង តណ្ហា ថ្នាក់ថ្នាំង អស់ឥតសង្ស័យ ។ តិតោវោ-រី បើតបទបាលី ចែងចេញ ច្រើនវិត្រ សោភកកា ព្រះសពើជ្ញវ័ត្ថ ឲ្យប្រយោជន៍វិត្រ- កពពាំង ៣ បាទ ។ មួយតីព្រះអង្គ ឆ្លាស់ឆ្លងអន្ទង់ សង្សារដេលស្ងួន មួយតី ព្រះអង្គ ត្រាស់ខ្ពង់ព្រះញាណ ដូចដល់ឋិតហាន ត្រិះត្រៃវិជ្ជា ។ មួយ ព្រះអង្គបាន ព្រះទ័យក្សេមក្សាន្ត អាសូរគុណា សត្វាសត្វជាក់ដល់

មណ្ឌលសួគ៌. លំ។ ដុះដល់ឋាន អម្រឹតបុរី ។ រីបិកាភៅ ចែង
ចេញថា សោភកភវតី ឯពុទ្ធញ្ញាណ ស្តេចមានចារមើ បរមត្ថ
ជាឪ សំឡាញ់សព្វសត្វ ។ មួយគឺព្រះអង្គ សពោជ្ឈពុទ្ធង្ស ព្រះញាណ
កាន់កាត់ កំលេសលោកធម៌ ចាំង ៨ ចាត់ ចោះបង់ខ្លាយខ្លាត់ បំបាក់
បបថាន ។ មួយគឺព្រះអង្គ បន្ទោបាបបង់ លាភសរសៃងឋាន ឆ្ងាស
ឆ្ងៃសង្សារ តណ្ហាមិនមាន មកបៀតបៀនបាន ប្រែប្រាស់ឃ្លាតឃ្លា ។
មួយគឺព្រះអង្គ ប្រកបរូបខ្លង់ ថ្កល់ថ្កើងអង្គា ប៉ុន្មានពីផល មណ្ឌលរូបា
បរិបូណ៌សុខសា- ប្បាយបុណ្យចារមើ ។ រីសោភាភៅ គឺព្រះពុទ្ធោ
សពោជ្ឈដ៏ឧស្រេ ព្រះអង្គលះលោក ចរចាកចេញពី សង្សារកេងត្រៃ
ដោះទុក្ខសព្វសត្វ ។ មួយគឺព្រះអង្គ ល្អល្អះត្រចង់ មួយគឺតិតកាត់
សង្សារខ្ចាត់ខ្ចាយ ខ្លាត់ខ្លាយចែកចាត់ ព្រះអង្គរំបោសសត្វ សល់
សែនសំខ្យា ។ មួយគឺព្រះអង្គ បន្ទោទុក្ខបង់ សព្វសត្វសង្សារ ចោះ
កើតទុក្ខធ្ងន់ ខ្លួនខ្លួច យកព្រះត្រៃជ្ញ ប្រែបត្រាប់ប្រាសត្រាណ ។
រីកភាភៅ ព្រះពង្សពុទ្ធោ កាច់កំលេសបាន ពាន់ហារយោសែច ដ្ឋិល
ផ្តាច់មិនមាន មន្ទិលកន្ធត្រាណ ប្រែប្រួបត្រាសប្រះ ។ មួយព្រះអង្គ
គាច កាន់កាច់កម្មកាច កតាចក្រសែរឡះ មួយព្រះអង្គកាច់ ចាបបង់ដ្ឋិល
ផ្តាច់ អស់ឥតសំណល់ បរិបូណ៌ចានឋាន ទិព្វានមង្គល អង្គឥតអំពល់

អំពីកម្មកាច ។ រីឯកាកោ ព្រះអង្គអគ្គ ឯស៊ប្រុះប្រាជ្ញ ប្រែប្រួល
ប្រាសប្រុះ លាភលះលែងពាជ- សម្បត្តិឯងអាច ចរចេញបួសបាន ។
ព្រះអង្គប្រសើរ យាងព្រះដំណើរ ចរចេញចាកហាន ជាអតិសេក
នៃក្នែកគ្រប់ប្រាណ ខេត្តាសត្វស្ថាន ដូលមកបង្គំ ។ មួយព្រះសំដែង
ទេសនាចាយចែង ចូលចិត្តអស់ព្រហ្ម តាំងខេពនិកវ អមរយក្ខយម-
ពជពក់សឹងសំ- ណាក់ន៏ងសាស្តា ។ មួយតីព្រះអង្គ ប្រសើរចេត្តចង់
ទាំសត្វសំទ្បា ចរចូលនិព្វាន បិតហានសុខសា- ប្បាយបម៊ូណាប្រាក-
ជគួរគុណគាប់ ។ រីឯកាកោ ព្រះពង្សពុទ្ធោ ឯងអាចក្រឡាប់ ពីពគ
តណ្ហា ទេសនាក្រាយប្រាប់ ប្រាប់ប្រៀបដូមប្បាប់ សត្វសត្វសែន
សល់ ។ មួយតីព្រះអង្គ ទាំសត្វប្រោះបង់ ចរចោលមណ្ឌល គតរ៉ៃដ្ឋ-
សង្ឃារ កិច្ចការកម្មកល់ មិនមានអំពល់ អំពីតណ្ហា ។ មួយទីសោតព្រះ
ខូន្ទានឲ្យលះ ឲ្យកាន់សីលា ព្រះញាណគីខ្ន ដវនបញ្ញា យកកុំនសីល
ជា ពំទាក់ពំនួន ។ មួយព្រះគិតកាត់ ប្រាមប្រដៅសត្វ អាចឲ្យទ្ធាប
ខ្ន ឲ្យកាន់កុសល មគ្គផលជួយជួន លះលែងពៀរពួន ប្រាបបានបទ
បុណ្យ ។ ហេតុនោះអញ្ជឹ ចាប់ចិត្តបង់ជុំ- នោះពិតរកពាន់ ទុនអង្គ
អតិវ៉ង ប៉ត់ប្រាថ- ន្ទឹមពាំងគួគន់ គិតគុណភុន្ទវ៉ែតន៏ ។ ទើបអកចរ-
ពា ថាលៃខេត្តា ចូរចាប់ចង់ចិត្ត រួសរៀនវិនវ៉ែ ចាំចេះឲ្យស្ទាត់ គិត
គុណភុន្ទវ៉ែតន៏ កាន់កុំភ្លេចភ្លាំង ។ នោះថ្ងៃនោះយប់ ដើរដេកឈរឈប់

ក្នុងខ្លឹកដែរនៃចាំង គោកគុកគុហា ការខាខៀងចាំង ចិត្តចាំរកាំង
រៀសគិតគុណ ។ ព្រះពុទ្ធប្រែជាន ប្រាសើរស្មើហាន តែនុ៎ងរឿងរ-
ន្ធាលចាំងទិសទស សោឡាសសួគ៌ស- ន្ធោធម៌មិនម- ច្ចុលភេសខៀង
ខាត់ ។ ភោះអ្នករៀនរំ- ពឹងពេកពិតពុំ កេចក្លឹកក្លាំងភ្លាត់ ក្លឹផ្កែកផ្លាក
ផ្លោះ បង់ចោះចាបចាត់ សូរសោយសព្វសត្វ សោយសុខសួគ៌ស្ងប់ ។
បទបានបង់ចិត្ត គិតគុណពុទ្ធរ័តន៍ រៃរៀនភ្លាយខ្លួល ត្រែកត្រែះត្រង់ត្រាប់
បង់ចាំផ្លាប់ផ្លល់ កិច្ចការកម្មកុល តើតរស្លឹងឯង ។ តាប្បសង់
សហាស្សាំ ទុក្ខតិត្តេ ឯកច្ចកិ សេចក្តីបន្ទែ ប្រាយប្រាប់
ប្រែបវែប ប្រែនវែបបបប្រាណ ។ ប្រើប្រែងប្រាណប្រុះ ព្រួញព្រឹស
ព្រមព្រះ ប្រែាសប្រាណខ្លួនាន ខេសន៍ខុកខៀងទៅ ដោយខន្ធវិតូ
ញ្ញាណ អ្នកណាបើបាន គិតគុណពុទ្ធរ័តន៍ ។ អ្នកនោះតបកើត ឱនន
យកកំណើត មួយសែនកំល្អាត់ កិច្ចកម្មកាយកាច ចោះចាបភ្លាយភ្លាត់
ចាត់បែតបង់ចាត់ បានបរិបូណ៌បុណ្យ ។ មិនមានថ្នោះថ្កក់ ភ្លាត់ទៅនរក
ខ្លួកខ្លន់ រូបរង៉ាវេទនា ជាតិជាតមួន់ ដល់ម្តងបទបុណ្យ បំបាត់បាបបង់ ។

នេះបទព្រហ្មគីត ពោលភាក្យពិតពីពូជពង្ស ពោធិសត្វវរង្ស
ប្រែបប្រែនប្រាយប្រាប់ខេត្ត ។ ចាយចែងចរចាចប់ សរសើរត្រែប់
គុណពុទ្ធា អស់កាថិអគ្គអក្ខក ប្រែប្រាំពីរបទបរិបូណ៌ ។ ខៀងខើប
ខេត្រក្សត្រួច តើតកាន់ក្លួចគន់គិតគ្នា ចមាមមែមួ មេត្រីត្រាប់ត្រង

ត្រែកត្រែះ ។ ប្រើប្រពន្ធថ្កុំណាប្រថវប្រែ រួសរិះរកវៀនរិះ ជួបបច្ចួលចិត្ត
ចង់ចេះ ចាប់ចាំចប់ចែងចរចា ។ ស្រើបស្រស់ស្រួលស្រាប់ស្រេច
ខេត្តក្សត្រចាប់ព្រះអង្គមហា- បុរសតែងថ្លៃថ្លា ខ្ញុំឃ្លានតែមួយឧត្តម ។
បើព្រះថ្កុដូរប្រសើរ ចិត្តចង់មើលតែអញខ្ញុំ ខ្ញុំយកមកឲ្យអ- ម្ចាស់ចួលចិត្តខ្ញុំបួងជា ។ ពួជពង្សព្រោធិសត្វ បុរសតែងធ្លាស់ឆ្លើយថា បើព្នេះចូរខេត្តា អ្នកយកមកឲ្យអញមើល ។ ខេត្តាសួរចង់ដាក់ ថាហៃអ្នកថ្កុដូរប្រសើរ ដ្បិតអ្វីអញនឹងដើរ ទៅខ្ជិខ្ជៃតពុំបាន ។ ពង្សព្រោធិសត្វអ្នកស្តែងស្តាប់ដាក់រំពឹងធ្យាន ដោយជាតិសញ្ញាណ រំពេចពិតពីថ្កុជ្ញា ។ ដឹងដោយព្រះយោបល់ តិតពុំទ្រលំចែងចរចា ថ្កុយថ្កាប់ទៅខេត្តា ហេតុពិតពីដើមដូច្នេះ ។ កាលជាតិមុនអញកើត យកកំណើតទៅស្រុកនេះ អង្គអញជួបជុំនចេះ ចាប់ចាំចប់សិល្បសាស្តា ។ ជាគ្រូតែងប្រដៅ សិស្សសើងទៅរៀនគ្រប់គ្នា អ្នកឯងសោតកើតជា ព្រាហ្មណ៍មករៀនសិល្បនឹងអញ ។ អ្នកយកតែរមណីរតន៍ ល្អតិចត្រជាសំឡាញ់មួយមកនឹងឲ្យអញ អ្នកខុកទៅដើមជ្ញលនេះ ។ លុះរៀនសិល្បសាស្តសព្វ ចង់ចាំចប់ចួលចិត្តចេះ លេះលាំងវេះ រំលឹងទៅហានគ្រឹហា ។ រីឯតែវល្លះល្អ ពុំខាន់យកតាំត្រីក្សា ភ្លាំងក្ងេចខុកទៅខា ដើមជ្ញលនេះពុំឲ្យគ្រូ ។ លង់លុះអ្នកនឹងស្លាប់ ត្រូកទ្រព្យតែវនោះស្លុ ពុំខាន់បួងជាគ្រូ

វិញ្ញាណអ្នកនឹងបានរួម ។ ចាំចាប់ដួចដិតដល់ ដោយយុំដើមក្តុលជាបឋម
ខឿនទើបឋិតថេរលំ- នៅនេះនឹងទៅពុំបាន ។ ទើបខេត្តវែស្តង់ស្តាប់
ចូលចិត្តចាប់ដឿស្មោះស្មាន គាន់តែវេចូលប្តាន មកបួងពន្យ
គោធ ។ ខឿនទើបថ្កាយថ្កាប់ថា តែវសោតាមានស្តី អាចឲ្យស្រែ
សួស្តី ក្តីរុនរឿងភាំងដើមក្តុល ។ ឯអស់តាំងមនុស្សម្នា នៅតាកតាប់
យង់យល់ ខ្លួបខ្លាចរិទ្ធិពល ថាខេត្រគួមានចេស្តា ។ ចាចូលមកសំពះ
រីអ្នកខ្លះនាំបណ្តា- តាកូវមកបួងា ទុតឲ្យវែនេះនឹងស្លាត់ ។ ដ្បិតអញ
នេះពុំនៅ នឹងចេញទៅទីខេត្តថ្លាត់ ឯពន្យរោធសត្ត ខន្ធួលហើយឲ្យទៅ
វិញ ។ ថ្កាយថ្កាប់ថានៃអ្នក តែវនេះដាក់ជាទ្រព្យអញ អ្នកយកទៅ
ទុកវិញ សន្យឹមអ្នកវិលមកយក ។ ខេត្តថាបើចាំ ខ្ញុកទំពាំអ្នកមក
យល់ឃ្លូខ្ញុំរកេ ទៅទីខេត្តត្រែងពុំបាន ។ រោធសត្តថាកុំ អ្នកបារម្ភ
ត្រួតត្រួយថ្កាណា ដ្បិតតែវនេះអញបាន ខន្ធួលយកពីអ្នកហើយ ។
ខេត្តស្តាប់ពាក្យរោ- ធិវរេកើបឆ្ងាស់ឆ្លើយ ឲ្យសាធុការហើយ ខន្ធួល
ខ្ញុកទើបឃាត់ថា ។ អ្នកឈប់សំពន្ធស្ងេះ លុះត្រឹកនេះបរិភោគ្តា អាហារ
ទិព្វទុជា- រសរួចហើយសឹមអ្នកទៅ ។ ឃាត់ស្រែចយកកម្រាល ទិព្វ
មកត្រាលលើលំនៅ ឲ្យរោធិចមទៅ ព្រះអង្គនៅផ្ទំសំពន្ធ ។ ខេត្តសំពះ
លា ចរយាត្រាចេញពីឋាន ទៅទើបអន្តរាធាន ពិតពុំឃើញកន្លែងឡើយ ។

លង់លុះដល់ត្រីកត្រាង កុំស្រែចស្រាងព្រះសុរិយា ខ្ចីយេខ្ចីបខ្ចាំ
រៀបគាហារមកថ្វាត់ថ្វាយ ។ ឯអង្គពង្សព្រុទ្ធា សោយអស់គាហារតាំង-
ឡាយ បរិបូណ៌សុខសប្បាយ ស្រែចព្រះអង្គលាខ្ចែតស្ងួ ។ ចុះ
ចាកចរចេញពី មណ្ឌលទីឋានសំណាក់ ដើរស្មោះឆ្ពោះត្រង់តក្កិ ទៅ
កប្បាសគ្រាមា ។ អធិតវុត្តំ ចតកឈ្មោះជិដ្ឋតា ថ្វាថ្លែងពីខ្ចាំ
បូជាតែរមិញស្រែចស្រាប់ ។

បទគាថគតិតែង តខើបចាយចែង ចរចាជួបចាប់ តំណើរទំនង
សើរសេង៍សារសើ្ច រុះរៃរៀបរាប់ និពន្ធខ្ញៀតខ្ញៅ ។ ពិតពីមានមា ណាព
ទិត្យនៅនា ឋានបិតលំនៅ ក្នុងកប្បាសគ្រាម នោះនាមឈ្មោះចៅ
កុលកោសីនៅ នៃបទន្ធកវិយា ។ នាង៍នាដនិត្តិនី កបតើតកូនស្រី
សន្ទុតនាមា នាង៍កល្យាណី ឫកពង៍សោភា សុភាពល្អ
ល្អះ ។ ប្រដូចព្រះបន្ទូ ពេញបូណ៌មីសា្បន់ រង់រឿងរីករះ ពីបូពិ
ទំសមី ស្មើថ្ងាថ្លៃ ចែងចាំង៍ត្រាង៍ព្រះ កក្កដាត់ផ្សេងដំ ។ ហាក់
ដូចស្រីសួគ៌ គំនាប់គំនួរ សាក់សំអស់អង្គ ខ្ចែខេសខ្ចែខ្ចន់ ល្អាស
ល្អន់ត្រចង់ ត្រចះវែងរ្យៃ វែកសស្រៀបស្រស់ ។ ប៉ែប្រមប៉ែប្រៃ គាប់គួរ
ល្មមល្មៃ មិនខាបមិនខ្ចៃស់ មិនជាត់មិនធំ សោតសមកំពស់ ជួនចូល
សោភ្ឋស-វិស្សាផ្ងៀងជាក់ ។ កបតើតបញ្ចូពិធ កល្យាណវិធ ត្រឹម
ត្រូវគ្រប់លំក្ខណ៍ ល្អលើសលែងស្រី ផែនដីតាំងចែក ឯកឯង៍ឥតអ្នក

ណាទំនងដូចមិនដូច្នេះ ។ ប្រាជ្ញាប្រាជ្ញប្រុះ ជាវិនាសធ្លុះ ពេកពុំពីតាល់ ដឹងដោយសញ្ញាណ មិនមានខើសពាល់ ស្រង់ស្រាយអស់អាថ៌ កិច្ចការប្រស្នា ។ ហេតុពីជាតិមុន នាងបានធ្វើបុណ្យ ចាំសីលភាវនា ខើបជាតិនេះមាន សប្រាជ្ញាញាណ ខ្ជាក់ចាំងលក្ខណា កើតកបបរិបូណ៌ ។ មាតាបិតា ស្ងួនត្រង់ក្បាំ បុត្រតែតន់ជណ្តូល មិនមានមោះហ្មង ចាំចង់អាស្សរ ហេតុអគ្គមហេសី កនៃស្រែពេជ្ឈ ។ រីឯអគ្គមា- ពុកនាងដីតាតែងយាត្រាត្រាច់ ចរះចេញចូលចំ - ការពុំដែលដាច់ នាងនាដតែងវេចបាយជូនបិតា ។ តាប់តាល ១ ថ្ងៃ នាងនាដស្រីថ្ងៃ ចំអីនអស់ភា- ហារហើយនាងវេច ស្រាប់ស្រែចយាត្រា ចេញចាកត្រឹមហា ៗ ទៅខើបប្រទះ ។ យល់ពង្សពោធិ. សត្វសាងចារមើ ដោមធាយស្រឡះ អស់អគ្គសញ្ញិគ្គ រូបពងល្អះ នីរអ្នកប៉ុនប៉ះ ធ្លុមត្រឹមដុតដល់ ។ នាងមៀងមើលជាក់ តន់តិតថាអ្នក នេះពុំដែលយល់ រូបពងល្អល្អះ ត្រចះច្ចើងថ្កល់ អស់អគ្គនិមិល កម្រកែមាន ។ ប្រុសនៅតែងស្រុក នេះទឹងមើលមុខ មួយមិញមិនមាន ស្មោះស្មើងល់ធ្លុម ប្រៀបត្រឹមមួយគ្នាន អ្នកនេះពីស្ថាន ខ្ជៀតខើបចំឡែក ។ ឯអគ្គព្រះមហាបុរសថ្លៃថ្លា ដើរតែឯងឯក យង់យល់នាងនាដ ត្រកាលល្អប្លែក មើលមិនពាស់ក្តែក ត្រឹមត្រូវលក្ខណា ។ (មានត)

អំពីបុណ្យបូជាសព

ព្រះពុទ្ធយោសាចារ្យ ជួន-ណាត

ជនហ្វាងសាលាបាលីជាន់ខ្ពស់ រៀបរៀង

លោកគ្រូ កែ-ម៉ម នាមនាយា មិស្សនាគ ជាចៅអធិការវត្ត
ពោធិព្រឹក្ស (ហោរពោលរ៉ាំ) ឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្ត
កណ្តាល ខេត្តលអនិច្ចធម្ម នៅថ្ងៃពុធ ៥កើតខែអស្សុជឆ្នាំមមីចត្វាស័ក
ព.ស. ២៤៨៥ ត្រូវនឹងថ្ងៃ ១៤ ធេកគូប្រ៉ ១៩៤២ ក្នុងជន្មាយុគំរប់ ៧៤
វស្សាបាន ៥៣ ។ លោកគ្រូ អិន-ឡឹម ជាគ្រូសូត្រវត្តនេះ ព្រមទាំង
សិស្សខ្មុំសិស្សទាំងអស់បានសុំអនុញ្ញាតពីការរួមខែត្រ ដំកល់សពរៀង
ចាកដល់ថ្ងៃព្រហស្បត៍ ១០កើតខែពិសាខឆ្នាំមមែបញ្ចស័ក ព.ស.២៤៨៦
ត្រូវនឹងថ្ងៃ ១៣ មេ ១៩៤៣ រៀបពិធីចូលបុណ្យបូជាសព, ថ្ងៃសៅរ៍
១៤កើតបូជាសព, ថ្ងៃអាទិត្យ ១៣ កើតខែពិសាខបង្ហិយបុណ្យ ។

បុណ្យបូជាសពនេះ ជាបុណ្យអធិកៈធម្មាធរឿងគួរឲ្យចង់ឃើញ
គួរឲ្យកើតសេចក្តីជ្រះថ្លា ។ បណ្តាសិស្សខ្មុំសិស្សរបស់សពនេះ មាន
លោកគ្រូព្រះពុទ្ធយោសាចារ្យ ជួន-ណាត (ជោតញ្ញាណោ) ចាងហ្វាង
សាលាបាលីជាន់ខ្ពស់ត្រូវនឹងភ្នំពេញជាដើម ទើបបណ្តាពួកគណ្យាណមិត្ត
របស់សពនេះ មានលោកគ្រូ អិន-ឡឹម (តិក្ខប្បញ្ញោ) ជាចៅអធិការ
វើបតាំងថ្មីនៃវត្តពោធិព្រឹក្សនេះជាដើម ជាអ្នកចាត់ការ បានធ្វើបាកំ

កំពូលបូជាសពនៅកន្លែងទីសួនខាងទិសឯកើតនៃឆ្នាល ជាលើ
រង្វង់តូចនេះ, ជាកំពូលនោះ ធ្វើរចនាដោយកប៉ាច់ចាក់ចេកនឹងស្លឹករៃ
ស្រស់ មានលាយតម្រងស្លឹកដៃក្រមស្រស់ខ្លះដោយអន្លើ។ ត្រង់កន្លែង
ដែលត្រូវប្រកប, ជាកំនោះឥតមានប្រើដែកគោលនឹងសំពត់សរឡើយ
ប្រើសុទ្ធសឹងតែចំណងនឹងកន្ទាស់ហើយនឹងស្រទាបចេក-ស្លឹកឱ្យស្រស់
តម្រងស្លឹកដៃក្រមខ្លះ តម្រងផ្កាពក់ខ្លះ រំលេចកប៉ាច់រចនាវិចិត្រតាមថ្នាក់
រហូតដល់កំពូល ។ ជាកំពូលនោះ មានពងសណ្ឋានជាសារតើសូត្រ៣
ជាន់, កំពស់ពីផែនដីដល់ចុងកំពូល ១៣ ម៉ែត្រ ៦០ សង់ទីម៉ែត្រ, មាន
ទ័ពពាយឬកជាវិតិព័ទ្ធជុំវិញជាកំពូលនោះ ក៏ប្រើកប៉ាច់ចាក់ចេកនឹងស្លឹក
ឱ្យស្រស់ដែរ, ជាការរចនាថ្មីក គួរយកជាបែបធ្វើតាមទៅក្នុងអនាគត,
ជាការកើតឡើងដោយស្នាដៃនៃពួកជាងជាចំណុះវត្តពោធិព្រឹក្សរួមជាមួយ
នឹងពួកជាងទៅភូមិជ្រាយអម្ពិលនឹងភូមិគោះនាក ស្រុកកៀនស្វាយ
ខែត្រកណ្តាល ដែលធ្វើតាមគំរូផែនទីបេះលោកគ្រូព្រះភទ្ទន្តោ សាធារ
ដ្ឋន-ណាត ថង្គាប់ជាងឈ្មោះយ៉ាសិស្សចាស់នៃសាលារចនាក្រុង
ភ្នំពេញឱ្យគ្រូ ។

ថ្ងៃសៅរ៍ ១២ កើតខែពិសាខ (១៥ មេ ១៩៤៣) វេលាម៉ោង ១៧ ទួល
ឆន្ទបូជាសព ។ ក្នុងវេលាបូជាសពនោះ មានអស់លោកឥស្សរជនថ្នាក់
ខ្ពស់គឺ សម្តេចព្រះសង្ឃនាយកគណៈមហានិកាយ, ព្រះតេជព្រះគុណ

ព្រះធម្មវិរិយត្រឹទ្ធ ស្តីការពីព្រះសង្ឃមាយកគណៈធម្មយុត្តិ, ព្រះតេជព្រះគុណលោកអ្នកឧកញ៉ាអគ្គមហាសេនា សេនាបតីក្រសួងព្រះបរមរាជវាំង ព្រះឃ្លាំងទទឹងធម្មការ, ព្រះតេជព្រះគុណលោកអ្នកឧកញ៉ារដ្ឋនាយកសេនា សេនាបតីក្រសួងរដ្ឋាធិការ, លោកឡឺវ៉ែស៊ីដង់ត៍ជីកណ្តាល លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ, លោកកូឈួយនៃលោកឡឺវ៉ែស៊ីដង់ត៍កណ្តាល, លោកអ្នកឧកញ៉ាអធិបតីរាមរ - អធិបតីនៃក្រសួងរដ្ឋវិចារណ៍, លោកចៅហ្វាយខែត្រកណ្តាល, លោកកូឈួយសេនាបតីនៃក្រសួងរដ្ឋាធិការ, លោកចៅហ្វាយស្រុកកណ្តាលស្ទឹង; ចំណែកខាងព្រះសង្ឃពាជាគណៈ: លោកគ្រូព្រះធម្មយោសាចារ្យ, ព្រះពុទ្ធវង្ស, ព្រះសោភ្យវង្ស, ព្រះញាណគោសលទទឹងអស់លោកបព្វជិតទីឋានានុក្រម-មហា-អាចារ្យ ទទឹងពួកលោកគ្រូចៅអធិការ- គ្រូសូត្រជាថេរខ្មុត្តរៈច្រើនវត្ត ព្រមទាំងកិកូបរិស័ទ. ទទឹងសាមណេរជាច្រើន រួមទាំងអស់ជាង ១០០ រូប, ខ្លួអស់លោកអ្នកពាក់ការទីលេខាធិការ លេខានុការ- មន្ត្រីឃ្លាំងទទឹងអស់លោកមន្ត្រីកិត្តិយស- គហបតីជាដើមទទឹងអស់ប្រជាជនជាច្រើន មកប្រជុំមើរជើរជាសក្តិយ៉ាខ្លះ ឈរខ្លះ ដោយពួកដោយគ្រួម មានរបៀបរៀបរយតាមថ្នាក់តាមលំដាប់នៃការប្រជុំធំ ។

លុះទួលឆ្លងរួចហើយ ក្មេងនេះដើរជ្រួតមួយស្របត់ ព្រះពុទ្ធឃោសាចារ្យទទឹងលោកគ្រូតិក្ខប្បញ្ញោ ជាទីសុំឲ្យអស់លោកឥស្សរជនអញ្ជើញ

ចូលកន្លងវិហារសំដែងសេចក្តីគោរពចំពោះព្រះពុទ្ធរូបថ្មកែវរួចហើយសុំឲ្យ
អញ្ជើញមើលទីវត្តខ្នងកោងបុណ្យដែលសង់រៀងពយ៉ាជួរជាសង្ឃាត់កន្លងទ
វត្តបែកខាងជើងខ្នងខាងទិសពាយ័ព្យនៃវិហារ, រួចហើយអញ្ជើញអស់
លោកមកខាងទិសឯក្បួនវិហារវិញ ហើយអញ្ជើញមើលលើសាលា
ចាស់វិន ខ្លួលកេសជ្ជៈដោយការបដិសណ្ឋារៈគ្រប់ស្រុយតាមគួរដល់
វេលា រួចហើយអស់លោកក៏លាវិលត្រឡប់មកកន្លែងកន្លះពេញវិញ ។

បញ្ជីស្រុងបំនួនតាំងបៅអធិការនិងមន្ត្រីសង្ឃ

ដែលទើបតាំងថ្មីក្នុងរោងឆ្នាំខែរកាឡែ ១៩៤៣

១- សញ្ញាប័ត្រលេខ ២៩ ចុះថ្ងៃ ២៦-៤-៤៣. តាំងគ្រូសូត្រ
ខន-ហួត កើតឆ្នាំរកា អាយុ ៤២ វស្សា ២៥ នាមធាហា ព្រហ្មសរ
ជាបៅអធិការវត្តស្វាកែត ឃុំគគីរ ស្រុកកៀនស្វាយ ។

២- សញ្ញាប័ត្រលេខ ២៦ ចុះថ្ងៃ ២៦ ៤-៤៣ តាំងគ្រូសូត្រ
ឆួ-ហ៊ុន កើតឆ្នាំមមាញ់ អាយុ ៣៨ វស្សា ១៨ នាមធាយ៉ា បញ្ញាកេសរ
ជាបៅអធិការវត្តសិរីសាគរ ឃុំព្រៃតាពោធិ៍សួស្តី (ស្រុកស្រីសន្ធរ) ។

១-កម្មាបនកិច្ចំណោះ ឧសភាសម្តេចព្រះមង្គលខេត្តាចារ្យ "ស៊ុក" ។

២-បញ្ចុះព្រះអដ្ឋិសម្តេចព្រះមង្គលខេត្តាចារ្យ "អៀម" ទំនងសម្តេចព្រះមង្គលខេត្តាចារ្យ "ស៊ុក" ។

៣- សម្ពោធទូងព្រះវិហារថ្មីវត្តបទុមវតីកជវកមក្រុងកំពត ។

កំណត់បុណ្យតាំងពីថ្ងៃ២០ រៀងទៅដល់ថ្ងៃ ២៥ ខែមីរ្យ១៩៤៣ ។

ហ្មឺនបណ្ឌាឧរុក្ស ចូ-ប៊ូ រៀបរៀង

ថ្ងៃទី ១ គឺថ្ងៃសៅរ៍ ១៥កើត ខែផល្គុន (២០មីរ្យ១៩៤៣)

ម៉ោង ១៤ គឺម៉ោង ២ រសៀល ប្រជុំព្រះសង្ឃកជាគណៈហានាទុក្រមតាំងពីគណៈ មានសម្តេចព្រះពោធិវង្ស (នាម ហ៊ុន) សង្ឃនាយកគណៈមហានិកាយ ទំនងព្រះធម្មវរិយត្តិ (ស្រី) ស្តីការដំទួសសង្ឃនាយកគណៈធម្មយុត្តិ ព្រមតាំងលោកកុង្សីយ៍សនាថតាមានលោកអ្នកទទួលភ្ញៀវអគ្គមហាសេនា (អ៊ីង-អ៊ី) ជាអធិបតី មន្ត្រីធំតូចគ្រប់ក្រុម ទំនង ចុះសក ចុះសិកា ជួបជុំហើយនិមន្តព្រះសង្ឃ ៨២ អង្គសត្តបរិសណ៌ចែកគ្នាព្រះសព រៀបចំហើយគ្រប់មុខក្រសួង ថ្វាយបង្គំព្រះសពសូមនិមន្តដោយក្បួនហែថ្មលព្រះមេរុ និមន្តព្រះគោដ្ឋដំគល់លើរថយន្តដែលរៀបចំតែងនាដោយគ្រឿងអលង្ការផ្សេង ។ មានរូបនាគ្នាតធំសម្បើម ១ គូដាក់សណ្តូកបណ្តាយសងខាងលើរថយន្ត មានតំណាយសំយុងចុះក្រោមព័ទ្ធ

ដ៏រីឯរថយន្តត្រូវជាប់ដោយផ្ទាំងដ៏ស្តើងឈើ មានព័ណ៌ដ៏ស្រស់បស់ល្អ
មានខ្សែយោងមុខតភ្ជាប់ពីរថយន្ត សម្រាប់ឲ្យពួកភ្នាក់ងារកាន់ទាញ
ដោយមិនច្បាច់ប្រៃគ្រឿងច័ក្រ រថយន្តដែលថ្វាយព្រះកាដ្ឋនេះ គាំងខៅ
ជាកណ្តាលក្បួនហែ បណ្តាយសងខាងក្បួនហែនោះមានខ្សែពួរវែង ។
ពីរកន្ទុយ ជាក់ម្ខាង ១ កន្ទុយសម្រាប់ឲ្យពួកភ្នាក់ងារដែលស្ងៀកពាក់
ខោអាវត្រហមកាន់ដើរជាជួរគ្នា ។

របៀបក្បួនហែ

នៅខាងដើមក្បួន មានភ្នាក់ងារ ១ នាក់កាន់ខ្លែវខ្នាតធំ ១ ដើរ
នាំមុខ បន្ទាប់មកមានទាហានក្រមរក្សាព្រះអង្គ ៣០ នាក់ ដើរពីរជួរ
ម្ខាង ១៥នាក់ តមកមានភ្លេងជាំង ១ វង់ មានក្រុមមហាវិទ្យាល័យស៊ុ-
សុវត្ថិប្រហែល ២០០ នាក់ ២០នាក់ស្លៀកសំពត់ចងក្បិនហើយកាន់គ្រែ
ចារនឹងផ្កាខ្វឹមចន្ទន៍ គ្រែពីនោះស្លៀកពាក់តាមធម្មតាជារបៀបជាំង
ដើរជាបួនជួរ ។ បន្ទាប់មកទៀត មានពួកយុវនប្រហែល ១០០ នាក់
ស្លៀកពាក់តាមរបៀបស្របគ្នា ភ្លេងពិណពាទ្យ ១ វង់ គ្រែព្រះពុទ្ធរូប ១
គ្រែព្រះវៃតែជិងក ១ គ្រែព្រះអភិធម្ម ១ ភ្លេងចិន ១ វង់ ភ្លេងខ្ទង់ផ្លាក់ ១
វង់ មន្ត្រីខ្ញុំពាជការប្រុសនាក់ រថយន្តថ្វាយព្រះកាដ្ឋ នៅលើរថយន្តនេះ
មានអ្នកជាំងភ្លុំធំ ១ អ្នកអង្គព្រះកាដ្ឋ ២ នាក់ ទើងមានគ្រែថ្វាយលើ
គោកប្រដាប់ដោយគ្រឿងឥស្សរិយយស មានព្រះរូបកញ្ចក់ខ្នាតធំ ១ ផង

បន្ទាប់ពីវេយ្យន្តមកមានក្រុមព្រះសង្ឃខ្មែរមន្តវិហារជាច្រើនរយអង្គ តមកទៀត មានក្រុមឧបាសិកាដើរវិហារច្រើនរយនាក់ នៅសងខាងក្បួននេះមានអ្នកកាន់ទង់ដើរជា ២ ជួរគឺ អ្នកកាន់ទង់វែង ២០ នាក់ អ្នកកាន់ទង់នាគ ១៨ នាក់ អ្នកកាន់ទង់ក្អែប ១៦ នាក់ អ្នកកាន់ចាមរ ១៦ នាក់ អ្នកកាន់សែងភ្នាន់ ១៦ នាក់ អ្នកកាន់គូភាន ១៦ នាក់ អ្នកកាន់ទង់មង្គរ ១៦ នាក់ អ្នកកាន់ទង់ឥន្ទ្រិយ ១៦ នាក់ ក្បួនវិហារនេះរៀបចំនៅខាងមុខវត្តបទុមវតី ។

លុះរៀបក្បួនវិហារស្រេចហើយ ទើបនិមន្តសម្តេចព្រះពោធិវង្ស (នាម ហ៊ុន) សង្ឃនាយកគណមហានិកាយនិងព្រៃព្រះអតិធម្មនាំមុខវេយ្យន្តព្រះកោដ្ឋ ដល់ម៉ោង ១៦ គឺម៉ោង ៤ រសៀលជាវេលានក្តុតបុក្ខល្អហើយ ក៏ចេញក្បួនវិហារពីមុខវត្តបទុមវតីទៅតាមផ្លូវឡេឆស៊ីសុវត្ថិ បត់ទៅផ្លូវប៊ូឡីវ៉ាដ្ឋាដឹកព្រះត្រែ ទៅដល់មុខសាលាហ្វូនីស្វាច្បីខ្លួកំពង់ឆ្នាំងវេយ្យន្តហើយនិមន្តព្រះសង្ឃវត្តលង្កា ៨៦ អង្គសត្តបរិវារណ៍ លុះទៅដល់មុខវិទ្យាល័យស៊ីសុវត្ថិនិមន្តព្រះសង្ឃវត្តសាកវ័ន ៨២ អង្គសត្តបរិវារណ៍ទៀត ហើយបត់ឡើងទៅតាមផ្លូវអេម៉ែត្រដ ទៅដល់មុខវត្តឧណ្ណាលោមនិមន្តព្រះសង្ឃវត្តនេះ ៨២ អង្គសត្តបរិវារណ៍ រួចបែរទៅតាមផ្លូវគេស៊ីសុវត្ថិ (ផ្លូវមាត់ទន្លេ) ដល់ផ្សារស៊ីញ៉ែកមានក្រុមឧបាសកដើរតារទៅសាលាពេទានិមន្តព្រះសង្ឃគណធម្មយុត្តិកម្ពុជាចំណែក ២០ អង្គសត្តបរិវារណ៍ មួយរលឹក

ខៀតជាតំរៃ ៤ ជង្រុង ហើយវិលទៅតាមផ្លូវសុក្ខាវង្ស- ផ្លូវរទេះស៊ីសុវត្ថិ- ផ្លូវវត្តបទុមវតី កំចូលដល់ទីព្រះមេរុនៅវេលាម៉ោង ១៧ កន្លះ គឺហាង ៥ កន្លះល្ងាច ។ ក្នុងវេលាដែលក្បួនហែចេញទៅនោះ ឃើញមានភ្លូកមនុស្សប្រុសស្រីក្មេងចាស់គ្រប់សាសន៍ឈរមើលលើចិញ្ចើមផ្លូវពាំងសងខាងគ្រៀបគ្រាប្រកិតគ្នាឥតឮខ្មោះរហូតដល់ទីព្រះមេរុ ។ នៅខណៈដែលក្បួនហែចូលដល់មុខព្រះមេរុហើយ មានតួរួចផ្ទួនថ្កាំង-ខ្នែរ ភ្លេងចំនួនភ្លេងខ្លងគ្នាក់ប្រគំខ្លួលឮសូរសព្ទគឹកកងរំពង មានក្រមពិដ័យសង្គ្រាម ក្រមរក្សាស្រុក ទំនងក្រមរក្សាព្រះអង្គខ្លួលតំនាប់ជាព្រះកិត្តិយស ។

សម្តេចព្រះវរមាតាជាទីគាប់ចិត្ត ដំណាងព្រះករុណាម្ចាស់ជីវិតលើតួរ ទ្រង់គង់លើព្រះពន្លាខាងជើងដែលក្តីនៅមុខទីព្រះមេរុជាមួយនឹងដំណាងលោកឡាវេស៊ីដង់ស៊ុបរ៉ាយ៉ែរ ព្រមទាំងព្រះពរជវង្សាខុវង្ស អស់លោកកុងស៊ីយ៉ែរសេនាបតី ទំនងហ៊ុនសព្ទមុខមន្ត្រីថ្កាំង-ខ្នែរ ។

សម្តេចព្រះបរមាជអយ្យិកាទ្រង់ប្រថាប់លើព្រះពន្លាខាងត្បូងជាមួយនឹងសម្តេចព្រះបិតុច្ឆា ព្រមទាំងដំណាវខុនឯាង- ក្រមៈបាសិកាទ្រង់គង់ចាំខ្លួលគោរពព្រះសព ។

ខណៈនោះ ក្រមភ្លាក់ងារ ទំមន្ត្រីព្រះរាជដំកាល់លើពានេនវិហែប្រទក្សិណ ៣ ជុំព្រះមេរុចាយរទើបវិលវិហារឡើងតាមមាគ៌ាសោធ្យាណៈ

ទៅដំកល់លើបញ្ជា ៥ ជាន់ស្រែចេរីយនិមន្តសម្តេចព្រះពោធិវង្ស ខាម (ហ៊ុន) សង្ឃនាយកគណៈមហានិកាយទស់បន្តង់ ទីឯទីមន្តព្រះសង្ឃ ៨២ អគ្គសត្តប្បករណ៍ហើយប្រគេនទៀនកៅរឹតបក្ខគណនាដែលលោកឧត្តមលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ (ជួយប៉ុង) ជំនួយកន្លងបុណ្យមានប្រវត្តិសម្តេចព្រះគោដ្ឋវាង ២ ព្រះអង្គ:ខាងដើមផង តមកទៀតមានក្រមសិស្សាខុសិស្សនិមន្តព្រះសង្ឃសត្តប្បករណ៍ដើម្បីទុទ្ធិសប្រគេនកុសលចំពោះសម្តេចព្រះគោដ្ឋដារួចនៅលើក ។

ខាងវេលាដែលដំកល់ព្រះសពលើបញ្ជាក្នុងព្រះមេរុនោះ មានព្រះសង្ឃវាង ២ គណៈនិមន្តមកពីវត្តក្រៅនិងវត្តក្នុងក្រុង (តាមវាងពួកធុជ្ឈសក- ធុជ្ឈសិកា នឹងបណ្តាជនគ្រប់សាសន៍វាងហាសំវាងក្នុងសឹងតែនាំគ្នាមកជួយឧបអរសោភរមើលពិធីបុណ្យគ្រឹកគរគ្រង ចង្អៀតកន្លងទីមេរុនឹងទីវត្តវាងមួល ។

អំពីរបៀបព្រះមេរុ

គួរព្រះមេរុនោះធ្វើដោយគ្រឿងឈើ ទំហំខ្ពស់ ៧ ម៉ែត្រ បណ្តោយ ៨ ម៉ែត្រ កំពស់ ១៨ ម៉ែត្រ ដំឡៃ ៤០៥០,០០ ធ្វើមៅមុខវត្តបទុមវតីជាវាសិត្តព្រះមហាពោធិព្រឹក្ស ខាងក្នុងព្រះមេរុមានបញ្ជា ៥ ជាន់ធ្វើរបាយឈើប្រក់ក្តឹងប្រក់ប៉ាយយ៉ាមរបៃមនុស្សចង្អៀតធ្វើពីស្តាន់ក្រាបនឹង

គាត់តែងគ្រឿងសក្ការបូជាគ្រប់ជាន់ មានថែរក្សាទុកគ្រាលក្ការពីខ្ញុំវិញ ព្រះមេរុ នៅជុំវិញថែរពាំង ៤ ទិសមានទីស្នាសនសម្រាប់ព្រះសង្ឃគង់សូត្រព្រះធម្មពាល់វេលា នៅខាងមុខព្រះមេរុមានព្រះពន្ធា ២ ខ្នង គ្រឿងឈើច្រក់ស្លឹកមាតធំខ្ពស់ជាំមួនក្ដ ព្រះពន្ធា ១ ខ្នងខាងជើងសម្រាប់ថ្វាយព្រះតរុណាជាម្ចាស់ជីវិតលើតួង ទីឯលោកឡាវស៊ុដន័ សុម៉ែរីយើរ ព្រះពជវង្សាខុវង្ស អស់លោកកុងរ៉ាយ៍សេនាបតី មន្ត្រីជាំង—ខ្នែរ ឯព្រះពន្ធា ១ ខ្នងទៀតនៅខាងតួងសម្រាប់ក្សត្រីតង់ នៅខាងមុខព្រះវិហារមានជាំធំ ៗ ពីរខ្នងឆ្លើយឆ្លងគ្នា សម្រាប់ទទួលព្រះសង្ឃទីនេះជាសកនេះជាសិកាដែលមកកុនកំឡុងបុណ្យ នៅខាងមុខព្រះវិហារទីនេះខាងមុខព្រះមេរុ មានគុរៀបតាំងគ្រឿងសក្ការបូជាថ្វាយព្រះរតនត្រ័យចំនួន ១ : គុ គឺគុព្រះកច្ចុមុទ្ធកជាគណៈវត្តបទុមវតី ១ គុព្រះអមរកិរក្ខិតជាគណៈវត្តបទុមវតី ១ គុព្រះញាណវង្សជាគណៈវត្តពុទ្ធឃោសារាម ១ គុព្រះធម្មវិត្រលោកាចារ្យជាគណៈវត្តប្រយូរវង្ស ១ គុព្រះញាណវិរិយជាគណៈវត្តខ្នុនមណីរាម ១ គុព្រះចុង្ហាត់អរិយត្ថិទ្ធិ (ស៊ុន) វត្តបទុមវតី ១ គុព្រះមហាព្រហ្មមុទ្ធកជាគណៈវត្តស្វាយពពែ ១ គុលោកគ្រូចៅអធិការវត្តតាភ្ញៅ ១ គុព្រះចុង្ហាត់ធម្មទត្តម (ប៊ុច) វត្តកែវទត្តមស្វាយ ១ គុព្រះគ្រូនាគមុនីវត្តពាមសន្ដា ១ រួមជា ១០គុ នៅជុំវិញវត្តខាងជើងមានពេនរាំងខ ១ ខ្នង, នៅជុំវិញវត្តខាងតួងមានពេនណាំង-

តាលុង ១ ខ្នង; ទៅទិត្រពះវិហារ; ទិត្រពះចតិយធំ-តូច; ទិត្រពះមហា
នោធិ៍ត្រីក្ស ទីធំទៅទីកុដិ-ហោរិត្រកន្លែងវត្តបទុមវតីទាំងមូល សឹងតែ
លាបបូកស្អាតថ្មីទាំងអស់ ហើយតាក់តែងដោយប្រទីបជ្វាលាអគ្គិសនី
ភ្លឺច្បាស់រន្ធាលពេញទាំងអាវាស ចំណែកឯតួព្រះមេរុក៏ប្រដាប់ដោយ
ប្រទីបអគ្គិសនីតាំងពីកំពូលមេរុរៀងចុះមកដល់ផ្ទៃផែនដី មានសសរ
តាំងជួចរន្ធាក្តីខ្ទេងដាំនៅមុខព្រះវិហារសម្រាប់អុជពាល់ពិត្រី នៅខាង
ត្បូងព្រះវិហារមានកេងលាងច្រើនខ្នងខ្ទេតសម្រាប់ធ្វើកេសជ្ជៈ ទីធំ
ចាត់ចែងចង្ហាន់ប្រគេនព្រះសង្ឃរាល់ថ្ងៃ ។

កាលវែលាហែព្រះកោដ្ឋដំណល់លើបញ្ចា ៩ ជាន់ក្នុងព្រះមេរុស្រេច
ចៅ៉យ ដល់មោ៉ង ១៨ ឌីមោ៉ង ៦ ព្រលប់ មានភ្លេងខ្ទងធ្លាក់ប្រគំតាម
អំទេីមទីធំអុជប្រទីបជ្វាលាអគ្គិសនីភ្លឺព្រាងត្រាយសព្វទិសាទុទិស ជា
តាវុង៉ះរឿងអស្ចារ្យ ។

ដល់មោ៉ង ២០ ឌីមោ៉ង ៨ យប់ និមន្តព្រះសង្ឃគណៈមហានិកាយ
១៦ អគ្គីវែលតង់សូត្រត្រៃជម្មនៅទីស្នាងតាំង ៤ ទិសនោះចំរើនព្រះ
បរិត្តនាំព្រះមេរុ បន់ហើយអុជគាំជួចរន្ធាក្តីខ្ទេងបួនជា ព្រះភេនត្រយ៉ាង
១ ឡូវកំរ តាំងលែ្បងមហោស្រពក៏លេងទៀងទីអីងអាប់សម្រាប់ឲ្យ
បណ្តារជនមើលជាទីគំហាន្ត ។

ដល់ម៉ោង ២១ គឺម៉ោង ៩ យប់ ទិមន្តព្រះធម្មកថិក ១ អង្គទេសនា
រឿងព្រះធម្មគោរព មានសោភនដំបូលសព្វី ៤ អង្គ ៨ រូប នៅទីព្រះ
មេរុជ្រុងខាងលិច តែដោយមានពួកទុច្ចសក- ទុច្ចសិកាចូលចិត្តស្តាប់
ធម៌ទេសនាច្រើនពេក ក៏ឃាននិមន្តព្រះធម្មកថិកពីរបីអង្គទេសនាៈនៅ
ជ្រុងព្រះមេរុខាងកើតជាលំដាប់មកទៀត ទិមន្តព្រះសង្ឃគណៈមហានិ-
កាយ ១៦ អង្គសូត្រព្រះសត្តបរិត្តរណាគាថាមួយទីស្នាន៣ ទិស
តាំងពីព្រលប់ដល់ភ្លឺ ចំណែកឯល្ងាចមហោស្រពលេងទៅដល់ម៉ោង
២៤ គឺម៉ោង ១២ អធ្រាត្រឈប់ ។

ថ្ងៃទី ២ គឺថ្ងៃអាទិត្យ ១ រោចខែផល្គុន (២១ មីនា ១៩៤៣)

ម៉ោង ១០ ព្រឹក រៀបគត្តប្រគេនចង្ហាន់ព្រះសង្ឃ ១៦ អង្គដែលតាំង
សូត្រព្រះធម្មទេសនាពីល្ងាចនោះ ព្រមទាំងព្រះសង្ឃដាក់តន្តុក
១៣៤ អង្គទាន់នៅទីសាលាកុងវត្តរួមជា ១៥០ អង្គពេលថ្ងៃ ។

ម៉ោង ១៥ គឺម៉ោង ៣ រសៀល ទិមន្តធម្មកថិក ១ អង្គទេសនារឿង
ព្រះពុទ្ធគុណ មានសោភនដំបូលសព្វី ៤ អង្គ ។

តាំងពីម៉ោង ១៨ ដល់ម៉ោង ២៤ គឺម៉ោង ៦ ព្រលប់ដល់ម៉ោង ១២
អធ្រាត្រ រៀបពិធីបុណ្យដូចថ្ងៃទី ១ ។

ថ្ងៃទី ៣ គឺថ្ងៃបន្ទួ ២ រោច ខែផល្គុន (២២ មីនា ១៩៤៣)

ពីម៉ោង ៦ ដល់ម៉ោង ១០ ព្រឹក មានការបៀបចំធម្មបុណ្យវេរកថ្ពួកព្រះគេន ព្រះសង្ឃឆាន់ដូចថ្ងៃទី ២ ។

ម៉ោង ១១ ព្រឹក ក្រុមភ្ញាក់ដារចេតនាវេតិលព្រះសពចុះចាកបញ្ជាហៃ ទៅដំកល់ទៅទីស្នាននាងតេត ទើបក្រុមមេការបៀបចំទីបញ្ចាសម្រាប់ ឆ្លងព្រះសព ស្រែចហើយនិមន្តតែឯកតោដ្ឋប្រជាប់គ្រប់ដោយថ្នាក់មក ដំកល់លើគ្រឿងជាន់ដែលរំលេចដោយកញ្ចាច់ចាក់ចេកក្នុងព្រះមេរុវិញ ។

ម៉ោង ១៧ គឺម៉ោង ៥ រសៀល និមន្តព្រះសង្ឃ ៥៦ អង្គសត្តបរិកណ៌ចប់ហើយ ព្រះកុណាជាម្ចាស់ដីវត្តលើកឆ្នាំង ស្តុចយាងចូលទៅកាន់ទីព្រះមេរុ ជាមួយនឹងលោកឯកឧត្តមស្ទ្រេស៊ូដង់ស៊ុយប៉ារ៉ាយ៉ែរ ព្រមទាំងព្រះរាជអង្គារុង្សរ លោកកុង្សីយ៍សេនាបតីនិងនាហ្មឺនសព្វមុខមន្ត្រីជាច្រើន ជាតំណាងខ្ញុំមចន្ទ្រំនិងវៀតជួប ។ ឯគោសតាមទំនៀម ហើយព្រះស្តុចយាងទៅដែលលើព្រះពន្ធារួចហើយ ក្រុមភ្ញាក់ដារមេទ្រសួងពាយន្តនិងសំពែកសត្វបួនថ្នាយន្តនិងព្រះហត្ថក្តីវៀនទ្រនំព្រះរាជគានក្តីងរំលាយព្រះសព ។ ឯ: នោះក្រុមភាហានក្សាព្រះអង្គ ក្រុមតាំងយសគ្រាម នឹងក្រុមក្សាស្រុកខ្លួលតំនាំបាំគោរពគ្រឿងឥស្សរិយយស ព្រមទាំងក្រុមភ្ញៀងហ្គាកាំង ភ្លេងខ្មែរ នឹងភ្លេងខ្លួនភ្ញាក់ក៏បន្ទើសូរសើភ្លេងប្រគំតតកងរំតងស្នើគ្នានឹងសូរសំរៀងឆ្លងសំពែកសត្វជាន ។ ល ។ ក សំពែក អស្ចារ្យ ។

ម៉ោង ១៨ គឺ ម៉ោង ៦ ព្រលប់ ក្រុមសទ្ធិជាតអ្នកចាត់ពិធីបុណ្យជាន ចាត់លោក ញឹក - ទូ - ត្រួចរង្វិនសាលាជាំង ដែសទ្យេរឡើងលើកល្យ ព្រឹក្សដែលធ្វើទៅទិសទីតឹព្រះមេរុ ប្រយោគនច្រាក់កាក់តួចកប់ក្នុងថ្ម ក្រួចឆ្នាំរចំនួន ២០ រៀលមួយថ្ងៃគ្រប់ ៣ ថ្ងៃ ។

ពីរម៉ោង ១៨ ដល់ម៉ោង ២៤ គឺពីម៉ោង ៦ ព្រលប់ដល់ម៉ោង ១២ អធ្រាត្ររៀបពិធីបុណ្យជូនថ្ងៃទី ២ ក្រែកតែគ្មានព្រះសង្ឃសូត្រព្រះធម្ម មិនគ្មានភ្លេងខ្ទងឆ្នាក់ប្រគំយាម ។

ថ្ងៃទី ៤ គឺថ្ងៃអង្គារ ៣ រោច ខែជេស្ឋ ឆ្នាំល្អូន (២៣ មីនា ១៩៤៣)

ម៉ោង ៧ ព្រឹក និមន្តព្រះសង្ឃ ៨ អង្គ សត្តប្បការណ៍ ប្រែព្រះរូប មាន ឃ្លាតួ ៤ នាក់ បង្វិលពពិល ហើយប្រដុំព្រះសង្ឃ - ១ ឃ្លាសក - ១ ឃ្លាសិការ៉ែស ព្រះអង្គិសោធ ឲ្យជ្រះមន្ទិលហើយបិទដោយមាសសន្ទឹក ដាក់កន្ទឹកកោដ្ឋ ច្រាក់ក្រៃឡមាស ដំកល់លើពានច្រាក់ ១ ជាន់ ធំពានក្រៃឡមាស ២ ជាន់ ។

ម៉ោង ៨ ព្រឹក និមន្តកោដ្ឋព្រះអង្គដំកល់លើបញ្ជាវិញ ឯអង្គារ៉ែវហ ទៅបញ្ចុះជិតគល់ព្រះមហាពោធិព្រឹក្សខាងទិសបូព៌ ។

ម៉ោង ១០ ព្រឹក និមន្តព្រះសង្ឃ ១០ អង្គវែកគ្នាទៅទីព្រះមេរុ ឯ រៀបប្រគេនចង្ហាន់ព្រះសង្ឃអាគន្តុកៈឆាន់ជូនថ្ងៃទី ២ ។

ម៉ោង ១៨ គឺម៉ោងល្ងាចសៀល ប្រជុំព្រះសង្ឃ-ឧបាសក-ឧបាសិកា ជួបជុំនៅទីលោកៃត្រ ត្រង់វិមលធម្ម (ភ្នូង) ដែលជាទីដាក់កោដ្ឋព្រះអដ្ឋិ សម្តេចព្រះមង្គលទេពាចារ្យ "ស៊ឹម" ហើយនិមន្តព្រះសង្ឃ ៧៣ អង្គ សត្តបរិកណ៌ រួចព្រះវិមលធម្ម "ភ្នូង" និមន្តកោដ្ឋព្រះអដ្ឋិសម្តេចព្រះ មង្គលទេពាចារ្យ "ស៊ឹម" ចេញដំណើរលើបញ្ជាក្នុងព្រះមេរុ ជាមួយ ខ្ទង់ព្រះអដ្ឋិសម្តេចព្រះមង្គលទេពាចារ្យ "ស៊ុក" ស្រែចហើយនិមន្តព្រះ សង្ឃ ៧៣ អង្គ សត្តបរិកណ៌នៅទីព្រះមេរុ ១ លើកទៀត ។

ម៉ោង ១៩ គឺម៉ោង ៧ យប់ និមន្តព្រះសង្ឃ ១៥៥ អង្គចំរើនព្រះបរិត្ត នៅទីព្រះមេរុ ចប់ហើយនិមន្តព្រះធម្មកថិក ១ អង្គទេសនារឿងបឋម ត្រាស់ ហើយនិមន្តព្រះសង្ឃ ២ អង្គ សូត្រភ្ជាក់សេកអកិសេកព្រះពុទ្ធ បដិមាករដែលហាងថ្មី ។

តាំងពីម៉ោង ១៩ ដល់ម៉ោង ២៤ គឺតាំងម៉ោង ៧ យប់ដល់ម៉ោង ១២ អធ្រាត្រ រៀបពិធីបុណ្យផ្ទេរ ២ ក្នុងថ្ងៃទី ១១ ។

តំណើបុណ្យបញ្ចុះព្រះអដ្ឋិ

ថ្ងៃទី ៥ ខែពិឆ ៤ ពេលខែដាច់ស្រូវ (២៤ ម៉ាឬ ១៩៤៣)

ម៉ោង ៧ ព្រឹក ប្រជុំព្រះសង្ឃគណៈហាងគុកមាន ៤ គណៈ: មានសម្តេចព្រះពោធិវង្ស (នាម ប៊ុន) សង្ឃនាយកគណៈមហានិកាយ

ទីឯព្រះធម្មវិរិយ(ព្រំទ្ធកិស្រី)ស្តីការកន្លងវត្តបទុមវតី ជាប្រធានព្រមទាំងក្រុមឧបាសក-ឧបាសិកាដួបជុំហើយនៅបរិវេណគន្ធព្រះអដ្ឋិសម្ពុទ្ធព្រះសង្ឃនាយកទាំង ៤ ព្រះអង្គពីបញ្ចាកន្លងព្រះមេរុ៧ដងលើតុដែលតាំងនៅលើលានព្រះចេតិយធំចំពីខាងមុខ ។

មោងឹង ៨កន្ទុះព្រឹក ព្រះករុណាជាម្ចាស់ជីវិតលើកឬង ស្តេចយាងជាអធិបតី ជាមួយនឹងលោកឡឺវេស៊ីដង់សុបេរីយើរ ព្រមទាំងព្រះពជវង្សានុវង្ស លោកកុង្សីយ៍សេនាបតី មន្ត្រីចាក់ដ-វ៉ែន ។

គ្រានោះ លោកគ្រូព្រះវិមលធម្ម "ភួង" បានថ្លែងសុន្ទរកថាកន្លងទីមហាសន្និបាត ដូចមានសេចក្តីតទៅនេះ

សុន្ទរកថា

បុណ្យអដ្ឋិធាតុ ជំរាលទុកក្នុងព្រះចេតិយធំ

អាត្មាភាព សូមថ្វាយព្រះពរ ព្រះចុងសម្ពុទ្ធព្រះបរមបពិត្រព្រះករុណាជាម្ចាស់ជីវិត សូមទ្រង់ជ្រាប ។

សូមចំរើនពរ លោកឡឺវេស៊ីដង់សុបេរីយើរ ជាអធិបតីពជការអាណាព្យាបាល ព្រមដោយព្រះពជវង្សានុវង្ស ទីឯលោកសេនាបតីនាហ្នឹងសព្វមុខមន្ត្រីចាក់ដ-វ៉ែន សូមជ្រាប ។

ឥណ្ឌុកាសនេះ ព្រះបរមបពិត្រព្រះករុណាជាម្ចាស់ជីវិត ដែលទ្រង់មានព្រះវិរិយភាពឆ្ពោះទៅកន្លងទីមង្គលសម័យវិសេសនេះ ព្រមដោយ

លោកឡឺវេស៊ុដង់ត៍សុះប៉ើរយ៉ើរ នឹងព្រះបរមកដវង្សានុវង្ស លោកសេនាបតី នាហ្នឹនសព្ទមុខមន្ត្រី ដើម្បីនឹងទ្រង់ព្រះប្រោតព្រះកដកិច្ចដែលត្រូវតាក់តែងព្រះអដ្ឋិសម្ភេចចេញអាកាសចាំង ៦ ប្រមុខ ១- ព្រះអដ្ឋិសម្ភេចព្រះមង្គលខេត្តាចារ្យនាម "អ៊ឹម" ព្រជន្មាយុ ៧៣ ព្រះវស្សាដែលបានធ្វើឈាបនកិច្ចរួចហើយកន្លងអតីតភាគ ។

២— ព្រះអដ្ឋិសម្ភេចព្រះមង្គលខេត្តាចារ្យនាម "ស៊ុក" ព្រះជន្មាយុ ៨២ ព្រះវស្សា ដែលទើបធ្វើឈាបនកិច្ចក្នុងកាលបច្ចុប្បន្នភាគនេះ ។

ព្រះអដ្ឋិបច្ចុប្បន្ននេះហើយ ដែលកើតឡើងដោយអំណាច ព្រះបុញ្ញាធិគុណនៃពាជធម៌ព្រះបរមបពិត្រព្រះករុណាជាម្ចាស់ជីវិត នឹងលោកឡឺវេស៊ុដង់ត៍សុះប៉ើរយ៉ើរ ព្រមទាំងព្រះបរមកដវង្សានុវង្ស លោកសេនាបតី នាហ្នឹនសព្ទមុខមន្ត្រី ព្រមទាំងអាណាប្រជាជនផង ។

ព្រះករុណាជាម្ចាស់ជីវិត ស្តេចចេញជាព្រះពាជមុខ បំពេញព្រះពាជកិច្ចក្នុងអតិលក្ខិតសម័យ ដែលតែងតាំងជាមេរុ ព្រមទាំងសំលៀកបំពាក់នៃអគ្គមេរុដ៏សំក្តិសម គ្រប់គ្រឿងរុងរឿងជាមហោឡារិក ឬជាំលាយសពជាស្រែចបានឡើងជាអដ្ឋិជាតុក្នុងបច្ចុប្បន្នភាគនេះ ។

ឥឡូវនេះព្រះអដ្ឋិទាំងពីរដែលដំកល់ទុកនៅក្នុងកោដ្ឋទាំងគូ ទ្រង់ព្រះពាជទានឱ្យអនុញ្ញាតនឹងអនុញ្ញាតឱ្យនាំឡើងគាន់ខែដែលត្រូវប្រតិស្ថានទុកក្នុង

ព្រះចេតិយអគ្គធំ ទើបនឹងបដិសង្ខរណាថ្មី ក្នុងពេលដំពេញទៅដោយ
តិថីសុខក្ខគ្គឫក្សមហាមង្គលដ៏វិសេសនេះ ។

អាត្មាភាព ព្រមទាំងបណ្ដាសិស្សានុសិស្ស បពិត្រជនទាំងពួងអស់ សូមព្រះរាជទានទទួលព្រះរាជអំណរនឹងសូមរួមលេចក្តីអំណរដែលពេកក្នុងព្រះគុណ ដែលព្រះបរមបពិត្រព្រះករុណាជាម្ចាស់ដ៏វិតត្រង់ព្រះពជ្រមត្តមួងលោកបពិត្រទាំងពួងដួយ។បត្តមួងឲ្យសម្រេចតិច្ចបុណ្យនេះដោយសោមនស្សចង្អស់ពីព្រះរាជហឫទ័យនឹងដួងហឫទ័យ សូមថ្វាយព្រះរាជកុសលនឹងសូមដំរាបជូនកុសល ។

សូមអានុភាពព្រះរាជកុសលថ្វាយដល់ព្រះបរមបពិត្រ ព្រះករុណាជាម្ចាស់ដ៏វិតលើត្បូង សូមចំរើនន្ទូរព្រះជន្មាយុសុខសព្វាព ដំរង់ទៅកន្លែងព្រះបរមរាជសម្បត្តិលុះបំផុតខែត្រនៃព្រះរាជក្សត្រ ។

សូមអានុភាពកុសលដំរាបជូនដល់លោកឡាវេស៊ីជនតំសុបេរ៉ាយើរដែលជាអធិបតីរាជការអាណាព្យាបាល សូមចំរើនទីយាយុសុខសួស្តីទាំងក្នុងរាជកាយ ទាំងក្នុងនាទីរាជការ ទំនឹងផ្សាយដល់មហាជនតរាបាំងសែស សូមចំរើនន្ទូរវែងខ្ជិតលុះដំតល់ទៅក្នុងសេចក្តីសុខមហាប្រសើរគ្រប់ប្រការ ។

សូមអានុភាពនៃកុសល ចូរឃុំគ្រងអភិបាលព្រះបរមរាជវង្សានុវង្សលោកសេនាបតី នាហ្មឺនសព្វបុរមន្ត្រី ខ្ទួរទៅដល់អាណាប្រជារាស្ត្រ

ផ្នែកធំគ្រងកម្ពុជាណាចក្រ សូមសំរិទ្ធិកងពារ ៤ ប្រការដោយផលវិផល
សត្យាធិដ្ឋានខេរកុំបីឃ្លាត ។

ចប់សុន្ទរកថាតែប៉ុណ្ណោះ

កាលចប់សុន្ទរកថាហើយ លោកគ្រូព្រះធម្មវិរិយៈព្រឹទ្ធ (ស្រី) លើក
ព្រះកោដ្ឋអដ្ឋសម្ពេចព្រះមង្គលទេពាចារ្យ "អៀម" មកថ្វាយព្រះគុណ
ជាម្ចាស់ដីតលើតុប្លង់ លោកគ្រូព្រះធម្មទុត្តម "ទេស" លើកព្រះកោដ្ឋអដ្ឋ
សម្ពេចព្រះមង្គលទេពាចារ្យ "ស៊ុក" ជូនលោកឡឺវេស៊ុដង់ត៍សុប៉ែរយើរ
ព្រះគុណានំធំលោកឡឺវេស៊ុដង់ត៍សុប៉ែរយើរ ទទួលព្រះអង្គដាសេចក្តី
គារវៈ រួចហើយប្រគេនព្រះអដ្ឋកៅព្រះសង្ឃគាំង ២ អគ្គវិញ ឲ្យទាំងៅ
បញ្ចុះតង្ហែព្រះបតិយធំ ឯណោះ ក្លេងខ្លងធ្នាក់ប្រគំ ព្រមគាំងក្លេង
ពិណពាទ្យ ក្លេងថ្កាំង ក្លេងខ្នែរបន្ទីស្គរស័ព្ទគ្រហឹងអឺងកង គាំងសេ-
នាភហានគ្រប់ក្រុមក៏ទទួលតំនាប់ជាព្រះកិត្តិយស បញ្ចុះស្រេចហើយ
ទំមន្ទព្រះសង្ឃគណៈមហានិកាយ ១៥៥អង្គសត្តមប្បកណ្ណ ហើយប្រគេន
សៀវភៅមនោបុព្វកថាគ្រប់អង្គ ដើម្បីទុកឃើញព្រះពុទ្ធសាសនាថ្វាយសម្ពេច
ព្រះសុគន្ធាធិបតី "ជ៉ុន" ទំងំសម្ពេចព្រះមង្គលទេពាចារ្យគាំងពីរព្រះ
អង្គផង ។

ម៉ោង ១០ ព្រឹក វេរតគ្គប្រគេនចង្ហាន់ព្រះសង្ឃគាំងដូចថ្ងៃទី ២ ។

ពិធីបុណ្យឆ្លងព្រះវិហារ

ម៉ោង ១៩ គឺម៉ោង ៧ យប់ ខិមន្តព្រះសង្ឃភាជាគណៈហាទានុក្រម ចាំង ២ គណៈកំនួន ៤០ អង្គចំរើនព្រះបរិត្តកងព្រះវិហារ មានសម្តេចព្រះពោធិវង្សសង្ឃនាយកគណៈមហានិកាយ ទំងព្រះធម្មវរិយត្ថេរ (ស្រ) ស្តីការដំនួសសង្ឃនាយកកងវត្តបទុមវតី ជាប្រធាន ។

ម៉ោង ៤០ គឺម៉ោង ៨ យប់ ខិមន្តព្រះធម្មកថិក ១ អង្គទេសនាមៅទីព្រះមេរុ មានលោកនំនួលសត្វ ៤ អង្គ ។

ថ្ងៃទី ៦ គឺថ្ងៃព្រហស្បត៍ ៥កើតខែផល្គុន (២៥ មីរ៉ា ១៩៤៣)

ម៉ោង ៧ ព្រឹក ប្រជុំព្រះសង្ឃភាជាគណៈហាទានុក្រមចាំង ២ គណៈ ហានសម្តេចព្រះពោធិវង្ស ទំងព្រះធម្មវរិយត្ថេរ ជាប្រធានព្រមចាំងពួកឧបាសក-ឧបាសិកាជួបជុំកងព្រះវិហារ ។

ម៉ោង ៨ កន្លះព្រឹក សម្តេចព្រះបរមកជចិតាទ្រង់ជាដំណាងព្រះករុណាព្រះបាទសីសុវត្ថិ ស្តេចគាត់កម្រងផ្កាផៃលកំងនៅមុខព្រះលក្ខណាល វិហារយោងចូលជាអធិបតី ជាមួយនំងលោកឡឺវេស៊ីដត៍មែរ ជាដំណាងលោកឡឺវេស៊ីដងត៍សុប៉ែរយើរ ព្រមចាំងព្រះភជវង្សានុវង្ស លោកកុងឡ័យ ៈសេនាបតី ទំងនាហ្មឺនសព្វមុខមន្ត្រីជាកំងរ៉ែរ ទ្រង់ថ្វាយព្រះទៀនធូបបូជាព្រះពុទ្ធរូប ។

ទៅរំលោមហាសន្និបាតនេះ លោកត្រែរ៉ែន័យជរ "ប្លូម" ក្នុងថ្ងៃន=

សុទ្ធរតកថា

បុណ្យសម្ពោធធ្វើឆ្លងព្រះវិហារវត្តបទុមតើកជវរាម

អាត្មាភាព សូមថ្វាយព្រះពរ ព្រះបាទសម្តេចព្រះបរមបពិត្រ ព្រះករុណាជាអម្ចាស់ជីវិត សូមទ្រង់ជ្រាប ។

សូមចំរើនពរ លោកឧបាសុជនតំណាងសុខៈរីរយើរ ព្រមដោយព្រះពជវង្ស-ខុវង្ស ខ្ញុំលោកសេនាបតីនាហ្មឹនសព្វមុខមន្ត្រីចាក់ដែ-ទ្វៃរសូមជ្រាប ។

ក្នុងឧកាសដែលព្រះបរមបពិត្រ ព្រះករុណាជាអម្ចាស់ជីវិតស្តេចទ្រង់ព្រះនៅកងកណ្តាលជំនុំខែមហាមហុរតិឫក្សនេះ ដើម្បីនឹងសម្រេចខ្លួនព្រះពជកិច្ចបុណ្យសម្ពោធធ្វើឆ្លងព្រះវិហារ នឹងទ្រង់ខ្លួនក្តុំណោមកដែលជាកិច្ចសំខាន់បំផុត ដើម្បីសំគាល់ជាអំណោយដល់សង្ឃ មានព្រះធម្មវិនយត្រឹង "ស្រី" ជាសង្ឃរត្នៈ ។ ព្រះពជកិច្ចនោះជាព្រះចរិយាវត្តព្រះបរមក្សត្រដ៏ទ្រង់ខ្លួសាសនូបត្ថម្ភក៍ មានមកក្នុងកាលពុទ្ធសម័យបានធ្លើហើយ ដូចព្រះបរមបពិត្រទ្រង់ឧបត្ថម្ភនៅវេលានេះ ។

ឯវិហារវត្តនេះ តាមប្រវត្តិកត់ត្រាទុក កាលព័ន្ធចចត្វាស័ក ព.ស. ១៩៨៦ គ.ស. ១៦៤២ កងរដ្ឋកាលព្រះបាទសម្តេចព្រះបរមរាជាតញ្ញាយ៉ាត បានសាងម្តង ឈ្មោះវត្តខ្ពបតាយ៉ង ព្រោះមានខ្ពបរបស់វត្តជាខែត្រដែន តែកន្លងមក ៤៦១ ឆ្នាំហើយបាក់បែកសាបសូន្យអស់ទៅ នៅតែខ្លួលខឹងដុំសិលាស័ម ខឹងខ្ពបជាចាក ។

ដល់ឆ្នាំថ្វីសប្តស័ក ព.ស. ២៤០៨ គ.ស. ១៨៦៤ កន្លងរដ្ឋកាល ព្រះបាទសម្តេចព្រះនរោត្តមបរមបពិត្រ ព្រះសុវណ្ណកោដ្ឋ ចាននាង ព្រះវិហារឡើងខ្មែរ នៅទីដំណែលមុន ថ្វាយសម្តេចព្រះសុគន្ធាធិបតី ព្រះនាម "ចាន" គង់នៅជាសេដ្ឋចសង្ឃគណធម្មយុត្តិ ទ្រង់ចញ្ចូតនាម ជាវត្តហ្លួង ឲ្យហៅជាប់តទៅនាមវត្តនោះដែរថា "បទុមវតីពជវរាម" តែងំ ខ្ចប់ដុំវិញ តែបហៅថា ស្រះ។ ដុំវិញវត្តដាំពេញទៅដោយឈូក តែងំ ពជវរាម ថាជាអារាមហ្លួង ។

ដល់ឆ្នាំជូតឯកស័ក ព.ស. ២៤៤២ គ.ស. ១៩០១ កន្លងរដ្ឋកាល ព្រះបាទសម្តេចព្រះនរោត្តមបរមបពិត្រ ព្រះសុវណ្ណកោដ្ឋ ទ្រង់ឧបត្ថម្ភ តមក ឧកញ៉ាពិតិតឥស្សរ នាម "ម៉ី" ចានសូមព្រះពជាន្ធញ្ញាតសាន់ជួស ជុលម្តង មានសម្តេចព្រះមន្ត្តីលទេពាចារ្យ នាម "អៀម" ជាសម្តេចទៅ វត្តជំនួយចាត់ការ ។

ដល់ឆ្នាំថ្វីនព្វស័ក ព.ស. ២៤៨០ គ.ស ១៩៣៨ កន្លងរដ្ឋកាល ព្រះបាទសម្តេចព្រះសិរីសុវត្ថិមុនីវង្សបរមបពិត្រ (ព្រះវត្តិយកោដ្ឋ) ទ្រង់ លោកឡឺវេស៊ីដង់ត៍សុប៉ែរីយ៉ែរ "រីសូម" ជួយឧបត្ថម្ភដើមហេតុការណ៍ ព្រមដោយព្រះពជវង្សានុវង្ស នាហ្លួនសព្វមុខមន្ត្រី ទាំងបណ្តា ប្រជាទំនរ កងអាណាខេត្ត ជែរថ្វាជួយឧបត្ថម្ភ មានលោកសម្តេចព្រះអង្គវែ សេរីពជ នាម "ជួន" កាលនៅជាសម្តេចទៅហ្លាំង ខ្លួលការៈជួយ

ខំនុកបម្រែងតាមព្រះពាជបញ្ជាការ ចំណាយព្រះពាជទ្រព្យនិងទ្រព្យយោ-
សនាប្រមាណជាចំនួន ហើយរុះរើហោរចាស់ដែលបាក់ពុកតសាងជាវិហារថ្មីនេះ
កងជាន់សម្តេចព្រះមង្គលទេពាចារ្យ "ស៊ុក" ជាសម្តេចថៅវត្ត ជាអ្នក
គ្រងការកងការតសាង ។

ក៏កងសុភវាក្យនេះ ដើម្បីនឹងរំឭកនូវសម្បត្តិគុណដែលខ្ញុំថ្វល់
ខុកចំពោះព្រះភក្ត្រ ដូចមានភ័ស្តុតាងដ៏បំផុតដំណែលនេះ តែដ៏ច្រើរនេះ
ដូចក៏ដំណាងព្រះអង្គ សូម្បីព្រះអង្គខ្ញុំអស្ចង្គតលេខាកលោកនេះទៅ
កំទៅកិត្តិគុណជាដ៏សមគួរនឹងខ្លួលសេចក្តីសរសើរថា ស្តេចមកក៏មានព្រះ
ដំណើរល្អ ដំរង់ទៅក៏មានព្រះដំណើរល្អ យាងទៅក៏មានព្រះដំណើរល្អ ។

តែគួរឲ្យតើតសេចក្តីសង្វែគគិតន័កាឮកស្តាយជាទំហំ ព្រោះព្រះពាជ-
កិច្ចជាំងឡាយ ដែលត្រូវធ្វើបុណ្យកុងបង្កើយពុំទាន់បានធ្វើ ហើយខ្ញុំ
ព្រះសុវណ្ណគតទៅ អណ្តាប់មកខ្ញុំត សម្តេចជាថៅគាក់សក៏អនិច្ចធម្ម
ត្រូតទៅខ្ញុំត កិច្ចជាំងអម្បាលណោះ ក៏ធ្លាក់ទៅជាអញ្ញាត្រិតពាមតេត
កម្រែនឹងគាចសម្រែចបាន ។

ក៏សម័យនេះ ព្រះបាទសម្តេចព្រះបរមបពិត្រ ព្រះគុណជាអម្ចាស់
ជីវិត ខ្ញុំចេញព្រះពាជវិនិច្ឆ័យសម្រែចព្រះពាជទាយាទតីមតេតដែលជា
អញ្ញាត្រិតនោះ សម្រែចជាព្រះពាជការៈផ្ទាល់ព្រះអង្គត្រមនឹងឋសាទា-
ពិតលនៃលោកឲ្យវេស្ស៊ុដន្តរ៍សុបើរើយ៉ើរ នឹងលោកបពិត្រជាំងតួង

ជានស្រែះស្រួលដួយតបត្តម្ភ មានអ្នកទេកញ្ញាអគ្គមហាសេនា នាម "អ៊ឹង-អ៊ី" នឹងអ្នកទេកញ្ញាស្រីជម្ងាធិពជ នាម "ប៉ែន-ខុត" ជានយក ចិត្តខុតជាក់ជាប្រធានចាត់ការចំណាយព្រះពជទ្រព្យទ័ងទ្រព្យយោសនា តាមព្រះពជាខុញ្ញាតកើតឡើងជាមេរៀ ព្រមដោយប្រជាប់បុណ្យដ៏រចនា រុងរឿងជាពន្ធឹកបូជារំលាយសពសម្តេចព្រះមង្គលទេពាចារ្យ នាម "ស៊ុក" ជាស្រែច ជាទ្រណ្ឌ ១ ។

ជានចាត់អដ្ឋិធាតុ សម្តេចចៅអាវ៉ាសទាំងពីរប្រមុខ នាមអៀម ១ នាមស៊ុក ១ ប្រតិស្ថានខុតក្នុងព្រះចតីយ៍ធំដែលបដិសង្ខរណ៍ជាថ្មី ជាស្រែចជាទ្រណ្ឌ ៦ ។

ជានធ្វើបុណ្យសម្ពោធក្នុងព្រះវិហារប្រគល់ដល់សង្ឃមណ្ឌលជាស្រែច ជាទ្រណ្ឌ ៣ ។

ព្រះពជកិច្ចទាំង ៣ ទ្រណ្ឌនេះ ជានឧាមថា ព្រះបរមបពិត្រជាអម្ចាស់ដីវិត ទ្រង់ព្រះវិនិច្ឆ័យព្រះពជមរតកដែលពុំជានសម្រេចឲ្យជានសូរេច កើតឡើងជា ៣ ព្រះពជកុសលទ្រណ្ឌ ។

ព្រះពជកុសលទ្រង់ណា នុប្បជានដែលជានចំពេញទាំង ៣ ទ្រណ្ឌក្នុងអតិលក្ខិតសម័យនេះ ដោយជម្ងឺពលិនំងអាមិសពលិជាកលប្បនាផល សូមថ្វាយជាព្រះពជបណ្ណាការដល់ព្រះបរមគ្រូតាំងអំពីបឋមវង្ស ព្រមដោយព្រះពជនិន្ទាកូល ជាអណ្តាប់រៀបរៀង ដល់ព្រះជានសម្តេច

ព្រះបរមរតនត្តិយគោដ្ឋ ដែលទ្រង់ព្រះសុវណ្ណគតទៅ សូមទ្រង់បានទទួល
នូវព្រះពរជយណ្ណាការដែលនេះជាបេះសោមនស្ស ហើយចូរបានសណ្ឋិត
កង្គតដ៏សុខវិសេសជាផលដួចព្រះពរជ្ញិសថ្វាយ ។

សេចក្តីជាបំផុតនេះ សូមអានុភាពនៃព្រះពរកុសលថ្វាយដល់ព្រះ
បរមបពិត្រព្រះករុណាជាអម្ចាស់ជីវិត សូមទ្រង់ចំរើនសិរីសុវត្ថិវិឌ្ឍមង្គល
ព្រះជន្មសុខដំរង់នៅកង្គព្រះបរមេរាជសម្បត្តិជាទីសរណានៃខេមររដ្ឋ បាន
រុងរឿងស្ថិតស្ថេរចិរកាលលុះបំផុតព្រះពរជ្រាថ្នា ។

សូមអានុភាពកុសលជំពរជូនដល់លោកឡឺវេស៊ូដង់ត៍សុប៉ែរីយ៉ែរ
ដែលជាអធិបតីពរជគារោណ ព្យាចាល សូមចំរើនទូវាយុសុខសុវត្ថិ
កុំប៉ះឃ្លាតចាកទីតាំងនៃខេមររដ្ឋាភិបាល ។ ន៏ងផ្សាយទូទៅព្រះមហា-
ឧត្តរាចាកំដរសែស សូមចំរើនទូវមហាអំណាចឥទ្ធិពល ដំកល់នៅកង្គ
ក្រសេមសុខដ៏វិសេសគ្រប់ប្រការ ។

សូមអានុភាពនៃកុសល ចូរឃុំគ្រងបរិបាលព្រះពរវង្សានុវង្ស
លោកសេនាបតី នាហ្មឺនសព្វមុខទ្រង់ ទូទៅដល់ប្រជានិករគ្រប់និកាយ
ដែលបានមកសមោសរប្តុំបានមកក្តី សូមដំកល់នៅកង្គពរ ៤ ប្រការ
អនិដ្ឋាម្ចេណ៍ឯណា ដែលមិនជាទីគាប់ចិត្តកំបីដំតដល់ ។ ន៏ងសូមដល់នៃ
សក្យាធិដ្ឋានេះចូរអភិបាលព្រះពរបុរី ក្រុងកម្ពុជរដ្ឋាធិបតី ឲ្យចំរើនសិរី

សុខ ជ្រាស ចាកវិហិង្សាទុក្ខ ដែលមានមកអំពីនានាបច្ចាមិត្រ សូមរៈ
លាយជាវិហាមិត្រភាពវិញ ។

សុខុរកថាចប់ប៉ុណ្ណោះ

លុះចប់សុខុរកថាហើយ សម្តេចព្រះបរមកដបិតាខ្ញុំព្រះសុវណ្ណ-
គិត្តិរស្តេចយាងទៅចំពោះលោកគ្រូព្រះធម្មវិរិយព្រឹទ្ធ "ស្រី" ហើយទ្រង់
មានព្រះបន្ទូលផ្សាយឲ្យបណ្តាជនបានដឹងគ្រប់គ្នាថា ព្រះវិហារនេះបាន វេរ
ប្រគេនដល់ព្រះសង្ឃហើយ ។ ខ្ញុំដែលចំកស្មោគកជាក់ជាគ្រូព្រះហស្ត
លោកគ្រូព្រះធម្មវិរិយព្រឹទ្ធដែលស្តីការជាដំបូងសព្រះសង្ឃនាយក ។

ឧណៈខោះ ព្រះសង្ឃសូត្រធម៌ពហូរខេវាងធួងព្រះវិហារចប់ហើយ
សម្តេចព្រះបរមកដបិតាទ្រង់ច្រោះព្រះសុគន្ធវារីលើទីផ្ទៃព្រះវិហារ ជាមួយ
នឹងលោកឡឺវេស៊ីដង៏តមែរ ជាដំណាងលោកឡឺវេស៊ីដង៏តសុបែរ៉ែយ៉ែរ ។

ម៉ោង ១០ព្រឹក ទិមន្តព្រះសង្ឃចំរើនព្រះបរិត្តនឹងវេរកត្ត ប្រគេន
បង្ហាន់ព្រះសង្ឃ ។

ម៉ោង ១៦ គឺម៉ោង ៤រសៀល ទិមន្តព្រះធម្មកថិក ៣អង្គ គឺលោក
វត្តសាកវ័ន ១អង្គ លោកវត្តឧណ្ណាលោម ១អង្គ លោកវត្តលង្កា ១អង្គ
ទេសនាសង្គាយនាគ្រែប៉ៃ មានលោកអានគ្រែ ៤អង្គ លោកហត្ថបាស
៩០០អង្គ កុងព្រះវិហារវត្តបទុមរតី ។

កាលខេត្តនាសង្កាយនាចប់ហើយ លោក ញឹក-ន្ហូ ត្រូវឆ្លៀន សាលាចាក់ដីសែស ត្រូវចាត់ឲ្យឡើងលើកល្បែកូនប្រយោនផ្ទៃក្រូច ធ្វើបង្គប់ប្រាក់កាក់ចំនួន ៣០ រៀលមួយលើកខ្លះ ជាការសម្រែចបុណ្យចាំដ ៣ ផ្នែកតែមប៉ុណ្ណោះ ។

ពិធីបុណ្យព្រះមេរុព្រះសពសម្តេចព្រះមង្គលខេត្តាចារ្យ "ស៊ុក" ពិធីបញ្ចុះព្រះអដ្ឋិសម្តេចព្រះមង្គលខេត្តាចារ្យ "ភ្នៀម" ទំដ៏សម្តេចព្រះមង្គលខេត្តាចារ្យ "ស៊ុក" ព្រមទាំងសម្ភោធធ្នូដ៏ព្រះវិហារថ្មី វត្តបទុមវត្តជវាកាមពិធីបុណ្យចាំដ ៣ ផ្នែកនេះ ដែលកើតឡើងបានជាទុក្ខាកែវុងរឿងចាំដម្ល៉ះ ដោយព្រះគេជព្រះគុណលោកអ្នកឧកញ៉ាអគ្គមហាសេនាធិបតី (អឹង-អ៊ី) ត្រសួងព្រះបរមរាជវាំង ព្រះឃ្លាំងទំដ៏ធម្មការ ទំដ៏អ្នកឧកញ៉ាស្រីធម្មាធិរាជ (ប៉ែន-ន្ហុត) ជាគូឈួយ បានទទួលព្រះរាជទ្រព្យរបៀនព្រះករុណាជាម្ចាស់ជីវិតលើត្បូដ ទ្រង់គ្រាស់បង្គាប់ឲ្យចាត់ការក្នុងពិធីបុណ្យនេះ ទៅបរលោកថ្លង់ប្តេជ្ញគិតគូរ តាំងឲ្យមានក្រុមសង្ឃិច្ចាតទាងត្រហ្ស សម្រាប់ចាត់ការផ្សេង ។ ត្រប់ដំពូកបួបរួមជាមួយនឹងព្រះសង្ឃរាជាគណៈ ហានានុក្រម មានព្រះធម្មវរិយ ព្រ័ន្ទ (ស្រី) ស្តីការដំទួសព្រះសង្ឃនាយក ជាប្រធាន ទៅក្នុងសេចក្តីទុបត្តម្ភក៍របស់លោក សម្រែចដោយប្រកាសរបស់សេនាបតីត្រសួងធម្មការលេខ ៧ ចុះថ្ងៃ ៧ ១១ ២ ឆ្នាំមមីចត្វាស័ក ត្រូវនឹងថ្ងៃ ១៦ ឃ្លាំងវិរយេន្ទាំ ១៩៤៣ :

ត្រង់ប្រការមួយ-ត្រូវបង្កើតក្រុមសន្ទនាមួយ ក្នុងពួកឧបាសក-
ឧបាសិការដើងវត្តបទុមវតី ដើម្បីពិគ្រោះចាត់រៀបរៀបចំផ្តើមបុណ្យរំ-
លាយព្រះសពសម្តេចព្រះមង្គលទេពាចារ្យ "ស៊ុក" សង្ឃនាយកគណ
ធម្មយុត្តិ ។

ប្រការ ២- ឯក្រុមសន្ទនានេះ មានឈ្មោះដូចមានខាងក្រោម:

អ្នកលក្ខ ទេពញ៉ាសុរិន្ទមន្ត្រី ។ តិត្តិយស (មហាមន្ត្រី រ៉ុវត្រែត)
" អ៊ុំ ចៅក្រមរ៉ុវត្រែត
" នៅ "
" ឆន អាចារ្យវត្តបទុមវតី
" ទូ មន្ត្រីរ៉ុវត្រែត ក្រសួងព្រះរាជវាំង
" បញ្ញាញាណ មៀង
" លុយ យោគ្យរ៉ុវត្រែត ។

អ្នកម្នាងលួន ឧបាសិកា
ហួយ "
អ៊ុំ-អ៊ុន "
អ៊ុស "

ក្រុមសន្ទនានេះ ឲ្យនៅលើក្រមទេពញ៉ាមហាវិនិច្ឆ័យ
នៅ ចាងហ្វាងរ៉ុវត្រែត ជាអធិបតី ។

អង្គុជសុទិយោ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ជោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនឥន្ទមន្ត្រី ញ៉ឹក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ ភៅ-សុីម អ្នកត្រួតត្រា
សិស្សនៅសាលាបាលីកាន់ខ្ពស់

មាតិកា

ផ្នែកអក្សរសាស្ត្រ		ទំព័រ
អ្នកអាចារ្យ ជិត-ប៉ិន	សេចក្តីអធិប្បាយអំពីបុរាណសុភាសិត	៤៤១
ឃុនឥន្ទមន្ត្រី ញ៉ឹក-ថែម	កុលាបប៉ែលិន (តទៅកនឹងចប់)	៤៦៣
	រឿងព្រៃងខ្មែរ «និទានមាន់ឆ្នាក់»	៤៨៩
ពុទ្ធសាសនបណ្ឌិត្យ	កិច្ចការរបស់ក្រុមដំណុំរងាងទំនៀមទម្លាប់ . .	៤៩៦

ឆ្នាំទំរង់ទី ១៥ — លេខ ៧ ខែអ្ងូត ១៩៤៣ — ដំឡៃដារ: ១ ឆ្នាំ ១០ រៀល ។

អង្គរសិទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចេញពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនឧត្តមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ ភៅ-សុីម អ្នកត្រួតត្រា
សិស្សនៅសាលាបាលីកាន់ខ្ពស់

បញ្ជីរឿង

ផ្នែកអក្សរសាស្ត្រ		ទំព័រ
អ្នកអាចារ្យ ជិត-ប៊ិន	សេចក្តីអធិប្បាយអំពីបុរាណសុភាសិត	៤៤១
ឃុនឧត្តមន្ត្រី ញ៉ុក-ថែម	កុលាបប៉ៃលិន (តទៅកន្លែងចប់)	៤៦៣
	រឿងព្រៃងខ្មែរ "ខ្ញុំមានមាន់ឆ្នាក់"	៤៧៩
ពុទ្ធសាសនបណ្ឌិត្យ	កិច្ចការរបស់ក្រុមដំនុំរងខាងទំនៀមទម្លាប់ ..	៤៨៦

ឆ្នាំទំរប់ទី ១៩ — លេខ ៨ ខែតុលា ១៩៤៣ — ដំឡៃជាវ: ១ ឆ្នាំ ១០ រៀល ។

KAMBUJASURIYĀ

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Khun Nibandhamantri Nhok-Thêm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Kao-Sim, Surveillant général de l'Ecole Supérieure de Pāli.

TABLE DES MATIÈRES

Partie littéraire

		Pages
Achar Chit-Bin.....	Commentaire sur le "le Purānasubhasita".....	441
Khun Nibandhamantri Nhok-Thêm.....	Kolap — Pailin (suite et fin).....	463
	Conte populaire cambodgien inédit : "Nitéan Mean Thneak" (récit du coq servant d'appeau).....	489
Institut Bouddhique....	Travaux de la sous-commission des Mœurs et Coutumes.....	496

15e année — N° 8. Août 1943 — Abonnement: un an 10$00.

សេចក្តីអធិប្បាយ

អំពី

បុរាណសុត្តសិត

របស់លោកអាចារ្យជិត-ប៊ិន

ក្រុមដំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

"បង់បុណ្យបានបាប បើបង់បង់លាភរែងបាត់ធនទៅ"

ពាក្យនេះជាបុរាណសុភាសិតចាំងពីរោះ ជាពាក្យខំនឹមចំនៀមមានយូរយារណាស់មកហើយ ជាប្បាប់សណ្តាប់ស្រុករបស់ចាស់ៗ តាំងពីបុរាណមក តែងនិយាយប្រៀនប្រដៅកូនចៅរឿងៗមកជាបជាល់សព្វថ្ងៃនេះ ព្រោះហេតុនោះ ទើបបានឲ្យឈ្មោះថា "បុរាណសុភាសិត" ។

កាំង "បុរាណសុភាសិត" ពាំងពីរោះនេះ ពិតមែនតែមានសេចក្តីស្រដៀងគ្នា ប៉ុន្តែបើពិនិត្យឲ្យឃើញច្បាស់លាស់ទៅ គង់ឃើញខុសគ្នាខ្លះដោយអន្លើ ហេតុនេះ ខ្ញុំអធិប្បាយសុភាសិតនេះមួយម្តង ដោយឡែកពីគ្នា សូមលើកយកសុភាសិតីរោះដើមត្រង់បទថា "បង់បុណ្យបានបាប" មកអធិប្បាយជាមុនសិន សឹមអធិប្បាយចំពោះបទថា "បើបង់បង់លាភរែងបាត់ធនទៅ" ជាទាន់ក្រោយ ។

"បង់បុណ្យបានបាប"

សុភាសិតថា "បង់បុណ្យបានបាប" នេះជាពាក្យសាធារណ៍

ខ្ញុំទៅចាំដ៏ពិតប្រាកដ តើតថាគតនឹងមិនដឹងមិនឃើញនូវសេចក្តីសុខ
ដល់មនុស្សពួកខ្លះ ក្នុងលោកនេះ ដែលមានតំណាលតថាគតថា បានកន្តើ-
ញ្ឆោះ, យសស័ក្តិ, ទ្វេរអំណាច, បុណ្យកុសលដល់ខ្លួនពេក តែជា
មនុស្សខ្លះវិញ រមែងបញ្ជាក់នូវតថាគតដោយលំអៀងលើសពីហេតុ-ផលដ៏មានសិន, ស្រាប់តែពួកបរិស័ទ្ធអ្នកឯណាមួយ ក៏ចុះចូល
ដែលនូវនូវនឹងធ្វើអំពើអ្វីមួយក្នុងការដោយយោបល់យល់ថា "បើធ្វើបែបនេះ
ទៅមុខជានឹងបានកន្តើញ្ឆោះ, យសស័ក្តិ, ទ្វេរអំណាច, បុណ្យកុសល
ជាក្រោកជ" ហើយមិនបានពិចារណាឲ្យសមហេតុ-ផលដ៏មានសោះ;
ក៏អាត្មោះនោះ ដែលខ្លួនធ្វើដោយគំនិតយល់ថាមុខជានឹងបានប្រយោជន៍
ដល់ខ្លួន តុំបានសម្រេច ត្រឡប់ជាបានសេចក្តីវិនាសខ្លួនឯងតាមនឹងសេចក្តី
ក្តុំកុមកន្តុំខ្លួនវិញ ព្រោះហេតុតែខ្លួនធ្វើចំទៅលើអំពើពុំសមបានសំនឹង
មិនមែនជាសណ្តាប់នៃសេចក្តីល្អ ដូចជាអ្នកដែលចង់បានសេចក្តីសរសើរ
អំពីការខ្លួនឯងប្រឌិតប្រែទៅ តែមិនបានពិចារណាថា "អ្នកនេះគួរស្តីថា
អ្នកខ្លះមិនគួរស្តីថា" ហើយស្រាប់តែពួកបរិស័ទ្ធមនុស្ស-សត្វថែបណាក្តុំ-
ដោយកំចេះតែប្រឌិតស្តីថាទៅ ដកយកដល់បានសេចក្តីកក្រកំខ្វាក់ខ្វាយតាក្សរដើរ
ច្រានគោះបោះបោកនឹងសេចក្តីវិនាសផ្សេងៗ ពាក្យមនុស្ស-សត្វដែលខ្លួន
ស្តីប្រមៅមោមេកវិញក៏សឹងមាន ដូចនិយាយបក្សីត្រែលត្រែលោង ស្តី
ប្រមៅសត្វស្វា ត្រឡប់ជាបានសេចក្តីកក្រកំមកដល់ខ្លួនវិញ ។

រឿងបក្សីត្រលែងត្រលោងស្តីឲ្យស្វា

សេចក្តីដំណាលថា: មានសត្វត្រលែងត្រលោងមួយ ធ្វើសម្បុកនៅលើចុងឈើមួយដើមក្នុងព្រៃហិមពាន្ត ។ ទាន់ក្រោយមក មានសត្វស្វាមួយត្រូវខឹកភ្លៀងរងឹតដោកសត្វទាំងខ្លួនកន្ត្រិវស្ទាន់កាលរងាញ័រចំប្រប់ដេរចូលទៅកាន់រោងវិទោះ ឯត្រលែងត្រលោងឃើញហើយក៏សួរទៅថា "នែចង្រានរ! កញ្ចាស់ដៃដើរបស់បងឯង ហាក់ដូចជាមនុស្សដែរ ចុះហេតុអ្វីក៏បងឯងគ្មានផ្ទះទៅ? ស្វាឆ្លើយថា "នែត្រលែងត្រលោង! កញ្ចាស់ដៃដើរបស់យើងដូចជាមនុស្សក៏ពិតមែន ប៉ុន្តែខ្ញុំមិនមានបញ្ញាដ៏ប្រសើរដូចជាមនុស្សទេ" ។

ទើបត្រលែងត្រលោងនិយាយប្រដៅថា "យកក់សក់ក្តួនឆ្អឹងសម្រេចដល់បងឯងជាសត្វមានសភាពយ៉ាងនេះ ដូចម្តេចបាន?" ហើយក៏ប្រៀនប្រដៅទៀតថា "សេចក្តីសុះម៉ិនមានដល់បុគ្គលមានចិត្តម៉ិនខ្ជាប់ខ្ជួនជាអ្នកមានចិត្តហើសជាអ្នកច្រណែនម៉ិត ជាអ្នកមានកិរិយាម៉ិនខ្វែងគាត់នោះទេ នែស្វា, បងឯងត្រូវធ្វើខ្លួនឲ្យមានភាពុភាពបន្តិចទៅចុង, ត្រូវប្រតិត្តកក្នុងគិលរបង់ខ្លួនវិសេចក្តីឱ្យលែងអួសទេញ, ត្រូវធ្វើខ្លួមសម្រាប់ការពារត្រជាក់ខ្លឹងឲ្យល់ទៀង" ។

ស្វាគិតថា "ម៉ែអើ! សត្វនេះថាអញជាសត្វច្រណែនម៉ិត បើដូច្នោះមានតែអញសំដែងកិរិយាច្រណែនឲ្យវាដឹងម្តងចុះ" ហើយក៏ចាប់ពោច

សម្បុកគ្រែលេងគ្រែលោងដ៏ឆ្ងាត់ឆ្លាយអស់ ។ គ្រែលេងគ្រែលោងគ៏ហ៊ោរ
ដេញរៅម្ខាងទេវ ចាន់សេចក្តីក្តៅគ្រហាយរដាយស្ងួតឆ្អន្ទ ប៉ំផ្ទិចចំផ្ងាញ
ចោទរកចំលែងរបស់អាត្មាគន់គ្រានោះឯង ។

ទើបមានវាក្យចំអកដោយភាពប្រៀបធៀបថា:

គ្រែលេងគ្រែលោងហើរក្រែលួច គ្រែធំមគ្រែដួងកាល័យ
អប្បិច្ចាដ្ឋិតប្រែងផ្ទុងសំរ៉ី ភៅស្តីបន្ទុះបង្គោសស្ងួត ។
ជាតរកអស្ចារលាងរៅធោត អ្នមៅពិពោធក្រែធឫស្សា
កើតខ្លះកំភ្លាន់ក្បាច់ក្បាងជិត្តា ទឹងបោះណាស់ណាប្រែទូស្តុងង ។
ប្តុះផ្តៅតលោតផ្ងោះបោះហត្ត លួតចាប់ប្រែកាត្បាច្រើនជាង
សម្បុកគ្រែទំរោលរឹងផ្តឹង គ្រែលេងគ្រែលោងសៅហ្មងកាន់តែអើយ ។

ម្យ៉ាងទៀត ចាន់ដល់មនុស្សខ្លះជាអ្នកអាណិតការសូរគេហួសប្រ-
ទាណា ពុំបានត្រែវរំលាំងមុខថា ឧបត្ថម្ភសរគ្រែនឬមិនគួរឧបត្ថម្ភសរគ្រែ, ដូច
អ្នកខ្លះឃើញមនុស្សស្រីភ្លោណាមួយជាស្រីតំណាង មិនគួរដល់ការសរគ្រែ
ជាសារឬប្រែឧស្តាហ៍ដល់អ្នកធ្វើគុណលើខ្លួន ហើយត្រឡប់ជាចាន់សេចក្តី
ទុក្ខមកដល់ខ្លួនវិញ ពាំនេះគឺសាច្បាន់ចាន់ដ៏ប្រណីតជាបំផុតទេ ។ ដូច
ជាសត្វស្លាបណាមួយ ចាន់សេចក្តីស្លាប់ឥតការ គឺគ្រាន់តែរំលឹកចាន់
បុណ្យតំណាង ។

រឿងសញ្ជីវិមាណពស្ត្រីខ្លះ

សេចក្តីដំណាលថា: មានមាណព ៥០០ នាក់ជាកូនសិស្សអាចារ្យ ទិសាបាមោក្ខ; បណ្តាសិស្សទាំង ៥០០ នាក់នោះ មានសិស្សម្នាក់ឈ្មោះ សញ្ជីវិមាណព បានរៀនមន្តសម្រាប់ប្រោះមនុស្សស្លាប់ឲ្យរស់ អំពីសំណាក់អាចារ្យទិសាបាមោក្ខ; តែមិនបានរៀនមន្តសម្រាប់ការពារខ្លួនឡើយ ។ ថ្ងៃមួយ មាណពទាំង ៥០០ ព្រមទាំងសញ្ជីវិមាណព បានធ្វើដំណើរទៅកន្លែងមួយ ។ លុះបានចូលដល់ទៅក្នុងព្រៃហើយ ក៏ស្វែងរកឧសតែសព្វខ្លួន ។ ចំណែកឯសញ្ជីវិមាណព កំពុងតែដើរស្វែងរកឧស ក៏បានប្រទះឃើញខ្លាធំមួយស្លាប់ដេកនោចំពីមុខ; សញ្ជីវិមាណពជាមនុស្សខ្វះការពិចារណាលែលតឲ្យឃើញហេតុ-ផលវែងឆ្ងាយជាមុនសិន គ្រាន់តែឃើញខ្លានោះភ្លាម ក៏មានចិត្តចង់សង្គ្រោះប្រោះខ្លានោះឲ្យរស់ទើបស្រែកហៅទៅមាណពទាំងនោះថា "វុំយ! គ្នាយើងទាំងអស់គ្នា ចូរមកមើលខ្លាធំណាស់ដេកស្លាប់តង់ទ័ះនេះ ពួកអ្នកចាំមើលចុះយើងនឹងប្រោះខ្លានេះឲ្យរស់ឡើងវិញ" ។ ពួកមាណពទាំងនោះ ក៏នាំគ្នារត់មកមើលខ្លានោះ ទើបនិយាយទៅកាសញ្ជីវិមាណពនោះថា "អើ! បើព្រះស្តេចនេះប្រោះឲ្យរស់វិញបាន ចូរប្រោះចុះ យើងនឹងមើលផង,, ហើយក៏នាំគ្នារត់ឡើងកុងឈើទាំងអស់គ្នាទៅ ។ ឯសញ្ជីវិមាណព ក៏កាំងស្មាធ្យាយភយមន្តប្រោះខ្លានោះ។ ក៏រស់ឡើងភ្លាម ក្រេវក្រេមចិល

ទៅរើយើញសក្ដីវិមាណពាយវាំងរបេត ក៏ប្ដូរគាត់ថាបំពាក់គ្រឿងសក្ដីវិ-
មាណតាមតែគាត់ចង់ហាមាត្តនីនេះគ្រាងឯង ។ សក្ដីវិមាណពាយដែល
ឥរិយាបថសេចក្ដីវិនាសអាយុដល់ទៅយើងនេះ បំនែមនូវគំរើតហេតុក្នុងទេ មក
តែអំពីតហេតុចន្លោះបានបុណ្យកុសលទុំពីក្នុងកាលមុន ពាក់ព័ន្ធជួបគ្រប់គ្នាមក
ដល់ខ្លួនវិញ ក្នុងគ្រានេះឯង ។

ដើមមានគាថាចំមកដល់យើងតាមក្នុងគាថាថា ដូចនេះ

ទុ, ន, សក្ដីវិមាណ	ដែនឆ្នើមដែនល្អ
ច្រើនតែមានក្នុង	ដែនស្រុកចំណុងនៃត្រកូលធំ ។
ច្រើនដែនល្អក្រៃលែងពីមនុស្សលោក	ច្រើនក្រៃលែងស្មោះត្រង់ដោយចិត្តគោ
ដោយសង្ឃឹមចំពោះដល់ខ្លួន	ដោយបំណងបានដល់ខ្លួន ។
តែក្រែងខ្លួនឯងមិនចាំបាច់	មានប្រឹងតែធ្វើតិះដៀល
ដល់ជាតិគុណតបំពាក់ខ្លួន	ធ្វើឲ្យកិត្តិយសសាបសូន្យ ។

ម៉ៅនោះល្អដោយតតិយវិញ ពុទ្ធដល់មនុស្សល្អធំខ្លួនយញ្ញា ពុំដេះ
ប្ដូរចំពុតធំពុទ្ធសាសនា ដើម្បីបុណ្យចំទីមួយខ្លួន តើធ្វើបុណ្យឲ្យទាំនតាមតែ
ចំណើចិត្តខ្លួន ស្រែះភើយតែតំបន់ខ្លួន ឃើញមើញថាតួយើងណា
ក៏ធ្លាប់ជាធំធោរទៅ បំនយតបញ្ចប់ពាក្យតែម្ដង ។ ម្ដងណាមុខជាដល់ពេលធំបាន
ប្រាកដក្នុងកាលខ្លះតោងមានធ្វើបុណ្យទុំមួយ ។ តំណាក់ស្រា ពាក់ព្រែកមាន់
ខាងតែជាធំដើមយកទៅធ្វើបុណ្យឲ្យទាន ដើម្បីឲ្យខ្លួនបំពុង ម្ដងម្កាល

ដោតឆក់ប្រវ័ញ្ចន៍ឲ្យបានសំរេចយកមកធ្វើបុណ្យ មិនបានឯបុណ្យទេ ឲ្យបាបវិញក៏សំដីមាន ដូចដាំនិទានព្រាហ្មណ៍ម្នាក់សម្លាប់ពពែធ្វើមតកកត្តិ ភ្លាត់មិនបានឯបុណ្យសុំនបានឯបាបសោយទុក្ខកន្តនរកអស់កាលយូរអង្វែង ។

រឿងព្រាហ្មណ៍សម្លាប់ពពែធ្វើមតកកត្តិ

សេចក្តីដំណាលថា: មានព្រាហ្មណ៍ម្នាក់ជាអាចារ្យនៃសាស្តាបានឲ្យគ្រួជាអ្នកប្រែព្រឹត្តធ្វើមាតកកត្តិ បានសម្លាប់សត្វពពែមួយធ្វើមតកកត្តិ ដើម្បីជាបុណ្យកុសល ។ ដោយតំរេះតែសម្លាប់ពពែតែមួយប៉ុណ្ណោះ លុះព្រាហ្មណ៍នោះស្លាប់ទៅ គឺដៅសោយទុក្ខកន្តនរកអស់កាលយូរអង្វែង លុះរួចពីនរកមកត្រូវកើតក្នុងកំណើតតិរច្ឆានអស់ ៦៩៩ ជាតិ រៀរមកជាតិចុងក្រោយ ៥០០ ក៏បានមកកើតជាពពែក្នុងផ្ទះព្រាហ្មណ៍ម្នាក់ដែរដោយអ្នកធ្វើមតកកត្តិ ដូចជាខ្លួនពីដើមនោះដែរ ។

ថ្ងៃមួយដល់ថ្ងៃធ្វើមតកកត្តិរបស់ព្រាហ្មណ៍នោះ ព្រាហ្មណ៍ចុងក្រោយនឹងសម្លាប់ពពែនោះដើម្បីធ្វើមតកកត្តិ ឯពពែនោះដាសត្វនឹងដឹងថាតិចុងក្រោយព្រាហ្មណ៍ប្រាថ្នាទិនសម្លាប់ខ្លួនដូច្នោះ ក៏សើចហើយយំផង ។ ព្រាហ្មណ៍ដាម្ចាស់ឃើញពពែសើចហើយយំផងដូច្នោះ ក៏កើតសេចក្តីសង្ស័យ ដើរសួរពពែថា "ពពែតែ! ហេតុអ្វីបានជាឯងសើចហើយយំផង?" ។ ពពែក៏ទំលាយសារសត្វសព្វព័ត៌មានដែលជាបុព្វកម្មខ្លួន

ចាន់ធ្វើប្រពៃហើយអំពីជាតិមុនប្រាប់ព្រាហ្មណ៍នោះថា "ចាន់ជាខ្ញុំស្លេច
ព្រោះខ្ញុំមានសេចក្តីត្រេកអរណាស់ដោយសង្ឃឹមថា នឹងចាន់រួចពីកន្លែង
កន្លះថ្ងៃនេះ; ចាន់ជាខ្ញុំយ៉ា ព្រោះខ្ញុំមានសេចក្តីអាណិតចំពោះលោកជា
ម្ចាស់ដែលប៉ុន្មានទីសម្លាប់ខ្ញុំយកទៅធ្វើមតកកត្តា ដែលសិនជាសម្លាប់ខ្ញុំ
មែន មុនជានឹងភ្ជាក់ផៅសោយទុក្ខ ត្រូវគេតាត់ក្បាលអស់៥០០ជាតិដូច
ជាខ្ញុំនេះពុំខាន" ។ ព្រាហ្មណ៍ឮពាក្យពាក្យនៃពន្ធិយាយដូច្នោះហើយ ក៏កើត
សេចក្តីតក់ស្លុតចំពោះអំពើដែលខ្លួនគិតធ្វើនោះ ទើបឈប់លែងសម្លាប់
ពពែនោះទៅ ហើយនិយាយលួងលោមពពែនោះថា "នែពពែ! ឯង
កុំគិតក័យអ្វូវឡើយ យើងឈប់សម្លាប់ឯងហើយ យើងនឹងចើតលែងឯង
ឲ្យទៅរកស៊ីតាមសប្បាយចុះ" ។ ពពែនិយាយតបវិញថា "បើខ្ញុំក
ជាអ្នកសម្លាប់ខ្ញុំក្តីមិនសម្លាប់ខ្ញុំក្តី ខ្លួនខ្ញុំក៏នឹងតែមិនផុតអំពីសេចក្តីស្លាប់ក្នុង
ថ្ងៃនេះឡើយ" ថាហើយក៏ដើរទៅរកស៊ី ចាន់ទៅឈ្មេរស៊ីស្មៅលើខ្នង
ភ្នំមួយ ស្រាប់តែខ្លុះបាញ់ត្រូវដុំថ្មនោះខ្ចាតចំណែក ១ ដុំមកត្រូវកែងជើង
ស្តាំក្តិចនោះ ។ ពាន់ទេះក៏មកតែពីការចង់ចាន់បុណ្យខុសចំនង់ដែរទៅ
ជាចាន់ចាប់វិញ ដូចជាអ្វីនឹងព្រាហ្មណ៍សម្លាប់ពពែនេះឯង ។

ទើបមានពាក្យកំសត់ដោយគាថាពាក្យ ៧ ថា:

ព្រាហ្មណ៍ឆើមត្រាហ្មណ៍ត្រឹមត្រង់ត្រាជ្ញា ចុំនប៉ងប្រាថ្នាបុណ្យប្រាកដ
មានតែសក្តែមិនស្លាប់ ជេរដកកត្តាភ្ជាប់ជាកបុណ្យ ។

ត្រើរត្រាណាពិឃាតសត្វតែពៃ តែមួយសោះទេវតាទោសធ្ងន់
កើតក្នុងនរកជាន់ខ្ទរ់ ត្រូវតែកង្គន់យកសាច់ស៊ី ។
ហេតុចង់ជាន្តបុណ្យគុណកុសល ជាបតាមន ផលទ្រុលតេញទី
សោយទុក្ខភន្តសុទ្ធសល់សែនទ្រី តពៃឃោរឃៃសម្លាប់រំញ ។

ចប់សុភាសិត "ចង់បុណ្យហានជាប" តែប៉ុណ្ណោះ ។

"បបើចង់ណាភវែងបាត់ធនទៅ"

ពាក្យនេះជាសុភាសិតបុរាណ ចានដល់មនុស្សវែលវានេះរនាត ឈ្មោនពាន ចរចើនចង់ចានហួសប្រមាណពេក តែឮរ៉ៃជាចានសេចក្តី អន្តរាយខ្លួចខាតវិនាសធនជានទៅវិញ ដូចជាមនុស្សជាអ្នកប្រព្រឹត្តលេងល្បែងភ្នាល់ មានបៀរចោ៉ធ្លាដើម មានប្រាក់ដើម ៩០ ឬ ៦០ រៀលយកទៅលេងល្បែង ព្រោះឃើញប្រាក់ចាំងហ្មឺនចាំងពាន់បស់មៅល្បែងលុះលេងទៅមិនឈ្នះ តែឮបង់ចាញ់ ចានចាំងចានប្រាកថ្មី ចាតចាំងប្រាក់ដើមអស់រលីងពីវែ ក៏សឹងមាន ឬដូចអ្នកចង់ចានខ្លែឮរបស់ផ្សេង។ ហើយទៅលួចប្លន់គេ លុះម្ចាស់គេចាន់ក៏ចាប់យកទៅប្តឹងពាជការឲ្យពិន័យផ្តន្ទាទោសតាមជម្ងឺចិត្ត អ្នកនោះក៏ត្រូវខ្លួលទោស មានបង់ប្រាក់ឆ្នាក់ខ្លួនជាអ្នកត្រូចវែស្រ- ចម្ការ- ផ្ទះសម្បែងវែលជាខ្លែឮដើមរបស់ខ្លួនទៅវិញ ។

ម្យ៉ាងទៀត ជាឧបាសកដែលមានគំនិតចង់ជាន់ហ៊ាសហួសហេតុ ខុសពេល-វេលាដូចជាមានរឿងដំណាលតមកថា:

មានបុរសម្នាក់ឈ្មោះចៅមោយ ជាន់ចិញ្ចឹមមេមាន់មួយដើម្បីយកពងលក់ផងស៊ីផង ឯមេមាន់នោះកន្លងមួយថ្ងៃពង ១ ជាដំទៀមតុំដែលជាច់ចៅមោយក៏យកពងមាន់នោះមកស្ងោរស៊ុកល្ងាចគេ ថ្ងៃមួយចៅមោយមានដំណើរដើរទៅផ្សារ ជាន់ឃើញពួកអ្នកផ្សារធ្វើដំនូញមានទំនិញបុគ្គុផ្តុះសម្លុំណាសប្បាយដោយគ្មានសម្បត្តិ ពាំជំរំលៀតបំភាក់ទៀតសោតក៏ស្រួលតែល្អៗ ឯចៅមោយគ្រាឡកមើលខ្លួនឯងជាមនុស្សខុសថែបអំពីគេ ព្រោះខ្លួនជាអ្នកគ្រាន់តែសំលៀតបំភាក់សោតក៏មិនល្អដូចគេ ក៏ងើតគំនិតពពេចង់មានចង់ជាន់ឲ្យចាប់ដូចគេ ហើយក៏មកអង្គុយគិតថាចាប់ដើម្បីតែថ្ងៃនេះទៅ អញនឹងទំគេស៊ីឲ្យគាល់តែមាន ដូចជាអ្នកផ្សារនេះ ហើយចៅមោយក៏គាន់ផ្តើមគិតធ្វើដំនូញ ដើមដំបូងគិតថា ឥឡូវកុំទុកអញគ្មានថវិស់អ្វីសោះ មានតែមេមាន់មួយប៉ុណ្ណោះ; ឯមេមាន់នោះសោតកន្លង ១ ថ្ងៃពងតែមួយថែមទៀត គ្រាន់តែស៊ុខ្លួនឯងក៏កល់ៗថ្ងៃ ម៉ើប្រមិនជាអញអត់ធ្មត់មិនស៊ុ ហើយយកធ្វើដំនូញក៏ឃើញថាតិចណាស់ឯកន្លះពោះមេមាន់នេះប្រហែលជាមានតាន់ច្រើន យ៉ាងតិចត្រឹម ២០ ឬ ៣០ គ្រាអត់ពងកល់ៗថ្ងៃពុំដែលជាច់ ម៉ើដូច្នោះអញនឹងចាប់យកមកវែកយកពងឲ្យបានច្រើនគ្រាម ៗ ដើម្បីនឹងយកទៅលក់យកលុយធ្វើដើមទុន

តិតរហើយក៏ទៅចាប់យកមេមាន់នោះ មកច្រចាប់រឹតយកពងតាមចំណង់ចិត្ត ច្រចាប់មិនតិចរហូតដល់ទៅស្លាប់មេមាន់នោះទៅ ពងក៏មានច្រើនដែរ ខ្លួញក៏មានធ្លី មេមាន់ក៏ស្លាប់ឥតបានពងនៅទៀត ។ ហេតុនាំឲ្យនេះក៏ព្រោះតែចរចើនចង់ហួសប្រមាណ តាំងតែបានសេចក្តីវិនាសទៅវិញ ។

ទើបមានតាក្យបន្ទុះដោយ តាព្យបទកាកគតិថា:

មោយអើយតាយមោយ	កំនិតស្មោគ្រោក	ចង់ធ្វើចោរកែ
តិតរកែម្តង	ស៊ីសងមួយទៃ	ខ្លួចខាតភ័ន្តប្លែ
រឹតមាន់ចែកឡើយ ។	ព្រោះចង់បានច្រើន	ពងច្រែះចង់ខ្លួន
ផ្លូវបួនមួយថ្ងៃ	នឹងយកមកធ្វើ	សារពើធនថ្លៃ
ឲ្យដាក់ម្រែ	ទេយកចំណាញ ។	ដំឡូងមិនជាប់
ចំណាយខ្លួចទ្រព្យ	ចំណាប់ខ្មោះមិញ	ចំណីចំណាំ
មិនចាំជួរទិញ	ទាំងនស៊ីវិញ	តេញកោមនស្សអើយ ។

បើតាមតតិធម៌វិញ ឃើនដល់ឥន្ទ្រិយអ្នកច្រកបៈដោយអតិលោភឬអតិជ្ឈាវិសមលោភ ការលោភលន់ចង់ឃើនហើយចង់ឃើនទៀត មិនចេះឆ្អែតស្កប់ស្កល់ ដាមនុស្សឥតមានធម៌ស្តាប់ចោះតែខ្លួន ឧបាយណាដូចជាអ្នកដែលគេឲ្យបង់បេះល្មមសមគួរនឹងចិញ្ចឹមជីវិត ហើយមិនស្កប់ស្កល់ដោយបង់ដែលគេឲ្យទៅប៉ុណ្ណា ក៏រំលោភចង់ឃើនលើស

របស់ដែលឲ្យនោះគាល់តែគេលែងគាណិត គេលែងជជែកថ្លា គេឈប់ឲ្យទៅភ្ញៀវខានបានតទៅទៀត ដូចជានិទានព្រាហ្មណ៍ម្នាក់ចង់បានស្លាបហង្សមាសដែលហួសប្រមាណគ្រាន់តែបានខានបានវិញ ។

រឿងព្រាហ្មណ៍ចង់បានស្លាបហង្សមាស

កន្លងកាលដែលកន្លងទៅហើយ មានព្រាហ្មណ៍ម្នាក់ ទៅក្នុងក្រុងតាកណាស៍ ធ្វើកាលកិរិយាតាមខុសៗនេះទៅ ទៅកើតក្នុងកំណើតជាហង្សមាស. ហង្សមាសនោះប្រកបដោយញាណជាគ្រឿងរលឹកឃើញនូវជាតិ; ចំណែកកំរោនដ៏កូនស្រីៗរបស់គាត់នាំគ្នាធ្វើការឈ្នួលចិញ្ចឹមជីវិតសព្វៗថ្ងៃ, ។ ថ្ងៃ១ ហង្សមាសរំពឹងមើលទៅឃើញនាងទាំងនោះចិញ្ចឹមជីវិតដោយលំបាកដូច្នោះហើយក៏ហើរសំដៅទៅទីនោះ ព្រោះសេចក្តីស្នេហានឹងសេចក្តីករុណាចំពោះនាងទាំងនោះ លុះទៅដល់ហើយក៏ចាប់ថវត្តិហេតុសព្វគ្រប់តាំងអំពីដើមរួចហើយដុំរុះស្លាបមួយឲ្យទៅហើយប្រាប់ថា: នាងទាំងអស់គ្នា ឈប់ធ្វើការស៊ីឈ្នួលចុះ ពីថ្ងៃនេះទៅលក់តែស្លាបមួយចិញ្ចឹមជីវិតបានហើយ ថាហើយក៏ហើរចេញបាត់ទៅ; ឯស្លាបមួយគ្រាន់ថ្ងៃមួយគ្រាន់ដែរ; កាលស្រីទាំងនោះចាយវាយគ្រាន់តែបានអស់ទៅក៏ហើរមកដុំរុះឲ្យ ១ ទៀត ហង្សនោះធ្វើតែយ៉ាងនេះសព្វៗ កាលឥតបន្ទោះ ។ ស្រីទាំងនោះក៏បានជាអ្នកមានគ្រប់ស្តុកស្តម្ភបែកពីប្រក្រតី; ថ្ងៃមួយព្រាហ្មណ៍ជាមាតាប្រាប់ថាចង់ឲ្យមានលើសពី

នេះទៀតទៀត, ក៏បបួលកូនស្រីៗនោះថា:: ម្នាលកូនស្រីទាំងឡាយអើយ! ធម្មតាសត្តានចិត្តនៃសត្វតិរច្ឆានកម្រធ្វើដូច្នោះរៀងៗខ្លួន ពេលនេះកាលណាគាត់មកយើងគិតចោចស្វាបយកខុងទាំងអស់តែម្តងទៅ, ។ ធីតាទាំងនោះឮហើយទំាំាគ្នាអង្វរឃាត់ថាកុំឡើយ។ តែព្រាហ្មណ៍មាតាថ្កាថ្កំាធំពេកចង់ចាន ហួសមាត្រចានជាមិនស្តាប់ពាក្យនរណាសោះ, បរបេសនឹងវែកចិត្តឯងឯចាប់ចោចចាល់តែចានដូចជាណាន ។ គាន់តែនាងព្រាហ្មណីចោចអស់មកស្វាបនោះក៏ក្លាយទៅជាស្វាបកុកអស់ទៅ; ហង្សមាសក៏ហើរលែងរួច, នាងព្រាហ្មណីយកហង្សទៅត្រចក្នុងពាងធំ, ដល់ដុះស្វាបម្តងទៀតក្លាយទៅជាស្វាបសទាំងអស់, លុះហង្សនោះដុះស្វាបជិតឡើងវិញក៏ហើរទៅកាន់លំនៅខ្លួនលែងមកកាន់ទីនោះទៀត ។ ការដែលព្រាហ្មណីដល់ខ្លួវក្តីកំសត់ទៅវិញយ៉ាងនេះ ក៏មកតែអំពីចរិតចង់លាភពេកបានជាថ្កាត់ធនទៅ សមដូចសុភាសិតបុកណានោះឯង ។

ទើបមានពាក្យចំអកដោយភាព្យ ពាក្យ ៧ ថា:

អាស្សរព្រាហ្មណ៍ស្រីកំសត់	ត្រីក្រក្ខុតិតអត់ទ្រព្យា
ព្រាហ្មណ៍ប្រុសច្រាសចោលទោលកំព្រា	តួយព្រាត់រងាគំងកូនស្រី ។
ស្រីបស្រែលចចើងចង់ចានណាស	ប្រឹងច្រែងងិកស្វាបហង្សបក្សី
បក្សាផែលឡាប់ដាស្វាមី	ស្វាប់សោយជាតីជាហង្សមាស ។
មានចិត្តអាណិតកូនច្រែពន្ធ	ធ្វើកុណ្ឌស្វាបង្វរច្រាក់កាស
ចង់មានជុតជាប់ច្រញាប់ណាស់	ដាតម្តងមួយក្រាលច្រាសលែងមក ។

ត្រាក្នុងសំណេកសាច្បាប់ភ្ញាក្រុង ដែលដាក់ទើបទុនទុកត្រាន់រាក
ក្នុងស្រុកស្តីប្រាក់ទាក់ទំពេក ជំរៃដែលឆ្លងកន្លែងកន្លះ ។
ចេញដើរក្តីដែលតាមរោមកោង ត្រាក់ចេះត្រាក់ភាន់ច្រាន់សេសសល់
ក្រែបើសាពីដើមផ្ញើចក្ខុរលាស់ តាំងឡូតាស់ត្រាក់ត្រែរកើយ ។

ឬរឿងខ្លះ គាវដែលសរចេញឆ្ងល់ណាតវែងជាតន់ឆន្ទៈនេះ មិនមែនមានរឿងទំណាលនៃប៉ុណ្ណោះទេ, អតែដែលប្រែតែតែថាមានរហើយដល់ប្រមាណជាតិ ភាសាតាមប្រែយោងន៍អស្សារតែតាមទៀងមានប្រែនណាស់ ដូចយ៉ាងសន្ទូចចតម្លួយដល់ទូរដែលណាជាស្តេច សាយោកដូច មានបន្ទាត់ជាប់ស្តេតរាយៈបក្ខិលេស តែអតិដូច្នេះសមណោក "បាចើនបន្ទាលាតុក្ខានៈហើយចង់ជាន់ខ្លាត" ពាលនៃជីវិតាន់ប្រែតក្បាលស្ងាប់ខាន យោយោកដូចទៅទៀត, សូមនាំរឿងខ្លះយកមកពណ៌នា ដូចតាមតែណាវែងខ្លាត ។

រឿងបងប្អូនបង្កើតលាន

កុនដីតាន់ឆ្លុះយោកសំបុកហើយ ក្រុងដីតាលខ្លោះ មានប្រាក់ជាតិតូចស្តាក់ទេសម៌ក្រែងចុះខាងណាបី ដាំអ្នកខ្លះខ្លួនប្រពន្ធជាតិឈ្មោះខ្លួនដែរដី, ថ្ងៃមួយតាន់តិនដីដែលក្តីមក្តុះចាស់យោកមើប កំប្លុងទៅកុនដែរត្រែអង្គុយលើកុដ្ឋិដាំតែអំពីនឹងស្ងាធ្លាយមក្តុ យោលដែលតាន់តំកុដ្ឋិស្ងាធ្លាយខ្លោះ មានសត្វជាតិមួយទេវដែតសម្លឹស្តាប់កុនដែរដួលមួយខាលនៃតាំស្ងាត់ ក្បុរបងប្អូនខ្លោះ

ចាំមន្តស្លាត់ហើយ ក៏ចាប់ចូលទៅក្នុងវិត្រតាំងស្មាធ្យាយបន្តនោះ; បង្កើតពួកចចកជាច្រើនឃើយ, ឲ្យដើរប្រមូលហៅពួកសត្វដើរបួនមានសេះដំរី, ពស់ហ៊ាំទ្វាធំ, ជ្រូកព្រៃជាដើម មកឱ្យរៀបរាប់ ជាសត្វខ្លាំងក្រាមអំណាចខ្លួន ហើយតាំងខ្លួនជាស្តេចឈ្មោះសត្វទាបាទ, បានតាំងមេចចកមួយឲ្យជាអគ្គមហេសី ។ ហើយក៏រៀបចំយានដំទិន្នៈ ឥន្ទ្រកដស័ង្ខ៍ ដ៏រលើងរំមួយគូ ខ្លងឯងដ៏រកើតដស័ង្ខ៍នោះទៀត, គាស់ស្តេចចចកនោះ ឲ្យខប់រាប់ច្រើនដូច្នោះ ក៏លុះដាំយសេចក្តីប្រមាទរហូតដល់លោកចន្ទំបានខ្វះតែស្តេចវត្តថ្មមួយទៀត ទើបបបួលពួកសត្វដើរ ៤ ជាប់រាប់ថា: យើងតាំងឡាយនិន្ទាចាមចាប់ព្រះចុងភាពណាសស័ងណ្តើមយកពង្ស តែតែហើយក៏នាំបរិវារចំនួន១២យោជន៍ឲ្យវែហាមខ្លួនៗ លុះទៅដល់ដីតក្រុងភាពណាសី ក៏មញ្ជូនពាក្យទូតឲ្យនាំសារ ទៅថ្វាយព្រះចុងភាពណាសីថា ព្រះអង្គឲ្យពាក្យសម្បត្តិមកយើងតែម្តង ប្តូចនឹងប្តាំង, ពួកមនុស្សក្តៅហើយក៏តិតតំយែតក្តាមាទាំគ្នាមើញទៅបិទទ្វារព្រះខនធរឹតរាប់, គ្រានោះ បុរោហិតនិយាយលួងលោមសម្រុះសម្រួលព្រះពាក្យនឹងអាណាប្រជាទុកស្តួចថា: សូមព្រះអង្គកុំព្រួយព្រះពាក្យហាប្តូរឲ្យសោះ, ព្រោះការចម្បាំងនេះ ជាការកិច្ចរបស់ខ្ញុំព្រះអង្គនេះ; ព្រះហើយក៏ឡើងទៅលើប៉មក្នុងវិស្តេកស្តួរទៅចចកថា: ម៉ើសំឡាញ់សត្វទាប: ចូរអ្នកខ្លីឆ្កាំងដូចម្តេច; ចចកក្រាបថា: ខ្ញុំស្តេចដស័ង្ខ៍វែសសម្លាប់មនុស្សឲ្យអស់ ហើយយកពង្ស;

បុរោហិតឮហើយក៏ចុះពីនោះមកកាយគន់ខួងគេរៀមទុស្សទាំងឡាយយក
ស្មៅសណ្តែកពាជមាសមកបុក [តរចៀក] គ្រប់ៗគ្នា ទាំងសត្វដើម ៤ ដោយ
ហោចទៅសូម្បីតែសត្វធ្នាក់គេបុកមិនឲ្យសល់ដែរ; (លុះមហាជនរៀប
[សេច]ហើយ) បុរោហិតក៏ឡើងលើប៉មនោះម្តងទៀតហើយ ទំយាយ
ជូញ្ជាផ្លាល់ថា: នែសព្វទាឋ: អញាមើលទៅមុខឯង មិនមែន[ច្រើក]ជស័ចាំ
ឲ្យ[សេក]ឯទេ; ដ្បិតមីពជស័ចាំដែលមានដើងធំធំដៃ[គហម]ស្រស់ត្រូ
ដល់ដាតិត្តធំៗទៅទាំងម្ល៉េះនេះ មិនមែនមកលុះក្នុងអំណាចនៃចចកចាស់
[ចាក]ជដូចឯងទេ បើឯង[គាន់]ចំឲ្យ[សេក]មើលទៅចាំ! ។ ចចកឮ
ហើយក៏ខឹកតួចចិត្តខ្លាំងពេក[សេក]បង្គាប់ទៅពាជស័ចាំថា: អ្ហ៎ឯងកល់
គ្នាទៅឲ្យស្រួលសិនចុះ, អញឲ្យ[សេក]តែពាជស័ចាំ ដែលអញដុះលើ
ខ្នងសិន បង្គាប់រួចហើយក៏គោះខ្នងពាជស័ចាំជាដំនិះនោះដោយដើង; ពាជ-
ស័ចាំនោះក៏ត្រៀតមាត់ទៅកន្ត្រោងជំរៃបន្ទឹស័ចាខាងដែលគេច្រឹតាមមិន
កើតនោះអស់រាប់ជង ជំរៃដល់ទូរសេចក្តីតក់ស្លុត រត់ជាន់ក្បាលចចក
ដែលជាក់មកស្បែរដើងនោះតាល់តែស្លុតខ្លួចខ្លី ដកជដល់ស្ទាប់កន្ត្រក់នោះ
ទៅ ។ ជំរៃពាំងនោះត្រូចគ្នាឯងស្ទាប់អស់ដែរ, ឯពួកសត្វដើងបួននោះ
សល់តែរាជស័ចាំប៉ុណ្ណោះ, [សេក]ពីនោះអម្បាលម៉ានក៏ស្ទាប់តរលើគ្នា
ពាំងអស់មានទំហំ ១២ យោជន៍តត់ ។

(កាលសត្វតាំងនោះស្លាប់ទៅ) បុរេហិតក៏ជួនស្តេចប្រមូលមនុស្ស ឲ្យមកយកសាច់សត្វតាំងនោះទៅបរិភោគតាមចំណង់ចំណែក។ សត្វ ។ ខ្លួន សាច់សល់ពីនោះ ក៏បែកគ្នាហាលធ្វើជាងឿត សម្រាប់ភោក្តាតាមប្រថា្ន ។

បពិត្រព្រះជាម្ចាស់ទូរទៅនាសអន្តរាយអាប្តូជីវិតយ៉ាងនេះ មិនមែនអំពីអ្វី ទេ គឺតែងមកអំពីបរិច្ចាគដ៏ប្រសើរជាប្រត់ធនទៅ សមដូចសុភាសិត នោះឯង ។

ទើបមានពាក្យចំអកដោយគាថាបន្ទាប់ថា:

បពិត្រលោកៈ បើបរោរមោហៈ បរិច្ចាគដ៏ល្អ បរិសុទ្ធបរិបូណ៌ មិនមើលអត្ថភាព ខ្លួនថ្លៅក្លាយខាប មិនស្ងប់ស្ងុំការ ។ អាត្មាខ្ញុះបន្តិច អាត្មាដឹងតស់ក្បាច់ អាតមានថា ដែលសប្បុរសស្តាប់ ស្ងួរសាប្តូរថា ស្ងួតប្រាយសំក្បា អាចិន្តបុរោហិត ។ ស្តាប់ជាន ដៀងជាក់ ខ្ញុះចាំត្រូវប្រាថ្នាក់ ដឹកជាក់ក្នុងចិត្ត ហើយទើបចេញបរ ដើរបរហ្លួងមិត្ត មីរមកដុំដិត តែតគ្មានសោយរាជ្យ ។ មិនតែប៉ុណ្ណោះ មានះតែតខុស ទំនិញយអំណាច កេណ្ឌទ័ពយោធា ម្ចាស់អង្គអាច ដោយចិត្តភោគភាព តែតធ្វើសង្គ្រាម ។ ប្លាំងយកតេជៈដៃ ដណ្តើមយកដំរី ឲ្យល្បីភ្លាមៗ លោស្រែះបំពែភ្នាក់ បែកមាត់ជាក់ផ្តាម បែកក្បាលហូរ-ឈាម ដំរីជាន់ក្បាល ។

ប្រាសាទនេះ ស្ថិតនៅលើជើងភ្នំតូចមួយដែលមានឈ្មោះថា ភ្នំតាមាន់ ដែលមានចម្ងាយប្រហែលជា ៣ គីឡូម៉ែត្រ ពីភូមិតាមាន់ ឃុំតាមាន់ ស្រុកសង្កែ ខេត្តបាត់ដំបង ។

ប្រវត្តិប្រាសាទ និងការជួសជុលចុងក្រោយ

ប្រាសាទតាមាន់ មានប្រាង្គ ចំនួន ៤ ខ្នង តាមរចនាបថ មានសិល្បៈ ស្ថាបត្យកម្ម ដូចប្រាសាទតូចមួយចំនួនទៀត ដែលមានក្បាច់ចម្លាក់ ដ៏ស្រស់ស្អាត ។

តាមសេចក្តីសរសើរថា សេដ្ឋីបុត្រទាំង ៤ នាក់ខាងលើ មានកិត្តិសព្ទល្បីល្បាញមកគ្រប់ទិសទី ក៏ចាត់ជាអ្នកស្គាល់ស្គាល់ដោយសេចក្តីសុខ-ចំរើន តាំងតែពីក្មេងរៀងរាបមក រហូតដល់មានវ័យចំរើនឡើងចំនួនជាអាយុ ៤០ ឆ្នាំខ្លះ ៤៩ ឆ្នាំខ្លះ ៥៧ ឆ្នាំខ្លះ តទួលមានជាបាបកម្ម ដែលឯកនាងទុកមកអំពីជាតិនាយ ឬក៏ពេលស្រាប់តែជាបស់ខ្លួនបណ្តាលឲ្យដែរ សេដ្ឋីបុត្រទាំង ៤ នាក់ ។ ឯសេដ្ឋីបុត្រទាំងនោះវិញមានខ្លះអ្វីទេ តាំងតែអំពីសរសៃឈាមចំបាក់ទីងត្រឹមអស្ថិរភាពផ្សេងៗ សង្ឃឹមថា បន្ទាប់ហាបែបបាក ក៏បេះតែជាមានជាំងអស់ តែតែងមានមន្ទិលសង្ស័យចំណាប់ ព្រោះគ្មានលទ្ធផលច្បាស់លាស់ ទាំងឲ្យខ្លាំងនិងតទល់នឹងទុក្ខមិនសប្បាយចិត្តយ៉ាងខ្លាំង ។

លុះសេដ្ឋីបុត្រទាំង ៤ នាក់ខាងលើ ចំរើនវ័យឈ្មោះមានគ្រួសារ មានកូនតូចធំ ក៏ដើរកាងជាំងកូនក្រមុំគេតទៅ តទួលដែលមានកោតសម្បុរស្មើគ្នា

ការត្រែកកូលទាំងនោះ ឃើញរូបកូនកំលោះនោះល្អស់ក៏ចេះតែច្រ-
តែកគ្នាទេញក្អែកនរណាមួយសោះ ត្រង់គោគសម្លឹងនោះតែទេញចំគ្គ
ណាស់ទៅហើយតាស់តែចំពែកប៉ុណ្ណោះទេ, ការដែលមានចិត្តសូវ
ស្វែងរកដណ្តឹងកូនត្រកូលខ្ពស់មួយ ។ ទើបទុកជាម្តាយអាតុកត្រមឲ្យក៏កូន
ប្រែកកឬក៏កូនមិនប្រែកកទេតែម្តាយអាតុកមិនត្រមឲ្យ តែបែបនេះសត្វ ។
កន្ទែងខាល់ចំណោះកេពុំឃ្លានសោះទៅជាអ្នកឆ្នែងប្រពន្ធពេក ។

លុះត្រាជាឯត្រែកាយមក សេដ្ឋីបុត្រតាំង៦ នាក់ការមើមិនសម្រេច
សេចក្តីប្រាថ្នារឿងខ្លួនយ៉ាងនេះហើយ ក៏ចូលគ្នាសំពះលាសុំប្រាក់
មាតាបិតាដើម្បីនឹងធ្វើដំណើរទៅកត្រែមើលក្បាលចំពែក ។ ឯមាតាបិតា
ក៏អនុញ្ញាតបើកឲ្យតាមសេចក្តីសុំរបស់កូន ។ ឯពួកសេដ្ឋីបុត្រក៏នាំគ្នា
ចេញចាកគេហដ្ឋានត្រាច់ចរយាត្រាទៅកាន់ទិសដែលខ្លួនប្រាថ្នានោះ ។
លុះដើរយូរលង់ឆ្ងាយផុតស្រុកទេសរបស់ខ្លួន ឃាននដល់ទៅកន្លែងព្រៃមួយ
ឃើញអាស្រមបទមួយ ប្រតិស្ឋានទៅកន្លែងព្រៃនោះដែលជាទីកន្លែងរបស់
ឥសីមួយរូប ជាអ្នកចេះមន្តគុណវិជ្ជាជាលំពែក ។ ឯពួកសេដ្ឋីបុត្រ
ក៏នាំគ្នាដើរសំដៅតាត់ទៅកអាស្រមបទនោះ ដល់ហើយបានជួបនឹង
មហាឫសីក៏នាំគ្នាថ្វាយបង្គំ លុះថ្វាយបង្គំហើយក៏អង្គុយកន្លែងដ៏សមគួរ ។
ទើបមហាឫសីសួរទៅថា "ម្នាលចៅទាំងឡាយអើយ ! ចៅមកនេះតើ
មានប្រាថ្នាអ្វី ? សេដ្ឋីបុត្រទាំងអស់គ្នាក៏ក្រាបទូលមហាឫសីសព្វគ្រប់តាម

ព័តមានរឿងខ្លួនតទៅ ទើបសេដ្ឋីបុត្រនាំគ្នាសំពះសុំតាឫសីឲ្យលោកជួយ
សង្គ្រោះមើលក្បាលចំពែកថា "បពិត្រលោកតា! សូមមេត្តាជួយសង្គ្រោះ
មើលខ្ញុំព្រះករុណាចាំងឲ្យបានទៅ ។ ឥសីក៏ឆ្លើយថាមិនអីទេចៅរឿង
នេះតាជួយបាន តែចាំស្អែកសិន ។ មានសេចក្តីថា' នៅជិតអាស្រមបទ
នោះ មានស្រះមួយពេញ ដោយមន្តអាគមសព្វមុខ បើពុកជាខនណាកើត
ពេគអ្វីក៏ដោយចុះមុជតែម្តងសុខសើងជាចាំងអស់ តែមានត្រណមយ៉ាង
គឺងរុំងគឺថាស្រះនោះ បើពុកជាមនុស្សមានពេគគិចក្តីច្រែនក្តីមុជបានតែ
ម្តងៗទេ តែថែមពីដងកើតពេគលើសដើម នេះជាសេចក្តីពិតណាស់ ។

សេដ្ឋីបុត្រចាំង ៤ នាក់បានទៅនៅសំណាក់កន្លែង នាងអស់មួយយប់
លុះដល់ព្រឹកព្រាងស្ងាងអរុណាទ័យហើយ ឫសីតើនចាកទីសយនាក់
ហៅសេដ្ឋីបុត្រចាំងនោះថា "អីចៅចាំង ៤ នាក់មកអាយ" ។ "ព្រះករុណា
ម្ចាស់លោកតា" សេដ្ឋីបុត្រឆ្លើយហើយទើបនាំគ្នាដើរចូលទៅ ។ ឫសីបាន
នាំទៅឯមាត់ស្រះនោះ ដល់ហើយក៏និយាយហាមថា "ចៅចាំងអស់គ្នា
អើយ ស្រះនេះគមគឹ្ងណាស់ លុះតែមនុស្សមានទន្លីសន្ធោសទើបជា
ពេគបាន បើមនុស្សគ្រាស់ទៅដោយអគតិជ្ឈាសៃមលោក ហើយមិន
សម្រេចប្រយោជន៍ទេ ហេតុនេះចៅឯងមុជតែម្តង ហើយទើបសេដ្ឋីបុត្រ
នាំគ្នាចុះមុចទៅ លុះដើរឡើងត្រមគ្នាក៏ឃើញសក់ដុះភ្លាមភ្លាមពេញ
ក្បាលថ្នាំរឿងខ្លួន ក៏កើតសេចក្តីរំលោក ចរចើងចង់បានហើយបានខ្លែត

ទើបនិយាយគ្នាថា "យើងមុជតែម្ដងសោះម្ល៉ះទៅហើយ ចំណង់បើយើងថែមទៀត តើម្ដេចទៅអេះ? មិនរតែតែគាស់ចោកត្មាំងមិនចែកទៅហើយ" ថាហើយក៏នាំគ្នាមុជចុះម្ដងទៀតស្រាប់តែរងើបឡើងលើសដើម។ ពីដើមគាន់មានសក់តែងំជាយតែតងបន្តិច។ ដល់ម្ដងនេះអស់លើងពាងដើមពាងចុង តើតវិប្បដិសារីស្ដាយគ្រាយ; ឥសីក៏លែងខ្វល់មើលគ្រោះឯងមិនតមជាមនុស្សចេះចង់លាភហួសខ្នាតពេកភាគប្រយោជន៍អសារឥតការទេ។ ។

ឯសេដ្ឋីបុត្រពាងំ ៤ នាក់នោះ កាលបើឥសីលែងខ្វល់ឆ្ការដួងចិត្តហើយក៏លាត្រឡប់មកកាន់ស្រុកលំនៅរបស់ខ្លួនវិញ លុះមកដល់ផ្ទះម្ដាយអាពុកមើលមិនស្គាល់។ ចុះហេតុអ្វីបានជាមិនស្គាល់? កូនរបស់ខ្លួនទេតើ? បានជាមិនស្គាល់គ្រោះថែកពេក។ ថែកយ៉ាងណា? ថែកត្រង់ដែលកាលទៅពីផ្ទះនៅមានសក់ត្រង់ជាយតែងរ៉ើង។ ខ្លះដល់ត្រឡប់មកវិញរលោងជាងចាតផ្ដិលទៅទៀត នេះហើយដែលនាំឲ្យម្ដាយអាពុកនឹងអ្នកផ្ទះរបស់ខ្លួនមើលមិនស្គាល់ នាំបណ្ដាលឲ្យកើតសេចក្ដីអៀនខ្មាសក្ដៅក្រហាយចិត្តភ្ញាំងរកអ្វីប្រៀបមិនបាន ហេតុនាំងនេះមិនមកពីអ្វីទេ ពិតជាមកអំពីអកដ្ឋាវិសមលោភសមដូចសុភាសិតថា: "បើចិង

ទើបមានឧភាក្យចំអកដោយគាថាភាក្យ ៧ ថា:

ឧ: ឱ មុខគួរឲ្យអាណោច អាស្សរអសោចិត្តខំអនេក
ពួកសែន្ធីក្រែក្បាលទំពែក ពុនដៃកក្រែកមាសត្រាសរាគ្រែ ។
តាប់ផ្ទៃខណផ្ទប់ឥសីស៊ីទ្វី សិល្បសាស្ត្រសាងព្រឹទ្ធសន្សំឃ្យរ
ស៊ីក្តីស៊ីទ្វិតួមសមងាគ្រែ សព្វញ្ញាសុះសព្វមន្តឧសថ ។
លោកជួយទទួលជួយតាជាល ទំពែកគ្រែងាលជាលចៃរង់
ដោយទឹកស្រែះស្រែងតូចកែងុត ឆុងជាប់ងុះធុតបរិសុទ្ធស្តែង ។
តែមានគ្រែណមតមកំណត់ មុងដម្ពងជ្រែកពនប្រែកលែង
ធ្លុខថែមពីរងងិងថងជាយគ្រែង រែករែងរលីងទាំងអស់អង្គ ។
ឱសេដ្ឋីបត្រែកន្ធងុតកក្ខ ផ្ទុងភពទំលាប់ជាប់ជំណង់
ម៉ុងដម្ពងសក់ងុះស្រែះខ្ចើយង់ ដោះចង់ចុះទៀតចង់រៀតអើយ

បរិយោសានកថាភាក្យ ៧:

ពុកណាគាសិតសន្ធិតស្ទះ សង្ខិចប៉ុណ្ណេះដាក់អស់ខ
សន្ធតិថាចប់សព្វលំអាខ ភាក្យទាំងពីរស្មានម្ភៃឯងបានឯង ។

វគ្គទី ៦

គេហស្ថានរតនសម្បត្តិត្រូវបោះបង់

ក្នុងថ្ងៃមួយនោះជាវេលារសៀលប្រហែលម៉ោង ៤ នាងនារីខឹងចៅចិត្តតំពុងអង្គុយឆ្លើយឆ្លងគ្នានៅក្នុងបន្ទប់ធ្វើការ នាងនារីផ្តើមនិយាយឡើងថា "តាំងពីបងចិត្តមកនៅធ្វើការជាដំណួយលោកឥព្រហ្មណ៍ កិច្ចការក៏ចំរើនឡើងច្រើនជាងពីដើម" នាងនិយាយដោយសុចរិតហើយនឹងចាប់និយាយតទៅទៀត ស្រាប់តែឮសូរថយន្តមួយមកចតនៅមុខផ្ទះគេនសម្បត្តិ ចៅចិត្តក៏ស្ទុះគ្រាកឡើងទៅមើលតាមបង្អួចហើយត្រឡប់មកអង្គុយនៅកន្លែងដដែលវិញ ។

នារី- "បងចិត្តៗ អ្នកណាមកនុ៎ះ ?

ចិត្ត- "ហ្ន៎ឡាត់ស្រុកៗសង្កែ, តែម្នាក់ទៀតបងមិនស្គាល់"

នារី- "អេះ, គេមកធ្វើអី ? ចុះបងចិត្តមិនទៅទទួលក្រៀវដំណួសលោកឥព្រហ្មវិញ" ។

ចៅចិត្តគ្រាគរឡើងដើរចេញទាំងនាងនារីឲ្យដើរតាមទៅផង ។ ដល់លោកហ្ន៎ឡាត់ឈរយ៉ាងអង់អាច នៅខាងមុខផ្ទះជាមួយនឹងបុរសម្នាក់ទៀត មានពាក់ងមាំឡៅសក់ក្រញាញ់ក្អែកក្រលួង ចៅចិត្តដើរចូលទៅសួរដោយសុភាពថា "ជនន៍ឡាស លោកអញ្ជើញមកតែអ្នកណា ?

តែលោកចាន្តាត់គ្រាន់តែញាក់មុខហើយ ដាកទៅខួលសំពះ
នាងនារីដែលឈរតើតែក្រោយចៅចិត្ត រួសពយបស្រែយនឹងនាងដោយ
ឥតរលែងចៅចិត្តដែលឈរច្រេះដោះទៅចំពោះព័ម្ខនោះឡើយ ។

ចាន្តាត់ - "លោកឪពុកនៅទេ, ឃុនានារី?

នារី - "ចាំស-នៅ, មើលទៅលោកប្រហែលនៅក្នុងបន្ទប់មើលសៀវភៅខាងលើ, ចុះលោកចាន្តាត់មានធ្វេីអ្វី" ។

ចាន្តាត់- "ចាទ, មានខ្លះដែរ តែខ្ញុំចាទនាំថៅកែផាន់មកទិញត្បូង ដើម្បីយកទៅលក់ឯស្រែនគរ" លោកចាន្តាត់តបហើយទំញញឹមឲ្យស្រស់តែត្រឡប់ជាគាស់ក្អែងរបស់ចៅចិត្តជាបំផុត ។

នាងនារីញញឹម ខួលដោយកិរិយាខន់ក្ងន់ ហើយនិយាយថា "អញ្ជើញលោកឡើងទៅខាងលើ ឲ្យជួបនឹងចា"និយាយថ្លៃគ្នាចុះ" ថាហើយនាងក៏ដើរនាំមុខក្រៀវឡើងទៅលើផ្ទះថ្មាក់លើ ជួបនឹងលោកហ្វូនតេនសម្បត្តិកំពុងដេក មើលសៀវភៅលើកៅអីផ្តៅ លោកក៏ក្រោកឡើងនិយាយកាត់ចាត់ដោយសេចក្តីស្និទ្ធស្នាលថា "អាហ៍! លោកចាន្តាត់ឬ? អញ្ជើញ - អញ្ជើញមកខាងណោះ ចុះលោកមានធ្វេីអ្វី?

ចាន្តាត់- "ខ្ញុំចាទនាំថៅកែផាន់មកទិញត្បូង" លោកចាន្តាត់ឆ្លើយត្រមនឹងចាញកៅអីមួយឲ្យថៅកែផាន់អង្គុយ ខ្លួនឯងក៏អង្គុយលើកៅអីមួយកែ្សខាងនាងនារី ឯចៅចិត្តឈរយ៉ាតឆ្ងាយពីនោះបន្តិច ដ្បិតមិនទាន់

ខុកចិត្តមនុស្សចំណូលថ្មី កងធំក្អែកត្រឡាតដែលឈ្មោះថាថៅកែផាន់នោះសោះ ។

ហ្វូងគេនសម្លឹងឆាកថៅខាងថៅកែផាន់ហើយសួរថា "ថៅកែត្រូវការទិញត្បូងបែបណា ?

ផាន់- "ខ្ញុំបាទគោងសុំពិនិត្យមើលសិន បើត្រូវចិត្ត ខ្ញុំបាទនឹងនិយាយថ្លៃទិញយកថៅលក់ឯទៀតនា" ។

ហ្វូង- "បាទ បានថៅកែ, វេលានេះត្បូងមានច្រើនតណាំផ្សេង ។ តែកល្អតាំងអស់" ហើយលោកហ្វូងឆាកថៅខាងថៅចិត្តប្រាប់ថា "ចិត្តថៅយកត្បូងមកឲ្យ ថៅកែពិនិត្យមើលបន្តិចមើល" ។

ថៅចិត្តដើរចូលថៅក្នុងបន្ទប់បាត់ថៅមួយស្របក់ត្រឡប់ចេញមកវិញកាន់ហិបត្បូងដែលថ្មហើយ ២-៣ ហិបយកថៅដាក់លើតុហើយបើកបង្ហាញថៅកែផាន់ ។

ថៅកែផាន់ឆ្លៀតឱកាសបើកក្អែកត្រលួងគាលដែលបានឃើញត្បូងពណ៌ផ្សេងៗក្នុងហិបនេះមានចំនួនដល់ថៅដាង ២០០ គ្រាប់ ថៅកែផាន់ចាប់លើកឡើងពិនិត្យមើលដោយប្រយ័ត្នហើយដាក់ថៅវិញនិយាយថា "ត្បូងអស់នេះតែកល្អមែន ប៉ុន្តែហេតុដូចមានដំឡៃច្រើន ?

លោកហ្វូងត្រឹកស្នាលហើយថា "មិនសូវដាថ្លៃប៉ុន្មានទេមានដំឡៃថោកជាងឯទៀតនាច្រើន" ។

រួចថៅកែជាន់ចាប់ ๑ គ្រាប់លើកឡើងមើលម្តងទៀត ហើយសួរថៅថា "តានេះថ្មា, ๑ គ្រាប់នេះជាថ្មប៉ុន្មានទៅ ?

ហ្វូង - "យ៉ាងនេះទឹកល្អក្រៃចិន ๑ គ្រាត់ ๒๐๐ រៀល តុង ๑ គ្រាប់នេះប្រហែលជា ๔ គ្រាត់" ។

ជាន់ - "តានេះថ្មា, ថ្លៃបន្តិច បើបុះបន្តិចទៅទៀតបានទេ ?

ហ្វូង - "មិនដាអ្វីទេ បើថៅកែត្រូវការក៏បុះជូនឲ្យបានខ្លះ ដោយសេចក្តីគប់អានន្តា" ។

ជាន់ - "បុះថ្លៃបានប៉ុន្មាន ?

លោកហ្វូងចាប់តួងគ្រាប់នោះមកតិនិត្យមើលម្តងទៀត ហើយថា "បែបនេះបុះជូនបានតុង ๑ គ្រាត់ ๒๐ រៀល" ។

ថៅកែជាន់មើលមុខលោកបាស្បាត់ ជាខ្មៅងងឹតសូមឱ្យជួយគិតគូរតែថ្លៃផង ។

ឯលោកបាស្បាត់ញាក់មុខច្រាបថា "គួរសមហើយថៅកែ ព្រោះស្នងថែបនេះមិនសាយកេទុកដល់ណាទេ" ។

ថៅកែជាន់ក៏ញញឹមយើញធ្មេញស្អុយ ហើយនិយាយតែថ្លៃនឹងលោកហ្វូងថា "រឿងនេះទុកជាស្រែចាំថៅចុះ តែវេលានេះ ខ្ញុំបានមិនបានយកច្រាក់មកទេ ដល់ព្រឹកស្អែកខ្ញុំបានឥវ៉ាន់យកច្រាក់មកជូនហើយចុះ ឯកន្លងមៅផង មើលទៅឲ្យតែប្រហែលជាត្រូវការយ៉ាងច្រើនគ្រាប់ផង" ។

ហ្គួង ។ "ចាន, ចាន, អង្គាល់ក៏ចាន ខ្ញុំនៅផ្ទះជាដរាបមើអញ្ជើញ
មកតែជួបនឹងខ្ញុំជានិច្ច" ។

ថៅកែផាន់និយាយដោយគួរឲ្យចោទថា "សូមអាត្រេះគុណជាបំផុត
តែខ្ញុំចាន សូមឲ្យលោកមេត្តាបន្តិច ដ្បិតខ្ញុំចានមិនដែលឃើញរបៀបដឹក
គ្រួងសោះ សូមលោកមេត្តាទុកឲ្យខ្ញុំចានៅមើលម្តងចានឬទេ ?

លោកហ្គួងសើចហើយថា "ចាន, ចាន ថៅកែ ខ្ញុំមិនកំណាញ់ទេ
មានអណ្តូងគ្រួងនៅក្បែរ ផ្ទះនេះក៏មាន ទៅនាំគ្រែយផ្ទះនេះឯង
អញ្ជើញទៅមើលចានតាមត្រូវការ" ។

លោកហ្គួងក៏គ្រែកឡើងពីកៅអីហើយថា "អញ្ជើញមកអាមខ្ញុំ
ទៅចិត្រទៅជាមួយដង" ។

ទៅចិត្រមិនចង់ចេញទៅចោលនារីឡើយ គេក្រែឡែកមើលចា-
ឡាត់ស្រែកនោះដោយកិរិយាមិនទុកចិត្តសោះ ហើយសួរទៅថា "សូម
អោស, លោកមិនអញ្ជើញទៅមើលទេឬ ?

លោកចាឡាត់ត្រូវក្បាលហើយថា "មិនទៅទេ, ឆ្លាប់មើលរាប់
ទាំងរយៈទាំងពាន់ដងមកហើយ" ។

ឯនារីនាំក៏គ្រែកឡើងក្រែងខ្លាចទៅតាមទៅចិត្រទៅ ដោយនាំ
ដឹងចិត្តរបស់ក្មួស្រែកនោងយ៉ាងជាក់ច្បាស់ តែចាឡាត់ស្រែកយល់ឥតដឹងថា

"ប្រញាប់អញ្ជើញទៅណា ឃុននាវ៉ែ, ទុកឲ្យខ្ញុំបានអង្គុយឯកតែម្នាក់ឯងឬអី!

នាងនាវ៉ែមេរមកញញឹមតាមទំនៀមទាំងមិនដោះសាថាអ្វី ក៏ដាក់គូថអង្គុយលើកៅអីដដែលដោយទឹកមុខក្រៀមក្រំ ហើយសួរថា "លោកបាឡាត់មានរឿងអ្វីនិយាយទេឬ?

កាលបាឡាត់ស្រុកនោះឃើញទៅចេញផុតទ្វារទៅហើយ ក៏លើកកៅអីចូលមកជិតនាវ៉ែហើយក៏ញញឹមប៉ប្រឹមរួចនិយាយថា "រឿងរបស់ខ្ញុំមានច្រើនណាស់" ។

"មានរឿងអ្វីខ្លះ អញ្ជើញមានប្រសាសន៍ទៅចុះខ្ញុំនឹងចាំស្តាប់" ។

បាឡាត់ស្រុកសំឡឹងមើលមុខនាវ៉ែដោយទឹកមុខចំឡែក ហើយនិយាយតិចៗស្ទើរតែទៅជាឮប្រាប់ថា "ឃុននាវ៉ែ, ខ្ញុំមានរឿងសំខាន់ដែលត្រូវនិយាយជូនខ្លួនឃុន!" ។

នាងនាវ៉ែអង្គុយនៅតែស្ងៀម លោកបាឡាត់ក៏និយាយតទៅថា "ជារឿងសំខាន់ស្ទើរជីវិតរបស់ខ្ញុំតែម្តង! ដ្បិតជីវិតខ្ញុំវេតមួមកយូរណាស់ហើយ! ។

ទើបនាងនាវ៉ែដឹងខ្លួនថា ត្រូវបាឡាត់នោះនិយាយចែចង់ខ្លួនហើយតែម្ល៉េះ ជាមិនដឹងរឿងក៏អ្វីនៅតែស្ងៀមដូចប្រក្រតី ។

ចាឡាត់ - "ឃុននារី" ។

នារី - "ចាស" ។

ចាឡាត់ - មេត្តាជួយសង្គ្រោះខ្ញុំចាខផងចានេះ ?

នារី - ចុះនឹងឲ្យខ្ញុំជួយលោកចាឡាត់ដូចម្តេចខ្លះ ?

ចាឡាត់ - "បើឃុនស្ម័គ្រចិត្តជួយមែន តែងជួយចានជាក្រាកដ" ។

នារី - លោកចាឡាត់មិនទាន់ក្រាបរឿងឲ្យខ្ញុំដឹងថា ត្រូវឲ្យខ្ញុំជួយដូចម្តេច ?

ចាឡាត់ - ខ្ញុំគង់តែនឹងក្រាបឃុនឥឡូវនេះហើយ តែឃុនត្រូវធ្វើសញ្ញាថា បើសំដីដែលខ្ញុំនិយាយទៅនេះមិនជាទីតាប់ចិត្តទេ, សូមឃុនត្រាច្រណីកុំបីប្រកាន់ខឹងឡើយ ?

នារី - "ចាស, ខ្ញុំមិនខឹងនឹងលោកចាឡាត់ផ្តេសផ្តាសទេ" ។

ចាឡាត់ទិតចូលទៅជិតនាងនារីហើយនិយាយស្ទើរជាខ្សឹបថា "ខ្ញុំចាស្រឡាញ់ឃុនណាស់, ឃុននារី" ។

នាងនារីចង់ចំកើមជាងសងខាងភ្លាម ។

ចាឡាត់មើលមុខនារីហើយថា "ថ្លៃកណាស់ឬ ឃុននារី ?

នារីញាក់មុខហើយថា "ថ្លៃកណាស់ៗតែម្តង !

ចាឡាត់ - "ឃុនឃើញសេចក្តីមេត្តាស្នេហារបស់ខ្ញុំចាខជាការចំឡែកណាស់ទៅឬ ?

នាវី - "ទេ លោកជាម្ចាស់ ខ្ញុំទឹកមួលស្ងួតមិនក្លាបន់កនាថា លោកជាឱ្លាត់ចង់ចែងតែស្រឡាញ់ស្រីដូចយ៉ាងខ្ញុំនេះទេដឹង" ។

ជាឱ្លាត់ - "តែខ្ញុំជាទៀតនឹកមួលស្ងួតបន្តិច កុងការមកចងមេត្រីនឹងស្រីដូចឯងយូរ ដែលមានលក្ខណៈល្អត្រឹមត្រូវ" ជាហើយក៏លោតដៃទៅចាប់ដៃនាងតែនាងរលាស់ដៃចេញទៅ ។

នាវី - "ខ្លួនខ្ញុំឥតមានអ្វីល្អទេ លោកជាម្ចាស់" ។

លោកជាឱ្លាត់សើចហ៊ឺៗហើយថា "កុំនិយាយបន្លាចបន្តុះខ្លួនទៅស្រីយូរ មុនខ្ញុំនឹងមកនិយាយជាមួយនឹងយូរ ខ្ញុំជានឹកហើយតិតទៀតជាច្រើនត្រូវប៉ះ នៅរឹងមាំផុត ក៏ជាប់ចិត្តមកនិយាយនឹងយូរ" ។

នាវី - "ចុះលោកជាប់ចិត្តយ៉ាងម៉េច" ។

ជាឱ្លាត់ - "ជាប់ចិត្តថាត្រូវមកដឹកបង្ហែយូរជាន់ត្រជាបថា ខ្ញុំជាទស្រឡាញ់យូរ ជាសេចក្តីស្រឡាញ់តិតជាកងរាស្ត្រចេញមកតំបេះផ្លែរបស់ខ្ញុំជាទ ចុះខាងយូរតើអាចតបជាន់ឬមេថា យូរក៏ស្រឡាញ់ខ្ញុំជាន់ដែរ" ។

លោកជាឱ្លាត់ទំនិយាយយ៉ាងនេះគ្រប់ពីរកេរស្តាប់ តែនាងនាវីនៅតែយកពាក្យ ចៅចិត្តរបស់នាងនិយាយពីរកេរជាងនេះទៅទៀត ទើបត្រេកអរនៅក្បាថា "រឿងនេះ ខ្ញុំតបលោកជាឱ្លាត់មិនជាន់ទេ" ។

លោកជុំ ឡាត់បើកដៃកង់ហើយថា "គ្រោះរហ័សអ្វីបានជាវា
ភក្តីខ្ញុំជាទម្ងន់បាន?

នាវី - "គ្រោះខ្ញុំនឹងស្រឡាញ់លោកជុំ ឡាត់ណាស់" ។

ជុំ ឡាត់ - "ចុះហេតុអ្វីក៏ដែលស្រឡាញ់ខ្ញុំសោះ" (សួរនាងនាង
ដោយសំលឹងទៅនឹងមុខគ្នាបន្តិច) ។

នាវី - "មិនដឹងតបទេ, លោកជុំ ឡាត់, ការសំខាន់គឺថាខ្ញុំមាន
ចិត្តស្រឡាញ់លោកជុំ ឡាត់ត្រឹមប៉ុណ្ណេះគ្រប់គ្រាន់ហើយ" ។

ជុំ ឡាត់ - "តុត្មោ! ឃុនវ៉ា ឃុនទឹងសម្លាប់ខ្ញុំដោយឥតចង់ក្តី
អាណិតអាសូរសោះឬអី?

នាងនាវីមិនតប ។

ជុំ ឡាត់ - "ឃុនកំពុងតែលុះលំលាយចំផ្លាញ់ណាងល្អទឹងសេចក្តី
មេត្រីស្នេហាដ៏សុចរិតស្មោះត្រង់របស់ខ្ញុំជាខ្លាំងណាះនេះហើយឬ?

នាវី - "មិនមែនដូច្នោះទេ លោកជុំ ឡាត់ ស្ត្រីដទៃទៀតដែល
ល្អជាងគ្រាន់បើជាងក៏មានតារាគោកម៉ែបតំលោកមិនស្រឡាញ់! ។

ជុំ ឡាត់ - "ខ្ញុំជាខ សូមផ្តើជីវិតចំពោះរូបឃុនតែមួយប៉ុណ្ណោះ" ។

នាវី - "បើលោកជុំ ឡាត់នៅតែប្រកាន់ដូច្នេះ តង់តែឃ្លាងជាង
អស់មិនបានអ្វីឡើយ" ។

លោកបាឡាត់ឆាល់ច្រកក៏ក្រោកដើរលៀលវាលវែកក្នុងបន្ទប់នោះត្រែះរែះ
រកសំដីនិយាយ, នាងនាវដើរទៅឯបង្អួចចោលក្អែកក្រែកឡកមើលទៅឯ
ក្រៅយូរចាំមើលផ្លូវទៅចិត្តរបស់នាង ដោយខឹកអោនចិត្តនឹងបាឡាត់
កំណេរនេះពាន់ពាក ។

ឯលោកបាឡាត់នោះក៏ដើរទៅឈរពាំងឥវាងមុខនាង ហើយនិ-
យាយថា "ខ្ញុំដឹងហើយថា ហេតុអីបានជាឃុនមិនស្រឡាញ់ខ្ញុំ" ។

ឯទាងនាវឈរទៅតែស្ងៀម ដ្បិតនាងមិនត្រូវការស្តាប់សំដីវាក
របស់បាឡាត់នោះឡើយ ។

បាឡាត់- "ឃុនមិនស្រឡាញ់ខ្ញុំ, ព្រោះឃុនមានតួមនុស្សដែល
ឃុនស្រឡាញ់រួចទៅហើយមែនឬទេ!" និយាយសើចដាក់តិះដៀលចំអក
ចំអួយ ។

នាវដាក់ខ្ទាប់មកមួយរំពេចនឹកឡើងណាស់ដែលគេនិយាយមិនត្រែង
ចិត្តនាងសោះឡើយ ហើយនិយាយរេចញាទៅថា "ចុះយ៉ាងម្តេចលោក
បាឡាត់, មនុស្សដែលលោកថានោះគឺនរណា? កុំប្រើសំដីឈ្មានឆានមក
លើខ្ញុំខ្លាំងពេកណា!" ។

លោកបាឡាត់គាន់តែសើចខ្លាំងឡើងទៀតហើយថា "ខ្ញុំមិនបាន
ឈ្មានឆានចង្កាច់ឃុនអ្វីទេ គ្រាន់តែនិយាយថា "ឃុនមានគូស្រករបស់
ឃុនរួចទៅហើយ ខ្ញុំនឹងច្រាប់ឈ្មោះឥឡូវក៏បាន" ។

នាវ៉ែ- "នែ៎ណា ហ៎! (នាងស្ទុះទៅនិទ្ធិង) ។

ចាឡាត់- "ក៏ចៅចិត្តនោះឯង, មែនទេ, ចៅចិត្តវាក្មេងកំឡោះរូបស្រស់ សំដីផ្អែម តែវាទិទ្ធិលក្រដូចមនុស្សសុំទានគេមែនទេ! (ហើយក៏សើចគ្នាកក្អាយ) ។

នាវ៉ែ- "លោកអួតខ្លួនវិសេសយ៉ាងណាបានដាហ៊ានឱយាយសង្កត់សង្កិនបន្ទុះបង្អាប់គេយ៉ាងនេះ, បើពុតជាគេទិទ្ធិលក្រក៏ទិទ្ធិលក្រតែគ្មានសម្បត្តិច្រាក់មាស តែគុណសម្បត្តិសុភាពរៀបរយ ជាសុភាពបុរសជាកូនប្រុសមែនៗ នោះ ចៅចិត្តមានសក្តិគ្រប់, ឯខ្លួនលោកមានតែច្រាក់មាសមែនហើយ, លោកអាចទិញជូរបស់អ្វីបានតាមត្រូវការ តែលោកមិនអាចយកច្រាក់មាសរបស់លោកមកទិញសេចក្តីស្នេហារបស់ខ្ញុំបានទេ, លោកមានច្រាក់មាសដែលចៅចិត្តគ្មាន តែរបស់ដែលចៅចិត្តមាន; លោកមិនមានសោះឡើយមែនឬទេ?

ចាឡាត់- "ចុះខ្ញុំមិនមានអី? នៅខ្លះអ្វីទៀត?

នាវ៉ែ- "សុភាពបុរសនឹងគាំរ:ជាកូនប្រុស" ។

ចាឡាត់- "ក៏នេះមិនមែនកូនប្រុសទេឬ"

នាងនាវ៉ែសើចចំអកឡេហើយថា "ត្រូវហើយ, តែលោកចាឡាត់គ្រាន់តែមានកាយជាកូនប្រុស, តែចិត្តរបស់លោកទាបលើសស្រីទៅទៀតមែនទេ" ។

ជាឡាត់- "ខ្ញុំចង់លើសស្រីទៀតទេ" និយាយផ្ទួនពាក្យហើយសួរទៅគាំងថា "ចុះហេតុដូចម្តេចបានជាឃុនមិនយកប្រាក់ខ្ញុំដូច្នេះ?

នារី- ខ្ញុំឥតប្រមាថមាតមានអ្វីលោកទេ, តែនិយាយតាមត្រង់ទេតើលោកកូចហើយឬ ងាលចោះប្អូនទៅតណ្តាលព្រៃ អ្នកណាហ៊ានចេញទៅតលង់ធំធាត់ពួកចោរ? ហើយអ្នកណាតេះទៅពួនយកតែព្រះអាយុស្ទះទៅត្រាមថេងន្ត?

ជាឡាត់- "ខណៈនោះវាគ្មានគាំក្លើនទៅធំធាត់ដៃខ្ញុំទេ ឃុនក៏ជាធំស្រាប់ហើយ" ។

នារីសើចហើយថា "ចើខុកជាមានកំមិនហ៊ានជ្រាញដែរ មនុស្សកខ្វាចបែបនេះគិតតែរត់ជាទេដើរសត្រាតឲ្យច្រេចខ្លួនប៉ុណ្ណោះ!" ។

លោកជាឡាត់កាលត្រូវសំដីស្រីប្រមាថមើលងាយដូច្នេះក៏ប៉ើតក្អែតក្រឡេតច្រឡេតខឹងជាខ្លាំងរួចចាប់ដៃនារីទាំងពីរច្រាច់ណែនហើយច្រាប់ថា "ឈប់កុំនិយាយទៀត ខ្ញុំនឹងសងសឹកអំពើតបស់ឃុនឥឡូវនេះឯង" ។

នាងនារីទំលាស់ចេញជាប្រញាប់ តែលោកជាឡាត់ការតែច្រាច់ខ្លាំងទៀតហើយប្រកាសថាងងឹង ។

នារី- "លែងខ្ញុំ; លោកជាឡាត់, លោកមានអំណាចដូចម្តេចបានជាហ៊ានធ្វើគេដូច្នេះហ្ន៎!! (នារីស្រែកឡើង) ។

ចាន់ឡាត់ — "មិនអួតទេ, តែហ៊ានធ្វើព្រោះស្រឡាញ់ទេតើ! ឲ្យខ្ញុំថើបដោយស្រួលៗវិញ" ហើយទំប្រកាន់ខុសទាំណែន ខាងនាងក៏ទំបម្រះគេញក់ខ្លាំងទៅជាចំចាប់ប្រចាប់ខ្លាអីកៈឯកឡើង ពាល់តែថ្ងាចន្ទូបំរះថើតចេញលេចពន្លឺកាយចៅចិត្រស្ទុះចាញ់ត្រង់សំដៅទៅលោកចាន់ឡាត់ចាប់កន្ត្រាក់លោកចាន់ឡាត់នោះចេញ លោកចាន់ឡាត់ភ្លាត់ចំណាប់មិនបានការពារខ្លួន ទើបត្រូវចៅចិត្រងាល់ជួលម្ជាះចន្ត្រាំងទៅក្នុងបន្ទូបន្ទុះឯង ។

ចិត្រ - "អាក្រក់អីម្ល៉េះ អ្នកចាន់នេះ" ចៅចិត្រគំពាមទាំងធ្មេញប្រឆងនឹងលោតទៅសាំថែមទៀតតែនាងចាប់ដៃទាន់ហើយហាមថា "ប៉ុណ្ណឹងល្មមហើយ ចិត្រ, កុំថែមទៀត" ។

លោកចាន់ឡាត់ស្ទុះក្រោកឡើងប្រឆងនឹងលោតមកសងសឹកវិញស្រាប់តែហ្ជូនគេនសម្បត្តិនឹងចៅតែងាន់ដើរចូលមកកន្លងបន្ទូប់នោះ ទើបលោកចាន់ឡាត់នោះខន់ឆ៊ីត់ លោកហ្ជូនងាកទៅមើលមុខចៅចិត្រហើយថែរមកមើលមុខលោកចាន់ឡាត់ ដោយលោកមានសេចក្តីងឿងឆ្ងល់ណាស់ ទើបលោកសួរថា "កើតរឿងអី, ចៅចិត្រ, ទើបមានសួរអីកៈឯកស្ទើរតែនឹងក្លាយជាញាំងផ្ទះហ៊ឹ? ។

ចៅចិត្រមិនចាន់ឆ្លើយ ស្រាប់តែនាងនាំស្ទុះទៅឧបផ្តុកហើយថា "ប៉ា", លោកចាន់ឡាត់នោះនែអាក្រក់ណាស់" ។

ហ្ជូន- "ហ៎មេច លោកចាន់ឡាត់ធ្វើអី? (លោកហ្ជូនឈ្វេងសួរក្មួន) ។

នាវី – "ចំបាប់ខ្ញុំ, គ្រែរល្អជាន់ទៅចិត្តចូលមកតាន់ កុំអី....."
(ថារហើយនាងយំខ្សឹកខ្សួលយ៉ាងគ្មានក្តាញ់កង់ចិត្តជាបំផុត) ។

លោកហ្ជង់ខ្លួលស្តាប់ពាក្យកូន ទើបដើរចូលទៅជិតលោកជាខ្លួតនោះហើយនិយាយថា "ហេតុអីក៏លោកហ៊ានធ្វើអំពើច្បាងខាមដោយឥតអៀនខ្មាសដូច្នេះ ខ្ញុំជានេសាទគប់លោកដោយដៀងខុសចិត្តថាលោកជាមនុស្សល្អ ជាកល្យាណមិត្តរបស់ខ្ញុំ ឥឡូវលោកមែរជាតបស្នងសងគុណខ្ញុំដោយលក្ខណៈដូច្នេះនេះ ល្មមឈប់សេពគប់ពាប់កេគ្នាតាំងអំពីថ្ងៃនេះតទៅ" ។

លោកជាខ្លួតនិយាយសំដីខន់ទៅកេហ្ជង់តេនសម្បត្តិថា "ខ្ញុំជាខ្លួនជាខុសទៅហើយ សូមលោកអត់ទោសឲ្យម្តងចុះ" ។

លោកហ្ជង់ធ្វើជាសើចសោះកះគ្រែរហើយថា "លោកជាខ្លួតជាន់ជំងឺថាខ្លួនខុសនោះក៏ហួសវិលាទៅហើយ, តែល្អីយចុះ, ខ្ញុំមិនប្រកាន់ទោសតែក៏អ្វីទេ, តែដំណែលលោកមកធ្វើល្មើសលើខ្ញុំជាខម្មង់តង់គ្រានេះ ខ្ញុំអត់ទោសឲ្យ, តែយើងត្រូវតែលែងស្គាល់ពាប់កេគ្នាតទៅទៀត; ដ្បិតអំពើដែលលោកធ្វើនេះវាគ្រក់អប្បលក្ខណ៍គួរគាប់សំមុខណាស់ តែកាលបើលោកដឹងខ្លួនថាខ្លួនខុស; ខ៊ុះន! ត្រូវចេញ, សមគួរតែលោកដើរចេញទៅកុំបីចូលមកវិញទៀតឲ្យសោះ" លោកហ្ជង់ថា

ហើយក៏ថែរទៅថៅតែផាន់ហើយថ្លែងថា "ខ្ញុំនឹកស្ដាយណាស់ក្នុងហេតុ
នេះដែលកើតឡើងអម្បាញ់មិញនេះ" ។

ថៅតែផាន់មិននិយាយថាដូចម្ដេច ដើរសំដៅទៅរកលោកចាឡាត់
ខៈស្មាតិចៗ ហើយថា "ទៅ, លោកចាឡាត់ កុំបីតូចចិត្តពោលទស្ស
អ៊ី; ព្រោះអំពើដែលលោកបានធ្វើមកនេះជាការខុសពិត" ហើយក៏
ដឹកដៃលោកចាឡាត់ៗតនមុខដើរចេញតាមទ្វារនោះទៅ ។ ខាងឯលោក
ហ្លួងក៏មិនបានប្ដឹងផ្ដល់ដែលជាការតរឿងក៏ឲ្យវែងតទៅទៀត ដោយ
លោកនឹកថាជាគ្រោះថ្នាក់របស់លោកនឹងបុត្រីរបស់លោក ទើបស្ទុះរឿង
ខ្លួនត្រឹមប៉ុណ្ណេះ ។

* * *

រៀលព្រលប់ចូលយប់សន្ធឹក ព្រះចន្ទ្រារះឡើងពីបូព៌ាទិសយ៉ាង
ត្រចះត្រចង់ ហេតុកេរដែលកើតឡើងពីពេលថ្ងៃរសៀលមិនទាន់លុប
បាត់ពីខួរក្បាលរបស់ថៅចិត្រ ។ រៀលនោះថៅចិត្រតំពុងអង្គុយបណ្ដែត
ចិត្តទៅតាមការម្នាណ៌ដែលគិតនឹកនៅនារបៀងផ្ទះ ពោលភ្នែកត្រឡែក
មើលទៅលើមេឃឃើញភពក ១ ដុំធំតំពុងរះណ្ដែតត្រសៃតទៅទិសទាក
កើត ស្ដាប់សំឡេងស្ងឹកឈឹងសូន្យឈ្ងាវៗ ដែលត្រូវខ្យល់បក់ សុនខនៅ
ខាងផ្ទះដិតខាងក៏ព្រុសតឹតកងហើយវែកលូយ៉ាងលន្ធន់លន្ធោច ថៅ-
ចិត្រក៏ចាប់ភ្ញឹកនឹកដល់ទុក្ខដែលអនិច្ចកម្មទៅហាក់ដូចជានៅថ្មីៗនឹកឡើង

រៀបណាទឹកភ្នែកក៏ហូរស្រក់មកដោយមិនដឹងខ្លួនច្បាស់ ហើយទឹក
រលឹកដល់ថ្ងៃណាំរបស់ផុតមុនដែលគាត់លះបង់លោកនេះទៅ ចៅចិត្ត
ក៏គិតឃើញថា ខ្លួនរបស់ខ្លួនឯងនិពិត។ ចំតាំងខ្លួនច្បាស់ឡើងមកនេះ
គិតទៅគិតមក តំនិតចៅចិត្តជាប់ខោខើរលើរូបនាងនារីពាងអស់;, នាង
នារីតែមួយដែលអាចជួយញ៉ាំងជីវិតរបស់គេឲ្យស្រស់បស់ផ្លូវផងនិតទៅមុខ,
ប្រសិនបើបែរជាមិនសំរេចដូចបំណង ជីវិតរបស់ចៅចិត្តស្ទើរតែទៅជា
សោះសូន្យឥតរីកពន្លកឡើយ; តែគេដឿជាក់ក្នុងសេចក្តីមេត្រីស្នេហាវាង
នារីនឹងខ្លួនគេជាខ្លាំងបំផុត ទឹកដល់ត្រង់ណេះចៅចិត្តក៏ញាញីមប៉ប្រឹមតែ
ម្នាក់ឯង ហើយគេគ្រែកឡើងដើរចូលទៅក្នុងបន្ទប់ ប្រះខ្លួនដេកលើភួក
ខ្នាតតូចដែលនាងនារីដេរឲ្យដោយថ្លៃដៃរបស់នាង ទម្លាក់មុងមាញជួយមក
ជណ្តប់ប្រុងស្មាតន់ឯងដេកឲ្យលក់សប្បាយ" ។

ភាគាសនៅវេលាយប់ជ្រៅ ទៅនៅស្រុកបម៉ៃលិនត្រជាក់ខ្លាំងបន្តិច
ផ្លូមេឃស្រឡះច្បាសចាកពពកដូចច្រូ ហាក់ដូចជាអណ្តែតនៅលើ
កំពូលភ្នំបម៉ៃលិន បញ្ចាំងពន្លឺសស្អាតសាចចូលមកតាមចន្លោះបង្អួច មាន
ខ្យល់រំភើយ។ បក់ចូលមកប៉ះនឹងសៀមុងរបស់ចៅចិត្ត។ សូរសេកូឆ្កែត្រុសនឹង
សូរលូនទៅតែឮសោនមិនដាច់សំរេងឡើង ចៅចិត្តដេកសំរឹងមើលដួងច្រូ
ហើយធ្វេចភ្នែកដិតតែនឹងដេកលក់ទៅហើយ ។

"ប៊ុន! ប៊ុន! សូរកាំភ្លើងលាន់ឮឡើងនៅក្បែរខាងបរិវេណផ្ទះ ដូចជាជាស់ចៅចិត្តដែលជិតលក់ឲ្យភ្ញាក់រលឹតឡើងវិញ ហើយគេបានសុះគ្រែកឡើងយ៉ាងប្រញាប់ប្រញាល់ អង្គុយចាំស្តាប់ឲ្យជាក់ច្បាស់ តើមានហេតុអ្វីកើតឡើង? ក្អែកសំឡឹងមើលកាំភ្លើង ១ ដែលក្បួរនៅទំនិងជញ្ជាំងខាងក្បាលដំណេកជារបស់ដែលហ្វូងគេនសម្បត្តិឲ្យមកពុកបង្ការអន្តរាយ ស្ងប់ស្ងាត់ទៅមួយស្របក់, ប៊ុន! ប៊ុន! ប៊ុន! សូរក៏លាន់ឮឡើងទៀតជាច្រើនណាត់, ចៅចិត្តក៏សុះគ្រែកឡើងចាប់កាំភ្លើងសុះចុះពីផ្ទះមកស្រាប់តែឃើញភ្លើងភ្ញីខ្ចាលអស់ចាំងភូមិ ទើបរត់ទៅផ្ទះពួកកម្មករក៏ឃើញពួកកម្មកររួមធ្មុំគ្នា ខ្លះកាន់កាំភ្លើង ខ្លះកាន់លំពែង ខ្លះកាន់ជារបែងខ្លួនជាស្រេច ។ សូរកាំភ្លើងក៏លាន់ឮឡើងទៀតជាច្រើនណាត់ ព្រមទាំងសូរហ៊ោរបស់ពួកចោរយ៉ាងអឺកៈធឺ។ បន្តិចស្រាប់តែឮសូរស្រែកអេះអះនៅលើផ្ទះធំ, ចៅចិត្តចាំបានច្បាស់ជាសំឡេងរបស់ហ្វូងគេនសម្បត្តិ ។

"អាពួកនេះសំខាន់ណាស់ ឯងឃើញផ្ទះណាមានទ្រព្យសម្បត្តិពីតែងនាំមកឲ្យពួកវាចូលប្លន់" នេះជាសំឡេងតាសុខគ្រកបរវេយន្តឮស្ទើយ។ មកតាមឮស្រាប់ ។

ចៅចិត្តបានដឹងច្បាស់ជាមានពួកចោរចូលប្លន់ក៏នាំពួកកម្មកររួចញៅទៅសំដៅផ្ទះធំយ៉ាងរួសរាន់ ក៏ស្រាប់តែឃើញពួកចោរជាចំនួនច្រើន

កំពុងប្រកាសគោរពចង់ក្លាមកំចិតក្លាមសឹងមានអាវុធគ្រប់ដៃ ដើម
ទាំងពួកអ្នករៀតយុទ្ធនឹងពួកចោរយ៉ាងម៉ឺងម៉ាត់ ។

ការតស៊ូរវៀងពួកចោរនឹងពួកអ្នករ សុទ្ធតែមានអាវុធគ្រប់ដៃខាំង
សងខាងគាន់តែភ្លាំងខ្លឹច ។ ដល់ថ្នាក់ប្រឡូកគ្នាមិនគិតស្លាយជំនែរឿន
ឯ ឯចៅចិត្រមែបទឹងដើមឈើ ១ ដើមដាវកំចាំង, លើកកាំភ្លើងបាញ់
ជម្រងំចោរម្នាក់ដួលផ្ងារៀងយ៉ាងគ្រាប់កាំភ្លើង ១ គ្រាប់ដំបូង ១ គ្រាប់
ទៀតត្រូវចោរម្នាក់ទៀតគាន់ដាវនៅដៃខាងឆ្វេងពីរដួលទៀត; ១ណាៈនោះ
ស្អូវស្រែកហៅ ស្អូវកាំភ្លើង ស្អូវថ្នូរចេមអ្នកដែលត្រូវបួសក៏លាន់ឮកង-
រំពងនៅខាងកូម ។

ចៅចិត្រទុកឲ្យពួកអ្នករតែទល់នឹងពួកចោរនៅខាងក្រោម
ខ្លួនឯងដោរដៃស្ទុះរត់ឡើងទៅលើផ្ទះធំ តែបានឮស្អូវសំឡែងតស៊ូហ៊ោង
អឺកៈដឹកនៅបន្ទប់ខ្លួលក្បែរ ក៏ស្ទុះភ្លែតចូលទៅស្រាប់តែឃើញចោរ
មានធំឡើងតែលើម្នាក់ ចាប់គ្រវាត់លោតហួងដួលគាំងពណ្តាលរលែងបន្ទប់
នោះឯង ។

ចៅចិត្រស្រែកឡើងថា "អាដាន់ អាដាចៅតែចោរទេឬ អាទាំងពួក
ចោរមកបន្ទប់ឬ?

អាដាន់ជាមហាចោរចិត្តទមិឡទាំងសំញែញែងសស្វាចដូចជាយក្ស

គប់ទៅថា "អើ! អញនេះហើយ ឯញត្រឡប់មកសងសឹកអាវិញឲ្យទាន់ចិត្ត ហើយយកត្បូងពាំងអស់ទេស់ចៅហ្វាយអាទៅផង" ។

ចៅចិត្តទាំងឮញ្ញត្តកត្តហើយលើកកាំភ្លើងដម្រង់និយាយថា "អានេះមិនយកទេឬ" ហើយចុញ្ចប់ចំសំដៅដើមទ្រូងមហាចោរ ១ ណាត់ តែមហាចោរវៃចំណាប់ គ្រាប់កាំភ្លើងត្រូវតែចុងសក់មហាចោរ ផ្ទុះផញ្ចាំងទៅហើយវាស្ទុះភ្លែតដល់ខ្លួនចៅចិត្តប៉ះយ៉ាងខ្លាំង ចៅចិត្តភ្លាត់ចំណាប់ដួលផ្ងារចង្កើត កាំភ្លើងរបូតទៅខាងកៀនផញ្ចាំង តែចៅចិត្តក៏វៃចំណាប់ម្ខាមគ្រាកឡើងស្ទុះភ្លែតជាក់មហាចោរវិញ មួយដៃជំបួងត្រូវផ្កាមក្បាលគុម្ពត្រចៀកញាំងមហាចោរឲ្យត្រេតចយគ្នាទៅម្ខាង ចៅចិត្តស្ទុះទៅទំងាល់ ១ ដៃថែមទៀត តែថែរជាត្រូវមហាចោរវាត់ ១ ដៃត្រូវខាងលើត្រចកក្បែកខាងក្នុង កងកាយគូចស្ដើងរបស់ចៅចិត្តក៏រលាស្ងួតទៅប៉ះនឹងផញ្ចាំងផ្ទះ មហាចោរស្ទុះមកនឹងថែមយ៉ាងពេញទំហឹងដៃ តែចៅចិត្តគេចផុតទៅបន្តិចទើបធ្លាក់ឲ្យ ១ ដៃលើកត្រគាយយ៉ាងតំបន់រចស់មហាចោរនេះ ត្រូវផញ្ចាំងផ្ទះឮសូរគ្រាំងស្ទើរតែរបើតង្វាយចេញទៅ ។

មហាចោរលាស់ដៃជាប្រញាប់ ក៏ស្រាប់តែប៉ះនឹងកណ្ដាប់ដៃរបស់ចៅចិត្តយ៉ាងធ្ងន់ត្រង់បបូរមាត់ចេញឈាមខ្លាច តែមហាចោរចិត្តមុតគ្រាន់តែត្រេតទៅបន្តិច ក៏ស្ទុះត្រចាបូលមកជាក់ចៅចិត្តវិញ ចៅចិត្តគោងថយក្រោយទៅ ២-៣ ជំហាន ដោយនឹកស្ញើចនឹងកណ្ដាប់ដៃយក្ស

បេស់មហាចោរ ដែលអាចផ្តួលមនុស្សធម្មតាត្រឹមតែមួយដៃ។ ប៉ុណ្ណោះ, មហាចោរគាត់ដាច់សំរេចភ្លាមតែម្តងៗ គេចង្អុរទើបគេតបទៅវិញ ទីឆកៅអី។ នៅក្នុងបន្ទប់នោះ មហាចោរលើកដៃកាត់ កៅអីចាក់ច្បាវ ហើយមហាចោរស្ទុះចូលមកខ្លួនដូចជាក្រមើព្រៃ, ចៅចិត្តថយទៅបំរះ ផ្ញាំងស្រាប់តែដើងគេទៅដាន់លើកាំភ្លើង, ទើបចាប់កាំភ្លើងឡើងប្រ. ញាប់ផ្តងទីឆស្មា ហើយដម្ងោះកែសំរេវដើមត្រង់មហាចោរដែលស្ទុះ ត្រង់ត្រូវចូលមកខ្លួន ប៉ុង! ចាត់ផ្សែងពងកាយសំបើមដូចក្រមើព្រៃនៃ មហាចោរដួលត្រង់ដេកស្លុកស្តឹងនៅក្នុងបន្ទប់ខ្ទុះឯង ។ លុះចៅចិត្ត យើញមហាចោរអស់ឫទ្ធិអំណាចទីងត្រាកមកតស៊ូថានខ្លួន ទើបដាក ទៅតិត្យមើលហួងវតនសម្បត្តិ ដែលដេកស្រាប់នៅក្នុងបន្ទប់ខ្ទុះដែរ, លើកកញ្ជាលដាក់លើក្បៅហើយចាប់អង្រែនមើល លោកហួងក៏បើកភ្នែក ឡើងហើយសួរខ្សារ៉ា យ៉ាងអស់កំឡាំងថា "អាដាន់ទៅណាហើយ?

ចិត្ត- "ស្លាប់ហើយ ថានត្រាស, ព្រះគេដ៏ព្រះគុណល្អមាន កំឡាំងត្រាកអង្គុយថានឬទេ?

ហួង- "ល្អមអង្គុយថាន ខ្លួនខ្ញុំមិនជាអ្វីទេ គ្រាន់តែអស់កំឡាំង ណាស់, អាឆតនោះវាចាប់ឯងធ្វោកស្ទើរតែស្រាច់" ។

ហួងវតនសម្បត្តិនិយាយមិនទាន់ផុតពាក្យ ស្រាប់តែសំឡេងស្រួច ឆ្ងាយដាសំឡេងស្រីស្រែកឡើងយ៉ាងខ្លាំង ហួងវតនសម្បត្តិបើកភ្នែក

ក្រែឡាតចាំបាស់ជាសំឡេងនារីបុត្រីរបស់លោក ក៏ត្រូវពួកចោរចូលលុកលុយដែរ ។ ឯចៅចិត្តខ្ជូនឯងអស់កំឡាំងជិតដួលទៅហើយ, គ្រាន់តែឮសំឡេងស្រែកនេះឡើងក៏កើតកំឡាំងម៉ឺងម៉ាត់ដូចជាគោឡើងអមួយរំពេច ទើបគេស្ទុះលោតឡើងទៅបន្ទប់ថ្ងាក់លើចូលដល់ដំណេកនាងនារីរំពេច ស្រាប់តែឃើញបុរសកំឡោះម្នាក់កំពុងចំបាប់ប្រវាប្រតប់នឹងនាងនារី, ចៅចិត្តស្ទុះភ្លេតចាប់កន្ត្រាក់កាងកាយបុរសនោះរួចញ្ជាំងដោយងាយមកឯរបៀង មិនដូចកាលគេស៊ូនឹងមហាចោរនុ៎ះឡើយ ។

ចៅចិត្តស្រែកគម្រាមថា "អាចូរឡាត់, អាហ៊ានពុះពារចូលដល់ទីនេះឬ ?

ចូរឡាត់- "អាចិត្ត, អញនឹងបញ្ជូនវិញាណអាឯងទៅស្នាននរកឥឡូវនេះឯង" ចូរឡាត់ស្រែកគំពមគបមកវិញ ហើយចាប់ហូតកាំបិតស្នៀតលើកឡើងចាក់សំដៅដើមទ្រូងចៅចិត្ត ។ គេចផុតខ្លួយទៅ ទើបគេដួចកណ្តាប់ដៃសំដៅចំត្រូវកន្ទុយចូរឡាត់ខ្ទួរតែ តែមួយដៃក៏ដួលស្រាប់តែទៅទីនោះឯង នាងនារីស្រែកភ្ញាត់សំឡេងដោយសេចក្តីតក់ស្លុតស្លាំងកាំង ។

ចៅចិត្តស្ទុះទៅប៊ីនាងនារីចូលទៅក្នុងបន្ទប់ហើយថា "ខ្ញុំនឹងកប្បីយវឡុះស្រែចឥឡូវនេះឯង" ថាហើយចៅចិត្តត្រឡប់ទៅវិញជាប្រញាប់ឯចូរឡាត់នោះខំប្រឹងលន់អាគ្នាក្រោកឡើងរើងរើងដូចកាលត្រូវមន្តវិជ្ជា

ទៅសម្តុនដែន. លុះចិត្តស្ទុះភ្លែតចាប់អារម្មណ៍ឃើញឡាត់ខ្លួនវិតនោះលើកខ្សែន
ស្ទុយហើយគិតមថា "នេះសត្វចាប់នាងនាវ" ហើយរៀក ១ ដៃយ៉ាងខ្លួន
ត្រង់ចង្កាចាប ឡាត់ខ្លួនវិតនោះក៏ដួលផ្ងារចន្ត្រាំងទៅទៀត រួចគេចាប់សក់
ក្បាលស្ទុយខ្សែនទៀតហើយស្រែកថា "នេះសម្លាប់អញ" ហើយគេ
ដាក់ ១ ដៃចំបំពង់ត ពន្លាយទៅចាប ឡាត់ខ្លួនវិតក៏ច្បាស់ចាត់ញាណ
ត្រមាំងរាក់ ១ ដើនយ៉ាងដូចន់ ពេលអស្តុកក៏អណ្តែតខ្លាក់ចុះមកដល់
ដីភ្លាស្ទុរត្រាំង ដាក់សោនៃដីវិតទៅចាប ឡាត់ខ្លួនវិតចិត្តអាត្រក់ខ្លោះ ។

តាលមហាចោរដាំងស្ទាប់តាំងពីនោក់ . ឯពួកចោរដាទៅរកក៏ថែក
ឡាត់ខ្លួយតែចូលដៃត្រមស់ទៅ ។ រំលងដែលពួកកម្មករដេញពួកចោរតែ
ឡាត់ខ្លួយចូលដៃខ្លោះ ពួកកង.ត្រវែលក៏មកដល់ហើយជួយដេញពួក
ចោរតាមត្រាយពួកកម្មកទៅដែរ តែឥតចាប់ចោរម្នាក់សោះ ព្រៀ
លែងតែពួកចោរដែលត្រវែរបួសជាខ្លួន់ដេកទៅក្នុងភូមិខ្លោះប៉ុណ្ណោះ ។
ដល់ព្រឹកខ្សែនហ្លួងតេនសម្បត្តិបាត់ឲ្យប់ណាយប្លន់ត្រសួងពន្ធការតាម
ច្បាប់ អំពីហេតុរបៀតចោរកម្មដែលកើតខ្សែនកន្លងមកខ្លោះសត្វត្រប់ ។

* *

អារិសាធ

ព្រឹកខ្សែន, ហ្លួងតេនសម្បត្តិបានហៅប្រជុំពួកកម្មករទាំងរស់មក
ប្រជុំគ្នាហើយដប់លៀងការហារកោដន ដើម្បីសំដែងសេចក្តីត្រកអរ

ចំពោះពួកកម្មករ ដែលមានចិត្តស្មោះត្រង់ជួយការពារពួកចោរយ៉ាងម៉ឺងម៉ាត់ត្រាតែមានជ័យជំនះ ហើយលោកអនុញ្ញាតឲ្យពួកកម្មកររយៈសំរាកធ្វើការមានកំណត់៣ ថ្ងៃ ។ ត្រាបពេលដែលពួកកម្មករនាំគ្នាលោកហ្វូនទៅសំរាកពន្លឹកាយ ដ្បិតសុទ្ធតែអស់ធុំយទន្ធិនឿយហត់អស់កំឡាំងពាំងអស់គ្នា លោកហ្វូនក៏ទៅសំរាកពន្លឹកាយដែរ ហើយលោកពិចិត្តដល់ឧបការគុណទ្រង់ស្មោះត្រង់ចេះចៀងចិត្តដោយសព្វគ្រប់ទៅក៏យើញថា គេមានមេត្រីចិត្តស្មោះត្រង់ស៊ូប្រកដរឹតខ្ជួនមកប្តូរដើម្បីជួយជីវិតលោកទន្ធិជីវិតបុត្រលោកពីត្រាមតហើយគួរតែរកឧបាសតបគុណ ។ មួយវិញទៀត សេចក្តីសុខស្តាលវេងបុត្រីលោកទន្ធិនរូបចៅចិត្តនោះសោតទៀតលោកក៏ចាន់ជ្រាបច្បាស់ថា មិនអាចទន្ធិបំពាសបំពត់ឲ្យដាច់គ្នាចាន់ទេ លោកហ្វូនគិតមកដល់ត្រឹមណេះ ទើបហៅបុត្រីលោកឲ្យទៅហៅចៅចិត្តមកទន្ធិនិយាយការសំខាន់មួយដាមួយទន្ធិនលោក ។

ចៅចិត្តក៏ដើរចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ, ខណៈនោះហ្វូនគេនសម្លឹងគិតអង្គុយផ្អែកលើកៅអីធំ ចៅចិត្តក៏ដើរចូលទៅដោយសេចក្តីគោរពហើយជំពាចថា "ឋានឆ្កាស, ខ្ញុំចាន់មកហើយ" ។ ឯនាងនាវីក៏ឈរតែមស្តាប់នៅខាងមាត់ទ្វារបន្ទប់ ។

ខណៈនោះ នាយចិត្តក័ដងអង្គន ទឹកភ័យត្រែងលោកចាន់ដំងរឿងរបស់ខ្លួនទន្ធិនឲ្យនាងនាវី ហើយបណ្តាញចេញពីផ្ទះនោះទៅ ទឹកអ

ត្រែងៈលោកត្រៃតអនេឆ៌តាតខល់យ៉ាងម្ដីងម៉ាត់ ត្រាតែបានផ្ដាច់ជីវិត-
មហាចោរបង់ទៅដល់ភ្លើនោត់តាលតិយបម៌មិញនេះ ទើបគេចំប្រឹងតាត់ចិត្ត
និយាយសួរទៅលោកវិញទៀតថា "រឿងអ្វី, ភានត្រាស?"

លោកហ្ជីនត្រហែមតិចៗ ហើយថា "រឿងសេចក្ដីតាប់គួរទេងបុណ្យ
គុណរបស់អ្នកឯងណោះ" ។

ពេលចិត្របានឮពាក្យនេះ បានធ្លុចិត្តដូចជាគេលើកភ្នំបេញពីដើម
ទ្រូង ។

លោកហ្ជីនទិយាយដោយទឹកសំដីពេញទៅដោយសេចក្ដីមេត្តាករុ-
ណាថា "ខ្ញុំត្រូវតែតបគុណអ្នកឯងខ្លះ ឬទេ" ។

ចិត្រ- "មិនចាំបាច់ទេ, ភានត្រាស ខ្ញុំបានធ្វើការត្រម់យ៉ាងនេះ
មិនបានត្រូវថ្នាការតបស្នងរបស់ព្រះតេជព្រះគុណសោះឡើយ ត្រៃអំពី
សេចក្ដីគុណដូចព្រះតេជព្រះគុណ អាណិតអាសូរដូចសព្វថ្ងៃនេះគ៏ល្មម
ត្រម់ត្រាន់ហើយ" ។

ហ្ជីន "មិនល្មមទេ, ចិត្រ, ដ្បិតអ្នកឯងយកជីវិតខ្ញុំបម្រុងសង្គ្រោះតែមិន
រស់តិរបៀត្រាមកហើយ" លោកបន្ថែម ត្រេចក់ហើយលាន់មាត់ថា
"ណ្ហើយចុះ! ចូរនិយាយតាមត្រងំមកចុះ តើត្រូវការអ្វីខ្លះ?

ចិត្រ- ភានត្រាស, ខ្ញុំបានតែត្រូវការអ្វីទេ ខ្ញុំបានជាកូនឈ្លួល
របស់ព្រះតេជព្រះគុណ អំពើដែលខ្ញុំបានធ្វើទៅគាំងប៉ុន្មានសុទ្ធតែ

ធ្វើដោយសេចក្តីកតញ្ញូតវេទិតាចំពោះព្រះគុណ, ឥតត្រូវការ
បំណាច់វង្វាន់អ្វីទេឡើយ" ។

លោកហ្ជូនលើកដៃហាមថា "ម៉ូនបាច់និយាយរេរាំងឲ្យវែងសេចក្តី
ទេ ខ្ញុំដឹងថាអ្នកឯងនិយាយមិនត្រង់មែនទេ ?

ចៅចត្រង់ប្រឹងកាត់ចិត្តកាត់ថ្នើមនិយាយតបដោយសំដីជាច្រើន ថា
"ខ្ញុំ-ចាស, ខ្ញុំ-ចាស, សូមដុំ-ដំរាប. . . . . "

លោកហ្ជូននិយាយកាត់ឡើងថា "ប៉ុណ្ណឹងចុះ; ខ្ញុំដឹងហើយថាអ្នកឯង
ត្រូវការអ្វី ខ្ញុំអាចតាយចិត្តត្រូវនាំងអស់ ណ្ហើយចុះ ខ្ញុំឲ្យ-ឲ្យគ្រប់យ៉ាង
តាមត្រូវការ" ដល់ត្រង់នេះ លោកនុនឡឺបន្ទឹងត្រចៀកនាយចិត្រច្រាបថា
"នុះហ្ន៎! ដែលអ្នកឯងត្រូវការបន្ទះស្មៅដោយដីតែមែនទេ? លោក
លើកដៃចង្អុលទៅមាត់ភ្នូវ ។

ចៅចត្រងើងរោងទៅមួយស្របក់ ស្ទើរតែមិនជឿត្រចៀកខ្លួនថា
ខ្លួនបានឮអ្វីអស្ចារ្យមិញានេះ កាលបានស្មានតែក៏នុនគ្រាបនោចំពោះមុខ
លោកហ្ជូនថ្លែងពាក្យអរគុណច្រើនជាអនេក ដោយចិត្តត្រេកអរលើស
លុប តែគេមិនអាចពុំពាក្យពេចន៍ដែលចៅចត្រនិយាយថាដូចម្តេចឡើយ
ក្នុងខណនោះ ។

* * *

លុះបានឃុតពាក្យសម្តីរួចរាល់ ក៏ទៅជួបប្រាស្រ័យសួរសុខទុក្ខគ្នាទៅវិញទៅមក ដោយសេចក្តីសិនេហាស្និទ្ធស្នាល ដូចជាបងប្អូនបង្កើតរបស់ខ្លួនដែរ ។ ក្រោយមកទៀត ក៏ចាត់ចែងរៀបចំមង្គលការអាពាហ៍ពិពាហ៍ ជូនដល់បុត្រីរបស់ខ្លួនតាមប្រពៃណីរៀងមក ។ ដល់ថ្ងៃកំណត់ ក៏ចាត់ចែងរៀបចំគ្រឿងសក្ការៈ ដែលសមគួរនឹងយកទៅជូនដល់ឪពុកម្តាយកូនប្រសារ ។ លុះ

រឿងព្រៃនខ្មែរ

និទានមាន់ជ្រាក់

កាលដើមនោះមានបុរសស្រីពីរនាក់ប្តីប្រពន្ធ មានកូនប្រុសពីរនាក់ ជាអ្នកកំសត់ទុគ៌តពិបាកពន់ពេក រកស៊ីគ្មានតែចិញ្ចឹមអាគ្នាត្រឹមល្ងាចរាល់វេលាទៅ ។ លុះដល់ពេលមួយនោះ កាលដែលប្តីប្រពន្ធពាំងពីរនាក់ចូលដំណេកហើយក៏និយាយគ្នាថា សព្វថ្ងៃនេះយើងរកស៊ីតែប្តីប្រពន្ធពីរនាក់នេះត្រួយលំបាកណាស់ ឯកូនប្រុសយើងពាំងពីរនាក់ ក៏មិនជួយរកស៊ីយើងសោះ ក់ចេះតែដើរលេង ចើដូច្នោះ យើងបណ្តេញក់ទៅ ដូច្នេះកុំបាយឲ្យក់ស៊ីគ្នានេះ ឯប្តីប្រពន្ធគិតគ្នាម្ល៉ោះហើយ លុះព្រឹកឡើងកាលណា ក៏ហៅកូនពាំងពីរមកប្រាប់ថា អាក់មកអាយអាពុកនឹងនិយាយប្រាប់ឯងបន្តិច ឯកូនពាំងពីរនាក់យើញម្តាយអាពុកហៅដូច្នោះហើយ ក៏ស្ទុះទៅម៉ែម៉ាស្មានជាម្តាយអាពុកហៅឲ្យចំណីស៊ី លុះដល់កូនពាំងពីរទៅដល់ហើយ ក៏ម្តាយអាពុកនិយាយប្រាប់ទៅថា អាក់ឯងពាំងពីរនាក់ទៅរកបាយស៊ីចុះ អញមិនឲ្យឯងស៊ីទេ ប៉ុន្តែអញអាណិតអាក់ឯងណ្តើយចុះអញឲ្យប្រាក់ឯងមួយឃ្លាទ្រ គ្រាន់ឯងយកទៅទិញអង្ករគេងាំបាយស៊ីខ្លួនឯងចុះ ។

ឯកុមារពាំងពីរនាក់បងប្អូនឮម្តាយអាពុកបណ្តេញខ្លួនដូច្នោះ ក៏ខ្ចួលយកប្រាក់មួយឃ្លាទ្រពីម្តាយអាពុករួចហើយ ក៏ដើរចុះពីផ្ទះនោះទៅ

លុះដើរបន្តិចទៅកុមារប្អូនឃ្លានបាយណាស់ ហើយនិយាយនឹងបងថា អ្នកបងខ្ញុំឃ្លានបាយណាស់ ឯកុមារជាបងឮប្អូនស្រដីថាឃ្លានបាយដូច្នោះហើយក៏ក្តុំយទៅវិញថា អានាងអើយចាំល្ងាចបន្តិចសឹមបងទៅសូមបាយគេឲ្យស៊ី ឯកុមារប្អូនឮបងថាដូច្នោះហើយក៏ស្ងៀមមិនស្រដី ឯកុមារទាំងពីរក៏បណ្តើរគ្នាទៅ ។ លុះដល់ផ្ទះមួយនោះ ក៏ដើរចូលទៅលុតជង្គង់សំពះនិយាយថា ខ្ញុំចាស៎សូមទានបាយលោកពាល់គ្នា ក្រែងលោកណាមានបាយកកបាយក្តាំងសេសសល់ សូមទានលោកបន្តិច ។ ឯអ្នកផ្ទះឃើញក្មេងទាំងពីរនោក់ សូមទានបាយដូច្នោះហើយ ក៏មានចិត្តអាណិតស្រឡាញ់ ហើយសួរទៅក្មេងទាំងពីរថា នែអាក៉ាទាំងពីរនោក់មកពីណា ម្តាយអាពុកគ្មានទេឬ ឯកុមារទាំងពីរនោក់ឮអ្នកផ្ទះគេសួរដូច្នោះហើយ ក៏ឆ្លើយទៅវិញថា ខ្ញុំចាស៎កាលនៅផ្ទះនៅឡើយ ខ្ញុំចាស៎រត់តែរលងទាំងពីរនោក់បងប្អូន ឯអាពុកម្តាយខ្ញុំចាស៎ឃើញខ្ញុំចាស៎រត់លេងដូច្នោះ គាត់ក៏ខឹងគាត់ហៅខ្ញុំចាស៎មកប្រាប់ថា ឲ្យខ្ញុំចាស៎ទៅកចាយគេឯទៀតស៊ីទៅហើយគាត់និយាយថា អញគ្មានចាយឲ្យអាឯងទាំងពីរនោក់ស៊ីទេ ហើយអាពុកខ្ញុំចាស៎ចុនឲ្យប្រាក់មួយចាស៎ ហើយប្រាប់ថាឲ្យខ្ញុំចាស៎ទាំងពីរនោក់យកទៅទិញអង្ករស៊ីចុះ ឯខ្ញុំចាស៎ក៏នាំបងប្អូនបណ្តើរគ្នាមក ។

ឯអ្នកផ្ទះឮក្មេងទាំងពីរនោក់ និយាយដូច្នោះហើយ ក៏អាណិតហើយយកអង្ករមកឲ្យមួយផ្តិល អម្បិលមួយកញ្ចប់ហើយឲ្យចាយទំនុកក្មេង

ចាំងពីរស៊ី ឯកុមារចាំងពីរនាក់លុះស៊ីរួចគាលណាក៏សំពះលាគេទៅ
ហើយនាំគ្នាដើរទៅដល់ស្រុកណា ក៏សួរមកប្តាយគេស៊ីស្រុកនោះតែរឿង
កបដកបទៅ លុះដើរទៅប្រទះនឹងផ្ទះមួយនោះ គេនិយាយគ្នាពីវិធីពាក់
មាន់ ឯកុមារឮគេនិយាយគ្នាដូច្នោះក៏សួរទៅគេថា អ្នកអើយអ្នកមាន
មាន់ជាក់លក់ដែរឬ ឯអ្នកផ្ទះឮកុមារចាំងពីរសួរកេងញាមាន់ជាក់ដូច្នោះ ក៏
ឆ្លើយទៅវិញថា នែកុមារចាំងពីរនាក់ យើងគ្មានមាន់លក់ឲ្យទេ ប៉ុន្តែយើង
ប្រាប់អ្នកឯង ឲ្យអ្នកឯងទៅកេងញាមាន់ជាផ្ទះនៅត្រង់ណោះ ដ្បិតជាផ្ទះនេះ
គេជាអ្នកលេងមាន់ អ្នកឯងទៅរកកេងញាគេចុះ ។

ឯកុមារចាំងពីរនាក់ឮអ្នកផ្ទះគេប្រាប់ដូច្នោះហើយ ក៏លាគេដើរទៅ
ទៀត លុះដើរទៅដល់ផ្ទះជាំនោះ ក៏សួរទៅជាំថា លោកឥពុកឮគេថា
លោកអាពុកមានមាន់លក់មែនឬ ឯជាំឮកុមារថាដូច្នោះហើយក៏ឆ្លើយទៅ
វិញថា ឥមានដែរប៉ុន្តែឥលក់ថ្លៃណាស់ ក្រែងកូនមិនហ៊ានកេងញ ឯកុមារ
ចាំងពីរជាំថាដូច្នោះហើយក៏សួរទៅថា លក់ថ្លៃប៉ុន្មានលោកឥ ឯជាំក៏ឆ្លើយ
ទៅវិញថា ឯមាន់ជាក់ចាប់គេលក់តែមួយចាន ប៉ុន្តែនេះកូនមាន់ឥលក់
ឲ្យឯងតែពីរចាន ។ ឯកុមារឮជាំស្រដីដូច្នោះហើយក៏ឆ្លើយទៅវិញថា ខ្ញុំ
មានតែប្រាក់មួយចានទេ គ្រាន់តែញាំបាយឲ្យឆ្អែតប៉ុ ឯជាំក៏ឆ្លើយទៅវិញថា
បើកូនមានតែប៉ុណ្ណោះ អាពុកនឹងថាអីសឹមអាពុកឲ្យបាយឲ្យអង្ករកូនឯង
ឯកុមារចាំងពីរក៏ឆ្លើយទៅវិញថា បើលោកឥថាឲ្យមាន់ខ្ញុំយកមកម៉ាលម៉ើ

ឯជ្វាក៏ដើរទៅចាប់មាន់នោះយកមកឲ្យកុមារ ឯកុមារបានយើញមាន់ដូច្នោះហើយក៏សួរទៅជ្វាថា លោកឪមាន់នេះវេញហើយឬនៅទេ ឯជ្វាក៏ឆ្លើយថា មាន់នេះវេញហើយកូន ឯកុមារឮជ្វាថាដូច្នោះហើយក៏ឆ្លើយទៅវិញថា បើដូច្នោះខ្ញុំសូមសំណាក់នឹងឪបាទមួយយប់សិន ថាតែម្ល៉ោះហើយក៏ឲ្យគ្រចាក់ទៅជ្វាហើយក៏ដេកនៅផ្ទះជ្វានោះទៅ ។

លុះដល់ព្រឹកឡើងកាលណា ជ្វាក៏រៀបដណ្តាំបាយសម្រាប់ឲ្យកុមារទៅនឹងពីរនោះស៊ីៗរួចហើយក៏ខ្ចប់បាយនឹងត្រីជាអំទៅឲ្យកុមារទៅនឹងព័រនោះក្រួចស្រេចហើយក៏ស្រាយមាន់ហុចឲ្យទៅកុមារ ឯកុមារក៏បានទទួលយកមាន់អំពីជ្វារួចស្រេចហើយ ក៏លាជ្វាដើរចូលទៅកន្លែងព្រៃ ចេញអំពីព្រៃលេចវាលចេះតែដើរទៅ ។ លុះដល់ទៅដើមឈើមួយនោះ ក៏នាំបងប្អូនឈប់សុំបាយលុះស៊ីបាយរួចហើយក៏ប្រុះដេកនៅក្រោមដើមឈើនោះលក់ទៅ ។

ក្នុងវេលាថ្ងៃនោះ ក៏ស្តេចក្រហាយដល់អាសនាព្រះឥន្ទ្រគង់ទៅពុំសុខ ទើបទ្រង់នឹកក្នុងព្រះកដហ្ឫទ័យថា នេះមានហេតុកេរអ្វីបានជាស្តេចក្រហាយដល់អាសនាអញអ៊ីម្ល៉ោះ ទ្រង់ត្រិះរិះតែម្ល៉ោះហើយ ព្រះឥន្ទ្រក៏ទ្រង់មើលទិព្វចក្ខុទតមើលទៅមនុស្សលោកឃើញកុមារទៅនឹងពីរនោះបងប្អូនខ្សឹបត្រួយល់ចិត្តគ្នាស៊ប់ ហើយទ្រង់ព្រះដម្រិះក្នុងព្រះកដហ្ឫទ័យថា បើអញមិនទៅជួយឃើញជាមិនបាន ដ្បិតកុមារទៅនឹងពីរនោះមានបុណ្យមានអំណាច ទ្រង់ត្រិះគិតម្ល៉ោះហើយ ក៏ហៅវិហោរផ្ទុក

ផ្ទោះចុះមក ខ្ញុំឯងតែងើយឃើញកុមារទាំងពីរនាក់ដេកលក់ត្រេកម្ងប់ឈើ ហើយព្រះឥន្ទ្រកំនើតក្តាងអណ្តូងពីរនៅខាងក្បួងកុមារនោះ ហើយខ្ញុំឯងសរសេរអក្ខរនៅមាត់អណ្តូងទាំងពីរ ឯកងសេចក្តីអក្ខរអណ្តូង ១ ថា ឲ្យចុះទៅកងអណ្តូងមេរះនឹងរលាយខ្លួនជាត់ទៅ ឯអណ្តូងមួយទៀតនោះថា បើរលាយខ្លួនជាត់ទៅហើយ ឲ្យយកទឹកពីអណ្តូងនេះទៅចាក់កងអណ្តូងនោះ ទើបជានរស់ឡើងជាមនុស្សវិញ លុះខ្ញុំឯងសរសេរអក្ខរបិទនៅមាត់អណ្តូងរួចស្រេចហើយ ក៏ហៀរហោះទៅស្ថានវិមានរបស់ព្រះអង្គវិញ ។

ឯកុមារដែលដេកលក់ត្រេកម្ងប់ឈើទាំងពីរនាក់នោះ លុះដល់ភ្ញាក់ឡើង នាំចងប្អូនដើរទៅទៀត លុះដើរបានបន្តិចទៅក៏ឃើញអណ្តូងពីរនៅទន្ទឹមគ្នា ហើយក៏នាំគ្នាដើរទៅកាន់អណ្តូងនោះ ប្រយោជន៍ដើម្បីនឹងរកទឹកលុបមុខ ដើរទៅដល់មាត់អណ្តូងនោះកាលណា ក៏ឈ្ងោកមើលទៅឃើញអក្ខរសរសេរបិទនៅមាត់អណ្តូង ហើយដើរទៅអណ្តូងមួយទៀត ក៏ឃើញអក្ខរសរសេរបិទនៅមាត់អណ្តូងដូចគ្នា ។ លុះមើលអក្ខរដឹងសេចក្តីស្រេចហើយកុមារទាំងពីរមកគិតគ្នាថា យើងចង់ចោះមាន់យើងទៅល្បងមើល ឯកុមារប្អូនថា តាមតែអ្នកបងចុះ ខ្ញុំមិនដឹងទេ ឯកុមារបងឮកុមារប្អូនថាដូច្នោះហើយ ក៏ចាប់មាន់ចោះទៅកងអណ្តូង លុះដល់ទៅកងនោះកាលណា ក៏រលាយធ្លុះជាត់ទៅ ឯកុមារទាំងពីរនាក់ឃើញមាន់រលាយជាត់ទៅដូច្នោះហើយ ក៏ទៅដងទឹកពីអណ្តូងមួយទៀតយកមកចាក់ ស្រាប់តែឃើញមាន់រស់ឡើងវិញភ្លាម ។

ឯកុមារពាំនីពីរយើញមាន់រស់ឡើងមានរូបល្អដូច្នោះ ក៏និយាយទៅ
នឹងគ្នាថា បើដូច្នោះអ្នកណាទំងុះទៅមុន ឯកុមារបងធ្វើយឡើងថា មានតែ
ប្អូនចុះទៅមុន សឹមបងចុះទៅក្រោយ ឯកុមារប្អូនឮបងថាដូច្នោះក៏ធ្វើយ
ទៅវិញថា ឯកងឹចាប់មិនដែលប្អូនដើរមុនបងទេ បើដូច្នោះមានតែអ្នកបង
ចុះទៅមុនខ្ញុំទើបបាន ឯកុមារបងឮប្អូនថាដូច្នោះហើយ ក៏ធ្វើយទៅវិញ
ថា បើប្អូនឲ្យបងចុះ មានតែប្អូនយកទឹកអណ្តូងនោះមកចាក់ឲ្យបងផង
កុមារប្អូនក៏ធ្វើយទៅថា បងចុះទៅចុះសឹមខ្ញុំដងទឹកចាក់ឲ្យ កុមារបងឮប្អូន
ថាដូច្នោះហើយក៏លោតចុះទៅកងឹអណ្តូងនោះភាលណា ក៏លោយធ្លុះ
ចាត់ទៅ ឯកុមារប្អូនយើញបងរលាយចាត់ទៅហើយ ក៏ទៅដងទឹក
អណ្តូងតាមឯណេះយកមកចាក់អណ្តូងឯណោះ ក៏យើញបងរស់ឡើង
មានរូបនោះល្អណាស់ ហើយកុមារប្អូននិយាយទៅនឹងបងថា អ្នកបង
ចាក់ទឹកផងប្អូននឹងចុះទៅ ឯកុមារប្អូនថាតែម្ល៉ោះហើយ ក៏លោតចុះទៅ
កងឹអណ្តូងហើយរលាយចាត់ទៅ កុមារបងតាំងស្រែកឲ្យហោយំស្ងាន
ជាប្អូនស្លាប់ លុះយំយូរបានបន្តិចទៅក៏ភ្ញាក់ស្មារតីនឹកយើញឡើងថា ខ្ញុ
មែនហើយអញយំនេះខុសទេតើ គេឲ្យយកទឹកអណ្តូងតាមណោះមក
ចាក់ខាងណេះទើបបានរស់ឡើង កុមារបងថាតែម្ល៉ោះហើយ ក៏ទៅដង
ទឹកអណ្តូងឯណោះយកមកចាក់អណ្តូងឯណេះវិញ ហើយក៏យើញប្អូន
រស់ឡើងវិញ មានរូបឆោមលោមភាណានោះល្អ ហើយនិយាយទៅនឹង

ប្អូនថា ប្អូនអើយយើងល្មមទៅហើយ រីឯកុមារប្អូនក៏ឆ្លើយឡើងថា ល្មមទៅហើយអ្នកបង ហើយកុមារបងប្អូនក៏បបួលគ្នាដើរទៅ ។ លុះដើរយូរទៅកុមារបងនោះមានអាយុបាន ២០ឆ្នាំ កុមារប្អូនអាយុបាន ១៥ឆ្នាំ ទើបកុមារបងនឹងកុមារប្អូននិយាយគ្នាថា យើងបងប់ចាក់ដង់មាន់យើងនេះល្បងមើលឯកុមារពាំងពីរនិយាយគ្នាតែម្ដង់ហើយ ក៏បណ្ដើរបងប្អូនទៅដល់ណាដែលស្ងាត់ឆ្ងាយពីស្រុកពីភូមិគេ ទើបបាននាំចាក់ដង់បងមាន់នោះរួចស្រេចកាលណា ក៏បបួលបងប្អូនពួនចាំមើល ។

ឯមាន់នោះឃើញគេយកខ្លួនទៅបងចាក់ដង់កាលណា ក៏ខន់ស្ងាប ៣ ដងហើយរងាវកុកកេងកែតែត ។ ឪងនិយាយឯកូនក្រមុំចៅហ្វាយស្រុកដែលនៅក្នុងផ្ទះ កាលណាបើបានឮមាត់មាន់រងាវហើយ ក៏ក្ដៅក្រហាយខឹងនៅពុំបាន ឯមាន់ក៏ខន់ស្ងាបរងាវទៅម្ដងទៀត ឯកូនក្រមុំចៅហ្វាយស្រុកឮមាត់មាន់រងាវម្ដងទៀតហើយ ក៏កាន់កូមលើកឡើងកណ្ដៀតហើយក៏ដើរសំដៅទៅមាត់មាន់រងាវនោះ លុះដើរទៅដល់មាត់គ្រែពាំងឪកក៏ឮមាន់រងាវម្ដងទៀរខាងក៏ឈប់ស្ដាប់ ឮជាក់ជាមាត់មាន់រងាវហើយក៏ដើរទៅតាមមាត់មាន់រងាវ លុះដើរបានបន្ដិចក៏ជាប់ឪងដង់កុមារពាំងពីរនាក់នោះ ។

ឯកុមារពាំងពីរនាក់នោះ បានឃើញកូនក្រមុំចៅហ្វាយស្រុកហើយក៏ចាប់នាងនោះយកវល្ងិចងដៃនាងនោះពាំងពីរភ្ជាប់គ្នាស្រេចហើយ ក៏នាំ

ទទួលរង្វាន់ដែលបានតែងរឿងប្លែងឆ្នាំល្អ

តាមសេចក្តីយោសនាចុះក្នុងទស្សនាវដ្តី កម្ពុជសុរិយា កាលពីក្នុងថ្ងៃ ២៣ ខែ មីនា ឆ្នាំ ១៩៤៣, សុំឲ្យអ្នកចេះដឹងខាងខ្មែរ តែងប្រកួតរឿងពិធីបុណ្យចូលឆ្នាំតាមទំនៀមខ្មែរ ហើយបញ្ជូនទៅក្រុមជំនុំវង្ស រួបរួមលទ្ធិទំនៀមខ្មែរ នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ។

នោះកាលពីថ្ងៃ ២៩ ខែ មីនា ១៩៤៣ លោកយោគី ស៊ែត-ខាត់ ធ្វើការនៅក្រសួងសិក្សាធិការ បានតែងរឿងនោះបញ្ជូនទៅឲ្យក្រុមជំនុំៗ ពិនិត្យទៅឃើញថាតែងត្រឹមត្រូវល្អ ទើបសម្រេចឲ្យរង្វាន់ ជាសៀវភៅផ្សេងៗ រួមជាដំណែល ១០រ ០០ ជាស្រេចហើយ ។

អធិបតីក្រុមជំនុំ

ទឹងជួនរង្វាន់យ៉ាងពេញចិត្ត

សូមជូនដំណឹងមកលោក-អ្នកចេះដឹងខាងទំនៀមទំលាប់តាំងពីក្បាលដ្បិត "ក្រុមជំនុំវង្ស រួបរួមលទ្ធិទំនៀមខ្មែរ" នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ក្នុងពេញ ត្រូវការសូមឲ្យអ្នកចេះដឹងតាំងពីក្បាលក្បួនគ្នា អំពីរឿងពិធីបុណ្យដែលគេតែងធ្វើក្នុងទុកាសចេញវស្សា :

១- តិធីបុណ្យចម្រើនព្រះជន្ម ២- តិរីបុណ្យ ៣ យ៉ាង ដែលអ្នកស្រុកខ្លះគេតែងនិមន្តព្រះសង្ឃចុះទៅឆាន់តាមចឹង ហើយមានធ្វើនំផ្ការស្នោរបូរគេនលោកឆាន់ផង ។

របៀបតែងនោះ សូមអធិប្បាយសេចក្តីឲ្យពិស្តារល្អិតល្អសព្វគ្រប់តាំងអំពីដើមរហូតដល់ចប់ គឺ :

១- ទំនៀមបុណ្យនេះមានសំដែងទុកក្នុងគម្ពីរតែម្តាអ្វីដែរឬទេ ?

២- ទំនៀមនេះមានធ្វើមកតាំងពីកាលណា ?

៣- ការធ្វើដូច្នោះ ដើម្បីអ្វី ?

៤- របៀបធ្វើដូចម្តេចខ្លះ ដូចយ៉ាងប្រគំចោះធ្វើដូចម្តេច? កន្ទោងធ្វើពីអ្វី មានលក្ខណៈដូចម្តេច? ហើយមានដាក់គ្រឿងសំណែនអ្វីខ្លះក្នុងកន្ទោងនោះ ? ចូរអធិប្បាយឲ្យសព្វគ្រប់ ។

កាលតែងហើយឲ្យបញ្ជូនទៅក្រុមដំខុំដូចមានខាងលើ យ៉ាងយូរណាស់ឲ្យបានត្រឹមថ្ងៃ ១៥ កើតខែអស្សុជឆ្នាំនេះ ក្រុមដំខុំបានទទួលហើយនឹងពិនិត្យមើល កាលឃើញរបស់អ្នកណាត្រឹមត្រូវល្អនឹងឲ្យរង្វាន់ដល់អ្នកនោះភ្លាម ហើយនឹងប្រកាសផ្សាយដំណឹងតាមកាសែត ។ ឯរង្វាន់នោះមានច្រើន មានតិចតាមសេចក្តីដែលតែងល្អ ឬមិនសូវល្អ ។

ក្រុមដំខុំសង្ឃឹមថា អស់លោកតាំងក្សាយតន់រួសពនតែងមក ដើម្បីខុកជាក្តៅ កិត្តិយសតៈ ៧ ។



ទស្សនាវដ្តី គ្រប់គ្រងដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចោះពុម្ពជាភ្នាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនឥន្ទមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ ហៅ-សុំម អ្នកគ្រូឥតព្រាំ
សិស្សនៅសាលាចាលីជាន់ខ្ពស់

បញ្ជីរឿង

ផ្នែកអក្សរសាស្ត្រ		ទំព័រ
លោកគ្រូព្រះអាចារ្យ ពាង-សុខ .	ជាតកសុភាសិត	៤៥៥
អ្នកអាចារ្យ គឹម-អាន	រឿងព្រះជាទេវអសោកឧបោសថ (តទៅ) . . .	៥០៤
	រឿងព្រេងខ្មែរ: "ខ្ញុំចាន់ខមាន់ឆ្នាក់" (តទៅនិងចប់)	៥២៤
ផ្នែកសាសនា		
ព្រះជាឃ្មាត់ ធម្មប្បញ្ញាញាណ		
សុខ-ហ៊ាន	ធម្មាធិប្បាយ	៥៣៣
លោកគ្រូបៅអធិការជិន-ឆាក់ .	ប្រវត្តិលោកគ្រូបៅអធិការហៅ-ង៉ែត	៥៣៩
ដំណឹងពីក្រសួងធម្មការ	អំពីតាំងបៅអធិការនិងមន្ត្រីសង្ឃ	៥៤៤
— —	អំពីអនុញ្ញាតឲ្យធ្វើបុណ្យបញ្ចុះសីមានៅវត្តនានា	៥៤៩

ឆ្នាំគំរប់ទី ១៩ — លេខ ៩ ខែសេបតេមប្រ៊ី ១៩៤៣ — ជំនៃឡូដាំរ: ១ ឆ្នាំ ១០ រៀល ។

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចេះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនឥតទ្ធមន្តី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ ភៅ-ស៊ុម អ្នកគ្រូតគ្រា
សិស្សនៅសាលាបាលីជាន់ខ្ពស់

បញ្ជីរឿង

ផ្នែកអក្សរសាស្ត្រ		ទំព័រ
លោកគ្រូព្រះអាចារ្យ ញាង-សុខ .	ជាតកសុភាសិត	៤៩៩
អ្នកអាចារ្យ ធឹម-អាន	រឿងព្រះជាទអសោកឧបោសថ (តទក) . . .	៥០៤
	រឿងព្រេងខ្មែរ: "និទានមាន់ឆ្លាក់" (តទកនិងចប់)	៥២៤
ផ្នែកសាសនា		
ព្រះធម្មាធិបតី ធម្មប្បញ្ញាញាណ		
សុិន-ហ៊ាន	ធម្មាធិប្បាយ	៥៣៣
លោកគ្រូចៅអធិការជិន-ខាក់ .	ប្រវត្តិលោកគ្រូចៅអធិការពៅ-ដែត	៥៣៩
ដំណឹងពីក្រសួងធម្មការ	អំពីតាំងចៅអធិការនឹងមន្ត្រីសង្ឃ	៥៤៤
— —	អំពីអនុញ្ញាតឲ្យធ្វើបុណ្យបញ្ចុះសីមានៅវត្តខាង	៥៤៩

ឆ្នាំទំរង់ទី ១៥ — លេខ ៩ ខែសេបតេមប្រ៊ែ ១៩៤៣ — ដំឡៃជាវ: ១ ឆ្នាំ ១០ រៀល ។

KAMBUJASURIYĀ

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire : Khun Nibandhamantri Nhok-Thém, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse : Vénérable Kao-Sim, Surveillant général de l'Ecole Supérieure de Pāli.

TABLE DES MATIÈRES

Partie littéraire

		Page
Vénérable Achar Peang-Sok	Jātakasubhāsita	499
Feu achar Kim-An....	Légende de l'Empereur Açoka (suite)	504
	Conte populaire cambodgien inédit : "Nitéan Mean Thneak" (suite et fin).	524

Partie religieuse

Vénérable Préas Balat Dhammappaññānāna (Soun-Hean).....	Dhammādhippāya.....	533
Vénérable Chau Athikar Chin-Néak.....	Biographie du Feu Chau Athikar Pov-Ngĕt.....	539
Communiqué du Département des Cultes...	Nominations de Chau Athikar.....	544
—	Fêtes des Sima dans diverses pagodes.....	549

15e année — N° 9. Septembre 1943 — Abonnement: un an 10$00.

លោកគ្រូអាចារ្យ ពាង-សុខ ក្រុមជំនុំព្រះត្រៃបិដក

ប្រែខំងរៀបរៀង

ឧក្កមេ អក្កមេតញ្ចំ តសស្ស ចេតំ ឧទោ ឆរោ
ឧ បមាយិតវំ លាតិ សវេ បច្ចានុតប្បតីតិ ។

ប្រែជាពាក្យកាព្យ:

មិនត្រូវគ្រាំការណ៍ណា ដែលអាត្មាគ្រាំមិនបាន
ដូនមិនស្គាល់ប្រមាណ គ្រាំមិនបានចេះតែគ្រាញ ។
មិនលះការណ៍នោះទេ គង់ត្រូវគេនឹងចំផ្លាញ
ដូនជាអ្នកកៀបគ្រាញ គេបំផ្លាញហើយស្ដាយគ្រាយ ។

កច្ឆបជាតក[1]

កាលកន្លងនូវសង់ទៅហើយ កាលដែលព្រះបាទព្រហ្មទត្តកាំពុងសោយរាជ្យក្នុងក្រុងពារាណសី ព្រះពោធិសត្វបានកើតក្នុងត្រកូលសន្ធឆ្នាំងក្នុងភូមិមួយ ធ្វើការងារសន្ធឆ្នាំងចិញ្ចឹមកូនចៅប្រពន្ធ ។ ប្អូនជាក្នុងកាលនោះមានបឹងមួយជាប់ភាក់ខ្ងែជាមួយនឹងនេះ ក្នុងទីជិតនៃក្រុងពារាណសី ។ បឹងនោះជាប្រទេសមានវិការតែមួយជាមួយនឹងនេះក្នុង

---

១ សើរក្នុងកណ្ឌាណាធម្មវគ្គ ទុកនិបាតវណ្ណនា ។

ការលមានទឹកច្រែន ដល់ទឹកតិច ក៏ជាប់ផ្សង់ពីគ្នា ។ ពួកតែនំអណ្តើក តែងដឹងថា កន្លែងនេះនឹងមានភ្លៀងសម្បើ កន្លែងនេះនឹងមានភ្លៀងអត្តខាត់ ។ គ្រានោះពួកតែនំអណ្តើកដែលកើតកន្លែងនោះដឹងថា កន្លែងនេះនឹងមានភ្លៀងអត្តខាត់ ហើយក៏ចេញអំពីចំនោះទៅរកខ្ញុំ កន្លែងដែលទឹកជាប់ជាមួយគ្នា នៅឡើយ ។ ឯអណ្តើកមួយមិនបានទៅ ខ្ញុំនឹងគេ ព្រោះគិតថា ទីនេះជាវាលកូនចៅរបស់អញ ជាទីចំរុងចំរែនរបស់អញ ជាទីដែលមេបាអញធ្លាប់នៅ អញដើរចោលទីនេះមិនបានទេ ។ ដល់កន្លែងរដូវក្តៅទឹកកន្លែងនោះក៏រីងជាប់ ។ អណ្តើកនោះក៏ចូលទៅក្រាំងកន្លែងដ៏ ត្រង់ទីដែលពាងទិសត្បូយកដ៏ស្អិត ។ ពោធិសត្វបង់យកដ៏ស្អិតហើយទៅកន្លែងទីនោះដឹកដីរដាយចបធំ ចំលាយខ្លួនអណ្តើក គាស់អណ្តើកនោះដាយចបហាក់ដូចជាគាស់ដុំដ៏ស្អិតហើយចំលាក់ទៅលើគោក ។ អណ្តើកនោះក៏រងើកឧទានិយាយថា ព្រោះតែអញមិនលះអាល័យពីទីលំនៅ ជាន់តើបពុះប្រទះសេចក្តីវិនាសដល់ម្ល៉េះ ! ។ ថា ហើយក៏ឡើងរួលបានពោលគាថាទាំងនេះថា :

ជនិតំ មេ ភរិតំ មេ ឥតិ បង្កេ អវិស្សយិ
តំ អំ បង្កោ អជ្ឈភវិ យថា ទុព្ភលតំ តថា ។

អញក្រាំងកន្លែងមាក ដោយការយោគយល់កន្លែងចិត្ត
ថាទីនេះឯងពិត ជាកន្លែងអញកើតហើយ

ជាទីចំរើនស្ត គារវាល់ក្រៃមិនមានឡើយ

មរមោកនេះឯងហើយ សង្ឃត់អញ្ជឲ្យវិនាស ។

តំ តំ វចាមិ ភគ្គវ សុណោមាំ វចនំ មម

តាមេ ភ យទិ ភវញ្ញោ សុខំ យត្ថាធិគច្ឆតិ

តំ ជនិតំ ភវិតញ្ញូ រុរិសស្ស បជានតោ

យហិំ ជីវេ តហិំ តច្ឆេ ន ឯតោតមាតោ សិយា ។

បតិត្រលោកភគ្គវ:[1] ខ្ញុំវ:[2] ចំពោះលោក

ខ្ញុំសាញ្ជ្រៃមរមោក សូមលោកស្តាប់ពាក្យខ្ញុំ

ជនបានសេចក្តីសុខ មិនបានធុកក្តីណា

ទីពោះច្រើនបាត់ថា ជាទីតើតទីចំរើន

នៃប្រុសដែលដឹងច្បាស់ តើយល់ណាស់ខ្លួនការកើន

ទីឯការមិនចំរើន ដែលតើតមានដោយជាក់ស្តែង

ម៉ាណាល្មមរស់នៅ គ្រាវែតនៅម៉ៈពោះឯង

មិនត្រូវឲ្យតក្នែង ដែលខ្លួននៅសំឡាប់ខ្លួន ។

អណ្តើកកាលដែលនិយាយជាមួយនឹងពោធិសត្វយ៉ាងនេះហើយ ក៏ស្ងាប់ទៅ ។ ពោធិសត្វយកអណ្តើកពោះ ហើយប្រដុំពួកអ្នកស្រែកចាំងមួល ពួកគេមានមនុស្សចាំងពោះហើយរោលយ៉ាងនេះថា អ្នកចាំងឡាយចូរ

---

๑ ភគ្គវ: ជាឈ្មោះនៃពួកស្នូនផ្ទាំង ។ ๒ ពោល, និយាយ, ស្តី ។

ម្ដេចអណ្ដើកនេះ អណ្ដើកនេះកន្លងកាលភ្លូតត្រឹមធំអណ្ដើកដងវែងតែប៉ុណ្ណេះ
ក៏មិនអាចគាត់អាល័យអំពីលំនៅរបស់ខ្លួន មិនដែលជាមួយនឹងគេ ចាន
ក់ចូលទៅក្រាំងកន្លះដែលខ្ចុះយកដីស្អិត ជួនជាខ្ចុះកាលដែលយកដីស្អិត
ចានចំលាយខ្លាក់ដោយចបដំ ចំលាក់ក់ទៅលើគោក ហាក់ដូចជាចំ-
លាក់ដុំដីស្អិត អណ្ដើកនេះចានធ្វើអំពើដែលខ្លួនធ្វើហើយឲ្យជាក់លាក់
ខ្លីកន្ទួលដោយគាថា ២ ហើយស្ងាប់ទៅ អណ្ដើកដែលតើចពាក្យទេវ-
សេចក្ដីស្ងាប់យ៉ាងនេះ ព្រោះតែអាល័យលំនៅរបស់ខ្លួន អ្នកទាំង
ឡាយសោតកុំដូចជាអណ្ដើកនេះចាប់ដើមអំពីកាលនេះ អ្នកទាំងឡាយ
កុំប្រកាន់ដោយអំណាចតណ្ហា ដោយអំណាចត្រឹង១បកោតនឹងត្រឹង
បរិកោតឡើយ ។ ពោធិសត្វចានឲ្យដម្បូន្មានដល់មហាជនដោយចំនង
ដូចជាចំនងធម៌របស់ព្រះពុទ្ធ ។ ដម្បូន្មាននោះ សាយកាយទៅកន្ល
សកលដងមួយវិញ ចានគង់វង្សទៅអស់កាលចំនួន ៧០០០ឆ្នាំ ។ មហាជន
ចានបិតកន្លងទុក្ខរបស់ពោធិសត្វ ធ្វើបុណ្យមានទានជាដើម ចានចំពេញ
សគ្គបុរី (ត្រកូលរបស់ហានសូតិ) កន្លងកាលទីបំផុតនៃអាយុ ។ ពាំងពោធិ-
សត្វក៏ធ្វើបុណ្យដូចគ្នាហើយចានចំពេញសគ្គបុរីដែរ ។

ចប់ភណ្ឌជាតក ។

សុភាសិត

ធម្មសំវេគកាព្យ ៖

អណ្តើកស្ងាប់ចិត្ត គេភ័យគេគិត រត់ចោលលំនៅ គិតតែដំណើរ
មិនគើចចិត្តទៅ អំពីលំនៅ ទៅខ័ងខ្វែត ។

សួចួលទៅគាំង ក្នុងទ័កំបាំង គឺទ័កន្ទ្រែត កំដរប្រជួន ស្ងាប់
ខ្លួនបង់សឿត ព្រោះតែមិនធ្វែត រកទ័កៀមកក្បាត្ត ។

សន្ធោទកថា ៖

ព្រោះហេតុនោះ ពួកជនដែលចង់បានសេក្តីសុខ ទើសេចក្តីចំរើន
ដើម្បីខ្លួន មិនត្រូវជាអ្នកស្ងាប់ចិត្តទេ គឺត្រូវតែជាអ្នករិះរេកឧបាយដើម្បី
ភៅះខ្លួនចាកបាបត្រូវដែលកំពុងមានដល់ខ្លួន ឬដែលទើមានដល់ខ្លួន
បើមិនដូច្នោះទេ តែងជាអ្នកថ្លស់ឆ្ងោយដូចជាអណ្តើកនោះឯង ។

ពួកអ្នកស្រុកនោះក្នុងប្រទេសនោះ កំតក់ថេតក្តីមានាំគ្នាខិយាយអង្សាថា "ពួកយើងចង់ចាន់ប្រអប់ ៣៦ នោះណាស់ទៅហើយ តែបើដូច្នោះនឹងឲ្យប្រអប់តែមួយមកយើងក៏ចាន់ សូមកុំឲ្យតែសម្លាប់ពួកយើង" ។ គ្រានោះ ពួកយក្សក៏ត្រមតាមសេចក្តីអង្សាហើយប្រគល់ប្រអប់ដែលដាក់ព្រះសារីរិកធាតុនោះឲ្យមួយទៅ ។

មានហេតុដូចមានលើនេះ ព្រះពាសាទើបទ្រង់គ្រាស់ថា "ក្នុងប្រទេសដែលមានមនុស្សច្រើនជាងគេមួយគោដៅ អ្នកចូរកុំឲ្យព្រះចេតិយសារីរិកធាតុឲ្យលើសទៅតាមចំនួនពួកមនុស្សនោះ ក្នុងប្រទេសដែលមានមនុស្សតិចជាងគេមួយគោដៅ អ្នកចូរកុំឲ្យព្រះចេតិយសារីរិកធាតុទៅប្រទេសនោះឡើយ" ។ ទ្រង់មានព្រះបន្ទូលដូច្នេះហើយ ទើបស្តេចយាងចូលទៅវត្តកុក្កុដារាម លុះដល់ហើយទ្រង់យាងទៅជួបនឹងព្រះថេរៈព្រះនាមយស[1] ទ្រង់ប្រណម្យអញ្ជលីនមស្សការហើយគ្រាស់ថា "ឥឡូវនេះ ខ្ញុំមានប្រាថ្នាចង់សាងព្រះស្តូប ៨៤,០០០ ដោយតែដំណាងដំរៀងដាច់ខុសគ្នាមួយដុំ" ។

---

* មហាវង្ស ព្រះយសត្ថេរនេះ លោកជាអធិបតីក្នុងកាលធ្វើឧត្តិយសង្គាយនាឯក្នុងត្រៃត្រឹះទៀងអសោកនេះ តាំព្រះមោគ្គលីបុត្តតិស្សក្នុងដោអធិបតីវិញ ។

ព្រះ ថេរៈថ្វាយព្រះពរតបថា "ប្រពៃហើយ! ប្រពៃហើយ!! មហា-
ភជបើខ្ញុំឆ្កួថ្កាំងទីឆ្នាងព្រះស្តូបចាំងអស់នោះ ឲ្យសម្រេចតែម្តងក្នុង
ពេលមួយដងមួយគ្នា លុះដល់ពេលដែលមហាបពិត្រកំពុងកសាងព្រះ
ស្តូបនោះ អាត្មាភាពទីឆ្ងាំងជួងព្រះអាទិត្យថ្វាយដោយឋាតដៃ សូម
ចេញព្រះពាក្យខ្ញុំញាតទៅក្នុងប្រទេសចាំងអស់ឲ្យបានដឹងថា កុងពេល
ដែលអាត្មាភាពឆ្ងាំងជួងព្រះអាទិត្យដោយឋាតដៃ ត្រូវអ្នកចាំងអស់គ្នា
សាងព្រះស្តូបឲ្យហើយរួចស្មើគ្នា" ។

លំដាប់តពីនោះមក ព្រះថេរៈបានឆ្ងាំងជួងព្រះអាទិត្យដោយឋាតដៃ
ក៏អ្នកខតរចាំងឡើយបានសាងព្រះស្តូបចាំងអស់នោះ កុងពេលមួយដង
មួយគ្នា ត្រង់ប្រទេសក្នុងជម្ពូទ្វីប ការសាងរួចស្រេចអស់ហើយ ពួកអ្នក
ខតរចាំងអស់បានថ្វាយព្រះនាមដល់ស្តេចថា "អសោកធម្មិកភជ" ខ្ញុំ
បានព្យាយាមផ្សាយសេចក្តីក្សេមក្សាន្តជាសុខសួស្តីខ្លួនទៅសព្វសត្វចាំង
អស់នៅលើផ្ទៃនៃភូមិប្រទេស ខ្ញុំបានចារឹកព្រះស្តូបទីឆ្នាងព្រះវិហារចាំង
ឡើយ ក៏សេចក្តីល្អរបស់ព្រះអង្គវិសេសតែចំរើនធំឡើងយ៉ាងឆ្ងាំង ព្រះ
នាមព្រះអង្គថា "ចណ្ឌាសោក" ក៏វិនាសបាត់ទៅ ហើយកុងលោក
ចាំងមូល គេមាំគ្នាហៅព្រះអង្គថា "ធម្មាសោក" វិញ ។

កាលបើព្រះបាទអសោកសាងព្រះស្តូបរួចស្រេចហើយ ខ្ញុំមាន
ព្រះពាក្យថ្លែងថ្លែ សោយបិតសប្បាយរីករាយពន់ពេក ព្រះអង្គមានតួក

សេវកាមាត្យជាច្រើនតាន់តោមរោមជាបរិវារ ស្តេចយាត្រាចូលទៅកាន់វត្តកុតជាកម ទ្រង់ទៅថ្វាយបង្គំព្រះមហាថេរៈហើយត្រាស់សួរថា "តុង ជម្ពូទីបនេះ មានមហាជនជាច្រើន តែតើមានអ្នកណាមួយបានត្រូវទំនាយជាមួយនឹងខ្ញុំដែរឬទេ?"

គ្រានោះ ព្រះយសត្ថេរថ្វាយព្រះពរព្រះមហាក្សត្រយ៉ាងថា "មនុស្សឯទៀតក៏បានពុទ្ធព្យាករជាមួយនឹងមហាបពិត្រដែរ ។ តុងអតីតកាលពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រថាប់ទៅតុងកជាតិនុទ្ធិយានោះ ព្រះអង្គបានផ្តាញ់ខ្លួរៈស្តេចនាគឲ្យចុះចាញ់ព្រះអង្គ ។ គ្រាកាលដែលទ្រង់ប្រថាប់ទៅតុងកជាតិកស្សិរៈនោះ ព្រះអង្គបានញុំាងព្រាហ្មណ-មហាសាលឲ្យចុះចូលព្រះអង្គ ។ គ្រាកាលដែលទ្រង់ប្រថាប់ទៅតុងកជាតិគន្ធារៈនោះ ព្រះអង្គបានញុំាងមនុស្សចណ្ឌាលឲ្យចុះចូលព្រះអង្គ ។ គ្រាកាលដែលទ្រង់ប្រថាប់ទៅតុងកជាតិគន្ធារៈដដែលនោះ ព្រះអង្គបានផ្តាញ់គោឧសុភជាតិងនាគជ ឲ្យចុះចាញ់ព្រះអង្គ លុះព្រះអង្គបានត្រើសរើសមកតិច្ចដូចសំដែងមកហើយនោះ ទើបទ្រង់យាងទៅកាន់ភជាតិមជ្ឈកទៀត ទ្រង់មានព្រះពុទ្ធដីកានឹងព្រះអានន្ទថា "តុងមួយរយឆ្នាំទៀត ភជាតិមជ្ឈកទីនេះមានគហបតីម្នាក់ឈ្មោះគុប្តៈ មានកូនប្រុសមួយឈ្មោះតបុស្សនេះ ប៉ុន្តែភជាមិនមានទ្វត្តឹសមហាបុរិសលក្ខណៈទេ ក៏តថាគតនឹងឲ្យមនុស្សទាំងឡាយដែលថ្វាយចុះចូលដូចជាព្រះពុទ្ធមួយព្រះអង្គដែរ។

ចបគុប្តៈនោះ មិនបាច់ចូលឈានសមាបត្តិ ក៏គង់អាចកំណត់ដឹងចិត្តគំនិត
នៃសត្វលោកបានចំនួនមួយយោជន៍ ណោះនោះទើបបានជាប្រជានៃអ្នក
ទ្រទ្រង់ធម្មវិន័យតាំងអស់ ដោយការរៀបចំឲ្យបានត្រឹមត្រូវចំពោះល្អ
ឡើងត្រប់យ៉ាង ខ្លួនលោកនោះនឹងត្រូវទទួលកិច្ចដែលជានាទីនៃព្រះពុទ្ធ-
ជាម្ចាស់បាន" ។

ព្រះសម្មាសម្ពុទ្ធត្រាស់ទៀតថា "ឥឡូវនេះអ្នក
យើញនៃពានេះកំពុងតែមានព័ណ៌ខៀវស្រស់ខ្លះទេ ?" អានន្ទក្រាបទូល
តបថា "ខ្ញុំព្រះអង្គយើញហើយ" ។

ព្រះពុទ្ធភគវន្តទ្រង់មានព្រះបន្ទូលផ្ទួនទៀតថា "មានក្តីមួយឈ្មោះ
ចុរុម្ពា នឹងមានទីអាស្រមជាស្ថានតាំងនៅក្នុងអរណ្យប្រទេសឈ្មោះ
ខដកដីកា បរិក្ខារដោយផ្ទះនឹងមន្ទីរធំៗដែលជាប្រជានៃទ័កវ្ទូងឯទៀត
តាំងអស់ជាស្រែកដែលគេអាចធ្វើឈានសមាបត្តិឲ្យកើតបាន" ។ ទំនាយ
នោះនឹងទំនាយមហាភដ្ទាំងពីរនេះហើយដែលព្រះពុទ្ធទ្រង់ទាយមក ។

ព្រះពជាទ្រង់ព្រះសណ្តាប់ថេរភាពនេះហើយ ទើបត្រាស់នឹងព្រះថេរៈ
ថា: ព្រះមហាថេរដ៏ចំរើនសុទ្ធអង្គនោះបានចម្រើនឈ្នើងក្នុងលោកហើយឬ ?

ព្រះយសត្ថេរថ្វាយព្រះពរតបថា "លោកចម្រើនហើយ លោកបាន
តាំងបំបាត់បង់នូវតណ្ហាជាគ្រឿងជក់ក្នុងភពទាំងឡាយហើយ បានសម្រេច
ព្រះអរហត្តហើយមានពួកព្រះអរហន្ត ១៨.០០០ ចោមរោមជា

បរិវារនៅលើភ្នំចុឡុមណ្ឌ ក្នុងអារណ្យប្រទេសឈ្មោះនជកដិកា (នោះ) ។
ព្រះថេរៈអគ្គនោះ ចាននសម្រេចព្រះអរហត្តផលព្រមទាំងបដិសម្ភិទា-
ញាណ ដ៏បរិសុទ្ធផុតស្រឹងសាហ្មង លោកដាច់ពីភាពចិត្តនៃពួកបណ្ឌិត,
ពួកអរហន្តខីណាសវទាំងអស់ លោកចាននបើកទ្វារនៃព្រះធម៌ដោយ
ការទេសនារបស់លោក ។ ពួកទេវតា, (នាគ) យក្ស,មនុស្ស (នឹង
ពួកសត្វតិរច្ឆាន) ទាំងអស់សឹងតែចាននចូលក្នុងបុរីវៃវតីអមតមហានិព្វាន
ដោយសារតែគុណគឺខន្តិរបស់លោក" ។

ព្រះរាជាទ្រង់ត្រាស់ទៅនឹងពួកសេនាបតីថា "ចូរអ្នកទាំងឡាយ
ប្រុងប្រៀបឲ្យប្រញាប់ ស្តែមកុនវ្រេលាវេលាព្រមដោយពលថ្មើរជើង
ឥឡូវនេះ ដើម្បីនឹងចាននឃើញព្រះថេរៈទាំងឡាយដ៏ច្រើនពាន់ ដែលលោក
ចាននសម្រេចព្រះអមតមហានិព្វាន ហើយ ព្រះទាំងចាននឃើញព្រះថេរៈ
ចុបគុប្តៈ ដែលលោកចាននផ្តាច់បង់នូវកិលេសវដ្តអស់ហើយនោះផង" ។

ពួកសេនាបតីក្រាបទូលតបព្រះមហាក្សត្រិយ៍ថា "បពិត្រមហាភូ
ន្ទវរោះចង្រ្កិតគេក ចំណែកពួកពលយើងច្រើនណាស់ណាន់តាន់តាប់
គួរតែព្រះអង្គបញ្ជូនពាជនូតម្នាក់ទៅ, ៗទៀមន្តព្រះចុបគុប្តៈនោះមក លោកក៏
គង់តែនឹងនិមន្តមកមិនខាន" ។

ព្រះកជាត្រាស់ថា "ត្រូវហើយ ទៅជួបទំនឹងលោក ព្រោះហេតុអ្វី ព្រោះថាយើងមិនទាន់ឃើញ ណាដែលដូចជាគេថ្ងៃ[1] (វេជ្ជ) ទៅឡើយ យើងមិនគួរបន្ទោកមនុស្សដែលមានតាតដូចជាព្រះពុទ្ធនោះទេ" ។ គ្រានោះ ព្រះអង្គទ្រង់បញ្ជូនកជនតូចឲ្យទៅទូលព្រះវេរៈចបគុប្តថា "បពិត្រព្រះវេរៈ ពេលនេះខ្ញុំមានត្រាថ្នាចង់ទៅជួបទំនឹងលោកម្ចាស់ ចង់សាកបួរប្រស្នាទំនឹងលោកម្ចាស់ផង" ។

លុះកជតូចទៅគាចទូលព្រះវេរៈដូច្នោះហើយ ក៏ព្រះវេរៈត្រិះរិះថា បើប្រសិនជាអាត្មាអញបណ្តាយឲ្យស្តេចយាងមកក្នុងនគរនេះ ច័ដ្ឋកំចង្រៃតពេក ហើយពួកមហាជនក៏ត្រេកត្រអាលចុះកណាស់ផង គួរតែអាត្មាអញចូលទៅឯព្រះពុទ្ធដំណាក់វិញទើបស្រួល" ។ ព្រះវេរៈចាត់ការប្រមូលខ្លួកចំនួនតាមជាកន្សែន ដើរនំខ្លួយចំនួន ១២ យោជន៍ លោកឡើងដើរលើខ្លួកយ៉ាងនោះ ព្រមទាំងព្រះអរហន្ត ១៨.០០០ ក៏និមន្តចូលទៅកាន់ក្រុងចាជលិបុត្រដោយព្រះកិត្តិយសដ៏រុងរឿង គ្រានោះ មានកជបុរសម្នាកចូលទៅគាចទូលព្រះមហាក្សត្រយ៉ាងថា :

ព្រះវេរៈចបគុប្តៈនិមន្តមកដល់ហើយ ដើម្បីសេចក្តីចំរើនទំនឹងជា

---

១ ក្នុងអយុ - វិស្ស-កិនិ: ត្រាថ្នាព្រះចបគុប្តៈមុតស្មើចជាពេជ្រ ។ ក្នុងទិវ្យាទានខ្លួនព្រះចបគុប្តៈជាវិការនៃពេជ្រ ។

ប្រយោជន៍ដល់ព្រះពុទ្ធសាសនា ។ ក្នុងអាយុ៤រយឆ្នាំ ក្រោយ
ព្រះពុទ្ធនិព្វាន ។ ក្នុងអាយុ៥រយឆ្នាំ ក្រោយព្រះពុទ្ធនិព្វាន ។
ក្នុងអាយុ៦រយឆ្នាំ ក្រោយព្រះពុទ្ធនិព្វាន ។ ក្នុងអាយុ៧រយឆ្នាំ
ក្រោយព្រះពុទ្ធនិព្វាន ។ ក្នុងអាយុ៨រយឆ្នាំ ក្រោយព្រះពុទ្ធនិព្វាន ។
ក្នុងអាយុ៩រយឆ្នាំ ក្រោយព្រះពុទ្ធនិព្វាន ។ ក្នុងអាយុ១ពាន់ឆ្នាំ
ក្រោយព្រះពុទ្ធនិព្វាន ។ ក្នុងអាយុ១ពាន់ឆ្នាំ ក្រោយព្រះពុទ្ធនិព្វាន ។
ក្នុងអាយុ១ពាន់

ចូរមកដួចជុំរួបរួមគ្នាចាំងអស់ក្នុងទីនេះហើយយើងទៅដួចនឹងព្រះថេរអង្គ
នោះចាំងអស់គ្នា" ។

កាលព្រះបាទអសោកបានសួត្រតាថាប្រកាសដូច្នេះហើយ ទ្រង់
ចាត់ការឲ្យរៀបចំតាក់តែងនឹក្រុងនឹងឲ្យលាងសំអាតត្រង់ផ្លូវចាំងអស់
ហើយ ព្រះអង្គមានពួកសេវាមាត្យ នឹងពួកអ្នកនគរាមហាមមោម
កេមស្តេចទៅ ព្រមដោយក្ងេងត្បូរត្រនុំនឹងត្រែងត្រអូបមានគន្ធពីរោះ
ឈ្ងុយឈ្ងប់ត្រប់ឃ្នាង ស្តេចយាងចេញចាកក្រុងបាដលិបុត្រទៅតាមលំ-
ដាប់មាគ៌ា ទៅដល់ទីចំនួនកន្លះយោជន៍ ។ ព្រះអង្គទតឃើញព្រះថេរ
មានព្រះអរហន្ត ១៨.០០០ អង្គ់ចោមរោមហែជាដួរចាំងខាងស្តាំចាំងខាង
ឆ្វេង ហាក់ដូចជាដួងអង្គារចន្ទ្រ (ព្រះចន្ទ្រមួយចំហៀង) ។ ពេលនោះ
ព្រះពជាបុះចាកព្រះទីនាំងដំរីស្តេចយាងដោយព្រះបាទទៅកាន់ប្រាង្គនៃ
ព្រះអង្គទ្រង់ឈានព្រះបាទម្ខាងទៅលើនាវ ព្រះបាទម្ខាងស្ថិតនៅលើ.
ផែនដីទ្រង់ទទួលព្រះមហាថេរថ្នាក់ថ្នមដោយព្រះហស្ត នាំឡើងមកលើ
នោកហើយក្រាបថ្វាយបង្គំដោយគោរពប្រកបដោយអង្គ ៥ មានព្រះកាយ
ផ្កាល់នឹងផែនដី ព្រះអង្គជម្រាបព្រះបាទព្រះថេរ:[1] ហើយ ទតសំឡឹងមើល
ដោយគោរពចំពោះព្រះភក្ត្រនៃព្រះមហាថេរលើកព្រះហស្តឡើងប្រ-
ណម្យត្រាស់ថា :

---

១ ក្នុងទិវ្យាវទាន នឹងអាយុវង្សកិត្តិ: លិខិតនូវព្រះបាទចាំងតូរដោយព្រះដិវ្ជ ។

" ឥឡូវនេះ ខ្ញុំបានបង្ហើបសំឡេងត្រែរួចស្រេចហើយ ខ្ញុំបានធ្វើជម្ពូបដែលប្រដាប់ដោយវិក្រឹតភ្នំ, មហាសមុទ្រ, តារាគណ, សម្បុរទន្លេធំ, មនុស្សពួកទៅក្នុងលោកទាំងមូលឲ្យទៅក្រោមអំណាចខ្ញុំហើយ ។ តុមហាថេរៈ! មិនមានពេលឯណាដែលសប្បុរសកែកយកទន្លេងហួសទៅហើយ តាំងប៉ុន្មាន ឲ្យមានសទ្ធាក្លាហានកែកយចិត្តដូចជាយើញលោកម្ចាស់ឆ្លាស់ទីធំចក្កវត្តកាលឥឡូវនេះឡើយ ព្រោះហេតុអ្វី? បពិត្រព្រះមហាថេរ ព្រោះថាយើញលោកម្ចាស់ក្នុងពេលនេះដូចជាយើញព្រះសម្មាសម្ពុទ្ធដែរ " ។

ដោយព្រះសទ្ធាជ្រះថ្លាតែតាស់ក្នុងខ្លួន ហើយសេចក្តីគោរពចំពោះព្រះរតនត្រ័យក៏កាន់តែចំរើនឡើង ព្រះអគ្គទេវបុត្តធំបន្ទូលតាមថាតទៅនេះថា :

" តុព្រះថេរៈ! ទុកជាព្រះពុទ្ធព្រះអង្គនោះចូលបរិនិព្វានហួសទៅហើយ តែធំជាងលោកម្ចាស់ដែលមានព្រះជន្មនៅដាច់ខ្លួនស្មង់ព្រះអង្គ ។ តុព្រះថេរៈ! ព្រះពុទ្ធជាអាទិត្យវង្សធំអស្ចារ្យតទៅ លោកម្ចាស់ប្រាថ្នាខ្លួនស្មើនោះធ្វើទិក្ខិណាយុទ្ធរឿងឡើង ឥឡូវនេះ ខ្ញុំសូមឲ្យលោកម្ចាស់ឲ្យតាមនាក់ចង់ល់ខ្ញុំ។ ខ្ញុំនឹងប្រតិបត្តិតាមនាក់នោះ " ។

គ្រានោះ ព្រះថេរៈស្តាប់អង្វែលព្រះសំរែព្រះមហាក្សត្រាធិរាជដោយព្រះហស្តខាងស្តាំហើយថ្វាយព្រះពរតបដោយគាថានេះថា :

សូមព្រះអង្គកុំប្រមាទ សូមខ្ញុំតាំងព្រះពាជហឫទ័យភ័យខ្លាច (សេចក្តីខ្លុកខ្លាចរដ្ឋសង្ឃ) សូមខ្ញុំប្រយ័ត្នកុំបន្ទរបន្ទោយ! ភាពជាស្តេចត្រមាំងព្រះពាជខ្ញុំឲ្យជារបស់មិនជាយនឹងគ្រប់គ្រងទេ គ្រប់ៗគ្នា ត្រូវតែពឹងព្រះនិព្វាន ។ លោកនេះមិនមែនតាំងនៅទៀងទាត់ទេ ព្រះរតនត្រ័យក៏ជាវត្ថុមិនជាយនឹងបានជួបប្រសពេទេ បើបានជួបប្រសពហើយ សូមខ្ញុំគោរពប្រតិបត្តិជានិច្ចកុំខាន ។

"បពិត្រមហាពាជ សម្តេចព្រះសម្មាសម្ពុទ្ធខ្ញុំប្រទានឱ្យព្រះអង្គរក្សាព្រះធម្មវិន័យជាមួយនឹងអាត្មាភាព យើងគួរធ្វើសេចក្តីព្យាយាមជាមួយគ្នា ដើម្បីថែរក្សាគ្រប់គ្រងទុកឲ្យហ្មត់ចត់នូវខ្ញុំឲ្យជាមគ្គផលព្រះមុគ្គប្រទានឲ្យ" ។

ព្រះពាជាបានត្រាស់នូវគាថានេះទៀតថា:

"ការដែលព្រះពុទ្ធជាគ្គារៈឱ្យខ្ញុំនោះ ខ្ញុំបានប្រតិបត្តិតាមស្រេចហើយ ខ្ញុំបានប្រជាប់តាក់តែងប្រឹងតាមណ្ឌលដោយព្រះស្តេចនឹងព្រះវិហារដ៏វិចិត្រដូចជាគារណ្យប្រទេសដ៏ដេរដាសៅដោយកុំតាំងឡាយ ខ្ញុំប្រកបដោយសទ្ធាចិត្តបានតាក់តែងព្រះស្តេចតាំងនៅ ដោយខ្ពង់ជាយ, ខ្ពង់ជ្រងនឹងសួតច្នៃត្រដ៏មានដំឡៃ ហើយខ្ញុំបានរំលេចក្បាច់រចិត្រដោយរតនវត្ថុដ៏ច្រើនក្រៃពារ ។ ដើម្បីនឹងធ្វើប្រជាប់ឱ្យបរិសុទ្ធល្អរុងរឿងរៃថ្ងៃថ្លា បំធុតរហូតពេញតាំងដែនប្រឹងពី ខ្ញុំបានបញ្ចុះព្រះសារីរិកធាតុក្នុងជម្ពូទ្វីប

ជាច់ខ្លួនឯង ។ ខ្ញុំ, ភរិយា, បុត្រធំធីតា ឈោងឆ្នាមរោះ (ឃ្លាំង) ព្រះរាជកំដរធំធីតព្រះរាជដំណាក់, ប្រជាជនជាចំណុះខ្ញុំព្រមទាំងផ្ទៃនៃផែនដីទាំងមូល ខ្ញុំសូមវេរប្រគេនទូវាត្តុទាំងអស់នោះដោយគោរពចំពោះទៅព្រះពុទ្ធ ព្រះធម្មនិងព្រះភិក្ខុសង្ឃ" ។

ព្រះថេរៈថ្វាយព្រះពរសរសើរថា: ប្រពៃហើយ! ប្រពៃហើយ! មហាពាជ! ទ្រង់ធ្វើដូច្នោះគួរហើយ ។ លើនឹងប្រែបធ្មឹមគ្នាដោយពាក្យ ដោយដីរតប្តដោយទ្រព្យសម្បត្តិនោះ(១) ព្រះធម្មវិថ្លាសតាពរ៍ធំបុំងមាំមួនបំផុត ហេតុនេះបានជាគេលះបង់ឥតស្ដាយ (របស់ទាំងនោះ) ហើយគេបានទៅកើតក្នុងទេវលោក ។

ព្រះថេរៈថ្វាយព្រះភរយ៉ាងនេះហើយ ក៏ព្រះរាជាទ្រង់និមន្តព្រះថេរៈឲ្យចូលទៅក្នុងព្រះបរមរាជវាំង ទ្រង់ចាត់ឲ្យរៀបចំវ (រៃតស្នែង) ហើយលើកព្រះថេរៈដោយកំភ្លាំងព្រះពាហារបស់ព្រះអង្គឲ្យគង់លើវរោះនោះ កាយរបស់ព្រះថេរៈមានសម្ផស្សដ៏ទន់ត្រជាក់ដូចជាសំឡី ព្រះរាជាប្រណម្យអញ្ជលីហើយត្រាស់នឹងព្រះថេរៈថា: កាយរបស់ព្រះថេរៈទន់ដូច

---

(១) តាមសៀវភៅលោក ប៊ួរណូហ្វ នៃលេខ ចិមកពី អាយុវាសូកិន បុគ្គលដែលទុន្មានកាលកាយរបស់ខ្លួនក្នុងសេចក្ដីចំរើនដ៏ល្អ ទឹងប្រើវត្ថុជាគ្រឿងទំនុកបំរុងនិស់ការចិញ្ចឹមដ៏វិសេសបបូរ បុគ្គលនោះទឹងមិនសោយសោកក្នុងពេលជាទីស្លាប់ដោយតតិដ៏អក្រក់ ហើយទឹងទៅកាន់ទេវលោកនៃលជាទីប្រាថ្នា (របស់ខ្លួន) ។

ជាសំឡឹ ឯខ្ញុំដែលមានកុសលតិចតួចស្លុចរស្មីដ៏តាយរបស់ខ្ញុំគ្រាត
នត្រឹមមានសម្ផស្សដ៏រឹង" ។

ព្រះថេរៈថ្វាយព្រះពរថា: "កាលពីអតីត អាត្មាភាពបានធ្វើគ្រឿង
សក្ការបូជាតែវត្ថុដែលបរិសុទ្ធស្អាតរកអ្វីប្រៀបមិនបានជានិច្ច អាត្មាភាព
មិនបានចាត់ចែងដុំដំដើម្បីធ្វើគ្រឿងសក្ការបូជាឡើយ" ។

ព្រះមហាកស្សបត្ថេរ៍តាស់តបថា "កាលព័អតីតខ្លួនខ្ញុំជាភរកជា
មនុស្សស្លូតត្រង់តែល្ងង់ខ្លៅ ខ្ញុំបានដួចនឹងព្រះពុទ្ធកតវ័ដែលជាបុញ្ញក្ខេត្ត
ឥតខ្ចោះដែរ ឲ្យត្រឹមស្មើហើយខ្ញុំបានថ្វាយដុំដីដល់ព្រះអង្គ ព្រោះវិបាក
នៃកម្មរបស់ខ្ញុំខ្លោះ ទើបបានមកជាយាំងនេះឯង" ។

ព្រះថេរៈជ្រាបថ្នាំងចំបាត់រឿងដ៏សាវ័រយរបស់ព្រះរាជា ទើបសំដែងទឹក
ព្រះភក្ត្រពាក់ពាក់ស្រស់ស្រាយហើយថ្វាយព្រះពរថា: "លោកដែលជា
បុញ្ញក្ខេត្តឥតខ្ចោះដែរឲ្យត្រឹមស្មើ សូម្បីថ្វាយតែដុំដីក៏អាចធ្វើផលឲ្យ
សម្រេចបានថ្កើងរុងរឿងរៃថ្ងៃថ្ងាយ៉ាងនេះ" ។

ព្រះរាជាកាលបានឮព្រះសណ្ដាប់ន្ទូវថេរ៍ចាខ្លោះហើយព្រះអង្គ
មានព្រះរាជហឫទ័យសប្បាយរីករាយ ដោយមិនឆ្អែបបានដួចប្រទះរាសី
នេះឡើយ, ទើបទ្រង់អនុញ្ញាតឲ្យដល់ពួកសេនាបតីថា:

"ព្រោះតែខ្លួនខ្ញុំបានធ្វើទានដោយដុំដី ទើបខ្ញុំបានជាស្តេចចក្រពត្តិ

បើដូច្នោះត្រូវតែយើងនាំគ្នាមានចិត្តព្យាយាមធ្វើសក្ការបូជាដល់ព្រះតេន-
ត្រ័យ" ។

ព្រះមហាកស្សបត្ថេរជាស់ទីនឹងព្រះថេរៈថា: "ក្នុងកន្លែងដែលជាទី
គោចរនៃព្រះពុទ្ធ ទីស្ថានដែលព្រះអគ្គបុគ្គលបានយាងទៅ ហើយនឹងទ្រង់អា-
ស្រ័យនៅតាំងប៉ុន្មាន ខ្ញុំប្រាថ្នាចង់សាងព្រះស្តូបបូជាគ្រប់ទីស្ថាននោះៗ
ឲ្យបានសព្វអន្លើ ព្រោះហេតុអ្វី? ព្រោះថាសម្រាប់ពួកសត្វណាអ្នកមាន
សទ្ធាជ្រះថ្លាគោរពនមស្សការតទៅក្នុងអនាគត" ។

ព្រះថេរៈថ្វាយព្រះពរសេរសើរកុសលនោះ "ប្រពៃហើយ! ប្រពៃ
ហើយ! មហាពជ! ឥឡូវនេះត្រូវអាត្មាភាពទៅបង្ហាញទីស្ថានតាំងនោះ
ថ្វាយព្រះអង្គ" ។

ព្រះបាទអសោក បានទ្រង់នាំគ្រឿងសក្ការបូជាគឺសុគន្ធបុប្ផា, ផ្លូង
ខាលគ្រឿងក្រអូបនឹងគ្រឿងលាបជាច្រើនយ៉ាងប្រគេនដល់ព្រះឧបគុប្ត-
ថេរទ្រង់ប្រដុំចតុរង្គិនីសេនាសព្វគ្រប់ហើយ ស្តេចយាងហែហមព្រះឧប-
គុប្តថេរៈ ចូលគាន់សួនលុម្ពិនី ព្រះថេរៈបាននើកព្រះហស្តចង្អុលបង្ហាញ
ព្រះមហាកស្សបត្ថេរថា:

"ត្រង់ទីនេះហើយព្រះអង្គ ជាស្ថានដែលព្រះពុទ្ធប្រសូតចាកព្រះ
ឧទរព្រះមាតា" ។ ព្រះស្តូបនេះគេបានសាងមុនជាងបង្អស់បំផុត គឺត្រង់ទី
នេះហើយ ដែលព្រះពុទ្ធជាឯកអគ្គបុគ្គលបានទ្រង់ព្រះដំណើរ ៧ ជំហាន

ក្នុងវិថីដែលប្រសូតនោះ ព្រះអង្គទ្រង់ទស្សនាការតែប់ចំណែកនៃទិសទាំង ៤ ហើយលើកព្រះហស្តឡើងបន្ទឹងទាន់ថា: "នេះជាកតាអង្គ ក្រោយបំផុតរបស់យើងហើយ" ។

លុះទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ព្រះមហាកស្សបក៏ងាកផ្តេ ស្តេចឆ្ពោះតែពុំនៃអញ្ជលីប្រណម្យឡើងបែកបរដោយបញ្ចង្គប្រតិស្ឋាន ក្រាបផ្ងាល់ចុះលើផែនដីដោយសេចក្តីគោរព លើកព្រះហស្តឡើងប្រណម្យស្តេចទ្រង់ព្រះពិលាបហើយត្រាស់ព្រះគាថានេះថា:

"បុគ្គលឯណាអ្នកបានឃើញព្រះមុនីកតវ័តប្តុំនោះសោតអ្នកបានឃើញព្រះពុទ្ធ កាលដែលព្រះអង្គស្តេចមកកាន់លោកនេះ ទំនងអ្នកដែលបានស្តាប់ព្រះសូរសៀងដ៏ពីពេរបស់ព្រះអង្គ ពួកបុគ្គលនោះរមែងបានបុណ្យដ៏ទុត្តម ហើយបានផលប្រយោជន៍ដាទីក្សេមក្សាន្តចិត្ត ។ ខ្ញុំនឹងជាមនុស្សឥតវាសនាដ៏ខ្ពង់ខ្ពស់ ខ្ញុំមិនបានឃើញព្រះកតវ័ត ខ្ញុំមិនបានឃើញគាកាលព្រះអង្គប្រសូត ទាំងមិនបានស្តាប់ព្រះសូរសៀងដ៏ពីពេរបស់ព្រះអង្គ" ។

"គ្រានោះ ព្រះឧបគុប្តថេរ ចង្អុលបង្ហាញព្រះឋវិរក្ស្តែយ៍ត្រង់ស្ថានដែលព្រះនាងមាយាទេវីឈានចាប់មែកឈើហើយប្រសូតព្រះពោធិសត្វមក ព្រះថេរៈលើកប្រហស្តឡើងប្រកាសប្តូងសួងរុក្ខទេវតា លោកអ្នកដែលបានឃើញព្រះពុទ្ធឥឡូវនេះ ត្រូវអ្នកសំដែងកាយរបស់អ្នក

ឲ្យ[illegible]ដង្ហើមបង្ហាញ[illegible]មហាកប្បត្រិយ៍ ដើម្បីឲ្យស្តេចបានឃើញខ្លួនអ្នក ឲ្យព្រះអង្គខ្ញុំមានព្រះពុទ្ធសទ្ធាជាស់ក្នុងព្រះសាសនាទៀត" ។

គ្រានោះ រុក្ខទេព្តាសំដែងកាយចេញមក ព្រះថេរៈទេបត្តុប្ផៈថ្វាយព្រះពរស្តេចថា. "រុក្ខទេព្តានេះ បានឃើញព្រះពុទ្ធគ្រាកាលព្រះអង្គប្រសូតចាកព្រះទេវព្រះមាតា" ។

គ្រានោះ ព្រះកស្សបទសពលប្រណម្យព្រះហស្ត យាងប្រទក្សិណរុក្ខទេព្តាហើយត្រាស់គាថានេះថា :

"អ្នកបានឃើញព្រះអគ្គបុរសប្រកបដោយសុភលក្ខណ៍ដ៏ស្រស់បញ្ចង់កន្លងពេលដែលទ្រង់ប្រសូតចាកព្រះទេវ ព្រះអង្គមានព្រះកាយប្រកបដោយអាការៈទីឯអនុព្យញ្ជនៈ អ្នកបានឃើញព្រះនេត្រដ៏រៃឯខ្លាយដូចជាត្របកនៃផ្កាទន្សែដែរឬ ? អ្នកបានឮព្រះវាចាដ៏ទន់ពីពោះវបស់ព្រះវរបុរស ដូចជាសំឡេងនៃគោទសកកដនោះដែរឬ ?"

គ្រានោះ រុក្ខទេព្តា កាលដែលទទឹងខ្លួនតបមកវិញបានពោលនូវគាថានេះថា :

"ខ្ញុំបានឃើញព្រះអគ្គបុរសព្រះអង្គមានសម្បុរភ្លឺស្រស់ដូចជាតណាំនៃមាសដ្ឋិន ព្រះអង្គប្រសើរបំផុតជាងសត្វទ្វិបាទចាំងឡាយ ទ្រង់បានលើកព្រះបាទឈានទៅ ៧ ជំហាន ខ្ញុំបានឮស្តាប់ព្រះសូរសៀងវបស់ព្រះកតតែត (នោះផង)" ។

ព្រះមហាកិរ្តិត្រីយ៍គ្រាស់សួរតទៅទៀតថា : "កាលដែលព្រះអគ្គបុរសទ្រង់ប្រសូតព្រះអង្គប្រកបដោយសុភលក្ខណ៍ដូចម្តេចខ្លះ?"

រុក្ខវេដ្ឋាតបថា "ព្រះអង្គមានព្រះសូរសៀងមិនអាចនឹងអធិប្បាយប្រាប់ឲ្យច្បាស់លាស់កើតឡើយ ពាក្យពេចន៍ទាំងនោះមិនអាចនឹងសំដែងពន្យល់គ្នាបានទេ តែឥឡូវនេះខ្ញុំព្រះអង្គនឹងទូលដោយសេចក្តីបំប្លែញ ។ គ្រានោះ រុក្ខវេដ្ឋាពោលទូវគាថានេះថា :

"ព្រះកាយរបស់ព្រះអង្គភ្លឺស្រស់បញ្ចង់រុងរឿងពណ្ណពេញដោយរស្មីនៃពណ៌មាសមុខគួរអស្ចារ្យ ពួកមនុស្សនឹងទេវតាបានសោយបីតសប្បាយរីករាយដោយបានឃើញច្បាស់នឹងភ្នែក ឯរៃនៃប្រឹថពីត្រមាំងបពិតាំងឡាយ ក៏កក្រើករំភើបញាប់ញ័រ "រហូតចុះមកដល់ឆ្នេរនៃមហាសមុទ្រ ហាក់ដូចជាខាងត្រែវិលកាចាកមកគ្រាត្រែងទៅកណ្តាលសមុទ្រ" ។

ព្រះកាឡាបានបូជាទេព្យមួយសែនដង្ហឹងមាសទ្រង់ចាត់ឲ្យសាងព្រះស្តូបមួយនៅត្រង់កន្លែងនោះហើយ ទើបស្តេចយាងចេញទៅទៀត ។

ព្រះថេរៈបាននាំស្តេចតអំពីវិនោះទៅកាន់ក្រុងកបិលពស្តុដ៏ខ្ពង់ខ្ពែនេះ លោកបានលើកព្រះហស្តខាងស្តាំឡើងថ្វាយព្រះពរថា; "ត្រង់ស្ថានដ៏នេះហើយព្រះអង្គ ដែលគេថ្វាយព្រះបរមពោធិសត្វដល់ព្រះបាទសុទ្ធោទន" ហើយនាំទៅបង្ហាញមន្ទីរដែលគេសំកប់ធ្វើសក្ការបូជាដល់ទេវតាជារបស់

ទៃសាក្យ តែធំគ្រាន់តែនាំព្រះបរមគោធិសត្វចូលទៅដេម្បីគោរពដល់ទេវ-
រូបចាំងនោះ តែទេវរូបចាំងនោះដែលគេធ្វើអំពីឈើទំនឹងដ៏ឥន្ធ ក៏ត្រឡប់
ជាវិលចុះមកធ្វើគោរពនមស្សការលុតជង្គង់ចុះ ក្នុងទីចំពោះ
ព្រះភក្ត្រព្រះពោធិសត្វវិញ ។ ព្រះបាទសុទ្ធោទនជាបហេតុដូច្នោះ
ទើបប្រាប់ព្រះមាមថា; ទេវតាកង្ខពួកនៃទេវតា(១)" ។

ឥតីនោះមក ព្រះថេរៈបានបង្ហាញស្ថានទីដែលគេបានប្រជុំពួក
ព្រាហ្មណមហាសាល ដើម្បីទំនាយលក្ខណៈព្រះពោធិសត្វហើយបាន
បង្ហាញស្ថានទីដែលអសិតតាបស(២) បានពិចារណាមើលលក្ខណៈព្រះ
ពោធិសត្វហើយយល់ឃើញថាទំនឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គជាប្រា-
កដ ។ លំដាប់ពីនោះមក ព្រះថេរៈបានបង្ហាញព្រះពាយ៉ាតធំស្ថានទីដែល
ព្រះនាងមជ្ឈបតិចាំមើរក្សាព្រះពោធិសត្វ ហើយបង្ហាញស្ថានទីដែល
ព្រះពោធិសត្វបានសរសេរអក្សរ; ក្នុងទីដែលព្រះពោធិសត្វហាត់ឡើង
គង់យានដំរី; ស្ថានទីដែលព្រះពោធិសត្វហាត់ឡើងគង់យានសេះ; ស្ថាន
ទីដែលព្រះពោធិសត្វហាត់ឡើងគង់ព្រះពន្លាថ; ស្ថានទីដែលព្រះពោធិ-
សត្វហាត់ជាញាធ្ងូ; ស្ថានទីដែលព្រះពោធិសត្វសំណាក់អាស្រ័យ; ស្ថាន

---

១ ចិត្តវៃគោទ: ទេវតាំទេវ: អាយុ - វែង: កិត: ទេវតាក្រៃលែងជាងទេវតាទាំងឡាយ ។
២ បរិមសរណ្ដោធិ, ពាលទេវិលពាលស ។ អសិត: ប្រែថាមិនស; ពាឡ: ប្រែថាខ្មៅ ជាល្មោះ
ល្មងដំខ្លួសឆ្នាំជាន ។

ទីដែលព្រះពោធិសត្វទ្រង់ប្រថាប់ជាទីស្រស់ស្រាយជាមួយនឹងពួកស្រីតាំង ៦ ម៉ឺន ; ស្ថានទីដែលព្រះពោធិសត្វទ្រង់រំពឹង (ដល់លោក) ដោយទ្រង់ឃើញមនុស្សចាស់, មនុស្សឈឺ, មនុស្សស្លាប់, នឹងជាតិកំណើតហើយទ្រង់យាង (ជាមួយនឹងព្រះបិតា) ទៅកាន់អារម្យប្រទេស ។

តពីនោះមក ព្រះថេរៈបានទាំស្ដេចទៅកាន់ដើមជម្ពូព្រឹក្សហើយលើកព្រះហស្តឡើងចង្អុលបង្ហាញថា: គឺត្រង់ស្ថានទីនេះហើយមហាពោធិដែលព្រះពោធិសត្វទ្រង់ប្រថាប់នៅក្រោមម្លប់ឈើ , ដោយវិធីរំពឹងគិតពិចារណា ព្រះអង្គ ដើម្បីរំលែកខ្លួនចេញចាកកាមតណ្ហា ,ចាកពុតកំណាចនឹងអំពើដ៏លាមក ព្រះអង្គបានយល់ជាក់ស្តែង (ថាជាទោស) ទើបទ្រង់តាំងនៅក្នុងសមាធិ (អានាបានស្សតិកម្មដ្ឋាន) ហាក់ដូចជាមិនមែនកុមារគួបស្ដេចចូលកាន់បឋមជ្ឈាន ទ្រង់សោយខ្យល់វិមុត្តិសុខ ជាទីសប្បាយក្នុងឈានខ្លះ ។ ខណៈនោះម្លប់នៃឈើឯទៀត ក៏រំលេចទៅតាមមណ្ឌលព្រះអាទិត្យ តែម្លប់ជម្ពូព្រឹក្សនោះ មិនបានលះចេញព្រះពោធិសត្វទៅឡើយ ។ គ្រានោះ ព្រះបាទសុទ្ធោទនបានទតឃើញដូច្នោះហើយទើបក្រាបថ្វាយបង្គំផ្ទាល់នឹងផែនដីដោយបញ្ចង្គប្រតិស្ឋានចំពោះព្រះពោធិសត្វ ។

លំដាប់តពីនោះទៅ ព្រះថេរៈបានបង្ហាញភ្លាត្រង់ហើយថ្វាយព្រះពរថា :

តាមស្ថានទីនេះហើយ ព្រះអង្គ ដែលព្រះពោធិសត្វមានទេវតាតាំងមួយសែនជាបរិវារ ស្តេចយាត្រាចេញចាកក្រុងកបិលវស្តុ" ព្រះថេរៈបានបង្ហាញស្ថានទីដែលព្រះពោធិសត្វប្រថាននេះកណ្ហកៈទ័ងគ្រឿងពាក់ណោះដល់ឆាយទន្តកៈ (ឆន្នអាមាត្យ) ហើយទ្រង់គ្រាស់ឲ្យត្រឡប់វិលកាន់បុរីវិញ ។ តពីនោះមក ព្រះថេរៈបានបង្ហាញស្ថានទីដែលព្រះពោធិសត្វស្តេចយោងចូលទៅកន្លែងព្រៃតែមួយព្រះអង្គ ។ តពីនោះមក ព្រះថេរៈបានបង្ហាញ ស្ថានទីដែលព្រះពោធិសត្វទ្រង់កាត់ព្រះកេសាព្រះអង្គដោយកាំបិតដែលភ្ជាប់មកអំពីគាកាសហើយនឹកនៃ្ងដែលសត្តខេរវ៉ែ្ង[1] ឲ្យទទួលព្រះកេសាដោយរសេបក្តីគោរព ។ តពីនោះមក ព្រះថេរៈបានបង្ហាញស្ថានទីដែលព្រះពោធិសត្វ ទ្រង់ប្តូរព្រះកូសាដ៏មានដំលៃនឹងសំពត់កាសាយៈ អំពីព្រានម្នាក់[2] ។ តពីនោះមក ព្រះថេរៈបានបង្ហាញស្ថានទីដែលព្រះជាតិភូសារៈបានទទួលអញ្ជើញព្រះពោធិសត្វដោយទ្រង់ថ្វាយនគរាជាក់កណ្តាល ។ តពីនោះមក ព្រះថេរៈបានបង្ហាញស្ថានទីដែលព្រះពោធិសត្វស្តេចយាងទៅដួចនឹងតាបសកាលាម (អារ្យារគាបសកាលាមគោត្រ) និងឧទ្រកតាម (ឧទ្រកគាបសកាមបុត្រ) ។

---

១ សត្តខេរវ៉ែ្ង ជាឈ្មោះរបស់ព្រះឥន្ទ្រ ។ ២ សៀវភៅព្រះពុទ្ធសាសនារបស់លោកល្វី-ហ្សិណូតនៃរណោះនិ- មៅប្រែជាខ្មែរ ឃើញការចមហាព្រហ្មបានយកចីវរនឹងគ្រឿងបរិក្ខារសម្រាប់សមណៈមកថ្វាយ ។

តពីនោះមក ព្រះថេរៈបានបង្ហាញស្ថានទីដែលព្រះពោធិសត្វ ទ្រង់បំពេញទុក្ករកិរិយា យ៉ាងតឹងរ៉ឹងលើសលន់អស់រយៈពេល ៦ ឆ្នាំហើយទើបព្រះថេរៈពោលព្រះគាថានេះថា :

"ក្នុងរវាង ៦ ឆ្នាំ ព្រះពោធិសត្វទ្រង់បំពេញទុក្ករកិរិយាយ៉ាងតឹងរ៉ឹងលើសលន់ស្តេចផ្ទំតែលើផែនដីលើឥដ្ឋាទើបទ្រង់ជាបច្ចាស់ក្នុងព្រះចិត្តថា: សេចក្តីប្រព្រឹត្តដ៏តឹងនេះមិនសមគួរ មិនមែនជាផ្លូវដ៏ត្រឹមត្រូវពិតទេ ហើយទ្រង់លះបង់ចោលអំពើនោះទៅ ទើបប្រព្រឹត្តនូវធម៌ដ៏ពិតឡើង" ។

ព្រះថេរៈបានបង្ហាញតទៅទៀតថា : "ស្ថានទីនេះហើយមហាវដែលព្រះពោធិសត្វទ្រង់ទទួលបាយាសាយដោយទឹកដោះគោ[1] មានផ្ការាសមួយរយយ៉ាងអំពីនាងនន្ទពលិទ្ធីនាងនន្ទា[2]" ។ តពីនោះមកព្រះថេរៈបានបង្ហាញស្ថានទីដែលព្រះពោធិសត្វស្តេចយាងឆ្ពោះទៅកាន់ពោធិព្រឹក្ស ។

ព្រះពាក្យទ្រង់ត្រាស់ទៅសាងព្រះស្តូបមួយៗក្នុងស្ថានទីដែលព្រះថេរៈបង្ហាញហើយចាំងអស់នោះ ។

ម្យ៉ាងទៀត ព្រះថេរៈបានបង្ហាញស្ថានទីដែលកាលនាគភ[3] បានពោលពាក្យសរសើរព្រះពោធិសត្វលុះទ្រង់ព្រះសណ្តាប់ដូច្នោះ ។

---

១ ទិព្វាវទាន: ថ្វាយទឹកឃ្មុំនឹងទឹកដោះពោ ដែលបានចំរើនកើនឡើងដោយភាព។ អាយុ.វិភង្គ.ពិង: បានទទួលបាយាសាយដោយទឹកដោះគោដែលបម្រើញ ១៦ ដង ។ ២ បឋមសម្ពោធិ: ឆាងសុជាតា នឹងនាងបុណ្ណា ។ ៣ ទិព្វាវទាន; ពាលិកាគាថាដ ។

(នៅមានត)

គ្នាដឹកដៃចរណ្តើរទោងនោះទៅ លុះបណ្តើរទោងនោះទៅដល់ភូមិកាលណា ក៏និយាយទំនងអ្នកផ្ទះជិតស៊ំយាចខាងគ្នាតរៀងទៅថា អ្នកអើយ អ្នកឯងនិងញ៉ែយមាន់ខ្ញុំ រីឯអ្នកផ្ទះឮកុមារថាដូច្នោះហើយ ក៏មកគិតក្នុងចិត្តថា នេះដាកូនចៅហ្ន៎យស្រុកខេត្តើ ម្តេចក៏កុមារនេះយកមកលក់បើដូច្នោះតញ្ញឲ្យយកទៅលក់ឯចៅហ្ន៎យស្រុកម៉ែល ឯអ្នកផ្ទះគិតតែម្ន៉ោះហើយ ក៏ឆ្លើយទៅថា ខ្ញុំមិនទិញទេ តែគិតតែចៅហ្ន៎យស្រុកគេមានច្រើនច្រៀន បើដូច្នោះអ្នកឯងនិងទៅចុះ ឯកុមារទាំងពីរក៏នាំគ្នាដើរទៅទៀត ។

ឯចៅហ្ន៎យស្រុកឃើញកូនការណាហើយ ក៏សួរទៅកុមារទាំងពីរនាក់ថា ម្តេចក៏ឯងចាប់ចងកូនគេវិញ ។ ឯកុមារទាំងពីរ ឮចៅហ្ន៎យស្រុកសួរដូច្នោះហើយក៏ឆ្លើយទៅវិញថា ញ៉ែយមាន់ខ្ញុំចុងបាននាំខ្ញុំចុងចងជាប់ដើរតាមទៅដាច់ដងខ្ញុំចុង ឥឡូវនេះខ្ញុំចុងយកមកលក់ ឯចៅហ្ន៎យស្រុកឮកុមារថាលក់ដូច្នោះហើយក៏សួរទៅវិញថា បើកុមារឯងលក់តើថ្លៃប៉ុន្មានឯកុមារឮចៅហ្ន៎យស្រុកសួរថ្លៃដូច្នោះហើយ ក៏ឆ្លើយទៅវិញថា ឯតិច្បាប់បើញ៉ែយមាន់គេលក់មួយគ្រាណាតតែមាន ពីរគ្រាណាតតែមានឯនេះញ៉ែយមនុស្សខ្ញុំលក់ថ្លៃណាស់ ប៉ុន្តែនេះទាល់លើកលោកសូមទិញណ្តើយចុះខ្ញុំលក់តែបីណែនទេ ឯចៅហ្ន៎យស្រុកឮកុមារថាដូច្នោះហើយក៏យកច្បាប់បីណែនឲ្យទៅម្ចាស់កុមារទាំងពីរនាក់ ហើយក៏ទទួលយកកូន

នោះមក ។

ឯទៅកុមារពាំងពីរនោះបន្តិចក្អួន ក៏លាទៅហ្វាយស្រុកទៅលេងផ្សារ
ញ៉ែចំណីស៊ី ។

មានគាមាត្យមួយវាត់ទៅទូលមហាក្សត្រថា មានកុមារពីរនាក់បងប្អូន
ពាក់មាន់ ឥឡូវនាក់ចានកូនទៅហ្វាយស្រុក។ យកច្បាប់ណែនទៅ
លោះសឹងមិនព្រមឲ្យផង ស្តេចស្តាប់ហើយឲ្យទៅហៅទៅកុមារនោះមក
មានព្រះបន្ទូលទៅកុមារពាំងពីរថា ចុងឯងមានមាន់ឆ្នាក់ពាក់ចានមនុស្ស
មែនឬទេ ឯកុមារពាំងពីរក្រាបទូលស្តេចថា ក្រាបទូលមានមាន់ឆ្នាក់
ពាក់ចានមនុស្សមែន ស្តេចមានព្រះបន្ទូលថា បើមាន់ឯងគ្រាន់បើមែនពាក់
តែមហេសីធំអញចាន អញឲ្យទេតរអញទៅឯងសោយវាជ្យ ។

ឯទៅកុមារពាំងពីរក្រាបទូលថា សូមទ្រង់ព្រះមេត្តាក្រោស សូម
ពាក់ថ្វាយយកចន្លាល់មើល ហើយនាំគ្នាថ្វាយបង្គំលាស្តេចទៅ បងប៉ាមាន
ប្អូនកាន់ដង់ ទៅដល់ខាងក្រៅព្រះពាដពាំងស្តេចក៏ចាក់ដង់រួចបោះស្មឹង
បងមាន់ ហើយចេញមកចាំមើល ។ ឯមាន់ទះស្លាបបីដងរងាវគ្លាយកំ
ផែង ព្រះមហេសីស្តេចកិតក័យវាត់ទៅជាប់ដង់ កុមារពាំងពីរចាប់បង
បណ្តើរមកថ្វាយស្តេច ឯមហាក្សត្រទតទៅឃើញមហេសីជាប់ដង់កុមារ
គ្លាយកំផែងដូច្នោះ ស្តេចក៏សុំទិញមាន់នោះ ទើបទ្រង់អភ័សេក
ឲ្យកុមារបងគ្រងរាជ្យប្រគល់ស្រែស្មុំតាំងអស់ឲ្យផង ឯកុមារប្អូនឲ្យធ្វើជា

ឯព្រះមហាក្សត្រស្តេចយកមាន់ដើរចេញទៅពីនគរ ធ្វើដំណើរ
យ៉ាងអ្នកចាក់មាន់ ទ្រង់ត្រាច់ទៅលេចឮលួចលាក់ ចូលរៀតចេញឮលួច
អត់ព្រះក្រយាស្វាយ ទង់អស់ព្រះកាយស្តេចយកដង់ទៅចាក់ចោះស្នឹង
បងមាន់រួចស្រែចស្តេចថយមកពួនចាំមើល ឯមាន់ពុំមានវាស៊ាវចេះតែ
ប្រុក យូរចន្លួចស្តេចដំរីសមកតីនាយក៏ចាក់មាន់ទំនឹកក្តាំងពីរកប់ភាក់
កណ្តាលទៅក្នុងដី ដួចជាគេចកមាន់នោះនៅត្រង់ចន្លោះកណ្តាលក្តុក
ហើយដំរីនោះដើរវិលទៅលំនៅវិញ ព្រះមហាក្សត្រស្តេចទតទៅឃើញ
ថា ឧដំរីសពីណាស៊ុមកត្រួចសម្លាប់មាន់អញ។ ទ្រង់តែថ្កូវលំទៅនគរ
មួយ ស្តេចយាងទៅរតមាន់ឃើញក្តុកដំរីអមមាន់សងខាង មាន់នៅជា
កណ្តាល ក៏ស្តេចអស់ព្រះកាយពលសាជង្រួចដកស្នឹងប៉ាមាន់ អូសក្តុក
ដំរៅងពីរៈទៅដល់ក្រែមដើមព្រះរៃ។ លុះមហាក្សត្រចោះស្នឹងបងមាន់
រួចស្តេចយកក្តុកតាំងពីរដាក់ផ្ងមគ្នា ហើយស្តេចផ្ងំស្តុលទៅ ដោយសារ
អស់ព្រះកាយពលក៏ពុំដឹងព្រះអង្គ ព្រោះស្តេចអត់ក្រយាស្វាយមក ៧
ថ្ងៃហើយ ឯក្តុកតាំងពីរនោះមានឆាងពួនតាំងពីខោក់ទៅក្នុងក្តុកនោះផង
ឃើញស្តេចអត់ព្រះក្រយាស្វាយ ផ្ងំលក់ពុំដឹងព្រះអង្គ ក៏ខាងទាំបងប្អូន
ចេញមករៀបគោដនចំណីពុកទៅបុងព្រះចៅមហាក្សត្រ ហើយខាង
ទាំគ្នាចូលទៅខ្នើកក្តុកនោះដរដែលវិញ ។

ព្រះមហាក្សត្រស្តេចពុំបានជ្រាបជាក្តុកតាំងពីរ មានខាងពួនទៅ
ឡើយ ហើយស្តេចគើនឡើងតែឃើញចំណីភោជនអាហារនោះល្អ មុខ
គួរឲ្យចង់សោយ ក៏ទ័កក្តងព្រះទ័យថា តុអញអត់ក្រយាស្វាយ ៧ ថ្ងៃ
មកហើយពុំដែលបានបរិភោគសោះ ឥឡូវចំណីនេះល្អចំឡែក ថ្មមួយ
ទេវតាលោកមកនិម្មិតឲ្យ ថ្មមួយអ្នកណាគេផ្តើតាំពិសបំពុលអញ។ ឃ្លាន
ម្ល៉េះតើនឹងអត់ម្តេចបាន ហើយបើអញស្លាប់ទំនឹងចំណីនេះ ឲ្យឃើញជា
ស្លាប់នឹងចំណីនេះទៅចុះ ។ ស្តេចគ្រែរដូច្នោះហើយ ក៏យកអាហារចំ-
ណីនោះមកសោយទៅ ក៏មានឧជារសឆ្ងាញ់ពិសា មានព្រះកាយពលនោះស្រួលសប្បាយ ទើបស្តេចយកក្តុកតាំងពីរលាក់ទុកក្នុងកន្ទែង ១
ហើយស្តេចចេញមានកាន់ដង់ដោងទៅទៀត, ស្តេចយាង ៧ យប់ ៧ ថ្ងៃតែក្តុក
រុកតែព្រៃអស្រ័យតែផ្លែឈើ ពុំមានស្គាល់ក្រយាស្វាយដល់មួយវេលា
ឡើយ ស្តេចនឿយហត់ល្វើតល្វែណាស់ ក៏មានព្រះបន្ទូលថា តុអញ
អើយ ដ្បិតតែចង់សប្បាយយកនគរបូរទៀតមាន ដើរមកឲ្យតែលំបាកខ្លួន
ហើយស្តេចយកមាន់ទៅចោះស្នឹងចង់ចាក់ដង់ដុំវិញ ហើយព្រះមហា-
ក្សត្រស្តេចថយមកពួនលបចាំមើល ឯមាន់នោះខនេះស្ងាបរាវ ៣ ដង
ហើយគ្រាបចំពុះតយូរបន្តិច ស្តេចរមាសដើរមកឃើញលោតែស៊ុះទៅគ្រប
ពីលើមាន់ ជ្រុះកុមេពិក្សាលទៅនៅប្រចមាន់នោះឯង ហើយស្តេចរមាស
ក៏រើលទៅលំនៅវិញ ។

ឯកុយរមាសនោះ មានទាងំពួនទៅខាងក្នុង មាន់កកាយដីយក
ទៅគ្រាបប៉ុនតុក ព្រះមហាក្សត្រស្តេចឃើញរមាស ស៊ុះទៅហាក់ដូច
ជាគេនឹងនាំមាន់ ក៏ស្តេចនឹកក្នុងព្រះចិត្តថា តុរមាសនេះកំមកពីណា ក៏
ស៊ុះមកចាំមាន់អញស៊ី ស្តេចម្ចាស់ត្រៅទៅឃើញមាន់នៅគ្រាបប៉ុនតុក ស្តេច
ខានព្រះទ័យត្រែកអរពេកក្រៃ ក៏សាជង់រួចជកស្នឹងលើកមាន់បីឡើង
ទតទៅឃើញកុយរមាសក៏ស្តេចកាន់យកកុយរមាសនោះទៅ តែស្តេច
ពុំជ្រាបជាកុយនោះមានទាងំពួនទៅខាងក្នុង ព្រះមហាក្សត្រក៏ស្តេចវិល
មកគ្រាមដើមព្រៃវិញ ដោយសារអស់ព្រះកាយពល ក៏ដាក់កុយ
រមាសប្រឋមព្រះអង្គផ្ទំលក់ទៅ ហើយស្តេចពុំមានក្បាត់ព្រះអង្គឡើយ ។
ឯទាងំពួនទៅក្នុងកុយរមាសឃើញមហាក្សត្រស្តេចអត់ព្រះក្រយាស្វាយ
ក៏វាងំចេញពីក្នុងកុយមកនិម្មិតជាអាហារគោជនចំណីសឹងជាអាហារទិព្យ,
លើយចូលទៅនៅក្នុងកុយរមាសនោះដូចដែលវិញ ព្រះមហាក្សត្រស្តេច
តើនរៀងទតឃើញចំណីនៅប្រឋមព្រះឋាន ក៏ស្តេចនឹកក្នុងព្រះចិត្តថា
តុចំណីនេះអើយមុខតួឲ្យស៊ីប៉ុន្តែពុំដឹងជាចំណីនេះពីណាមក បើអញ
ឃ្លានម្ល៉េះតើនឹងអត់ត្រាំឯណាក៏បាន លើយព្រះមហាក្សត្រស្តេចសោយ
អស់គោជនចំណី រួចមានព្រះកាយពលស្រួលសប្បាយ ទើបស្តេចបី
មាន់គាន់ជង់យាងយាត្រាតទៅទៀត ។ ព្រះមហាក្សត្រស្តេចយាងលេច
ព្រលប្លួលព្រៃ លេចព្រៃចេញព្រលឹង ក៏ទ្រង់ទតឃើញទីក្រុងមួយល្អ

ក៏បីមានទៅដល់ទីនោះហើយចាត់ដង្កាំដុំវិញចង្កមានរួច ស្តេចថយមកពួនទៅដើមព្រះជៃមួយបៃលប់មើលមាន់ ក៏ពុំមានឃើញអ្វី ស្តេចអស់ព្រះកាយពលណាស់ក៏ផ្ទំលក់ទៅ ។ ឯមាន់នោះក៏ហេតុតែមានខ្លួនលក្ខណ៍ធំធាត់មានឯណាដូចមាន់នោះគ្មាន ក៏មាន់នោះខ្លះស្ងាបរងាវបើដងស្រាប់តែផ្ទុះថ្លាសាខមាសថ្លាសាខថ្លាក់ មានផ្លុះផ្សាផ្លូវធ្លាវៀចវៀងហើយមានកំពែងព្រះពជ្រកំផែង សុទ្ធសឹងតែមាសថ្លាក់តែវែងគ្រឹមខ្ពង់ខ្ពស់ មានរស្មីនោះហាក់ដូចភ្លើងភ្លឺគ្រប់មុខលុបលើមាន់នោះ ។

ឯព្រះមហាក្សត្រស្តេចតើនឡើង ទតទៅឃើញភ្លឺខ្ចាលខ្ចង់ផ្លៅកំលាន់ព្រះទ័យថា ទអ្នកណាអើយដុតភ្លើងពៃពាលមកឆេះមាន់អញនេះហើយ មាន់គ្នាទិញតែថ្ងៃដល់ទៅនតមួយ ក៏គ្មានអាណិតអាសូរគ្នាបន្តិចសោះ កំហ៊ានដុតភ្លើងពៃឲ្យពាលមកឆេះមាន់គ្នាស្ងាប់ចង់សៀត ។ ទើបព្រះមហាក្សត្រស្តេចដើរបណ្តើរវត់បណ្តើរទៅមើលមាន់ទំពស្ពាយមាន់នោះណាស់ លុះទៅដល់ឃើញមាន់ទៅជាដែលហើយឯថ្លាសាខមាសថ្លាក់កំពែងខ្ពាត់ខ្ពែងសុទ្ធសឹងតែវែងគ្រឹមខ្ពង់ខ្ពស់ ភ្លឺខ្ចាលខ្ចង់ផ្លៅ មានផ្សាផ្លូវធ្លាមានរបៀបរៀបរយ ហាក់ដូចស្ថានវិមានតុសិតសួគ៌នាយ ស្តេចឈ្វេងយល់តង្កៀតព្រះពជ្រហ្អែរឲ្យថា ទពិតមានមែនមិនគឺអ្នកឯណាធ្លើឡើយ គឺមាន់អញមានខ្លួនលក្ខណ៍ ទាក់ទៅកើតផ្ទុះថ្លាសាខមាសថ្លាសាខថ្លាក់មានកំពែងខ្ពាត់ខ្ពែងមានគ្រឹងប្រឹងស្រប់គ្រប់ប្រដាប់ពុំមានខ្វះអ្វី ហើយព្រះ

មហាក្សត្រស្តេចទៅយកក្តីតាំងពីខែឆ្នាំកុយរមាសមកទល់ដំណាក់ថ្មី
នេះជាមួយនឹងខាន់តែតំរូវប៉ុណ្ណោះ ។ ឯខាងពួនខែវកន្ធកកន្ធកុយ
រមាស ក៏ចេញមកថ្វាយខ្លួនជាមហាសម័គាំង ៣ អង្គ។ មានរូបឆោមលោម
ពណិបរិសុទ្ធហាក់ដូចស្រីសួគ៌តុសិត ស្តេចក៏មានព្រះទ័យប្រតិព័ទ្ធ
ស្រឡាញ់ខាងគាំង ៣ ពន់ពេក ទើបស្តេចទុកខាងក្តុកស្តាំជាមហេសីស្តាំ
ទុកខាងក្តុកឆ្វេងជាមហេសីឆ្វេង ទុកខាងពួនកុយរមាសជាមហេសី
កណ្តាល ព្រះមហាក្សត្រសោយភោគសម្បត្តិ នៅជាមួយនឹងមហេសី
គាំងបី ទ្រង់ប្រទានឆ្នាមនតវ៉ាយនេះថា បុរីបុស្សា។ លម្ងឹរន្ធីវៅត្រប់
ប្រទេស ក៏អស់ឈ្មួញជួញដែរត្រប់តាស។ នាំគ្នាមកនៅតេស៊ី លក់
ចេញទិញចូលជាច្រើនមហិមា ក្នុងក្រុងបុស្សាបុរី ប្រកបដោយសេចក្តី
សុខសប្បាយក្សេមក្សាន្ត ហើយស្តេចតាំងចិញ្ចឹមឲ្យមានមុខមន្ត្រីធំតូច
តាមអណ្តាប់អណ្តោយតាមឧត្តិយប្រវេណីតពីបុពណ្ណតមក ។

(តាឮពាក្យ ៧) បើនឹងរៀបរាប់ពីទំនិញ មានឈ្មួញជួរទិញដោយ
សឆាងាវ ផ្លូវផ្លាស្មុគ្មតែតាំងជាហាង ទំនិញច្រើនយ៉ាងល្អថ្លាថ្លៃ ។
ជាខិបខេសតែកតួងតួច-ធំ ជាហ៊ុមចិនចាវត្រៃឮដំខ្លៃ ខ្លួចតកញ្ចក់ខុក
សុទ្ធសៃ អាស្រ័យបើកលក់សព្វវៃលៅ ។ មាំឡាយៗរ៉ូបចិនគោយតាំង
ជាកំងំពួនលាវយួនជ្វា ដើរទិញទំនិញពាសពេញផ្លូវ គណានាងំពប់
កំពុតស ។ នឹងមើលទំនិញខាងហាងធំ រៀបចំត្រៃល្អដោយរបស់ តែវ

កន៏ចិញ្ចឹនមានគ្នានខ្លះ រេបស់របៀបរៀបរៀងគ្នា ។ សង្កិមសង្កៀន
ខៀនសក្ខាត មួកតាតរំលេចក្បាច់ក្បូរផ្កា សែសយលេចលយដោយជួរ
ជា លៀកផ្កាជាមួន៏ព័ណ៌ខ្មែ ។ តែវគួបតែវធំផ្ទុំដោយជួរ ចរណៃ
ក្បាច់ក្បូរស្រស់ញញឹម តែវដាក់ទឹកអប់ផ្កាប់ខន្ធឹម តែវរមរៀបដាក់ច័ន្ទន៍
ក្រឹស្នា ។ ពាំដោរកូនក្មែបក្រែមេបឈ្មប់ ក្រអូបសាយសព្ទសឹន៏រសជា
ព្រះពាយជាត់ផាយសាយសព្ទសារ នោះដូចកូនផ្កាមន្លារបុស្ប ។ មាន
ស្រាចាពំន៏តាំន៏លាយឡំ កាំបិតស្លាបព្រាសមអមចំរុះ តែវដើន៏ល្អស្តើន
ថ្លើន៏ភ្លឺច្បុះ បញ្ចុះលេចលាយតែវគ្រប់យ៉ាន៏ ។ ខណ្ឌមួយដាក់សុទ្ធតែ
ថាសតុះ ក្រដាសរុំកប់ខុកល្អស្រឡាន ទឹកោកខ្មោរដាក់ជួរខាន៏ ថ្នាក់
ក្រោមដាក់យ៉ាន៏ច្រឡំថោក។ ។ ជាន់លើដាក់សឹន៏មួកកាស្តិត រៀបដិត
មួកស្មៅស្មោះសើមសោក សៀតសិកជាជាន់មានតរគោក ឈ្មោកយក
បេញលក់ស្រណុកចិត្ត ។ ជាន់មួយដាក់សុទ្ធត្រែព្រាផ្កា ចំរុះព័ណ៌គ្នា
ជិតប្រកិត មានតែវបំពង់រាយគ្នាជិត សាច់ស្និទ្ធចូលចិត្តនឹញាតល់គ្នា ។
ផ្ទះផ្សារៀបជាទីជុំន៏សាច មីឡាតញាសស្វាចដោយជួរជា រៀបសុទ្ធបន
ឆ្ងួចុ៉ាន៏ន៏បៀ មនុស្សយួនចិនផ្ងារលេង៏ឈ្មួនរ ។ ខ្លះចាញ់ខ្លះឈ្នះមានពិ.
ការ ពាស់ក្បាច់ឈ្មោះគ្នាគ្រហឹន៏រ ខ្លះចាប់ពាក្យគ្នាថាណ្តើយមក កុំរ
ប្រឈ្មោះអ្វីន៏ន៏ចិន ។ អាចិកលាត់អារស្លឹកតាតខា ខ្មែរហៅចិនមក
លាត់ចន៏ក្បឿន ស្ទុះលោតកញ្ឆាត់ទៅយកចិន ជាល់កិនចិនចាញ់រត់ចូល

តៀម ។ អស់ពួកអ្នកលេងល្បែងបៀ ចាប់ឃាត់គ្នាឲ្យឈ្លើយ
ស្រឡាំង ចិនវាចាញ់យើងតែបួលតៀម រឹមវាមកតែវាកអ្វីទៀត ។ ខ្លះថាចិក
ឯងកុំអីស្ងាប់ កុំតែគេចាប់ចាញ់ចេញឃ្លាត កុំអីមិនរួចត្រូវបុកសៀត
បង់មាសយោងស្ងាប់ចោលប្រពន្ធ ។ ថាហើយក៏បបួលគ្នាទៅ តាមដោយ
លំនៅប្រជាជន ទើបមើលរបៀងរៀងគយគន់ តាមបន ដាយបងឯផ្សារ
ត្រី ។ តែមគ្រាញ់រៀលលេញត្រួលថ្ងាឆ្ពោ រែកផញ្ជួនឆោឡោច្រែន
ស្រាស់ត្រៃ ខ្លះបួលទិញផ្លូរសុំសួរថ្លៃ អាស្រយទិញទៅស៊ីពាល់គ្នា ។
មានតែរស់ឆ្ពោស្រហោកជ ប្រសំលក់ព្រឹកល្ងាចច្រែនត្រៃជាតិ សាច់
គោព្យួរជាក់ដោយខ្សែកគ្នា ជ្រូកជាក់ដើងមាំគារថ្នឹងលក់ ។ ត្រពាំ
តីផ្លុកបង្គា បង្គាងគុយតាវគាមាំហាមុក មេមួសស្វឹកត្រៃខ្ចីត្រប់មុខ ត្រហក់
អំបិលទឹកត្រីតី ។ អស់ពស្តុកស្រុកតាំងអ្នកផ្សារ តែងទិញពាល់គ្នា
យកទៅស៊ី គណនាពុំអស់សោកីឌី ថ្លៃងពីបូរីនៃមហាក្សត្រ ។

ស្តេចសោយរាជ្យបានមួយរយឆ្នាំ ដល់ផកកម្មមកចាំស្លាត់ សោយ
រំលាយដោយវិបត្តិ មរណៈមកដាក់ក្រយសង្ខារ ។ តាំងបីមហេសី
ស្រីព្រះសុំ តាំងទីបន្ទូមហាក្សត្រា វិនាសខ្លាយភ្នាត់ជាត់ត្រមគ្នា ដ្បិតជា
ភាពជុះឡើងឯង ។ សូរេចស្រែចតីរឿងមានខ្លាក់ កុមារតីរខោកដែល
យើងថ្លែង បងក្រែងខុកមកជារឿងត្រែង បរិបូណ៌ចែងចប់ប៉ុណ្ណេះហោង ។

ធម្មាធិប្បាយ

"ធម្មកាមតា"

សេចក្តីប្រាថ្នាកន្លងធម៌ដែលប្រពៃ ។

ព្រះបាទ្បាត់ធម្មប្បញ្ញាញាណ សុទ្ធ-ប៉ាន

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ។

សេចក្តីប្រាថ្នាបានដល់អាការៈដែលចិត្តមានបំណង តែវាអារម្មណ៍កន្លងវត្តុនោះៗ គឺយើញតែរបស់ល្អគាប់ចិត្ត ពេញចិត្ត ទើបប្រាថ្នាន៍ឆ្ងៃ ទុំ វត្តុនោះៗ ។ ពាក្យថាកាមៈនោះ នៅជាពាក្យកណ្តាល បានទាំងខាងល្អទាំងខាងអាក្រក់ តាមអំណាចធម៌ដែលបង្អោនទៅ កាមសព្ទក្នុងពាក្យថា ធម្មកាមតា ចាត់ជាសេចក្តីប្រាថ្នាខាងផ្លូវល្អ សេចក្តីប្រាថ្នាខាងផ្លូវលោក ប៉ែកខាងអាក្រក់នាំឲ្យដល់នូវសេចក្តីទុក្ខ ចាត់ជាកាមៈចំណែកអាក្រក់ គប្បីជ្រាបដោយនយពុទ្ធភាសិតថា:

កាមតោ ជាយតេ សោតោ កាមតោ ជាយតេ ភយំ

កាមតោ វិប្បមុត្តស្ស នត្ថិ សោតោ កុតោ ភយំ ។

សេចក្តីសោកទន្ទឹងភ័យ តែងកើតមកតែអំពីកាម បើប្រាសចាកកាមហើយ សេចក្តីសោកក្តី ភ័យក្តី ទន្ទឹងមានមកអំពីណា ។

អធិប្បាយថា: សេចក្តីតាប់ចិត្ត សេចក្តីក្រោធ្លាចំពោះសង្ខតធម៌ ដែលមានទម្ងន់ប្រែងតែង ជាអវិញ្ញាណកខ្លួន តើខ្លួនដែលមិនមានវិញ្ញាណ មានមាសក្រោធជាដើមក្តី ជាសវិញ្ញាណកខ្លួន តើខ្លួនដែលមានវិញ្ញាណគ្រប់គ្រង មានគោ ក្របី ដំរី សេះ ជាដើមក្តី ឬជាវត្ថុតាមដែលគួរក្រោធ្លាបានដល់រូប សំឡេង ក្លិន រស ផោដ្ឋព្វក្តី ដែលជាសភាពកើតមានក្នុងខាងដើម ប្រែប្រួលទៅក្នុងកណ្តាល រលត់ទៅក្នុងទីបំផុត កាលបើមានសេចក្តីក្រោធ្លាប្រកាន់មាំថាជារបស់ថាវិរៈ ព្រោះបែកធ្លាយដោយពិដ្ឋីហើយ លុះវត្ថុសភាពនោះ។ ត្រាត់ក្រោសវិនាសដោយបែកធ្លាយរលត់សូន្យទៅ អ្នកក្រោធ្លាដែលបែកធ្លាយដោយពិដ្ឋីក៏រមែងមានសេចក្តីសោកបរិទេវទុក្ខទោមនស្សជានិច្ច ។ សូម្បីតយន្តពាយក៏នៅស្កាត់ចាំជុំវិញខ្លួនដូចចោរឃ្លាំចាំប្លន់ស្តុកយដណ្តើមយករបស់ខ្លួនគេ កាលមិនបានតាមក្រោធ្លា តែងប្លន់ស្តុកយអ្នកម្ចាស់របស់ខ្លួនក៏មាន ។ ចំណែកបុគ្គលអ្នកមានក្រោជ្ញា សូម្បីមានខ្លួនសម្បត្តិ ក៏មិនស្តុតស្វាញប្រកាន់មាំក្រោធ្លាតែនឹងលះបែងចែកឲ្យជាប្រយោជន៍ខ្លួននឹងអ្នកដទៃ តាមគួរដល់ហាន: ព្រមទាំងស្គាល់ដឹងតតែនៃធម្មតារបស់សង្ខតធម៌ លុះវត្ថុនោះប្រែប្រួលទៅតាមសភាព ក៏មិនមានសេចក្តីសៅសោក ទាំងតយន្តពាយក៏មិនមានទោះប្លន់ខ្លួនឯងនឹងត្រូវចាកហានទៅ មិនបានមានសេចក្តីតាន់តូចដែលជា: ទុក្ខិតិកវិត្ត សេចក្តីក្រោធ្លាដូចដូចនេះ

បែកខាងផ្លូវលោក ។ ចំណែកសេចក្តីថ្នាំងផ្លូវល្អ ចានដល់សេចក្តីថ្នាំងគឺធម៌ដែលប្រពៃ ជាសាសនធម៌ សំដៅយកចារចនៈ គឺធម៌និងវិន័យ ជាពាក្យប្រដៅរបស់ព្រះដ៏មានព្រះភាគ សេចក្តីប្រតិបត្តិសម្រាប់ហ្វឹកហាត់អធ្យាស្រ័យឲ្យថ្លៃថ្នូរ ចាត់ជាធម៌ ។ សេចក្តីប្រតិបត្តិដ៏ជាប់ដោយវេបុល្យ ដែលព្រះអង្គទ្រង់តាំងទុកជាពុទ្ធអាណា ជាសិក្ខាបទ ឬជាអភិសមាចារ ស្មួយសេចក្តីប្រព្រឹត្តិរបស់ពួកគណៈឲ្យស្មើភាគគ្នា ឬជាគ្រឿងបរិហារគណៈ ចាត់ជាវិន័យ ។ ន័យមួយទៀត ពាក្យថាធម៌នេះ ចានដល់ សីល សមាធិ បញ្ញា ។ សីល ចានដល់វិន័យ សមាធិនិងបញ្ញា ចាត់ជាធម៌ដូចគោលហើយក្នុងជាវចនៈ ។ ន័យមួយវិញទៀត ចានដល់សទ្ធម្ម ៣ ប្រការគឺ បរិយត្តិសទ្ធម្ម ចានដល់ពាក្យប្រដៅ, បដិបត្តិសទ្ធម្ម ចានដល់សេចក្តីប្រតិបត្តិ, បដិវេធសទ្ធម្ម ចានដល់មគ្គផលនិព្វាន, ធម៌មានប្រភេទដូចបរិយាយមកនេះ ឈ្មោះថាធម៌ដែលប្រពៃជាស្ងាក្តាតធម៌ដែលព្រះអង្គត្រាស់ល្អហើយ កាលមានសេចក្តីថ្នាំងធន្ធ. ក៏បង្កើតខ្សែដ៏ជាសម្ងាត់ដែលជាប់ជាក់ខ្លួននឹងវារៈចិត្ត ធន្ធៈនេះលោកចាត់ជាឥទ្ធិប្បាទ គុណគ្រឿងសម្រេចចំណង់ជាអង្គពោធិបក្ខិយធម៌ គឺធម៌ជាផ្នែកនៃសេចក្តីត្រាស់ដឹងប្រការមួយ ។ កាមៈនិងធន្ធៈនេះអាចនិងពាញចង់គ្រែកសេចក្តីឥតយាមទុកមិនឲ្យជូរថយ គប្បីយើញតួយ៉ាងដូច **សម្តេចព្រះបរមសាស្តា** ព្រះអង្គទ្រង់អាស្រ័យកាមៈនិងធន្ធៈដែលជាផល

នៃព្រះមហាករុណា ទើបបានត្រាស់ជាព្រះអរហំសម្មាសម្ពុទ្ធបំពេញពុទ្ធ-
កិច្ចប្រតិស្ឋានព្រះពុទ្ធសាសនាសម្រេចបានដល់សព្វថ្ងៃនេះ ។ បើតាម:
ទំនងធម្មៈមិនមាននៅក្នុងព្រះហឫទ័យព្រះអង្គទេ ក្នុងខណៈដែលទ្រង់សាង
មហាកិរនេស្អមបំពេញពុក្កកិរិយា មុខតែអត់ធន់ចំពោះពុក្កលំបាកមិន
បាន គង់ទំនងត្រឡប់វិលត្រឡាយជាក់ធុរៈចោលមិនប្រឹងប្រែងតទៅទៀត
ភ្លាក់នៅក្នុងអំណាចនៃមារជាមិនខាន ។ មួយទៀត ឃើលព្រះអង្គទ្រង់ពិ-
ចារណាឃើញធម៌ដែលព្រះអង្គត្រាស់ដឹងនោះ ថាជាគុណជាតដ៏ស្ងុខុម
ល្អិតវៃពេកក្រៃមានពួកសត្តនិករណាទីងត្រកអារដឹងតាមឃើញតាម
បាន ព្រះហឫទ័យក៏ចង្អោនទៅក្នុងផ្លូវខ្ពស់ភ្ញាយតិច ទើបមិនទ្រង់ព្រះ
តម្រិះទំនាំសំដែងធម៌ តែសេចក្តីជ្រាបថាទីងសេចក្តីពេញព្រះហឫទ័យជា
កំឡាំងព្រះមហាករុណាចូលទៅឧបត្ថម្ភចាស់ក្លាហើយ ទើបទ្រង់មិនបាន
បោះបង់ធុរៈនោះចោល ទ្រង់ពិតពិលពិចារណាទៅក៏ឧតព្រះនេត្រឃើញ
អ្នកមានបញ្ញាអាចដឹងតាមនៅមាន ។ ចំណែកមនុស្សក្រៅពីនេះក៏ល្មម
ទំនងអប់រំសម្អាបដំបូតិ្តជាលំដាប់លំដោយគ្នាបានដែរ យ៉ាងណាបក៏អាចបាន
ទទួលប្រយោជន៍ជាលោកិយ លើកលុកតែអតព្វជ្ជបុគ្គលមួយចំពួកមិនបាន
សម្រេចគុណវិសេសខ្ពស់ឡើយ ព្រោះមិនបានតាំងចិត្តស្តាប់ធម៌ដោយគោ-
រព ប្រៀបដូចផ្កាឧប្បលដុះលូតលាស់ឡើងផុតអំពីទឹកហើយ បម្រុងនឹង

រកដល់វេលាព្រះអាទិត្យរះឡើង ដុះលូតលាស់នៅតែមស្មើនឹងខ្នែងខ្លះ ដុះលូតលាស់នៅក្នុងខ្នែងមានខ្នែងសម្រាប់ចំពាមរក្សាខុសខ្លះ ដុះលូតលាស់គ្រាន់តែជាចំណីនៃអណ្តើកនឹងត្រីខ្លះ លុះខ្ញុំពិចារណាដូច្នេះហើយ ទើបខ្ញុំអធិដ្ឋានតាំងព្រះហឫទ័យប្រកាសព្រះសាសនា ខ្ញុំមិនបានឃើញដល់សេចក្តីខ្វៃយហត់លំបាកព្រះកាយពាល បានប្រកាសព្រះសាសនាឲ្យផ្សាយធំទូលាយ ដោយព្រះវីរិយៈទសប្បារមី ឲ្យសម្រេចប្រយោជន៍ដល់សត្វលោកជាច្រើន ។

ធម្មតាមនុស្ស ធ្វើបុគ្គលជាន់ខាងឲ្យក្លាយទៅជាបុគ្គលជាន់ខ្ពស់ ធ្វើបុថុជ្ជនឲ្យក្លាយទៅជាអរិយបុគ្គល ព្រោះអាចធ្វើដំណើរឈានឡើងទៅកាន់សេចក្តីចំរើនខាងមុខ សមដូចសុភាសិតថា ឆម្មកាមោ ករំ ហោតិ អ្នកត្រូវការជាប់ប្រពៃ នាំឲ្យបានសេចក្តីចំរើន ។ អាស្រ័យសេចក្តីព្យាយាមប្រឹងប្រែងមិនបន្ធូរបន្ថយនេះហើយ ដែលអាចអប់រំសម្ងាបដិបត្តិឲ្យប្រសើរវិសេសឡើងបាន ថែមទាំងឲ្យបានសេចក្តីរីករាយសប្បាយចិត្ត ដោយនឹករំពឹងថា អាត្មាអញបានធ្វើសមគួរហើយ ខ្លួនឯងតិះដៀលខ្លួនឯងមិនបាន ទាំងវិញ្ញូជនក៏រមែងសរសើរ ព្រមទាំងមិនបានក្តៅក្រហាយចិត្តខាងក្រោយទៀត ។ សម្តេចព្រះលោកនាថខ្ញុំគ្រាស់ថា អ្នកដែលតាំងនៅក្នុងធម៌ជាទីពឹងឈ្មោះថាបានធ្វើកោះសម្រាប់ទីពឹងដល់ខ្លួន សមដូចធម្មកាសិតដែលព្រះដ៏មានព្រះភាគខ្ញុំគ្រាស់ទុកថា

ឆម្មឌីថា តិក្ខត្តុំ វិហារេ ធម្មប្បដិសារណា អនញ្ញាតា
សេចក្តីថា ម្នាលតិក្ខត្តុំពាំងឡាយ លោកពាំងឡាយចូរមានធម៌ជាគោរព
ពីឯពាំងនាក់ កុំមានតែដូចជាសារណៈឡើយ ។ ព្រះអង្គទ្រង់សំដែងធម្ម.
កថានេះ មិនមែនចំពោះតែពួកតិក្ខុប៉ុណ្ណោះទេ សូម្បីគ្រហស្ថក៏គួរពោល
បញ្ជូលបានដែរ ថ្ងៃបើព្រះអង្គទ្រង់គ្រាស់ចំពោះតែពួកតិក្ខុប៉ុណ្ណោះ ។
ពុទ្ធបរិស័ទដែលមានសេចក្តីជ្រះថ្លាក្នុងធម៌ ឈ្មោះថាបានធ្វើទីពឹងដល់
ខ្លួនស្រេចហើយ ពាំងជ្រាកដថាជាអ្នកបូជាព្រះសាស្តាដោយធម្មានុធម្ម.
ប្បដិបត្តិផង ។

ចប់ធម្មាធិប្បាយ ក្នុងធម្មកាមតាតែប៉ុណ្ណេះ ។

ប្រវត្តិលោកគ្រូចៅអធិការ ពៅ-ង៉ែត

វត្តអង្គសុរភី ឃុំកន្ទោរ-កំពង់ត្រាច-កំពត

លោកគ្រូចៅអធិការ ពៅ-ង៉ែត បិតាឈ្មោះ ពៅ មាតាឈ្មោះ អ៉ុយ ជាតិខ្មែរ កើតនៅភូមិជ្រៃទឹងខេរ ក្នុងឃុំកន្ទោរ ស្រុកកំពង់ត្រាច ខែត្រកំពត; កើតនៅថ្ងៃសៅរ៍ ៧ កើត ខែផល្គុនឆ្នាំចសំរឹទ្ធិស័ក, ព. ស. ២៤១៧, គ. ស. ១៨៧៤; គាយុបាន ១២ ឆ្នាំ មាតាបិតាបានយកទៅឲ្យនៅសិក្សាអក្សរសាស្ត្រខ្មែរ ក្នុងសំណាក់លោកគ្រូនាម ឈ្នាង ជាចៅអធិការវត្តអង្គសុរភី, ជាបឋមវ័យបានចេះដឹងមើលសរសេរបាន ។

ដល់អាយុ ១៧ ឆ្នាំ បានលាលោកគ្រូទៅនៅជួរ បំរើមាតាបិតាដោយបិតាមានជម្ងឺ; បិតាក៏ទទួលអនិច្ចកម្មទៅ ក៏នៅបំរើមាតាតទៅទៀត ។

លុះដល់អាយុ ២៤ ឆ្នាំ បានលាមាតាចូលមកឧបសម្បទាជាភិក្ខុភាវៈក្នុងវត្តអង្គសុរភី, លោកគ្រូនាម ឈ្នាង ជាឧបជ្ឈាយ៍ លោកគ្រូសូត្រខ្មែរជាកម្មវាចាចារ្យ; បាននាមក្នុងឆាយាជាចន្ទវង្សៈ ។

លុះបានឧបសម្បទារួចហើយ ក៏នៅក្នុងសំណាក់លោកគ្រូឧបជ្ឈាយ៍ សិក្សាចម្រាច់ធម៌វិន័យផ្លូវព្រះពុទ្ធសាសនា បានចេះដឹងច្រើននៅក្នុងវត្តអង្គសុរភីជាប់ជាបឋមក; មិនប៉ុន្មានប៉ុណ្ណោះ លោកក៏ធ្វើតសិក្សាខាងផ្លូវលោក គំលេខនព្វន្តខ្មែរ-ចិន បានចេះដឹងមិនខ្វះសោះ, ហើយបានតាំងបង្ហាត់បង្រៀនកូនសិស្សឲ្យបានចេះដឹងច្រើនតាក់តែទៀត ។

លុះដល់ឆ្នាំឃុំ ៣២ ឆ្នាំ លោកគ្រូឧបជ្ឈាយ៍យល់ឃើញថា កិក្ខុ
ភៅ-វង្ឍ៏ត ជាអ្នកមានចំណេះវិជ្ជា ព្រមទាំងកិរិយាមារយាទល្អ លោកក៏
តាំងឲ្យធ្វើជាគ្រូសូត្រឡើង ។ តមក លោកគ្រូឧបជ្ឈាយ៍ ក៏ទទួលអនិច្ច-
ធម្មភៅ ។

ដល់ឆ្នាំឃុំ ៥២ ឆ្នាំ លោកគ្រូសូត្រ ភៅ-វង្ឍ៏ត ចាន់ឡើងទីជា
ចៅអធិការ ព្រមទាំងធ្វើជាឧបជ្ឈាយ៍ បំពេញកិច្ចដល់កុលបុត្រចាន; លោកគ្រូចៅអធិការនេះ លោកមានអធ្យាស្រ័យល្អ ចាន់ទំយកព្រះ
ទ័យទុកជាក់បង្ហាត់បង្រៀនកូនសិស្សដោយអង្គលោកក៏មាន, ប្រែគេឲ្យ
ជួយបង្ហាត់បង្រៀនក៏មាន, ចាន់បេះដឹងខាងវិជ្ជាអក្សរសោស្ត្រ ព្រមទាំង
ធម៌ទ័យផ្សាព្រះពុទ្ធសាសនា; ហើយលោកចាន់ចាត់ចែងរៀបចំទីវត្ត
អោយមចាន់សាងកុដិ វិហារថ្មៗដ្ឋ ទៅកងទីវត្តសព្វថ្ងៃនេះ ។

លុះតមកទៀត លោកចាន់សុំពរជាអាណាព្យាចាលឲ្យបង្កើត
សាលាសិក្សាកុមារខ្មៅកងទីវត្ត សម្រាប់ឲ្យកូនអ្នកស្រុករៀនសូត្រតាំង
ប្រុសស្រី; ទើបពរជាព្រះគុណ ព្រះបរមរត្តិយសោដ្ឋជាម្ចាស់ជីវិតលើ
គ្បូង ព្រមទាំងពរជាអាណាព្យាចាលយល់ឃើញថា លោកគ្រូចៅ-
អធិការ ភៅ-វង្ឍ៏តនេះ យកព្រះទ័យទុកជាក់ក្តងការរៀនសូត្រល្អ ក៏ច្រើន
ប្រការ ប្រគេនគ្រឿងឥស្សរិយយសមកដែយមាស ១ ទុកជាព្រះកេរ្តិ៍ ។

លុះកន្លងមក ៣ ឆ្នាំទៀត ព្រះករុណាជាម្ចាស់ដ៏វិតលើតម្បូង ទ្រង់
ពាជការអាណាព្យាបាល ទ្រង់ប្រទាន ប្រគេនមេដៃយ ១ ទៀតឈ្មោះមុនី-
សារករណៈ ។ តទ្រង ៤ ឆ្នាំមកទៀត ព្រះករុណាជាម្ចាស់ដ៏វិតលើតម្បូង
ទ្រង់លោកគូវែរណើរហ្សីណាល់ ប៉ាស្តើយោ បានប្រទាន ប្រគេនគ្រឿង
ឥស្សរិយយស ១ ទៀតឈ្មោះមេដៃយអស្សរិន្ទ ដោយលោកមានគុណ
បំណាច់ទ្រង់ពាជការ ។

លុះចំណោមកទៀត លោកយោគព្រះទ័យខ្ពុកជាក់ទំរក្សាព្រះពុទ្ធ
សាសនា ទ្រង់កិច្ចការក្រៅដំណែលរបស់ពាជការដែលកើតមានក្នុងវត្ត មិន
ឲ្យវិនាសប្បាត់បង់ឡើយ; ទាំងបានបបួលធ្វើសកម្មភាសិការដើងវត្ត ឲ្យចូល
ជាព្រៃវៃត្រចិងក ១ បប់ ខ្ពុកសម្រាប់ឲ្យកុលបុត្រសិក្សាតឡើយ ។

លុះដល់ជន្មាយុ ៦៧ ឆ្នាំ លោកក៏មានកេតស្លឹកបណ្តាលឲ្យដើងក្នុង
ការជាយ, ពួកសិស្សាខ្ពុសិស្សរកថ្នាំមកព្យាបាល ក៏គ្រាន់តែបានធូរ
បន្តិចៗជាបមក ។

ដល់មកជន្មាយុ ៦៨ ឆ្នាំ កេតនោះបណ្តាលឲ្យដើងម្តងទៀត ខ្លាំង
លើសដើម រកថ្នាំតែមិនបាន គាន់តែខ្លាំងឡើងៗរាល់ថ្ងៃ មិនបានធូរ
ថយសោះ ។

ដល់មកថ្ងៃ ១ កើតខែកត្តិកឆ្នាំមមីចត្វាស័ក ព.ស. ២៤៨៥ គឺថ្ងៃ ៨
ខែវ្រឹស្ចិកឆ្នាំ ១៩៤២ នេះ ពេលម៉ោង ៩ យប់ លោកដឹងច្បាស់ថា

ខ្ញុំនេះលោកមិនជាទេ លោកឲ្យហៅតិក្ខុសាមណេរនៅក្នុងវត្តចាំងអស់មកប្រាប់ថា " ខ្ញុំមិនជាទេលោក, សូមលោកចាំងអស់គ្នានៅឲ្យសុខសប្បាយចុះ ហើយចំយកចិត្តទុកដាក់រៀនសូត្រឲ្យបានមាំមួនទៅមុខ " លោកមានន័យយ៉ាងស្រស់ត្រឹងជាច្រើន; ដល់ពេលម៉ោង ១២ យប់អ-ធ្រាត្រ លោកក៏ទទួលអនិច្ចធម្មចំពោះមុខសិស្សានុសិស្ស ទាំងឧបាសក ឧបាសិកា ដែលមកជួយថែរក្សាក្នុងទីនោះ ។ ពួកសិស្សានុសិស្សក៏បានលើកសពដាក់ក្នុងក្តារមឈូស ដែលរចនាដោយក្បាច់ពណ៌ផ្សេងៗ ហើយដាក់លើបញ្ជូ ៣ ជាន់ ដំកល់សពនៅក្នុងកុដិរបស់លោក បានធ្វើបុណ្យទក្ខិណានុប្បទានចំនួន ៣ ថ្ងៃ ប្រគេនកុសលចំពោះលោក, ហើយដំកល់សពចុងចំនួន ៥ ថ្ងៃ ។

លុះដល់មកថ្ងៃ ១៣ កើតខែចេត្រ ឆ្នាំមមែបញ្ចស័ក ព. ស. ២៤៨៥, គឺថ្ងៃ ១៧ ខែអាវិលឆ្នាំ ១៩៤៣ បានរំកិលសពចេញពីលើកុដិមកប្រទក្សិណជុំវិញវត្ត ហើយមកដំកល់ក្នុងជាកំយ៉តមានកំពស់ ១២ ម៉ែត្រដែលតាក់តែងដោយត្រឹងផ្សេងៗ នៅខាងកើតវត្ត ។

ដល់ថ្ងៃ ១៤ កើត ខែ-ឆ្នាំជវដែល គឺ ១៩ អាវិលឆ្នាំ ១៩៤៣ បានឯកឧត្តមសម្តេចសង្ឃនាយកព្រះនាម ហ៊ិន គណមហានិកាយ ទាំងព្រះតេជៈព្រះគុណព្រះពុទ្ធឃោសាចារ្យ ចាងហ្វាងសាលាចូលរួមជាន់ខ្ពស់, ព្រមទាំងព្រះសង្ឃគ្រប់វត្តក្នុងស្រុកកំពង់ត្រាច ទាំងអញ្ជើញអស់លោកមន្ត្រី

ធំ-គួច មានលោកឡឺវេស៊ុដង់ត៍ ទំនងលោកចៅហ្វាយខេត្តកំពត លោកចៅហ្វាយស្រុក កំពង់គ្រាច លោកម៉ាទីពូដ៍ លោកកង់ប៊ីហ្ស៊ូ, ទំនងលោកឯទៀតៗច្រើន អញ្ជើញមកកន្លែងការសុបណ្យនេះ មានចាំងពួកមាហានក្រុមរក្សាស្រុក ពួកយុវនជាច្រើននាក់; ដល់ពេលម៉ោង ៩ ល្ងាច សម្តេចទំនងអស់លោកមន្ត្រីធំ-គួច កាន់ជ្ញាចន្លុះចៅបួជាសព រួចហើយ សម្តេចសង្ឃនាយកកាន់ទៀនដុតធូបកាំជ្ជបសំរែកសត្តបួជា រំលាយសព ពួកក្រុមមាហាន ទំនងពួកយុវនតំនាំបន់សព ទំនងគ្រឿងឥស្សរិយយស (មេដៃយ) តាមទំនៀម ។

ដល់ថ្ងៃ១៩ កើតខែ-ឆ្នាំរដែល គឺ១៩ កក្រិលឆ្នាំ១៩៤៣ សង្គ្រាយ-នាជាកិច្ចឆ្លងបុណ្យ ហើយរើសអដ្ឋិធាតុជាក់កង់គោជដំកល់ទុកកង់វត្ត សុរតិ៍ មានលោកគ្រូ ជិន-នាក់ ជាចៅអធិការថ្មី ជាអ្នកថែរក្សាតទៅ ។

ចប់ប្រវត្តិលោកគ្រូចៅអធិការ ពៅ-ង៉ែត

វត្តអង្គសុរតិ ឃុំកន្ទោរ-កំពង់គ្រាច-កំពត ។

របស់លោកគ្រូចៅអធិការ ជិន-នាក់

អំពីចៅអធិការនៃវត្តមន្ត្រីសង្ឃ

ដែលទើបតាំងថ្មីក្នុងភូមិភាគទី២ ឆ្នាំ-ឆ្នាំ ១៩៤៣

១- សញ្ញាប័ត្រលេខ ២៧ចុះថ្ងៃ ៤-៥-៤៣ តាំងគ្រូសូត្រ លឹម-គន់ កើតឆ្នាំច អាយុ ៣៣ វស្សា ១៣ នាមធាយា ញាណវរោ ជាចៅអធិការវត្តសូភ័ ឃុំទឹកវិល ស្រុកស្អាង (កណ្តាល) ។

២- សញ្ញាប័ត្រលេខ ២៨ ចុះថ្ងៃ ៤-៥-៤៣ តាំងគ្រូសូត្រ រ័ត-ឡុង កើតឆ្នាំម្សាញ់ អាយុ ៣៩ វស្សា ១៩ នាមធាយា ព្រហ្មវង្សោ ជាចៅអធិការវត្តពពែត ឃុំពពែត ស្រុកស្វាយចាប (ស្វាយរៀង) ។

៣- សញ្ញាប័ត្រលេខ ២៩ ចុះថ្ងៃ ៤-៥-៤៣ តាំងគ្រូសូត្រ ត្រាប-អ៊ូច កើតឆ្នាំវក អាយុ ៣៩ វស្សា ១៩ នាមធាយា ចន្ទសរោ ជាចៅអធិការវត្តកំស្រែ ឃុំកដមន្ទីរ ស្រុកស្វាយចាប (ស្វាយរៀង) ។

៤- សញ្ញាប័ត្រលេខ ៣០ ចុះថ្ងៃ ៤-៥-៤៣ តាំងគ្រូសូត្រ សុខ-អ៊ុន កើតឆ្នាំវក អាយុ ៤៨ វស្សា ២៨ នាមយាធា សីលវិសុទ្ធិ ជាចៅអធិការវត្តព្រះពន្ធា ឃុំព្រះពន្ធា ស្រុកស្វាយចាប (ស្វាយរៀង) ។

៥- សញ្ញាប័ត្រលេខ ៣១ ចុះថ្ងៃ ៤-៥-៤៣ តាំងគ្រូសូត្រសោម-ទូ កើតឆ្នាំមមែ អាយុ ៤៩ វស្សា ២៨ នាមធាយា ទន្ទុត្តរោ ជាចៅអធិការវត្តទុម្ពរ ឃុំបទីស្វា ស្រុកកណ្តាលស្ទឹង (កណ្តាល) ។

៦- សញ្ញាប័ត្រលេខ ៣២ ចុះថ្ងៃ ៤-៥-៤៣ តាំងត្រួសូត្រនូ ឈួយ កើតឆ្នាំកុរ អាយុ ៥៥ វស្សា ២៩ នាមធាយ ធម្មសរ ជាព្រះគ្រូវតនសាគរ ចៅអធិការវត្តកំពង់ឃ្លាំង ឃុំកំពង់ឃ្លាំង ស្រុកដង្កៃក្រង (សៀមរាប) ។

៧- សញ្ញាប័ត្រលេខ ៣៣ ចុះថ្ងៃ ២១-៥-៤៣ តាំងត្រួសូត្រ ជ្រាក់-ខន់ កើតឆ្នាំមមី អាយុ ៥១ វស្សា ៣១ នាមធាយ ឥន្ទបញ្ញា ជាចៅអធិការវត្តសម៉ ឃុំត្រែពញ្ញ ស្រុកពាក់ឯ (ត្រែងវែង) ។

៨- សញ្ញាប័ត្រលេខ ៣៤ ចុះថ្ងៃ ២១-៥-៤៣ តាំងត្រួសូត្រ ស្ងួន-សៅ កើតឆ្នាំកុរ អាយុ ៣២ វស្សា ១២ នាមធាយ ព្រហ្មជោត ជាចៅអធិការវត្តខ្ចប ស្រុកស្អាង (កណ្តាល) ។

៩- សញ្ញាប័ត្រលេខ ៣៥ ចុះថ្ងៃ ២១-៥-៤៣ តាំងត្រួសូត្រ ឥន្ទ-ម៉ី កើតឆ្នាំឆ្លូវ អាយុ ៤២ វស្សា ២១ នាមធាយ យសគ្គោ ជាចៅអធិការវត្តតានូ ឃុំសំបួរ ស្រុករំដួល (ស្វាយរៀង) ។

១០- សញ្ញាប័ត្រលេខ ៣៦ ចុះថ្ងៃ ២១-៥-៤៣ តាំងត្រួសូត្រ សេក-ជ្រាក់ កើតឆ្នាំមមែ អាយុ ៦១ វស្សា ៤១ នាមធាយ ព្រហ្មគ្គោ ជាចៅអធិការវត្តចម្ការលើក ឃុំតាកេម ស្រុកត្រាំកក់ (តាកែវ) ។

១១- សញ្ញាប័ត្រលេខ ៣៧ ចុះថ្ងៃ ២១-៥-៤៣ តាំងត្រួសូត្រ ប៊ី-អ៊ុយ កើតឆ្នាំច អាយុ ៤៥ វស្សា ២៤ នាមធាយ ឥន្ទសរ ជាចៅអធិ-ការវត្តត្រែ ឃុំធ្លក ស្រុករំដួល (ស្វាយរៀង) ។

១២- សញ្ញាប័ត្រលេខ ៣៨ ចុះថ្ងៃ ២១ - ៥ - ៤៣ តាំងគ្រូសូត្រ ហួត-អ៉ិន កើតឆ្នាំខាល អាយុ ២៨ វស្សា ៨ នាមធាយោ ធម្មជោត ជាចៅអធិការ វត្តព្រលើ ឃុំផ្សារលើ ស្រុកចាកាន (ខេត្តសាត់) ។

១៣- សញ្ញាប័ត្រលេខ ៣៩ ចុះថ្ងៃ ២១ -៥- ៤៣ តាំងគ្រូសូត្រ ស-ខួច កើតឆ្នាំថោះ អាយុ ៤១ វស្សា ១៩ នាមធាយោ ធម្មត្ថេរ ជាចៅអធិការ វត្តគោកអញ្ចាន់ ឃុំចោមចៅ ស្រុកកំពង់ត្រាញ (កណ្តាល) ។

១៤- សញ្ញាប័ត្រលេខ ៤០ ចុះថ្ងៃ ២១ -៥- ៤៣ តាំងគ្រូសូត្រ ខា-ជន កើតឆ្នាំមមី អាយុ ២៥ វស្សា ៦ នាមធាយោ ធម្មចារោ ជាចៅអធិការវត្តស្រែល ឃុំត្រា ស្រុកកណ្តាលស្ទឹង (កណ្តាល) ។

១៥- សញ្ញាប័ត្រលេខ ៤២ ចុះថ្ងៃ ២៨-៥-៤៣ តាំងព្រះគ្រូ អមរបញ្ញាប៉ែន-ម៉ា អាយុ . . . វស្សា . . . នាយោ . . . ជាទីព្រះសិរីសម្ភតិវង្សកជាគណៈសម្រាប់ត្រី ។

១៦- សញ្ញាប័ត្រលេខ ៤៣ ចុះថ្ងៃ ២-៦-៤៣ តាំងព្រះធម្មវិរិយ-ត្រីខ្ចៃ អុក-ស្រែ អាយុ ៧៦ វស្សា ៥០ ធាយោ . . . ជាទីព្រះសុធម្ម-ធិបតី, សង្ឃនាយកគណធម្មយុត្តិ ។

១៧- សញ្ញាប័ត្រលេខ ៤៤ ចុះថ្ងៃ ២-៦-៤៣ តាំងព្រះវិមលធម្ម កែច-គួន អាយុ ៦៤ វស្សា ៤៣ ធាយោ . . . ជាទីព្រះមង្គលខេត្តាចារ្យ ទីពាជាគណៈសម្រាប់ឯក ។

១៨- សញ្ញាប័ត្រលេខ ៤១ ចុះថ្ងៃ ១-៦-៤៣ តាំងត្រួសូត្រ មាស-សោម កើតឆ្នាំថោះ អាយុ ៥៣ វស្សា ៣៣ ឆាយា សុធម្មត្ថេរ ជាទីហៅអធិការវត្តសំពេងបុរី ឃុំព្រៃ ស្រុកកំពង់ត្រែក (ព្រៃវែង) ។

១៩- សញ្ញាប័ត្រលេខ ៤២ ចុះថ្ងៃ ១-៦-៤៣ តាំងត្រួសូត្រ មាយ-ឃឹម កើតឆ្នាំវក អាយុ ៣៦ វស្សា ១៦ ឆាយាមហាពស្ស ជាទីហៅអធិការវត្តព្រះស្រីសារពេជ្ជ ឃុំតាគោក ស្រុកកំពង់ត្រែក ។

២០- សញ្ញាប័ត្រលេខ ៤៣ ចុះថ្ងៃ ១-៦-៤៣ តាំងត្រួសូត្រ ម៉ែន-សាង កើតឆ្នាំកេង អាយុ ២៩ វស្សា ៦ ឆាយា មុនីបញ្ញា ជាទីហៅអធិការវត្តសាន្តរ ឃុំសាន្តរ ស្រុកកំពង់ស្វាយ (កំពង់ធំ) ។

២១- សញ្ញាប័ត្រលេខ ៤៤ ចុះថ្ងៃ ១-៦-៤៣ តាំងត្រួសូត្រ ជឹង-ឹម កើតឆ្នាំវក អាយុ ២៤ វស្សា ៤ ឆាយា ចន្ទសិរោ ជាទីហៅអធិការវត្តជាច ឃុំជាច ស្រុកកំចាយមា (ព្រៃវែង) ។

២២- សញ្ញាប័ត្រលេខ ៤៥ ចុះថ្ងៃ ១-៦-៤៣ តាំងត្រួសូត្រ ងិន-ងិម កើតឆ្នាំវក អាយុ ២៤ វស្សា ៤ ឆាយា ចន្ទបញ្ញា ជាទីហៅអធិការវត្តមង្គលគិរី ឃុំព្រៃរំដេង ស្រុកគិរីវង្ស (តាកែវ) ។

២៣- សញ្ញាប័ត្រលេខ ៤៦ ចុះថ្ងៃ ៧-៦-៤៣ តាំងត្រួសូត្រ ស៊ុន-សាង កើតឆ្នាំជូត អាយុ ៤៣ វស្សា ២២ ឆាយា ធម្មសារ ជាទីហៅអធិការវត្តសំពេង ឃុំភូមិថ្មី ស្រុកគ្រូចឆ្មារ (ត្រាំង) ។

២៤- សញ្ញាប័ត្រលេខ ៤៧ ចុះថ្ងៃ ៧-៦-៤៣ តាំងគ្រូសូត្រ វង់-
កែវ កើតឆ្នាំកេង អាយុ ៣៨វស្សា ១៩ ឆាយា ធម្មសារោ ជាចៅអធិការ
វត្តព្រះធម្មវៃត្រ ឃុំផ្សារដែក ស្រុកពញាឮ (កណ្តាល) ។

២៥- សញ្ញាប័ត្រលេខ ៤៨ ចុះថ្ងៃ ៧-៦-៤៣ តាំងគ្រូសូត្រ
ប៉ែន-ខ្លូ កើតឆ្នាំរកា អាយុ ៧០ វស្សា ៤៥ ឆាយា ទន្តសារ ជាចៅ
អធិការវត្តសត្ប ឃុំសត្ប ស្រុកស្អាង (កណ្តាល) ។

២៦- សញ្ញាប័ត្រលេខ ៤៩ ចុះថ្ងៃ ៧-៦-៤៣ តាំងគ្រូសូត្រ
គង់-ខ្លួន កើតឆ្នាំមមី អាយុ ៦១ វស្សា ៤០ ឆាយា មុនីបញ្ញាវរ ជា
ចៅអធិការវត្តភាមព្រៃកគយ ឃុំភាមព្រៃកគយ ស្រុកស្អាង ។

២៧- សញ្ញាប័ត្រលេខ ៥០ ចុះថ្ងៃ ៧-៦-៤៣ តាំងគ្រូសូត្រ
ភ័ន-អ៊ុក កើតឆ្នាំមមែ អាយុ ៤៥ វស្សា ៦ ឆាយា សំវរតេរ ជាចៅ
អធិការវត្តព្រៃកដើងគ្រាន លើ ឃុំព្រៃកដើងគ្រាន ស្រុកស៊ុជរ
កណ្តាល (ព្រៃវែង) ។

២៨- សញ្ញាប័ត្រលេខ ៥១ ចុះថ្ងៃ ៧-៦-៤៣ តាំងគ្រូសូត្រ
ខន-ប៊ូ កើតឆ្នាំច្រូ អាយុ ៣១ វស្សា ១០ ឆាយា ព្រហ្មបញ្ញា ជាចៅ
អធិការវត្តខ័ពេជ ឃុំខ័ពេជ ស្រុកកំពង់ស្វាយ (កំពង់ធំ) ។

២៩- សញ្ញាប័ត្រលេខ ៥២ ចុះថ្ងៃ ១៤-៦-៤៣ តាំងត្រួសត្រៃបៃ-អិត កើតឆ្នាំមមី អាយុ ២៦ វស្សា ៥ ខែ ជាយោ សុវណ្ណត្ថេរ ជាទីរៀបអធិការវត្តត្រែសាំងជ្រំ ឃុំត្រែស ស្រុកជ័យសែន (ស្វាយរៀង) ។

អំពីអនុញ្ញាតឲ្យធ្វើបុណ្យបញ្ចុះសីមា

នៅឆ្នាំ ៣ (រាជអំណែនមើ ១៩៤៣)

១- ចុតហ្មាយលេខ ១០៣ ចុះថ្ងៃ ២៦-២-៤៣ អនុញ្ញាតឲ្យ អាចារ្យ សុខ-អឹម សម្រាប់វត្តអំពិលទឹក ឃុំអំពិលទឹក ស្រុកកំពង់ត្រឡាច (កំពង់ឆ្នាំង) ធ្វើបុណ្យបញ្ចុះសីមាវត្តនេះចំនួន ៣ ថ្ងៃ គិតតាំងពីថ្ងៃ ១០ ដល់ ១២ មើ ១៩៤៣ ។

២- ចុតហ្មាយលេខ ១៣៦ ចុះថ្ងៃ ២៩-៣-៤៣ អនុញ្ញាតឲ្យ ឈ្មោះ ណឹម-អ៊ុង ជាអាចារ្យសម្រាប់វត្តសិរីមង្គល ឃុំបុងជាង ស្រុកត្បូងឃ្មុំ (កំពង់ចាម) ធ្វើបុណ្យបញ្ចុះសីមាវត្តនេះ ៣ ថ្ងៃ គិតពីថ្ងៃ ១២ ដល់ថ្ងៃ ១៤ មើ ១៩៤៣ ។

៣- ចុតហ្មាយលេខ ១៣៧ ចុះថ្ងៃ ២៩-៣-៤៣ អនុញ្ញាតឲ្យ ឈ្មោះ ជឹម-ជា ជាអាចារ្យសម្រាប់វត្ត តុសិតារាម ឃុំព្រៃអណ្តូង ស្រុកស្ទឹងត្រែង (កំពង់ចាម) ធ្វើបុណ្យបញ្ចុះសីមាវត្តនេះ ៣ ថ្ងៃ គិតពីថ្ងៃ ២៦ ដល់ ២៨ មើ ១៩៤៣ ។

៨- ចុតហ្នាយលេខ ១៩៧ ចុះថ្ងៃ ២០-៤-៤៣ អនុញ្ញាតឲ្យ ឈ្មោះ ស្រេង-ខន់ អាចារ្យសម្រាប់វត្តកោះខ្នុរ ឃុំព្រៃតរកា ស្រុក កណ្តាលស្ទឹង (កណ្តាល) ធ្វើបុណ្យបញ្ចុះសីមាវត្តនេះ ៤ ថ្ងៃ គិតពីថ្ងៃ ១៤ ដល់ ១៧ ម៉ែ ១៩៤៣ ។

៩- ចុតហ្នាយលេខ ១៨១ ចុះថ្ងៃ ២៥-៥-៤៣ អនុញ្ញាតឲ្យឈ្មោះ ស្ង-កឹម អាចារ្យសម្រាប់វត្តបុប្ផាវដ្តី ឃុំផុង ស្រុកគងពីសី (កំពង់ស្ពឺ) ធ្វើបុណ្យបញ្ចុះសីមាវត្តនេះ ៣ ថ្ងៃ គិតពីថ្ងៃ ២០ ដល់ ២៣ ម៉ែ ១៩៤៣ ។

១- ចុតហ្នាយលេខ ១៨៧ ចុះថ្ងៃ ២៧-៥-៤៣ អនុញ្ញាតឲ្យឈ្មោះ សុំន-នន អាចារ្យសម្រាប់វត្តស្រែស្រង់ ឃុំសែនដី ស្រុកសំរោងទង (កំពង់ស្ពឺ) ធ្វើបុណ្យបញ្ចុះសីមាវត្តនេះ ៤ ថ្ងៃ គិតពីថ្ងៃ ១៤ ដល់ ១៧ ម៉ែ ១៩៤៣ ។

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចោះពុម្ពផ្សាយ
អំពីពុទ្ធសាសនៈបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនធំពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ កៅ-សុីម អ្នកត្រួតត្រា
សិស្សនៅសាលាបាលីជាន់ខ្ពស់

ឆ្នាំទីវៀន

ផ្នែកអក្សរសាស្ត្រ		ទំព័រ
លោកគ្រូព្រះអាចារ្យ ញាង-សុខ	និទានសុភាសិត ទី ១	៥៥១
អ្នកអាចារ្យ គឹម-អាន	រឿងព្រះជាទអសោកធម៌ហាកដ (តទៅ) . . .	៥៥៥
ផ្នែកសាសនា		
ព្រះគ្រូញាណសំវរៈញាណ-ឈឺ	លោកធម្មសូត្រ	៥៩៣
ដំណឹងអំពីក្រសួងធម្មការ	អំពីតាំងពៅឯធំការ	៦០៤

ឆ្នាំទំរង់ទី ១៥ — លេខ ១០ ខែធ្នូ ឆ្នាំប្រើ ១៩៤៣ — ដំឡៃជាវ: ១ ឆ្នាំ ១០ រៀល ។

KAMBUJASURIYĀ

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire : Khun Nibandhamantri Nhok-Thèm, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse : Vénérable Kao-Sim, Surveillant général de l'Ecole Supérieure de Pāli.

TABLE DES MATIÈRES

Partie littéraire

		Pages
Vénérable Achar Peang-Sok	Nĭtean Sŏp'easĕt, 1	551
Feu l'achar Kim-An	Légende de l'Empereur d'Açoka de l'Inde antique (suite)	557

Partie religieuse

Préah Ñānasamvara Nhean-Ch'œn	Lokadhammasūtra	593
Communiqué du Département des Cultes.	Nominations de Chau Âţ'ika.....	604

15e année — N° 10 Octobre 1943 — Abonnement: un an 10$00.

លោកគ្រូអាចារ្យ ញាង-សុខ ក្រុមជំនុំព្រះវិន័យបិដក

ប្រែនិងរៀបរៀង

១-ទិដ្ឋំ ទិដ្ឋេយ្យំ ទិដ្ឋព្វសុទ្ធ អក្ខាមោ
តំ បហាយិតរំ លោតិ ស វេ បច្ចានុតប្បតិ ។

ត្រូវអត់ត្រាំការណ៍ណា ដែលអាត្មាល្មមអត់បាន
ជនមិនស្គាល់ប្រមាណ អត់មិនបានការណ៍ល្មមសៃ ។
លះការណ៍ល្មមសៃលះក ស្រាប់យកការណ៍ដទៃ
ជននោះមិនប្រពៃ ការដទៃតែងស្តាយរាល់កាយ ។

២-ដើម្បីប្រែនិងបញ្ជាក់សុភាសិតនេះ ខ្ញុំនឹងស្រង់កុក្កដវត្ថុ[1] យកមកដំណាលតទៅនេះតទៅ កុក្កដវត្ថុនោះដាច់ពាក្យណាវត្ថុ[2] ។

កុក្កដជាតិ

៣-ឮថា កន្លងសម័យមួយពួកមានទេវតាមិនសុខចិត្តព្រោះតែពួកមនុស្ស បះតែស៊ីពួកញាតិរបស់ខ្លួន ទើបហៅគ្នីគ្នាមកប្រជុំគ្រប់គ្រាហើយប្រឹក្សាគ្នាថា ពួកយើងគិតធ្វើដូចម្តេចហ្ន៎ ដើម្បីកុំឲ្យពួកមនុស្ស

---

១ រឿងភ័ព្វរបស់មាន់ ។ ២ រឿងភ័ព្វវិលមានក្នុងកាលមុន (ក្នុងកាលពីព្រេង) រឿងព្រេង. រឿងភ័ព្វវិលពួកមនុស្សពីដើមដំណាល ។

ស៊ីបានទៀត ។ បណ្តាមាន់ទាំងនោះ មានមាន់មួយឆ្លើយថា គ្មានយើងមើយ? ពួកយើងបួរទៅនៅក្នុងព្រៃជ្រកកោនពីងពួនលាក់ខ្លួនសម្ងំនៅទៀនកោះនៃភ្នំទើបរួចអំពីកណ្តាប់ដៃរបស់ពួកមនុស្ស ។ មាន់មួយទៀតឆ្លើយទទឹងថា មិនរួច ទេ ពួកយើងតង់តែពួកមនុស្សស៊ីបានផង ពួកសត្វឯទៀតមានសំពោធនឹងកន្ត្រាំងជាដើមស៊ីបានផង អ្នកទាំងឡាយបួរស្តាប់ពាក្យខ្ញុំ ពួកយើងគិតគេណ្តែតលឆ្លើសគ្រាម[1] ទើពួកមនុស្សវិញ បើយ៉ាងនេះទើបរួចអំពីកណ្តាប់ដៃរបស់ពួកគេ ។ មាន់មួយជាទៀតឆ្លើយទទឹងថា មិនរួចទេបើពួកយើងគិតឆ្លើយ៉ាងនោះ តើបាននៅគ្រឿងអាវុធយុទ្ធក័ណ្តអំពីណា? ដើម្បីច្បាំងយុទ្ធ[2] ទើពួកគេបាន ពួកយើងមិនអាចតស៊ូនឹងពួកគេទេ ពួកយើងគិតទាំងគ្នាទៅសូមពរអំពីព្រះឥន្ទ្រវិញ ដើម្បីកុំឲ្យពួកមនុស្សស៊ីពួកយើងបាន ព្រះឥន្ទ្រទើងហាមប្រាមពួកមនុស្សតាមសេចក្តីសូមរបស់ពួកយើងមិនខាន ។ មាន់មួយជាទៀតឆ្លើយបណ្តាយផង ទទឹងផងថា គ្រប់ហើយ ប៉ុន្តែពួកយើងកុំទៅព្រៃចន្ទាខ្ចាចព្រៃងពួកខ្លែតាផ្តើលជ្រលដើមគិតថា ពួកយើងគេណ្តែតលទៅបង្ករឹងជណ្តើមពីជ្រលរបស់ព្រះឥន្ទ្រ វរ ។ ពួកខ្លែតាដេញចំលាក់ពួកយើង បើដូច្នេះ ពួកយើងមុខជាទើងខ្លួលរងគ្រោះជួជក[3]មិនខាន ពួកយើងត្រូវ

---

* ចំចាំង, ការគស៊ី ។ ២ ច្បាំងគ្នា, ច្បាំងតាំងផល, ប្រកាយប្រឡូកគ្នា ។ ៣ គ្រោះរបស់ដួងឯកព្រហ្មណ៍ (គ្រោះនៃលេខតាំងការទាំងមិនបាន) ។

ជ្រើសរើសកែតែអ្នកណាមួយ ដែលជាអ្នកម៉ឺងម៉ាត់អាចទៅសូមពរអំពីព្រះ
ឥន្ទ្រតែប៉ុណ្ណោះវិញស្រួលជាង ។ ពួកមាន់ចាំងអស់ទ្វើយបណ្តោយព្រម
គ្នាថា ចំជាត្រូវ ទើបជ្រើសរើសកែមាន់បែបនោះ ឃានឃើញមាន់គក
១ មាគ្រចន្ទ្រាំងហើយពិភាក្សាគ្នាថា ពាល់តែគេនេះទើបអាចទៅសូម
ពរបាន រួចបង្គាប់មាន់គកនោះថា នែអាគកអើយ! ឯងចូរទៅលួចំរើបស់
ពួកយើង ពួកយើងត្រូវការប្រើឯងឲ្យទៅសូមពរអំពីព្រះឥន្ទ្រ ពេលព្រឹក
ថ្ងៃស្អែកឯងចូរវៀបចំខ្លួនទៅហ្ន៎:! មាន់គកទទួលចំរើថា អើ ហើយញ៉ាំង
កាលដ៏សេសសល់អំពីថ្ងៃនោះនឹងពន្លឺនោះឲ្យគក្ខឹងហួសទៅ ដល់ពេល
ព្រឹកឡើងក៏វៀបចំខ្លួនទៅកាន់សំណាក់ព្រះឥន្ទ្រហើយថ្វាយបង្គំឈរទៅ
ក្នុងទីសមគួរ ។ ព្រះឥន្ទ្រឃានឃើញមាន់គកដែលឈរនៅក្នុងទីសម-
គួរហើយ ទ្រង់នឹកសន្ទិះសង្ស័យថា មាន់គកនេះមានកិច្ចអ្វីអេះ កាល
ដែលទ្រង់សួរមាន់គកដើម្បីជ្រាបកិច្ចនោះបានត្រាស់តាមថានេះយ៉ាងនេះគឺ:

៤- ឥធាគតោ កិមត្ថំ តេ ព្រូហាសរិ កុក្កុដ
ទុម្មនោ បតិតក្ខន្ធោ តម្មេ អក្ខាហិ បុច្ឆិតោ ។

ម្នៃអាគកអើយ ឯងបានមកហើយ ដោយខុនលំពោន ឯងសោត
កើតទុក្ខ មានមុខស្រពោន មានខ្លួនកំប្រុន តើត្រូវការអ្វី ។ អាគក
ចូរទ្វើយ យើងសួរឯងហើយ ចង់ដឹងសេចក្តី ឯងមកដោយត្រង់ ឬចង់
បានអ្វី ចូរឆ្លើយមក ប្រាប់យើងឲ្យត្រង់ ។

មានគតកាលដែលគ្រាបទូលរឿងនោះដល់ព្រះឥន្ទ្រ ក៏បានពោលគាថានេះយ៉ាងនេះ គឺ:

៥- យញ្ញាតយោ មនុស្សា នោ កត្តុ ការំ សុ អត្តនោ
សោតោ តេនត្ថំ អម្ហាកំ ឃរំ ជាជាម វាសវ ។

បពិត្រព្រះវាសវៈ: ខ្ញុំជាទាវ: ជាអ្នកថ្លង់ថ្លើង ពួកមនុស្សស៊ីញាតិជាជាតិនៃយើង ស៊ីវែតរលើង រលំចាត់ជាតិ ។ ហេតុនោះយើងក្តៅសោយសោកសុបរសៅ ព្រោះគេស៊ីញាតិ ព្រះអង្គសូមសួយ គឺជួយទ្រឹឃ្នាត ស្រោចស្រង់ពួកញាតិ នៃយើងឲ្យទាន ។

៦- កាលដែលមានគតគ្រាបទូលរឿងដល់ព្រះឥន្ទ្រយ៉ាងនេះហើយ បណ្តាពួកស្ត្រីទេពអប្សរដែលអង្គុយគាល់ព្រះឥន្ទ្រក្នុងសម័យនោះ មានស្ត្រីទេពអប្សរម្នាក់សាបមាត់ព្រោះយើញមានគត ហើយគ្រាបទូលព្រះឥន្ទ្រថា បពិត្រព្រះឧបបត្តិទេព ជាតិមានទំនងជាមានសាច់មានវសធ្លាញ់មែន ចានជាពួកមនុស្សចូលចិត្តស៊ី ខ្ញុំលព្រះបង្គំសាបមាត់ ចង់ក្តាប់សាច់អាតកនេះលមើល តើវសវបស់សាច់ធ្លាញ់យ៉ាងណាទៅអេះ សូមព្រះអង្គប្រទានអាតកដល់ខ្ញុំលព្រះបង្គំដោយអនុគ្រោះឲ្យទាន ។

៧- កាលបើស្ត្រីទេពអប្សរគ្រាបទូលចំណង់វបស់ខ្លួនដល់ព្រះឥន្ទ្រយ៉ាងនេះហើយ មានគតក្តៅហើយក៏តិតក័យញ៉ាំខ្លួនចំប្រប់តិតថា

អញ្ជាំងាលដែលខ្លួលចំរើតួកញាតិមកកុងទីនេះ គឺមកដើម្បីពឹងពរព្រះ
អន្ទ្រ គឺឲ្យព្រះអន្ទ្រដោះខ្លួនឲ្យរួចអំពីកណ្តាប់ដៃរបស់តួកមនុស្ស ឥឡូវ
នេះមានគេចង់ស៊ីសាច់អញក្នុងទីនេះទៀត ទីនេះក៏ដូចទីនោះ បើដូច្នេះ
អញមិនខ្លាមកទេ ហើយក៏ថយក្រោយទៅសាស ។ បែរត្រឡប់តមក
មនុស្សលោកវិញដោយឆ្ងាប់ឆ្ងាល់ ។ ឯណាតួកមាន់ដែលបាន
ឃើញមាន់គកកំពុងរត់មកអំពីចម្ងាយហើយនឹងសង្ឃឹមថាសេចក្តីថ្មីថ្មា
របស់ខ្លួនបានដល់ទីបំផុតហើយ មានមាន់ចៃមួយស្រែកសួរមាន់គកថាដូច
ម្តេច អាគក? មាន់គកឆ្លើយថា ដូច! ជា! ដូច! មាន់ចៃស្ទាប់
សេចក្តីមិនបាន សួរម្តងទៀតថា ដូចម្តេច អាគក? មានមាន់ពងមួយ
ស្តាប់សេចក្តីបាន (១) ក៏ឆ្លើយដួសមាន់គកថ្មាប់មាន់ចៃថា មិនកើតទេ
អាចៃ! ព្រោះហេតុនោះបានជាមាន់គកអាំវាថា ដូច! ជា! ដូច!
មាន់ពងអាំវាថា មិនកើតទេ អាចៃ! មាន់ចៃអាំវាថា ដូចម្តេច អាគក!
តាំងអំពីកាលនោះរៀងភមកដល់កាលនេះឯង ។ តួកមាន់ពាំងអស់
ពកគំនិតនឹកស្តាយក្រោយថា បើតួកយើងបានដឹងហេតុនេះមុន ម៉្លេះមិនៈ
ខ្លីប្រើចំរើឲ្យទៅពឹងពរទេ ដំណើរប្រើចំរើទៅនេះ ជាដំណើរសិយសៀវ
សោះ ល្ហើយចុះ តួកយើងបានជាពកដំណើរមកកើតកង់កំណើតមាន់
ហើយ ចូរកុំខ្វាចទឹកក្តៅ ទើបពោលតាមថ្លែងសេចក្តីស្តាយក្រោយថា:

១— ស្រុកខ្លះហៅថា "មាន់ចៃតាង" ។

๘- ឯវំ ពោ មហមំ ញាតេ មេសេ្ឋសុ្ឋញ្ញា ឧ ញាតកំ
មេសុ្ឋ អមេសុ្ឋយិម្ហា យំ តំ ឧ ត្វេវ វំ ឥធំ ។

បើរឿងយ៉ាន់នេះឯង យើងដឹងចែងជាក់ជាមុន ។
ម្ល៉ះយើងនឹងមិនសុំន លះបង់គុណគំនិតដើម ។
តីម្ល៉ះមិនប្រើញាតិ ដែលជាជាតិទៅអើតអើម
ស៊ូលះគំនិតដើម មិនបានសើមប្រយោជន៍អ្វី ។ (ចប់កុក្កុដវត្ថុ) ។

ធម្មសំរែកាព្យ

៩- តុមាន់ទាំងឡាយ រិះរកឧបាយ ដើម្បីកែកុន ខ្លួនចេញអំពី
គេស៊ីពេលមុន ស៊ូលះបង់គុណ នៃគំនិតខ្លួន ។ ជ្រើសរើសចំរើ បាន
ហើយក៏ប្រើ ឲ្យទៅតាំងភួន ព្រោះឥន្ទ្រិយ មានស្រើប្រថួន តីបង់
ស៊ីខ្លួន ខ្ចៅតដូចជាដូច ។

សម្មុសា្សហនកថា:

១០- ព្រោះហេតុនោះ ភ្លក្ខជនដែលចង់រើគំនិតចាស់ចោលចេញ
ប្តូចង់រើខ្លួនចេញចាកទីចាស់ ត្រូវពិចារណាតិតកាញ់ឲ្យឃើញគុណរបស់
គំនិតថ្មី ឬ ទីថ្មីសិន សឹមរើគំនិតចាស់នោះចោលចេញ ឬ សឹមរើខ្លួន
ចេញចាកទីចាស់នោះ បើមិនទាន់ឃើញគុណទេ កុំគាល់រើឡើយ បើមិន
ដូច្នោះទេនឹងទឹកស្ពាយក្រោយ ដូចជាភ្លក្ខមានដែលរើគំនិតចាស់ចេញមិន
ទាន់បានឃើញគុណរបស់គំនិតថ្មីហើយស្ពាយក្រោយនោះឯងមិនខាន ។

លើចព្រះបរមគ្រូតាឯកជាថ្វាយបង្គំព្រះបាទព្រះថេរៈ ហើយលើកព្រះហស្តប្រណម្យឡើងត្រាស់ថា: "ឥឡូវនេះខ្ញុំមានប្រាថ្នាចង់សួរកាលនាគតជានោះដែលជាអ្នកបានឃើញព្រះសម្មាសម្ពុទ្ធ តើឃើញព្រះអង្គស្តេចទ្រង់ពុទ្ធដំណើរទៅក្នុងមគធាណាខ្លះ?"

គ្រានោះ ព្រះថេរៈហៅកាលនាគតជាថា "ចូរអ្នកមកឲ្យឆាប់! ចូរអ្នកមកឲ្យឆាប់! ព្រះពុទ្ធចង់សួរអ្នកអំពីកាលដែលអ្នកបានឃើញព្រះសម្មាសម្ពុទ្ធតើឃើញព្រះអង្គស្តេចទ្រង់ពុទ្ធដំណើរទៅក្នុងមគធាណាខ្លះ(*)" ។

ក្នុងខណៈនោះ កាលនាគតជាក៏ប្រាកដឡើងចូលមកជិតព្រះថេរៈលើកដៃប្រណម្យទូលថា: "ខ្ញុំព្រះថេរៈម្ចាស់! ព្រះករុណាមានត្រូវការអ្វី?"

ព្រះថេរៈថ្វាយព្រះពរព្រះមហាក្សត្រិយ៍ថា: "អ្នកនេះឯងហើយជាកាលនាគតជា ដែលបានសូត្រគាថាសរសើរព្រះសម្មាសម្ពុទ្ធនោះ" ។

គ្រានោះ ព្រះពុទ្ធប្រណម្យព្រះហស្តឡើងត្រាស់ទូវគាថានេះថា: "អ្នកបានឃើញព្រះភគវតៃ ព្រះអង្គឥតបុគ្គលប្រៀបស្មើ ព្រះអង្គមានឆវីវណ្ណក្នុងផ្លូវត្រចះ ហាក់ដូចជាពណ្ណនៃមាសដ្ឋិន ព្រះអង្គមានវង្វន់ព្រះកត្រដូចជាដួងព្រះចន្ទដ៏ពេញវង់ ចូរអ្នកសំដែងប្រាប់ខ្ញុំ អំពីគុណ-

---

* មហាវង្ស: ស្តេចប្រើប្រាស់មាសដោយឫទ្ធិ ឲ្យទៅបង្គំកាលនាគតជាមកថ្វាយព្រះអង្គ ។

សម្បត្តិរបស់ព្រះអង្គ គ្រាកាលដែលទ្រង់យាងត្រឡោះទៅកាន់តោធិព្រឹក្ស
នោះ" ។

នាគពជ្ឈូលតបថា: ដើម្បីនឹងនិយាយសរសើរសេចក្តីវុង្សវឿនរបស់
ព្រះមហាមុនីនោះមិនមានពាក្យដែលទំនងពោលសរសើរឲ្យត្រឹមស្មើបាន
ទេ ឥឡូវនេះខ្ញុំនឹងថ្វាយដោយសង្ខេបហើយនាគពជ្ឈពោលនូវគាថានេះថា:

"កាលដែលព្រះភ្នំទ្ធដាក់ព្រះបាទជួបនឹងផែនប្រថពី ក៏កុំនឹងខ្នេ
តាំងឡាយដែលតាំងនៅលើផែនដីតាំងមូលប៉ាំងខ្លួសឡើង ហើយ
មហាច្រកឥតក៏ញាប់ញ័រ ៦ ដង ព្រះស្មើផ្សាយអំពីតាយព្រះតថាគតគ្រប
ទៅលើតន្ទីព្រះបន្ទូនឹងព្រះអាទិត្យ ហើយភ្លឺវុង្សវឿនឆ្ងៀលភ្លាត់តាំងទៅ
កុងទិសតាំង ១០ ដើម្បីជាប្រយោជន៍ដល់សត្វលោកតាំងពួង" ។

ខាងគ្រាយកាសេនូនានោះ ព្រះមហាកស្សត្រាធិពជបានប្រែសេ
ច្យសាងព្រះស្តូបមួយខ្ពើងកុងស្ថានទីនោះ ហើយស្តេចយាងហួសទៅ
ទៀត ។

កុងលំដាប់នោះ ព្រះថេរៈនិមន្តត្រឡោះទៅកាន់តោធិព្រឹក្ស លុះដល់
ហើយលើកព្រះហស្តចង្អុលបង្ហាញព្រះពុទ្ធាថា: "តើត្រង់ស្ថានទីនេះឯង
ហើយ ដែលព្រះពោធិសត្វទ្រង់មានព្រះមហាករុណាដ៏ធំដល់លោកទ្រង់
បានឈ្នះនូវមានេនឹងតលនៃមារហើយបានអនុត្តរសម្មោធិញ្ញាណ ព្រះ
ពុទ្ធាទ្រង់ត្រាស់ទ្យសាងព្រះស្តូបមួយនៅត្រង់ស្ថានទីនោះ ហើយទ្រង់

ព្រះពុទ្ធគាន ទ្រង់ប្រមូលសែនដំឡឹងមាស ។ ព្រះថេរៈបានបង្ហាញថា: "គឺត្រង់ស្ថានទីនេះហើយ ដែលចាតុម្មហាភជបានថ្វាយបង្គំ ៤ ដល់ព្រះពុទ្ធ ព្រះតថាគតទទួលបាត្រនោះហើយទ្រង់ទះរួបបាត្រទាំងនោះដោយព្រះហស្ត[1] ហើយអធិដ្ឋានធ្វើជាបាត្រមួយ" ។

តពីនោះមក ព្រះថេរៈបានបង្ហាញស្ថានទីដែលពាណិជទាំងពីរ-រយ[2]បានថ្វាយភោជនាហារ (ដល់ព្រះពុទ្ធ) ហើយបង្ហាញស្ថានទីដែលព្រះភោធិសត្វ[3] ស្តេចចូលទៅកាន់សំណាក់ស្តេចនៅបេនារេស (ពារាណសី) ។

តពីនោះមក ព្រះថេរៈបានបង្ហាញស្ថានទីដែលព្រាហ្មណ៍ម្នាក់ពោលសរសើរព្រះពុទ្ធ ។ ព្រះរាជាបានត្រាស់ឲ្យសាងព្រះស្តូបនៅទីត្រង់កន្លែងដែលព្រះថេរៈបានបង្ហាញហើយនោះ។ ។ លំដាប់ពីនោះមក ព្រះថេរៈបាននាំព្រះរាជាទៅក្នុងវិត្រថ្មសិលាគុន: ហើយលើកព្រះហស្តខាងស្តាំឡើងចង្អុលបង្ហាញព្រះមហាក្សត្រិយ៍ថា "ត្រង់ទីនេះហើយមហាភជដែលព្រះតថាគតព្រះអង្គបានញុំាងធម្មចក្រដ៏ឋិរវរឲ្យប្រព្រឹត្តទៅ" ។

---

១ សៀវភៅព្រះពុទ្ធសាសនារបស់លោកល្វី-ហ្វីណូត់ និងលោកដុំ-មៅប្រែជាខ្មែរថា ព្រះសម្មាសម្ពុទ្ធទ្រង់ច្រូតបាត្រទាំង ៤ ធ្វើជាបាត្រ ១ ដោយឫទ្ធានុភាពរបស់ព្រះអង្គ ។ ២ សៀវភៅព្រះពុទ្ធសាសនា របស់លោកល្វី-ហ្វីណូត់ថា ពាណិជពីរនាក់បានយកទំនិធ្វើអង្ករ ១ ពីចំកឃ្មុំ ១ ទៅថ្វាយព្រះអង្គ ។ ៣ គួរថាព្រះពុទ្ធ តែច្បាប់ដើមថាព្រះពោធិសត្វទ្វេះ ។

ព្រះរាជាបានប្រោសឲ្យសាងព្រះស្តូបមួយ ហើយព្រះរាជទាន
ទ្រព្យមួយសែនដំឡឹងមាស ។ ព្រះថេរៈបានបង្ហាញគន្លងទៅទៀត នូវ
ស្ថានទីដែលព្រះតថាគតព្រះអង្គញុំាងជដ៏លំដាំងមួយពាន់ឲ្យគាន់យកកេស
ជាកិក្ខុ ហើយបានបង្ហាញស្ថានទីដែលព្រះបាទពិម្ពិសារៈ ទ្រង់ព្រះ
សណ្តាប់នូវព្រះធម៌ទេសនា ហើយទ្រង់បានឃើញបញ្ចាស់នូវសម្ពុធមិ
ស្ថានទីដែលស្តេចនៃទេព្តាចាំង ៨៤.០០០ បានញុំាងកិលេសតិសេចក្តី
សៅហ្មងឲ្យហួតចេញពីខ្លួនសព្វានបានចរិសុទ្ធល្អត្រមាំងបានធម្មចក្ខុ
គ្រប់ៗគ្នា ស្ថានទីដែលភួកព្រាហ្មណ៍ទំងភួកគហបតីជាច្រើនពាន់បាន
សម្រេចនូវសោតាបត្តិផល ។

ព្រះថេរៈបានបង្ហាញតមកទៀត នូវស្ថានទីដែលសក្រទេវរាជ្ញ
(ព្រះឥន្ទ) មានសេចក្តីជ្រះថ្លា ស្ថានទីដែលព្រះតថាគតទ្រង់សំដែង
យមកបាដិហារ្យជាអស្ចារ្យ ហើយទំងស្ថានទីដែលព្រះតថាគតស្តេច
យាងចុះមកអំពីឋានត្រៃយដែលស្តេចទៅចាំវស្សានៅក្នុងស្ថានតាវត្តឹង្ស
ដើម្បីទំងសំដែងធម៌ប្រោសព្រះពុទ្ធមាតា ។

ព្រះរាជាបានទ្រង់ប្រោសឲ្យសាងព្រះស្តូបដ៏មានដំរៃឡ ក្នុងស្ថាន
ទីដែលព្រះថេរៈបានបង្ហាញហើយនោះៗ ។

តពីនោះមក ព្រះថេរៈបានទាំព្រះបរមសត្ថុតិយ៍ទៅក្រុងកុសិនគរ
(កុសិនារ) ហើយលើកព្រះហស្តឡើងចង្អុលបង្ហាញថា: "តើត្រង់ស្ថាន

ទីនេះហើយ ដែលព្រះតថាគតស្តេចចូលកាន់និព្វានក្នុងកាលជាខាងក្រោយដែលខ្ញុំចំពោះព្រះពុទ្ធកិច្ចចប់ហើយ" ។

ព្រះពជាខ្ញុំព្រះសណ្តាប់ពាក្យនោះហើយ ព្រះអង្គក្រាបចុះទៅលើផែនដី ស្តេចខ្ញុំព្រះពិលាបរហូតដល់ជាត់ស្មារតី សូន្យសញ្ញីភាពពួកពជរតោះជាន់យកទឹកមកប្រស់ព្រិសប់ព្រះកន្លះហើយ ទើបស្តេចត្រឡប់ជានព្រះស្មារតីតើនឡើង ជានខ្ញុំព្រះពជាតនខ្ញុំព្យមួយសែនដំឡឹងមាសនឹងថ្វាក់ឲ្យសាងព្រះស្តូបមួយនៅត្រង់ស្តានទីនោះ ។

លំដាប់នោះ ព្រះពជាប្រណម្យព្រះហស្តថ្វាយបង្គំ ដោយគោរពចំពោះព្រះជានព្រះថេរៈ ហើយត្រាស់ខ្ញុំតថាៈ "ឥឡូវនេះ ខ្ញុំមានថ្វាថ្នាទំនឹងនមស្សការព្រះស្តូប នៃពួកមហាសាវកបរមស់ព្រះពុទ្ធជាម្ចាស់ (ខ្ញុំត)" ។

ព្រះថេរៈថ្វាយព្រះពរសរសើរថាៈ "សាធុ! សាធុ! ទ្រព្រះពជា! ព្រះអង្គមានព្រះពជហ្ឫទ័យប្រកបដោយប្រសាទសទ្ធាដ៏ក្លា ទំនឹងសេចក្តីគោរពដ៏វិសេស" ។

ខណៈនោះ ព្រះថេរៈជានាំព្រះមហាកស្សត្រិយ៍ទៅកន្លងសួនជតវនហើយលើកព្រះហស្តឡើងថ្វាយព្រះពរថាៈ "បពិត្រមហាពជ នេះហើយព្រះស្តូបរបស់ព្រះសារីបុត្ត សូមព្រះអង្គទ្រង់ព្រះពជានុគ្រឿងសក្ការបូជា" ។

ព្រះពុទ្ធាត្រាស់ឆ្លើយថា "តុណ្ហីភាពរបស់លោកម្ចាស់អគ្គនោះ ដូចម្តេចទៅ?"

ព្រះថេរៈថ្វាយព្រះពរតបថា: "លោកជាសាវកទី ១ ជាធម្មសេនាបតីរបស់ព្រះតថាគត លោកជាអ្នកស្ងាត់ជំនាញក្នុងការញុំាងធម្មចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ" ។

"ព្រះតថាគតទ្រង់លើកដង្ហើមលោកជាចំបង លើសជាងពួកសាវកអ្នកមានប្រាជ្ញា ។ ប្រាជ្ញានៃសត្វលោកទាំងអស់ រៀវលែងតែប្រាជ្ញាព្រះតថាគតមួយចេញ ក៏មិនមានប្រាជ្ញាអ្នកណាមួយស្មើនឹងប្រាជ្ញារបស់ព្រះសារីបុត្តត្រឹមតែមួយចំណិត ដែលបែងជា ១៦ ដងហើយ ។ គេអាចនិយាយថាមានតែដោយសារឆ្លងបញ្ហាដ៏នេះ អ្នកណាទៀតនឹងអាចសំដែងអំពីប្រាជ្ញារបស់លោកឲ្យសព្វគ្រប់បាន" ។

កាលដែលព្រះថេរៈថ្វាយព្រះពរដូច្នោះហើយ ព្រះពុទ្ធាមានសេចក្តីជ្រះថ្លាពន់ពេក ទ្រង់ព្រះពុទ្ធានុញ្ញាតឲ្យមួយសែនដងដ៏ឆ្ងាំងមាសដល់ព្រះស្ថូបនោះ ។ កាលព្រះអគ្គថ្វាយបង្គំព្រះសារីបុត្ត ទ្រង់ត្រាស់ទូន្មានថានេះថា:

"លោកជាអ្នកបានតំណាត់បង់នូវចំណងនៃកាលល្បីល្បាញក្នុងលោកនេះ របស់លោកសាយសត្វខ្លះទៅពាំងលោក បណ្តាអ្នកដែលមានប្រាជ្ញាពាំងឆ្ងាយ មានតែលោកជាបម្បងលើសជាងគេពាំងរស់" ។

តទៅនោះមក ព្រះថេរៈបានបង្ហាញព្រះសូត្រនៃព្រះមៅគ្គល្យាយន (មោគ្គល្លាន) ដល់ព្រះមហាកស្សបៃយ៍ ថ្វាយព្រះពរឲ្យស្តេចព្រះពជ្ឈាន ត្រឿងសក្ការបូជា ។

ព្រះពជ្ឈាត្រាស់សួរទៀតថា: "គុណវិសេសរបស់លោកអង្គនោះ ដូចម្តេចទៅ?"

ព្រះថេរៈថ្វាយព្រះពរថា "លោកជាចម្បងលើសពួកអ្នកដែលមានឫទ្ធិបាទ (ឥទ្ធិបាទ) លោកអាចឈានតែដើងខាងស្តាំរបស់លោកទៅដល់ចុងនៃសក្រវាឡទ្វីប (ព្រះឥន្ទ្រ) បាន" ។ ម្យ៉ាងទៀត លោកអាចផ្តាញ់នាគពជ្ឈានទន្ទឹងមុខនន្ទឲ្យចុះចាញ់បាន ។ អាត្មាភាពសំដែងគុណវិសេសរបស់លោកបានតែដោយសង្ខេបថា តេរួងដល់ត្រៃយខាងនាយនៃមហាសមុទ្រសង្ឃរាសាគរបានដោយសារពាក្យជាគុណធម៌របស់លោកអង្គនោះ" ។

ព្រះពជ្ឈាបានព្រះពជ្ឈានទ្រព្យមួយសែនដង្ហើមាសដល់ព្រះសូត្រនោះ ព្រះពជ្ឈានហើយ ទើបប្រណម្យព្រះហស្តឡើងត្រាស់គាថានេះគ្រានោះថា:

"ខ្ញុំសូមនមស្សការព្រះមៅគ្គល្យាយនដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ លោកជាចម្បងលើសជាងពួកអ្នកដែលបានឫទ្ធិបាទពាំងឡាយ លោកបានកំចាត់បង់ខ្មារមារ ផក, សេចក្តីសោកទំនឹងសេចក្តីក្តួលក្រៃ" ។

លំដាប់តាំងនោះមក ព្រះថេរៈបានបង្ហាញព្រះស្តូបព្រះកស្សបដល់ព្រះមហាកស្សបត្រើយ លើកព្រះហស្តឡើងថ្វាយព្រះពរថា: "ស្ថានដ៏នេះហើយជាព្រះស្តូបនៃព្រះមហាកស្សបសូមទ្រង់ព្រះភគវានេត្រឿងសក្ការៈបូជាត្រង់ស្ថានដ៏នេះផង" ។

ព្រះពុទ្ធជាម្ចាស់សួរថា: "គុណវិសេសរបស់លោកអង្គនោះដូចម្តេចខ្លះ?"

ព្រះថេរៈថ្វាយព្រះពរតបថា: "លោកជាអ្នកប្រាថ្នាតិចបូលចិត្តតែរបស់តិច លោកជាចម្បងលើសជាងពួកអ្នកដែលប្រព្រឹត្តធុតង្គវត្ត ។ ព្រះតថាគតបានប្រទានដ៏សេនាសនៈសម្រាប់ព្រះអង្គឲ្យលោកគង់ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ដោះចីវរបស់ព្រះអង្គប្រទានដល់ព្រះមហាកស្សប ។ ព្រះថេរៈអង្គនោះតែងមានព្រះហឫទ័យមេត្តាដល់អ្នកខ្សត់ខ្សោតនិងអ្នកមានទុក្ខព្រួយ លោកជាអ្នកគ្រប់គ្រងរក្សាទូរឆត្រនៃរាជរបស់ព្រះពុទ្ធជាម្ចាស់ដែលអាត្មាភាពសំដែងឥឡូវនេះ តើនិយាយដោយសង្ខេបអ្នកណាឡើយនឹងអាចសំដែងអំពីគុណវិសេសនៃការប្រព្រឹត្តិតាមរបស់លោកឲ្យសព្វគ្រប់បាន?"

ព្រះកស្សបត្រើយធ្វើប្រសព្រះកដានខ្ញុំមួយសែនដង្ហើមសដល់ព្រះស្តូបនៃព្រះមហាកស្សបនោះ ក្រោបថ្វាយហើយក៏ប្រណម្យព្រះហស្តឡើងគ្រាស់គាថានេះថា: "លោកជាអ្នកគង់នៅក្នុងគុហានៃភ្នំ ជាអ្នក

ចានបន្ទាត់បង់ខ្លួវការរំភាន មិនចានប្រព្រឹត្តទៅតាមអំណាចនៃទោស: ពាំងពួង លោកចានចំរើនឈ្មាន(ឈាន) ខ្ពង់សមាបត្តិជាប្រក្រតី លោកជាអ្នកជ្រាបច្បាស់តិចចូលចិត្តតែបេះតិច គុណវិសេសរបស់លោកឥតគួនឹងប្រៀបផ្ទឹម ។ ឥឡូវនេះ ខ្ញុំសូមនមស្សការចំពោះលោកម្ចាស់អង្គនោះដោយការបន្ទន់ព្រះសិរខ្ញុំ សូមថ្វាយបង្គំចំពោះលោកម្ចាស់អង្គនោះដោយអស់អំពីចិត្ត" ។

តពីនោះមក ព្រះថេរៈចានបង្ហាញព្រះសួបព្រះកុលត្តេរោកុលដល់ព្រះមហាកស្សបថ្វាយព្រះពរឲ្យស្តេចព្រះពជនាគ្រឿងសក្ការបូជា ។

ព្រះពជាត្រាស់សួរថា "គុណវិសេសរបស់លោកម្ចាស់អង្គនោះដូចម្តេចខ្លះ?"

ព្រះថេរថ្វាយព្រះពរតបថា: "ព្រះតថាគតចានលើកលោកជាចម្បងលើសជាងពួកអ្នកដែលមានសេចក្តីអត់ធ្មត់ធំធេង ហើយនឹងពួកអ្នកដែលជ្រាបច្បាស់តិច លោកមិនដែលសំដែងតាថា ១ ច្រកបដោយចាន ៤ ដល់មនុស្សណាមួយសោះឡើយ" ។

គានោះ ព្រះពជាខ្ពង់ជ្រោសឲ្យព្រះពជនាមាសមួយពែជាក់ទៅលើព្រះសួបនៃព្រះថេរអង្គនោះ ពួកអាមាត្យក្រាបទូលសួរថា: "ព្រះសួបព្រះអរហន្តជាខ្ពង់ខ្ពស់ៗគ្នា ព្រោះហេតុអ្វី ចានជាខ្ពង់ព្រះពជនាគ្រឿងបូជាតែត្រឹមមាសមួយពែប៉ុណ្ណោះ?

ព្រះពុទ្ធគាស់តបថា: "ព្រោះលោកប្អូប (ចាកខុក្ខ) ចានតែខ្លួន លោកម្នាក់ឯង មិនចានធ្វើមនុស្សឯទៀតឲ្យប្អូចចាកខុក្ខផង ព្រោះហេតុនោះហើយចានជាយើងបូជាតែតឹមមាសមួយពៃប៉ុណ្ណោះ" ។

ក្នុងទៅតាដែលក្បែរព្រះស្តូប ចានបង្ហែរមាសមួយពៃនោះថ្វាយមកព្រះពុទ្ធវិញ ទើបពួកអាមាត្យគ្រាបទូលទៀតថា "លោកជាអ្នកមានសេចក្តីជ្រាថ្លាតិចជោយពិត ចានជាលោកមិនខ្វល់យកមាសមួយពៃនោះទៅឬ?"

គ្រានោះ ព្រះថេរៈចានបង្ហាញព្រះស្តូបព្រះអានន្ទត្ថេរដល់ព្រះមហាកស្សត្រយ៉ាងថ្វាយព្រះភាទ្យេស្តេចព្រះពុទ្ធជានគ្រឹងសក្ការបូជា ។ ព្រះពុទ្ធាគាស់សួរថា: "គុណវិសេសរបស់លោកម្ចាស់អង្គនោះដូចម្តេចខ្លះ?"

ព្រះថេរៈថ្វាយព្រះភាតបថា: "ព្រះតថាគតចានលើកព្រះអានន្ទនោះជាចម្បងលើសជាងភ្លូកអ្នកដែលជាភហុស្សុត លោកចានចាំជាក់ច្បាស់ខ្លួនធម៌របស់ព្រះពុទ្ធជាម្ចាស់ ។ កំលាំងគំនិតជ្រាជ្ញានឹងការឈ្លាសវាងរបស់លោកដ៏ធំទូលាយប្រៀបដូចជាមហាសមុទ្រ ។ ការបស់លោកផ្ចង់ល្អមតឹរកេះក្បាះក្បាយ មនុស្សនឹងទៅតាទាំងឡាយតែងធ្វើសេចក្តីគោរពចំពោះលោកអង្គនោះ លោកអាចកំណាត់ដឹងខ្លួនពុទ្ធអធ្យាស្រ័យចានលោកចរិយាជោយសេចក្តីល្អនឹងពេញទៅជោយគុណសម្បត្តិគ្រប់យ៉ាង លោកជាឃ្លាំងមួយដែលពេញណោនចង្អៀតទៅជោយព្រះធម៌" ។

ព្រះពុទ្ធជាម្ចាស់ព្រះអានន្ទអាចខ្លួលបាន ព្រោះដូច្នោះទើបយើងបូជាស្ថានទីនេះ ច្រើនលើសជាងស្ថានទីទាំងពួង" ។

កាលដែលព្រះពុទ្ធបានបូជាព្រះសព្វញ្ញុតញាណរួចហើយ ទ្រង់សម្តែងរឿងកាយក្នុងព្រះពុទ្ធទ្រង់ពន់ពេកស្តេចត្រាច្បាយបង្គំទៀបព្រះបាទព្រះថេរៈហើយលើកព្រះហស្តប្រណម្យឡើងដោយគោរពត្រាស់គាថានេះថា :

"ខ្ញុំបានសម្រេចអត្តភាពជាមនុស្ស បានបរិភុតន្តូវបានទាំងសែន ។ ឥឡូវនេះខ្ញុំបានធ្វើកិច្ចរបស់ខ្ញុំនោះរួចស្រេចហើយ មិនមែនជាការឥតអំពើទេ ដែលខ្ញុំបានខ្លួលអត្តភាពនេះ ។ ខ្ញុំបានដួបទីបុញ្ញក្ខេត្តដ៏ប្រសើរ

ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ដល់ផលសម្រាប់អត្តភាពជាមនុស្ស ។ ដោយ
សារខ្លួសម្បត្តិ ដែលជាបបស់ប្រកបដោយពោសហើយពុករលួយ
៧។ ជាយ។ ខ្ញុំបានបំពេញកុសលឲ្យបានសម្រេចផលដ៏ធំមួនដល់
ព្រះធម៌ជាម្ចាស់ ។ ព្រះស្តូបតាំងឡាយដែលខ្ញុំបានកសាងគុកជាគ្រឿង
លំអនៃផលក្តីប ដ៏ដេរដាសដូចជាពពកមានពណ៌សដែលជាគ្រឿងលំអ
នៃអាកាសវេហាស៍ ។ ខ្ញុំបានដួបប្រសព្វនឹងព្រះធម៌របស់ព្រះពុទ្ធដែល
ជាសការៈដ៏បរិសុទ្ធផុតគ្រឿងសៅហ្មង" ។

កាលខ្ញុំគ្រាស់ទូវគាថានេះចប់ហើយ ព្រះពជាខ្ញុំថ្វាយបង្គំលា
ថយចេញចាកទីនោះ៧ ។ ខុកជាព្រះបាទអសោកបានព្រះពជាមាន
ខ្លួន ១ សែនដំឡឹងមាសដល់ព្រះស្តូបមួយ។ គប់កន្លែង (ក្នុងព្រះស្តូប
តាំង ៤) គឺព្រះស្តូបនៅទីប្រសូតព្រះពុទ្ធម្ចាស់ ព្រះស្តូបនៅទីដែម
ពោធិព្រឹក្ស ព្រះស្តូបនៅទីញុំាងធម្មចក្រដ៏បវរឲ្យប្រព្រឹត្តទៅនឹងព្រះស្តូប
នៅទីនិព្វាន គឺព្រះអង្គគង់មានព្រះពជសង្ឃដ៏វិសេសបំផុតចំពោះតែ
ត្រង់ព្រះស្តូបនៅពោធិព្រឹក្សនោះ ព្រោះហេតុអ្វី ? ព្រោះថាទីនោះព្រះ
សម្មាសម្ពុទ្ធបានខ្ញុំគ្រាស់សម្មាសម្ពោធិញ្ញាណ ជាន់ជាព្រះពជា ខ្ញុំ
ព្រះពជាគ្រឿងប្រជាប់តែនវត្តដ៏មានដំណែរជាច្រើនប្រគារដល់ព្រះស្តូប
នៅពោធិព្រឹក្សនោះ ។

ព្រះអគ្គមហេសីទី ៣ របស់ព្រះមហាក្សត្រិយ៍ខ្ញុំព្រះនាមព្រះនាង តិស្សរក្សិតា[1] កាលឃើញព្រះពុទ្ធសង្ខារបស់ព្រះជាម្ចាស់អស្ចារ្យដូច្នេះ ទើបព្រះនាងត្រិះរិះដូច្នេះថា "រតនវត្ថុដ៏មានដំលៃវិសេសដែលព្រះអង្គមានទាំងប៉ុន្មានខ្ញុំព្រះពុទ្ធជានដល់នោធិព្រឹក្សទាំងអស់ហើយ" ។ ខណៈនោះព្រះនាងមានព្រះសង្វេគ្យហៅមនុស្សចណ្ឌាលឈ្មោះមាតង្គៈមកគាល់ហើយត្រាស់ថា: "អ្នកអាចនឹងលាយដើមពោធិព្រឹក្សដោយវេមន្តបានឬទេ"?

មាតង្គៈបុរសតបថា: "ប្រសិនបើព្រះនាងប្រទានវត្ថុនានាជាមាសដល់ខ្ញុំ ខ្លួនខ្ញុំនោះនឹងអាចលាយបាន" ។

គ្រានោះ ព្រះនាងសន្ទុតថានឹងប្រទានវត្ថុនានាជាមាសដល់មនុស្សចណ្ឌាលនោះ ក៏មាតង្គៈបុរសលាក់អាថ៌កំបាំងនោះទុកដោយសេចក្តីលំបាកនៃខ្លួន រាល់ថ្ងៃដើរសំដៅទៅដើមពោធិព្រឹក្ស ហើយកាយកខ្សែបន្ទាត់ទៅវាស់ដើមពោធិព្រឹក្សនោះរាល់ចំណងនឹងសម្ងាត់ដោយវេមន្តរបស់ក្នុងមួយរំពេចនោះដើមឈើក៏ស្វិតស្រពោនល្មមបុរសនឹងមើលទៅ ។

ពួកជាបុរសអ្នកក្បាលដូរដើមឈើនោះឃើញដូច្នេះ ក៏មកក្រាបទូលដល់ព្រះមហាក្សត្រិយ៍ថា: "ឥឡូវនេះដើមពោធិព្រឹក្សកំពុងតែស្វិតស្រពោនទៅឯង" ។ ខណៈនោះពួកជាបុរសពោលនូវគាថានេះថា:

---

១ មហាវង្សៈខាងអាសន្នមិត្តាជនហេសីទីវង្គតទៅបាន ៤ ឆ្នាំទើបព្រះជាម្ចាស់អាសោកតាំងនាងតិស្សរក្សិតាទេវី ជាអគ្គមហេសីឯកឡើងតែនាងនេះមិនមានសទ្ធាន្រិះថ្វាក្នុងព្រះពុទ្ធសាសនា ។

"នៅត្រង់ស្ពានទីដែលព្រះតថាគតបានត្រាស់ដឹងនូវវិជ្ជាកន្លងមក ខ្ញុំបានត្រឡប់ពីគ្រួសារវិញ ឥឡូវនេះដើមឈើនោះឯងកាន់តែថយកំឡាំងណាស់ទៅហើយ កាន់តែស្ងួតស្រពោនបុះសន្សឹមៗទៅហើយ" ។

ព្រះកស្សបកាលខ្ញុំព្រះសណ្តាប់ពាក្យនោះហើយ ខ្ញុំក៏អស់ព្រះស្មារតីដួលបុះទៅលើដែនៃប្រឹថពី លុះខ្ញុំបានខ្លួនគឹតឡើងវិញ ក៏ព្រះកស្សបយាងមកដល់ទីនោះ ទើបត្រឡប់បានព្រះស្មារតីឡើងវិញ ខ្ញុំព្រះពាលាបរៀបរាប់ថា: "កាលខ្ញុំឃើញព្រោធិព្រឹក្សក៏ហាក់ដូចជាបានឃើញព្រះសម្មាសម្ពុទ្ធម្ចាស់ដែរ ប្រសិនបើដើមព្រោធិព្រឹក្សនោះស្ងួតស្រពោនទៅហើយ ខ្លួនខ្ញុំនឹងស្លាប់ទៅជាមួយដើមជាក្រាកដ" ។

ព្រះនាងតិស្សាក្សត្រីក្រាបទូលលួងលោមព្រះកស្សបថា: "បើពុកជាដើមព្រោធិព្រឹក្សក្រៀមដាច់តែទៅខ្ញុំម្ចាស់ឯងនឹងអាចបំរើមហាកដឲ្យព្រះអគ្គខ្ញុំព្រះសម្មាខ្ពុកព្រះកស្សបវិញតែរៀងទៅ" ។

ព្រះកស្សបត្រាស់ថា "មានតែដើមព្រោធិព្រឹក្សនោះអាចធ្វើសេចក្តីសុខដល់ខ្លួនអញ ឯជាតិស្លែកាពណាទើងធ្វើបាន! គឺត្រង់ទីនោះឯងហើយដែលព្រះសម្មាសម្ពុទ្ធម្ចាស់ព្រះអគ្គបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ" ។

ព្រះកស្សបត្រាន់តែមានព្រះឧទ្ធារតែប៉ុណ្ណោះ ក៏ព្រះនាងតិស្សាក្សត្រីត្រង់ដួលក្លិសក្តៅកងចិត្តកើតវិប្បដិសារីឡើង ទើបនិយាយទាំងបុរសឈ្មោះ

មាតង្គ:ថា "ឥឡូវនេះអ្នកអាចធ្វើដើមពោធិព្រឹក្សឲ្យរស់ឡើងវិញបានឬទេ?

មាតង្គ:បុរសក្រាបទូលតបព្រះនាងថា "ប្រសិនបើឈើនោះមិនទាន់ស្ងួតក្រៀមនៅឡើយ ហើយនៅមានដាំតសូម្បីតែបន្តិចបន្តួច ក៏ខ្ញុំនឹងអាចធ្វើឲ្យបានដូចដើមឡើងវិញ" ។

ខណៈនោះមាតង្គ:បុរសស្រាយខ្សែអង្ករ ដែលចងព័ទ្ធសំពាបណ្តើរ សូត្រគាថាមន្តដោះបណ្តើរ ដោយសេចក្តីត្បិយាមពេញចិត្តទុកចំស្រោចពោធិព្រឹក្សនោះដោយទឹកដោះគោមួយពាន់ក្អម តាំងនោះមកមួយស្របក់ ដើមឈើនោះក៏រស់ឡើងវិញជាប្រក្រតីដូចដើម ។

ពួកពាជបុរសអ្នករក្សាបានឃើញឈើនោះលូតលាស់ស្រស់សន្ធឹកឡើងវិញក៏មកគ្រាបទូលដល់ព្រះពាជាថា "បពិត្រមហាពាជ ពោធិព្រឹក្សរស់ឡើងវិញហើយមិនបានថ្លែកអំពីកាលជាន់មុននោះទេ" ។

លុះព្រះពាជាទ្រង់ព្រះសណ្តាប់ពាក្យតែប៉ុណ្ណោះ ក៏មានព្រះបីតិសោមនស្សស្ដេចយាងទៅជិតដើមពោធិព្រឹក្សព្រះអង្គខត្រងំទៅដើមឈើនោះទ្រង់ត្រាស់ថា: "ពាជកិច្ចឯណាដែលស្ដេចពាំមិសាន៍ឯពួកស្ដេចឯទៀត មិនទាន់បានធ្វើឲ្យសម្រេចនៅឡើយ ពាជកិច្ចនេះខ្ញុំនឹងធ្វើឥឡូវនេះឲ្យបានចំណែកព័រយ៉ាង ។ ចំណែក ២ យ៉ាងគឺអ្វីខ្លះ? គឺចំណែក ១ ខ្ញុំនឹងធ្វើឲ្យមានមហាកម្មសម្ភោត្យធួង ព្រមទាំងឲ្យធ្វើក្អមមួយពាន់ដោយ

វត្តដ៏មានដំណែងជាក់ពេញទៅដោយ សុគន្ធជាតិសម្រាប់ស្រោចដើមពោធិ-
ព្រឹក្ស ចំណែកមួយទៀតទុំនំដង្វែងព្រះអរិយសង្ឃជាច្រើនឲ្យអស់
កាលនៃរដូវភ្លៀង(១) ៥ ខែ ។

គ្រានោះ ព្រះពជាគ្រាស់ឲ្យធ្វើក្អមដ៏ប្រសើរចំនួនមួយពាន់ជាវិការ
ភ្នំមាស, ប្រាក់ទំនឹងតែវែខ្សែទង់ឲ្យចំពេញដោយសុគន្ធភ័រហើយឲ្យ
ស្រោចដើមពោធិព្រឹក្សនោះព្រះអង្គឲ្យធ្វើប្រដាប់ស្អិតស្អាងដើមឈើនោះ
ដោយកម្រងផ្កា ដោយលំអិតសុគន្ធជាតិទំនឹងគ្រឿងលាបលន់តាំងពួយដ៏
ច្រើន ។ ព្រះពជាស្រង់ព្រះភ័រហើយទង់ព្រះពស្តូថ្ងៃដំបូងសុទ្ធស្អាតល្អ
ព្រះអង្គសមាទានទ្វេអដ្ឋង្គឧបោសថ ស្តេចឡើងទៅលើរោងពោធិព្រឹក្ស
នោះតំបាណោះមើលគ្រប់ទិសទាំង៤ហើយគ្រាស់បង្ហើសង្ឃថា "ឧព្រះអរិយ-
សង្ឃទាំងពួយដ៏ច្រើន លោកជាសាវកនៃព្រះសម្ពុទ្ធម្ចាស់ លោកប្រតិ-
បត្តិដើម្បីចំរើនទ្វេរគាយល់ត្រូវ លោកជាអ្នកផ្តាំចំបង់ទ្វេរចំណងនៃតណ្ហា
បានដោយប្រសនៃកុសលបង់លោកដែលកើតព្រមដោយសមាធិ លោក
ជាអ្នកមានគុណធម៌គួរភ្ជួរមនុស្សភ្ជួរទេវតានឹងភ្ជួរអសុរគ្រាត ខ្ញុំសូមឲ្យ
ភ្ជួរលោកទាំងអស់នោះ និមន្តមកដល់ទីនឹងខ្ញុំដោយមេត្តាចិត្តរបស់លោក
ដល់ខ្ញុំ សូមឲ្យព្រះករុណាទាំងអស់នោះព្រមទទួលទ្វេនិមន្តរបស់ខ្ញុំ ។

---

(១) ក្នុង-អាយុវង-កឹង បញ្ជាសើប្រែថា "ប្រែដុំសង្ឃជាច្រើនមកធ្វើកុសលអស់ ៥ថ្ងៃ តែបើពិ-
និត្យមើលតាមកំណើសដីមរបស់ភាក្យបញ្ជាសើ គួរនឹងប្រែថា "អស់កាលនៃរដូវភ្លៀងប្រាំខែ"
ហៅវិញ: ធ្វើបញ្ជាសើ ។

"ពួកលោកទាំងអស់ ដែលជាអ្នកសោយន្ទូវប៊ីតក្នុងជ្ឈាន (ឈាន) ទី៦ សមាបត្តិមានប្រាជ្ញាចក្ខុកើតឡើងត្រមេហើយ ជាអគ្គនៃព្រះអរិយសង្ឃ ដែលបានសម្រេចន្ទូវព្រះអមតមហានិព្វាន លោកជាកុលបុត្រដ៏ពិតឥតបុគ្គលប្រៀបផ្ទឹម ជាអ្នកបានខ្ជួលរក្សាពុកន្ទូវព្រះធម៌ជាមគ្គកវបស់ព្រះសុគត សូមឲ្យព្រះគុណាទាំងអស់អង្គនោះត្រមខ្ជួលន្ទូវការនិមន្តវបស់ខ្ញុំដោយមេត្តាចិត្ត ។

"ពួកលោកដែលគង់នៅក្នុងដែនកស្មីរៈ ជាអ្នករួចផុតបាកភ័យអន្តរាយទាំងឃប់ទាំងថ្ងៃ ត្រមទាំងលោកជាអ្នកប្រព្រឹត្តនៅក្នុងព្រៃត្រមហាវ័នទី៦ព្រៃវេតៈ សូមនិមន្តមកដងដោយមេត្តាចិត្តវបស់លោក សូមឲ្យព្រះគុណាទាំងអស់នោះត្រមខ្ជួលន្ទូវការនិមន្តវបស់ខ្ញុំ ។

"ពួកលោកដែលគង់នៅស្ថានទេវមិនពបស្មើ ទៀបមាត់ស្រះដ៏ធំឈ្មោះអនវតប្ត ទី៦ពួកលោកដែលគង់នៅនាមាត់ទន្លេនាគ្រោះជ្រលងភ្នំទី៦នាគុហាឈ្មោះសេរីសកៈត្រមទាំងពួកលោកដែលគង់នៅនាភ្នំគន្ធមាទនៈ សូមនិមន្តមកដោយមេត្តាចិត្តវបស់លោក សូមឲ្យព្រះគុណាទាំងអស់នោះត្រមខ្ជួលន្ទូវការនិមន្តវបស់ខ្ញុំ" ។

កាលព្រះពជាបានអធិដ្ឋានការនិមន្តយ៉ាងនេះហើយ ពួកព្រះថេរៈទាំងនេះ ក៏និមន្តមកអំពីទិសទាំងបួនចំនួនបីសែនអង្គ ។ មួយសែនអង្គជាព្រះអរហន្ត ពីរសែនអង្គជាព្រះស្រោតាបន្នព្រះសក្ទាគាមិន (សកិទាគាមី)

ន៏ដ៏ព្រះអនាគាមិន (អនាគាមី) មានចាំដ៏ពួកមនុស្សជាសាមញ្ញបុថុជ្ជន ន៏ដ៏ពួកជនអ្នកមានចិត្តដ៏បរិសុទ្ធ ក៏មកអង្គុយប្រជុំគ្នានៅសាលាតែកន្លែងមួយសម្រាប់ព្រះមហាថេរ ជាកន្លែងចំនេរមិនមានអ្នកណាមួយហ៊ានចូលទៅអង្គុយឡើយ ។

ព្រះពជាត្រាស់សួរព្រះយសត្ថេរថា "ព្រោះអ្វីបានជាខុកទំសេនាសនៈនេះឲ្យនៅចំនេរ ?"

ព្រះថេរៈថ្វាយព្រះពាតបថា "ន៏ដ៏មានព្រះមហាថេរមួយអង្គទៀតត្រូវលោកអង្គនោះគង់នៅត្រង់ទីសេនាសនៈនេះ" ។

ព្រះពជាត្រាស់សួរទៀតថា: "ព្រះមហាថេរមួយអង្គនោះធំជាងលោកម្ចាស់ឬ?" ព្រះថេរៈថ្វាយព្រះពាតបថា: "កុងីកាលមុនព្រះពុទ្ធម្ចាស់ទ្រង់ត្រាស់ថា: "កិក្ខុដែលជាចម្បងលើសជាងពួកអ្នកដែលបន្ទឹស្តីហានាទ (នោះ) ឈ្មោះបិណ្ឌោលភារទ្វាជៈ ព្រះថេរៈអង្គនោះលោកចាស់ជាងអាត្មាភាព" ។

កាលព្រះពជាទ្រង់ព្រះសណ្តាប់ពាក្យនេះហើយ ក៏ព្រឺកេមត្រីសែ្បកឮកទៀងដូចជាឈើកទម្ពៈ (កូម្ព) ដែលកំពុងមានផ្កាកែសុះស្គាយ ទ្រង់មានបន្ទូលទៀតថា "លោកដែលបានជាន់បានឃើញព្រះតថាគត មានច្រើនអង្គឬ?"

ព្រះថេរៈថ្វាយព្រះពរតបថា "មានតែព្រះអរហន្តព្រះនាមបិណ្ឌោលមួយព្រះអង្គនោះ ដែលបានបានឃើញព្រះពុទ្ធកាលព្រះអង្គដែលទ្រង់ព្រះជន្មនៅក្នុងលោកនេះ" ។

ព្រះពាជាត្រាស់សួរថា "ខ្ញុំទើនឃើញព្រះអរហន្តនោះផងឬទេ?" ។

ព្រះថេរៈថ្វាយព្រះពរតបថា "ព្រះអង្គគង់ទើនបានឃើញលោកអង្គនោះនឹងនិមន្តមកដូចនឹងមហាពាជក្នុងកាលឥឡូវនេះ" ។

ព្រះពាជាត្រាស់ដោយពេញព្រះពាជហឫទ័យថា: "ខ្ញុំនឹងបានសម្រេចប្រយោជន៍ដ៏ធំទូលាយហើយ ប្រសិនបើខ្ញុំបានឃើញព្រះថេរៈបិណ្ឌោលជាបឋមក្នុងកាលឥឡូវនេះ ព្រោះហេតុតែមគ្គាចត្តារបស់លោកដល់ខ្ញុំ" ខណៈនោះព្រះពាជាប្រណម្យព្រះហស្តរង់ចាំ ប្រឹងឧតសំឡឹងឆ្ពោះទៅឯអាកាសវេហាស៍ លុះព្រះអង្គទស្សនាការព្រះថេរៈបិណ្ឌោលដែលគួរនោងដូចជាអង្គនៃអគ្គិបន្ទូរហើយប្រហែលគ្នានឹងពាជហង្ស មានព្រះអរហន្តជាច្រើនពាន់អង្គចោមរោមជាច្រើន លោកនិមន្តចុះមកក្នុងទីនោះ ចូលទៅគង់លើសេនាសនៈជាខាងមុខព្រះយសត្ថេរ ក៏ពួកព្រះថេរៈទាំងបីសែនដែលគង់នៅត្រៀបត្រាក្រោកឡើងព្រមគ្នាទាំងអស់ធ្វើសេចក្តីគោរពចំពោះព្រះមហាថេរអង្គនោះ ។ ព្រះមហាកស្សត្រៃយ៍បានទ្រង់ទស្សនាការព្រះបិណ្ឌោលត្ថេរ លោកមានព្រះកេសដ៏សព្រោង មាន

ចំពោះមដ៏ក្រៃស់ មានព្រះកាយដ៏ប្រជាប់ដោយសុភលក្ខណៈនឹងអនុព្យ-ញ្ជនៈគាំងខ្លាយជាវេបុល្លៈនៃព្រះជេតវនតុទ្ធ (បវេកតុទ្ធ) ក៏ព្រះពាលាលុតព្រះជានុចុះថ្វាយនឹងផែនដី លើកតំបន់អញ្ជលីថ្វាយបង្គំប្រកបដោយអគ្គជ្រុំ ទ្រង់គុនជប់ព្រះបាទព្រះវេរៈហើយងើបឡើងព្រះអង្គបញ្ជរព្រះជានុហើយត្រាស់នូវគាថានេះថា:

"ឧព្រះវេរៈ! ខុកជាព្រះតថាគតព្រះអង្គនោះចូលព្រះនិព្វានហួសទៅហើយ តង់ចុងលោកម្ចាស់ដែលមានព្រះជន្មទៅជាជំនួសស្នងព្រះអង្គ ។ ដោយសេចក្តីមេត្តាចិត្តរបស់លោកម្ចាស់ជាទីពឹ សូមលោកម្ចាស់ឲ្យទាន នូវនុក្ខដើម្បីខ្ញុំនឹងបានជាស់គឿនគំនិតមាយោខ្ញុំទៅតាមនុក្ខនោះ[1] ។

កាលទ្រង់សូត្រគាថានេះចប់ហើយ ព្រះពាលាស្តេចសួរព្រះវេរៈថា: "លោកម្ចាស់បានទាន់បានឃើញព្រះតថាគតមែនឬ?

ព្រះវេរៈថ្វាយព្រះពរតបថា: "បពិត្រមហាពាជ អាត្មាភាពបានឃើញព្រះតថាគត ព្រះអង្គនោះមានព្រះឆវិវណ្ណដ៏ពណ្ណកាយដូចជាដុំនៃមាសឆ្អិន ព្រះកន្ត្រៃព្រះអង្គដូចជាព្រះចន្ទ្រដ៏ពេញវង់ ព្រះកាយព្រះអង្គប្រជាប់ដោយលក្ខណៈគាំង ៣២ ព្រះស្បូរស្បៃង៍ព្រះអង្គធ្ងន់ជ្រៅមុតហើយពីរោះអស្ចារ្យ (ហាក់ដូចជាសំឡេង) នៃព្រហ្ម ព្រះមហាករុណាព្រះអង្គមានគុហាជាទីសេនាសនៈ" ។

---

១ ពាលព្រះបាទអសោកធ្វើបន្ទំអង្គព្រះវេរៈរួចគុប្តនោះ ពាំសូត្រគាថានេះផែង ។

ព្រះរាជាត្រាស់សួរទៀតថា: "លោកម្ចាស់ជាន់ឃើញព្រះមហាមុនីនោះនៅត្រង់ណាខ្លះ?"

ព្រះថេរៈថ្វាយព្រះពរតបថា: "កាលដែលព្រះសម្ពុទ្ធម្ចាស់ព្រះអង្គអាស្រ័យនៅជាមួយនឹងពួកព្រះអរហន្តជាំង ប្រាំរយអង្គក្នុងទីសម្ងាប់នៅសំចតក្នុងគិម្ពវដ្ដ ជិតក្រុងរាជគ្រឹះនោះ អាត្មាភាពក៏នៅក្នុងទីនោះដែរ អាត្មាភាពបានជាំងចិញ្ចឹមជីវិតដោយលាភសក្ការៈនៃបុញ្ញក្ខេត្តនោះផង"។

"កាលព្រះអង្គគង់នៅក្នុងនគរសាវត្ថី ព្រះអង្គបានសំដែងយមកប្បាដិហារ្យដ៏ធំសម្លើមអស្ចារ្យដើម្បីនឹងផ្ដាញ់ផ្ដាលពួកតិរ្ថិយ ទ្រង់ទម្លាក់ព្រះពុទ្ធជាំងឡាយដ៏ថ្កើងរុងរឿងមុខគួរអស្ចារ្យពេក ហើយព្រះអង្គថ្លែងដោយឫទ្ធិឲ្យបានឃើញជាក់ច្បាស់នឹងភ្នែកគប់ៗគ្នា ព្រះរស្មីភ្លឺផ្លេកឆ្វៀលឆ្លាត់ឡើងទៅអាកាសចាំងរហូតដល់ទៅស្ថានព្រហ្មឈ្មោះអកនិដ្ឋ ពេលនេះអាត្មាភាពក៏នៅក្នុងទីនោះដែរ"។

"ក្នុងកាលជាខាងក្រោយនៃការសំដែងធម៌ប្រោសព្រះពុទ្ធមាតាទៅស្ថានតាវត្តឹង្ស ព្រះពុទ្ធស្ដេចយាងចុះមកមានពួកទេវតាហែហមអមព្រះអង្គ អាត្មាភាពក៏នៅក្នុងទីនោះដែរ"។

"កាលព្រះអង្គស្ដេចយាងដល់មាត់ទ្វារនគរសង្កស្ស អាត្មាភាពក៏នៅក្នុងទីនោះដែរ"។

"កាលនាងកិត្តិនីរេញ្ចនរបស់ស្លាប សំដែងចំដីហាវ្យនិម្មិតធ្វើជាស្ពេចចត្រៃភត្តិ មានព្រះពុទ្ធបុត្រាមួយចាន់គត់មកគាបថ្វាយបង្គំខ្ញុំបព្រះពុទ្ធនោះ អាត្មាភាពក៏ទៅកន្លែងនោះដែរ" ។

"កាលដែលនាងសុមាគធាកន្លែងក្រងបូណាវ៉ែនបានទទួលព្រះសម្មាសម្ពុទ្ធទៅ ក៏ពួកព្រះអរហន្តចាំងក្រាំរយអង្គបានសំដែងបុទ្ធិចាដីហាវ្យគប់ៗអង្គ រហូតទៅដល់ក្រងបូណាវ៉ែន ពេលនោះខ្លួនអាត្មាភាពឯងបានចាំងសំដែងបុទ្ធិចាដីហាវ្យអង្គុយទៅកន្លែងតនតុហា នាក់ដែរតនបតិត ហើយអាត្មាភាពក៏បានចូលទៅកន្លែងក្រងបូណាវ៉ែននោះដែរ[1]" ។

"កាលដែលព្រះពុទ្ធចូល ទៅកន្លែងក្រងពជគ្រឹះព្រះអង្គកំពុងស្ពេចយាងទៅចំណាចាត គ្រានោះមហាពជបានថ្វាយដុំដីដល់ព្រះអង្គនោះ ពជគុប្តៈបានប្រណម្យដៃជួយអនុមោទនាឯង ពេលនោះព្រះពុទ្ធបានព្យាករណ៍ឲ្យមហាពជ អាត្មាភាពក៏បានឃើញដែរ" ។

ព្រះមហាកស្សបត្ថេរជាធំពជត្រាស់សួរម្ចាស់ទៀតថា "ឧព្រះថេរៈ! លោកម្ចាស់គង់នៅឯណា អម្បាញ់មិញនេះ?"

---

១ ធម្មបទដ្ឋកថាៈ "នាងបូប្បសុកាជាធីតានៃអនាថបិណ្ឌិកសេដ្ឋី ដែលបានឮភ្លាមទៅទៀតនោះ បានរំលឹកពុទ្ធគុណហើយបាប់ផ្តាំមួយៈ ៤ ព្រាប់អង្គាសឲ្យទៅនិមន្តព្រះសម្មាសម្ពុទ្ធមកទទួលភត្ត ព្រះអង្គបានគ្រាបកំដែលនិមន្តមកជាមួយនឹងព្រះអរហន្តចាំងក្រាំរយដោយឥទ្ធិប្បាដិហារ្យជាសិរីសួស្តីដ៏ច្រើនសើរអស្ចារ្យ ពួកអ្នកទាំងនោះមានសេចក្តីត្រេកអរថា បានជាក់ចែងធ្វើមហាទានរហូតអស់ ៧ ថ្ងៃ ។

ព្រះថេរៈថ្វាយព្រះពរតបថា: "ថ្វាយព្រះពរមហាភាគ! អាត្មាភាពនៅលើកុន្ទមាទនបព៌ត" ។

ព្រះរាជាត្រាស់សួរថា: "មានតិក្ខជាបរិវារលោកម្ចាស់ប៉ុន្មានអង្គ?

ព្រះថេរៈថ្វាយព្រះពរតបថា "តិក្ខ៦ំអស់ ៦ ម៉ឺនមហាភាគ! ពេលល្ងាមហើយ! ព្រោះហេតុអ្វីបានជាទ្រង់ត្រាស់សួរអាត្មាភាពច្រើនម្ល៉េះ? ល្ងាមពេលដែលទន់ឆ្ងៃព្រះរាជាមានកត្តដល់ព្រះតិក្ខុសង្ឃ ហើយលុះកាលជាមាន់គ្រាយកត្ត អាត្មាភាពនឹងដំណាលរឿងរ៉ាវអាត្មាភាពថ្វាយព្រះអង្គទៀត" ។

ព្រះរាជាត្រាស់ថា: "ទ្រព្រះថេរៈ! ខ្ញុំប្រាថ្នានឹងប្រព្រឹត្តតាមដំបូន្មានលោកម្ចាស់ហើយ ប៉ុន្តែគំនិតរបស់ខ្ញុំដែលបានផ្ចួចដើមឡើងកាលជាន់ដំបូងចំពោះត្រង់ទៅព្រះពុទ្ធជាម្ចាស់ ខ្ញុំសូមស្រោចរោងព្រឹក្សសិនហើយតទៅខ្ញុំនឹងប្រគេនកត្តដល់ព្រះតិក្ខុសង្ឃ ។ ព្រះបរមក្សត្រ័យ៍ទ្រង់ត្រាស់ហៅសារថីតែជាអ្នកចាត់ចែងក្នុងការបរិភោគតានហើយ មានព្រះរាជឱង្ការថា: ខ្ញុំបូជាទ្រព្យមួយសែនដំឡឹងមាសដល់ព្រះសង្ឃខ្ញុំនឹងស្រោចដើមរោងព្រឹក្សដោយទឹកសុគន្ធជាតិនឹងភ្នួមដ៏មានដំឡៃជាងមួយពាន់ ។ អ្នកចាំងឡាយចូរវាយរគាំងប្រកាសប្រាប់ឈ្មោះខ្ញុំថាជាទានបតីដែលជាអ្នកធ្វើទានដល់ប្រជុំសង្ឃជាំច្រើន អស់កាលនៃរដូវក្តៅនេះ[1]។

---

១ មើលទំព័រ ៥៣២ លេខយោង ១ ។

គ្រានោះ ព្រះកុនាលភជនុរស រៃគាកឈរឡើងនៅខាងស្តាំ ព្រះមហាក្សត្រិយ៍នៅស្មៀមពុំស្រដីគ្នាន់តែលើកម្រាមព្រះហស្តពីរឡើង ដែលសំគាល់ថា: "ខ្ញុំនឹងបូជាខ្មោកុណា" ហេតុនោះពួកជនទាំងអស់នាំគ្នាសើចគឹកកងឡើង ទាំងព្រះពជាក៏ទ្រង់ព្រះសម្លឹងដែរហើយ ព្រះអង្គត្រាស់សួរពេជគុប្តសេនាបតីថា: "អ្នកណា ហ៊ានធ្វើអ្វីដូច្នោះ?

ពេជគុប្តសេនាបតីក្រាបទូលតបថា "សូមទ្រង់ព្រះមេត្តាគ្រោសកង ពួកមនុស្សជារច្រើនពាន់នេះ មានមនុស្សជាចំនួនច្រើនដែលជាអ្នកចង់ធ្វើបុណ្យកុសលដោយរៃគ្រលែង" ។

ព្រះពជាត្រាស់បន្ទូលទៀតថា "អញនឹងបូជាខ្លួយបីសែនដង្ហឹង មាសដល់ព្រះសង្ឃ អញនឹងស្រោចដើមពោធិព្រឹក្សដោយទឹកសុគន្ធជាតិនឹងក្អមទាំងបីពាន់សុទ្ធសឹងមានដាំឡៃ" ។

ខណៈនោះព្រះកុនាលភជនុរសលើកម្រាមព្រះហស្ត ៤ ឡើងម្តងទៀត ។

ព្រះពជាត្រាស់សួរពេជគុប្តសេនាបតីថា "អ្នកណា ហ្នឹងហ្ន៎! ពេចន៍តាំងនឹងអញ?

ពេជគុប្តសេនាបតីលុតជង្គង់ចុះ ហើយក្រាបបង្គំទូលថា "សូមតេជ! ខណៈឡើយហ៊ានតតាំងនឹងព្រះនរិន្ទនេះ! មានតែព្រះកុនាលជាភជនុរស ហើយជាកុមារតូចដែលតែងក្រសាលលេងជាមួយនឹងព្រះពជបិតា" ។

ព្រះមហាក្សត្រាធិរាជឧត្តមសំឡឹងឆ្ពោះទៅខាងស្តាំព្រះអង្គបានឧស្សាហ៍ព្រះកុនាលកជនុរស ហើយទើបត្រាស់នឹងព្រះមហាវេវថាៈ "ខ្ញុំសូមឧទ្ទិសឃ្លាំងរតនវត្ថុ(១) រថរបស់ខ្ញុំ បានបរិចារកាត់ឯអស់របស់ខ្ញុំ, ពួកមុខមន្ត្រីរបស់ខ្ញុំព្រមទាំងខ្លួនខ្ញុំ កូនខ្ញុំឈ្មោះកុនាលនឹងមនុស្សដទៃទៀត ដូចារត្តទាំងអស់នេះទៅព្រះកិកុសង្ឃ ។ ខ្ញុំប្រាថ្នាបង់ឲ្យគេប្រកាសនាមរបស់ខ្ញុំឲ្យបានជាក់ច្បាស់ថាជាអ្នកបរិច្ចាគទាន ដល់ប្រជុំសង្ឃដ៏ច្រើនអស់កាលនៃរដូវភ្ញៀងទាំង ៥ ខែ" ។

កាលទ្រង់បរិច្ចាគទានរួចស្រេចហើយ ក៏ពួកភិក្ខុសង្ឃអនុមោទនាថ្វាយព្រះពរ លុះព្រះអង្គទទួលត្រេកអរនឹងអនុមោទនាពរនេះ ស្តេចត្រាស់ឲ្យសោងកំពែងក្នុងទិសទាំង ៤ នៃពោធិព្រឹក្ស ហើយស្តេចយាងទៅលើខឿនពោធិព្រឹក្សនោះទ្រង់យកក្អមទាំង ៤ ពាន់ដ៏មានដំឡៃ ពេញទៅដោយសុគន្ធវារី ព្រះអង្គស្រោចដើមពោធិព្រឹក្សនោះ លុះទ្រង់ស្រោចរួចហើយ ទើបស្តេចប្រគេនកត្តិជល់ព្រះភិក្ខុសង្ឃ ។

ព្រះយសត្ថេរថ្វាយព្រះពរថា "ទុព្រះរាជា! ព្រះអង្គបានដួចនឹងបុញ្ញក្ខេត្តមួយដ៏ឧត្តមបំផុត សូមទ្រង់កុំព្រួយព្រះពជ្ឈប្បទ័យថានឹងបានទទួលត្រកិរិយាសដទៃផ្សេងទៀតឡើយ" ។

---

១ ក្នុងទំព័រខាងមុខ នឹងអាយុ.វង.ពឹង: ស្តេចរក្សាឃ្លាំងរតនវត្ថុទុក ។

ព្រះពជាស្តេចអគ្គិសេនាបតីហារដោយផ្លាស់ខ្លួនព្រះអង្គ រហូតដល់ពួកសាមណេរតូច។ ។

គ្រាមួយមានសាមណេរពីរូប ជាមិត្តសំឡាញ់ភ្ជាប់គោរពដល់គ្នាខ្លាំងគ្នាសាមណេរមួយរូបចាប់ក្រាបត្រគេនទៅសាមណេរមួយ ហើយសាមណេរនោះត្រូវគេនក្រាបត្រឡប់មកវិញដែល ។ សាមណេរមួយរូបត្រូវគេនទំពីដំទៅសាមណេរមួយ ហើយសាមណេរនោះត្រូវគេនទំពីនមកវិញដែល ។ សាមណេរមួយរូបត្រូវគេនដំណាច់ទៅសាមណេរមួយ ហើយសាមណេរនោះក៏ត្រូវគេនដំណាច់មកឲ្យវិញដែលឲ្យគ្នាទៅវិញទៅមកយ៉ាងនេះ ព្រះមហាកស្សបត្ថេរឯកដងតឃើញ ទើបស្តេចទ្រង់ព្រះសម្រួលដោយព្រះដម្រិះថា "សាមណេរទាំងពីរនុ៎ះ លេងទៅវិញទៅមកដូចជាពាក" ។ លុះទ្រង់អគ្គិសេនាបតីហារហួតទៅដល់មុខព្រះថេរៈ ក៏បានថ្វាយព្រះតេរស្សរថា "នែព្រះពជា! កាលបើព្រះអគ្គទតឃើញវត្ថុណាមួយផុតចក្ខុវិស័យ ទ្រង់ទំងមិនបានទីកនិន្នាក្តងព្រះពជហ្ឫទ័យទេឬ?

ព្រះពជាត្រាស់តបថា "នេះលោកម្ចាស់ តែពលនេះខ្ញុំឃើញច្បាស់ទំងក្អែកជាសាមណេរទាំងពីរូបនោះកំពុងលេងដូចជាពាកតូច។" ។

ព្រះថេរៈថ្វាយព្រះពរថា: "បពិត្រមហាពជ! កុំស្តេចនិន្នាឡើយ សាមណេរទាំងពីរូបនុ៎ះជាព្រះអរហន្តបានក្រែបងកនូវទំពកអម្រឹតមហាទិញ្ញានហើយ" ។

ព្រះបរមគ្រូតែយ៍ខ្ញុំព្រះសណ្ដាប់ថវាក់ថានោះហើយ ព្រះពុទ្ធ-
ន័យតេញាភៅដោយសេចក្ដីរីករាយ ទើបខ្ញុំព្រះដម្រែះថា: "អាត្មាអញ
ខ្ញុំដែលតែងសំពត់មានសាច់ម៉ដ្ឋដល់ព្រះសង្ឃឲ្យបានត្រប់រូបគាំងអស់" ។

ខណៈនោះ សាមណេរពាំងតាំរូបដ៏ងព្រាកដម្រែះដូច្នោះ ទើប
ប្រកាសគ្នាថា "ឥឡូវនេះ យើងគួរខ្ញុំងឲ្យព្រះពុទ្ធាខ្ញុំមានព្រះពុទ-
ស្ដាត្រមាំងសេចក្ដីគោរពខ្ញុំតុណាឡើងទៀត" ។

គ្រានោះ សាមណេរពាំងតាំរូបនោះ សាមណេរមួយរូបប្រុង
ប្រៀបស្លាកសម្រាប់ដែលត់ មួយរូបទៀតនាំយកទូរត្រឿងដែលត់មក
ក្នុងទីនោះ ។

ព្រះពុទ្ធាខ្ញុំឥតឃើញដូច្នោះ ទើបមានព្រះបន្ទូលខ្ញុំងសាមណេរ
តាំងតាំរនោះថា "ម្នាលកម្មាស់នាំគ្នាធ្វើអ្វីហ្នឹងញាប់ដៃម្ល៉ះ?"

សាមណេរថ្វាយព្រះពរថា "ព្រោះតែអាត្មាភាពតាំងតាំរូបនេះ
ទើបព្រះអង្គមានព្រះពុទ្ធបំណងខ្ញុំងព្រះពុទ្ធានសំពត់មានសាច់ម៉ដ្ឋដល់
ព្រះភិក្ខុសង្ឃទូទៅគ្រានេះ អាត្មាភាពតាំងតាំរូបប្រុងប្រៀបត្រឿងដែ-
លត់ត្រៀមខ្ញុកឲ្យហើយ ដើម្បីខ្ញុំងដែលត់សំពត់តាំងនោះ" ។

គ្រាខ្ញុំងព្រះសណ្ដាប់ពាក្យនោះហើយ ព្រះពុទ្ធាស្ដេចខ្ញុំងព្រះ
ឱដ្ឋាថា "សាមណេរតាំងតាំរូបនេះដ៏ងខ្ញុំងតំនិតរបស់អញ" ហើយ
ស្ដេចខ្ញុំងសោមនស្សដ៏តែតែខ្លាំងឡើងទៀត ទើបព្រះអង្គប្រាយបន្ទូ

ផ្តាល់ទឹងដៃដោយបញ្ចូនប្រតិស្ថានគោរពចំពោះព្រះចុន្ទសាមណេរ
ទាំងពីរប្រការ ស្តេចដើរចេញប្រណម្យព្រះហស្តត្រាស់ថា: "ពួកញាតិ
មិត្រនិងពួកពលជាបរិវារបស់ខ្ញុំ ជានសេចក្តីចំរើនដ៏ធំទូលាយ
ដោយជានជួបនឹងបុញ្ញក្ខេត្តយ៉ាងប្រសើរបំផុតនេះ, ឥឡូវនេះខ្ញុំនឹងបរិច្ចាគ
វត្ថុដែលខ្ញុំអាចនឹងបូជាជានទាំងអស់នោះ" ។ ព្រះមហាកស្សបត្ថេរ ត្រាស់
នឹងសាមណេរទាំងពីរប្រការនោះថា "ព្រោះដោយសារគុណានុភាពលោក
ម្ចាស់ ទើបខ្ញុំជានបូជាវត្ថុដែលព្រះកិត្តិសង្ឃត្រេកអរបូជាដូច្នេះ" ។

តពីនោះមក ព្រះចុន្ទអរសោកជានធ្វើនូវបញ្ជាសិបឆ្នើយ ព្រះអង្គជាន
ព្រះរាជទានទ្រព្យមួយសែនដំឡឹងមាស, ព្រះរាជធីតាបស់ព្រះអង្គ, ពួក
ជាតិបរិជាតិ, ពួកសេនាបតី ខ្ញុំនបស់ព្រះអង្គ ព្រះរាជទានសព្រះនាម
កុនាលនឹងវត្ថុឯទៀតជាច្រើន ដល់ព្រះសង្ឃហើយស្តេចយាងត្រឡប់
ទៅកាន់វិសេនព្រះអង្គវិញ ។

ខាងក្រោយដែលព្រះចុន្ទអរសោកទ្រង់មានព្រះរាជសទ្ធាជ្រះថ្លានឹង
ធ្វើសេចក្តីគោរព (ចំពោះព្រះធម៌របស់ព្រះពុទ្ធនោះមក) ទ្រង់ជានសាង
ព្រះស្តូប ៨៤,០០០ នឹងធ្វើកិច្ចបញ្ជាសិនោះក៏ពួកអ្នកស្រុកនឹងអ្នកខនា
ពេញទាំងសកលជម្ពូទ្វីប នាំគ្នាមានប្រសាទសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធព្រះ
ធម៌ខ្លាំង ។

អវជាតនៃព្រះអនុជ របស់ព្រះបាទអសោក

ព្រះអនុជរបស់ព្រះបាទអសោក ព្រះនាមវីតសោក[1]ជាអ្នកមានសទ្ធាជឿក្នុងធម៌វិន័យរបស់ពួកតិរ្ថិយ តែរាល់ពេលដែលព្រះធម៌ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ព្រះអនុជបួលចិត្តជឿថា "ពួកសមណៈជាសក្យបុត្រ ដែលចេញបួសហើយបានសមគមហានិញ្ចាននោះសូម្បីតែម្ចាក់ត្បូងផង" ។

គ្រានោះ ព្រះបាទអសោកត្រាស់ទៅវីតសោកថា "ដូចម្តេចបានជាអ្នកដ៏ឆ្ងាយយ៉ាងនោះ?"

ព្រះអនុជក្រាបទូលថា: "ព្រោះពួកសមណជាសក្យបុត្រទាំងនោះសោកវៀរចាកសេចក្តីប្រតិបត្តិដ៏លំបាក ហើយសែ្វងរកតែសេចក្តីសុខសម្រាន្ត" ។

ព្រះមហាក្សត្រិយ៍ត្រាស់ទៅវីតសោកដាក់ព្រះអនុជថា "ចូរអ្នកបំភ្លេចឲ្យដាច់ កុំដឿងក្នុងដែលគេមិនគួរដឿងដូច្នោះឡើយ រហើយកុំគុំនឹងដល់អ្នកមានសទ្ធាល្អឲ្យសោះ ត្រូវតែអ្នកមានសទ្ធាដ៏ជ្រះថ្លាទូលាយដឿងក្នុង

---

១ ច្បាប់ដើមដាក់តាមពាក្យចំនួនថា សុទនោ អ្នកប្រែថា សុទ្ធន្តៈ បើតាមបែបនេះរកប្រាកដមិនបាន តែដែលខ្ញុំដាក់ថាសេចក្តីវីតសោកនោះដោយអាងខាងដើម ថា: ព្រះមាតារបស់អសោកមានព្រះរាជបុត្រមួយទៀតឈ្មោះវីតសោក ។ ក្នុងច្បាប់អាយុវង្សក៏ដូចគ្នាមានពាក្យថាវីតសោកដែរ ហេតុនោះវីតសោកទើបត្រូវដាង, បើសិនឡើងយកសេចក្តីដាប្រមាណជាយើញដាមិនប្លែកគ្នាទេ ព្រោះសុទនៈក្តីប្រែថាឡសុទ ឯវីតសោក (គឺថាជាឡសុទដូចគ្នា) ។

ព្រះតុន្ដុកដ៏ព្រឹទ្ធមិនឆ្ងាយព្រះសង្ឃខ្សោយ" ។ កន្លងណាៈដងនៃតព្រះថេរៈ
អសោកស្ដេចកំពុងយាងប្រកាត (បរជ្ញា) ជាមួយនឹងព្រះវិតសោក
ជាព្រះអនុជទ្រង់ចានទស្សនាការព្រាហ្មណ៍ម្នាក់កំពុងវែកកំដៅខ្លួនដោយ
គំនរភ្លើងខាំងធ្ងាំក្នុក វិតសោកជាព្រះអនុជមានចិត្តគេញាៈដោយសទ្ធា
និងសេចក្ដីគោរព ទើបចូលៈទៅជិតទ្រង់ថ្វាយបង្គំដើងព្រាហ្មណ៍ហើយ
ត្រាស់សួរថាៈ "លោកប្រព្រឹត្តក្នុកកំរៃយោដ៏លំបាកនេះ ប៉ុន្មានឆ្នាំមក
ហើយ?"

ព្រាហ្មណ៍តបថាៈ "ដប់ពីរឆ្នាំហើយ" ។

"លោកទំលាប់បរិភោគអ្វីជាអាហារ?" ព្រាហ្មណ៍តបថា "បរិភោគ
តែផ្លែឈើនិងម៉ែមឈើ លោកបំពេញកាយដោយសំលៀកបំពាក់អ្វី អាត្មា
បំពេញកាយតែដោយសំលៀកបំពាក់ស្មៅ" ។

"លោកយកអ្វីធ្វើជាទំដេក?"

ព្រាហ្មណ៍តបថាៈ "កម្រាលស្មៅជាគ្រែដេករបស់អាត្មា" ។

(ព្រះវិតសោក) សួរថា "កិច្ចដែលលោកធ្វើពាំនោះមានផ្លែអ្វី
ដែលលំបាកកៃក្រៃលែងជាងនេះទៀត?"

ព្រាហ្មណ៍តបថា "កាលបើអាត្មាឃើញសត្វម៉ែគក្នុងផ្លូវដែលក
ក្លាញីឈ្មោលក ក៏ភ្លើងកាត់តែត្រូវខ្លួនអាត្មាធ្វើឲ្យរហប់រលស់សព្វសព្វជាមិន
ខ្លះឯងជាកិច្ចដែលលំបាកបំផុតរបស់អាត្មា" ។

រីតសោកទើបគ្រាស់ថា "ខ្ញុំ! លោកអ្នកបិទបាំងកាយតែដោយសំលៀកបំពាក់ដ៏សៅហ្មង បរិភោគតែអាហារដ៏សៅហ្មង ហើយលោកនៅតែមានពាគគណ្ហា នៅឡើយទៀត ចំណង់បើពួកសមណៈជាសក្យបុត្តដែលបិទបាំងកាយតែដោយសំលៀកបំពាក់ដ៏ប្រសើរ បរិភោគតែអាហារមានរសឆ្ងាញ់ដូចម្តេចឡើយនឹងរម្ងាប់ពាគគណ្ហាបាន ក៏ស្តេចអាសោកជាព្រះដង្កាអញមិនដែលដឹងរឿងប្រព្រឹត្តតបធម៌នេះសោះឡើយ ឃើនជាស្តេចចាញ់ចោកពួកសមណៈជាសក្យបុត្តដល់ម្ល៉ោះ" ។

ព្រះចាទអាសោកទ្រង់ព្រះសណ្តាប់ពាក្យព្រះអនុជហើយ ទើបទ្រង់គ្រាស់នឹងពួកសេនាបតីព្រះអង្គថា: "យើងត្រូវប្រែឧបាយកលយ៉ាងវិសេសមួយ ដើម្បីនឹងឲ្យរីតសោកមានប្រសាទសទ្ធាជះភ្លឺក្នុងព្រះធម៌របស់ព្រះសក្យមុនី ហើយនឹងព្រះអមតមហានិព្វាន" ។

ពួកសេនាបតីក្រាបទូលថា "បពិត្រមហាកសត យើងនឹងតាមព្រះពាសនាព្រះអង្គ" ។

ព្រះមហាក្សត្រិយ៍ទ្រង់ដោះគ្រឿងប្រដាប់ព្រះសិរីនឹងមង្គដដែលជាគ្រឿងសំគាល់នៃព្រះពាសាហើយ ទើបទ្រង់ព្រះតស្តូសម្រាប់ស្រង់ស្តេចយាងចូលទៅស្រង់ទឹកក្នុងបន្ទប់ វេលានោះពួកសេនាបតីក្រាបទូលព្រះអង្គម្ចាស់រីតសោកថា: "កាលបើព្រះចាទអាសោកនិវត្តទៅ ព្រះអង្គនឹងជាក្សត្រិយ៍ដណាងឡើង ពេលនេះ សូមព្រះអង្គទ្រង់គ្រឿងប្រ-

ជាប់ព្រះសិរីធម្មឆ្នូរនេះលេម៉ើល ទើបបានឃើញថា: "ព្រះអង្គល្អសម-
រម្យជាក្សត្រិយ៍យ៉ាងណាដែរ ឬទេ?" ។

ព្រះវិតសោកក៏ផ្សឹតាមពាក្យពួកសេនាបតី បានប្រជាប់ព្រះកាយ
ដោយវត្ថាភរណៈដូច្នោះហើយ ស្តេចឡើងប្រថាប់លើបល្ល័ង្កផ្ស
ស្រាប់តែព្រះពជាស្តេចចេញចាកបន្ទប់ទឹកទ្រង់ទតឃើញវិតសោកជាព្រះ
អនុជប្រថាប់លើបល្ល័ង្កផ្ស ក៏ព្រះអង្គត្រាស់គម្រាមថា "អញមិនបាន់
ស្មាប់ទៅឡើយ ឯងហ៊ានសោយពជ្យទៅហើយ!" ខណៈនោះព្រះ
ពជាទ្រង់ត្រាស់ព្រះសូរសៀងដ៏ខ្លាំងៗថា "យើអ្នកណាទើបវិយ!" គ្រា
នោះពួកចណ្ឌាល (ពេជ្ឈឃាត) ដៃម្ខាងកាន់ដាវ ដៃម្ខាងកាន់គាំង
លេចឡើងស្រមតនាំគ្នាចូលទៅក្រាបទូលព្រះពជាថា "សូមទ្រង់ព្រះ
មេត្តាប្រោសព្រះអង្គមានព្រះពជប្បាថ្នាឲ្យបានត់ការយ៉ាងណា?"

ព្រះបរមក្សត្រិយ៍ត្រាស់តបថា "គ្រានេះត្រូវយើងលះបង់ចេវិត-
សោកចោល យើងអនុញ្ញាតឲ្យអ្នកកាលំគ្នាវាយប្រដៅផ្តាញ់ផ្តាលវាឲ្យ
យើង" ។

ពួកសេនាបតីក្រាបទូលសូមពោសថា "ព្រះវិតសោកជាព្រះអនុជ
ព្រះអង្គដ៏ពិតប្រាកដណាស់ សូមទ្រង់ព្រះមេត្តាប្រោសទ្រង់ព្រះពជទាន
ពោស កុំផ្តន្ទាកុំផ្តាញ់ផ្តាលឡើយ" ។

ព្រះពុទ្ធ ត្រាស់ថា "យើងអនុកូលតាមពាក្យអ្នកទាំងឡាយ យើងព្រមឲ្យវាសោយពុទ្ធបានត្រឹម ៧ ថ្ងៃសិនចុះ តែតទៅនឹងត្រូវពិឃាតជីវិតបង់" ។

ក្នុងពេល ៧ ថ្ងៃនោះ គេលេងតូរ្យតន្ត្រីពប់ដោយសែនកក្រើង ពួកព្រាហ្មណ៍ទាំងមួយសែនក៏មកប្រជុំគ្នាចំពោះព្រះភក្ត្រ ប្រណម្យដៃពោលសរសើរគុណព្រះចៅវិតសោក ពួកស្រីតន្ទាល់ទាំងមួយសែនចោមរោមតាល់ចំរើរត្បិបត្រា ឯពួកចណ្ឌាល (ពេជ្ឈឃាត) ទាំង ៤ មានដៃប្រលាក់ដោយឈាមនៅស្រស់ៗ ធ្វើអាការៈហាក់ដូចជាចង់ពិឃាតអ្នកណាមួយ ស្រែកសួរសេពួទ្រហឹងអឺងកងនៅមាត់ទ្វារទាំង ៤ ថា: "ពត្រីមួយថ្ងៃនេះ ក្នុងផុតទៅហើយ នៅតែ ៦ ពត្រីទេតរេ យើងនឹងចំណាយការយអ្នកឯង យើងនឹងផ្តាច់បង់អាយុវាសអ្នកឯង យើងនឹងពិឃាតជីវិតអ្នកឯង សេចក្តីស្លាប់របស់អ្នកឯងជិតដល់ហើយ" ពួកវាធ្វើអាការក្នុងថ្ងៃទី ១ ដូច្នោះហើយក៏ធ្វើរឿងៗមករហូតមកដល់ថ្ងៃទី ៧ ក៏ស្រែកតែសួរសំឡេងបែប ១ ។

លុះថ្ងៃទី ៧ ក្នុងផុតហើយ គេនាំព្រះចៅវិតសោកទៅតាល់ព្រះពុទ្ធ ស្តេចទ្រង់ត្រាស់សួរព្រះអនុជថា: "ក្នុងពេល ៧ ថ្ងៃនេះ ឯងសប្បាយចិត្តណាស់ទៅឬ?"

ព្រះវិតសោកតបថា ក្នុងពេល ៧ ថ្ងៃនេះចក្ខុទ្វារមិនបានឃើញរូបារម្មណ៍អ្វីទេ អណ្តាតខ្ញុំមិនបានលិទ្ធភ្លក់រសារម្មណ៍អ្វីទេ ព្រោះអ្វី? ព្រោះ

ថាខ្ញុំបានឃើញពួកចណ្ឌាល (ពេជ្ឈឃាត) កាប់ស្រែកដង លើកដាវងាប់
ទៅដ៏ជាក់ជាំនឹងតែពីថ្ងៃទី ១ កន្លងហើយក៏ថា "ឯងសោយភត្តបាន ៧ ថ្ងៃ
ហើយ ឯងនៅតែគ្រឹម ៦ ថ្ងៃទៀតទេ" តែបៃបនេះកាលថ្ងៃហួតមកដល់
ថ្ងៃទី ៧ ខ្ញុំព្រះអង្គជាខ្លុកក្រយៅស្រែវាសាច់ឥតមានណាម័យមកយាយី ខ្ញុំ
ព្រះអង្គពំពីតិតថប់បារម្ភស្បែងខ្លាច ក្នុងពេលកន្លែងនោះខ្ញុំព្រះ
អង្គមិនគាបនឹងផ្ទុំបានទេ បើដូច្នេះតើ សេចក្តីសុខសម្រាន្តនឹងមានដល់
ខ្លួនខ្ញុំព្រះអង្គដូចម្តេច?"

ព្រះមហាកស្សបត្ថេរ៍ត្រាស់តបថា: "ត្រាន់តែជាខ្លុកនឹងមរណៈភ័យ
ដែលនឹងចំផ្ទាញជីវិតមួយប៉ុណ្ណោះ ឯងថាមិនដឹងនូវសេចក្តីសុខក្នុង
ភាពជាកញ្ជាធិបតីទៅហើយ ចំណែកបើពួកសមណៈជាសក្យបុត្រ លោក
តែងនឹកឃើញនឹងជាខ្លុកក្រយដល់សេចក្តីលំបាកនានា ដែលរួមនឹងកើតខ្លុក
គឺជាតិ, ជរា, ព្យាធិ នឹងមរណៈ សេចក្តីលំបាកនៃពួកអ្នកដែលផ្ទាក់ផៅ
សោយខ្លុកក្នុងនរកមានក្តៅនេះផង្គរខ្លាចផ្សង។ ត្រង់ប៉ាន សេចក្តីលំ-
បាកនៃពួកសត្វតិរច្ឆាន ដែលមានសេចក្តីតក់ស្លុតជាទម្ងន់ នឹងការត្រាំ
ពួកសត្វឯទៀតស៊ីជាអាហារ សេចក្តីលំបាកនៃពួកប្រេត ដែលត្រហល់
ត្រហាយដោយសេចក្តីស្រេកឃ្លាន ។ ក្នុងពួកមនុស្សនេះអ្នកណាដែល
ជាអ្នកមានសេចក្តីសុខ តង់តែមានសេចក្តីខ្លុកលំបាកជាប់ភ្លាមមក ចាំបាច់

ទំយើយទៅថ្វីដល់ពួកសត្វដែលមិនមានសេចក្តីសុខនោះ សូម្បីខេត្តចាំង-ឡាយដែលជាអ្នកសោយតែសេចក្តីសុខជង់ក៏ដោយ ក៏គង់តែមានទុក្ខ ព្រួយទំនឹងការច្យុតទៅក្នុងអនាគតដែរ ។ ក្នុងកំរិយាបួកូរមនៃតពចាំង ៣ សត្វដែលមានដំរែតចាំងឡាយគ្រប់ចំពួករមែងឈឺកាយឈឺចិត្ត ហើយ សេចក្តីលំបាកចាំងអស់នោះ បង្ខំដម្រែញាតៅរកសេចក្តីស្លាប់ទំនឹងធ្វើទុក្ខបុក ម្នេញពួកសត្វឲ្យបានសេចក្តីក្តៅក្រហល់ក្រហាយ ។ ខន្ធចាំងឡាយ ៥ ដូចជាពួកចណ្ឌាល (ពេជ្ឈឃាត) ដែលគាន់ជារងារឡើងទំនឹងប្រហារជីវិត ។ អាយតនៈចាំងឡាយ ៦ ដូចជាភូមិដែលគេចំផ្លាញហើយ ។ អារម្មណ៍ចាំងឡាយ[1] ៥ ដូចជាចោរបួនដែលជាខ្មាំងសត្រូវ ។ ពួកសត្វចាំងអស់ក្នុងកពចាំង ៣ សុទ្ធតែត្រូវក្លិងគឺអនិច្ចតាធម៌គេះបំផ្លាញទៅជាខិច្ច ។ វត្ថុចាំងអស់មិនទៀង, ជាទុក្ខ, សូន្យទៅខេ មិនមានជារបស់ខ្លួន ព្រោះហេតុដូច្នោះ ឋានជាគេថា:ពួកសមណៈជាសក្យបុត្រមិនចាប់ប្រ-ព្រឹត្តធ្វើកិរិយាដ៏លំបាក ហើយលោកឋានដល់ខ្លួរអមតមហានិព្វានមិន មែនឬ? ចិត្តរបស់ពួកសមណៈមិនមែនសៅហ្មងដោយកាមកាតខេ កាម-កាតនោះដូចជាឪកដែលមិនស្អិតជាប់នៅលើត្រចកនៃផ្កាឈូកឡើយ ពួក សមណៈចាំងនោះ មានចិត្តខ្សឹយណាយទំនឹងវដ្តសង្សារហើយរើបលោក ភ្លេចខ្លួនចេញចាកកពទៅបាន ចុះបើលោកប្រព្រឹត្តធ្វើយ៉ាងដូច្នោះហើយ ដូចម្តេចបានជាមិនបានសម្រេចផលគឺអមតមហានិព្វាននៅឡើយ ?"

---

១ រូប, សម្បុត, ក្លិន, រសៈនិង សម្ផស្ស ។

ព្រះចុតអរសោក ខ្ញុំនឹងបួនានព្រះវតសោកជា ព្រះអង្គុជគ្រប់ថែប យ៉ាងដូច្នេះហើយ ។ណៈនោះ ព្រះវតសោកប្រណម្យព្រះហស្តហើយទូលព្រះវរៀមថា: "បពិត្រមហាភាជ! ពេលនេះខ្ញុំសូមដល់នូវព្រះរតនត្រ័យជាទីពឹងទីរលឹក" ។

គ្រានោះ ព្រះចុតអរសោកកេកព្រះសុរង្គព្រះមុនុជហើយត្រាស់ថា "យើងមានប្រាថ្នាចង់ធ្វើឯងឲ្យមានប្រសាទសទ្ធាជ្រះថ្លាក្នុងព្រះធម៌របស់ព្រះភ្នុ ហើយឲ្យឯងតិតនឹងរលឹកព្រះធម៌នោះឡើង ព្រោះដូច្នោះ បានជាយើងធ្វើទុក្ខយកលនេះ ដោយពិតនោះ យើងមិនសម្ងាប់ឯងទេ" ។

គ្រានោះ ព្រះវតសោកបានថ្វាយគ្រឿងសុគន្ធជាតិនឹងផ្កាកម្រងដល់ព្រះស្តូបតាំងឡាយរបស់ព្រះពុទ្ធហើយ បានទៅស្តាប់ធម៌ទេសនាខ្ពង់បានធ្វើសក្ការបូជាដល់ពួកតិក្ខុសង្ឃ ហើយស្តេចយាងដម្រង់ចូលទៅគាន់តែកុកកាម លុះស្តេចយាងទៅដល់ថ្វាយបង្គំព្រះយសត្ថេរហើយទើបប្រថាប់ទៅក្នុងទីចំពោះព្រះភក្ត្រព្រះថេរៈស្តាប់ធម៌ទេសនា ។ លំដាប់នោះ ព្រះថេរៈពិចារណាមើលនូវបទិស្សយក្នុងកាលមុនរបស់ព្រះវតសោក ក៏ជ្រាបភ្លាមរហូតដល់កុសលមូលជាបុរេរបស់ព្រះអង្គដែលបានសាងមកពុំហើយ ជាតិនេះជាបច្ចិមជាតិ ត្រូវព្រះអង្គស្តេចចូលកាន់ព្រះនិព្វានក្នុងអត្តភាពជាបច្ចុប្បន្ននេះឯង ព្រោះហេតុនោះ ព្រះថេរៈទើប

លោកធម្មសូត្រ

ព្រះគ្រូញាណសំវរៈញាណ-ឈឺន

ក្រុមដំនុំប្រែព្រះត្រៃបិដកក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យប្រែនិងរៀបរៀងជាសេក្តី ។

ភាគ្យនាំ

សៀវភៅ "លោកធម្មសូត្រ" នេះ ខ្ញុំបានដកស្រង់មកពីគម្ពីរជាច្រើន គឺពីអដ្ឋកនិបាតព្រមទាំងអដ្ឋកថា, ពីមង្គលត្ថទីបនីអដ្ឋកថា-មង្គលសូត្រ, ពីអដ្ឋកថាធម្មបទ នឹងមិលិន្ទប្បញ្ហា; ដើរសរើសយកសេចក្តីតែត្រង់លោកធម៌ទាំង ៨ ប្រការ, មកបង្កប់ជាកម្រងជាមួយគ្នា កំណត់ឲ្យឈ្មោះសៀវភៅនេះថា "លោកធម្មសូត្រ" តាមដើម, រៀបរៀងចប់រួចស្រេចមកជាហូរណាស់ហើយ តាំងពី ព. ស. ២៤៨១ គ. ស. ១៩៣៨ តែមិនទាន់មានឧកាសនឹងឡើងកាន់ពុម្ព, លុះមកដល់ឆ្នាំមមីចត្វាស័ក ព. ស. ២៤៨៥ គ. ស. ១៩៤៣ នេះ, ស្រាប់តែព្រះសាគ្យវង្ស អធិបតីវគ្គនៃក្រុមដំនុំប្រែព្រះត្រៃបិដក, លោកតម្រូវឲ្យរៀបរៀងរឿងអ្វី ១ ដើម្បីនឹងដាក់ចុះក្នុងសៀវភៅគម្ពីរសុរិយាជាមួយនឹងអស់លោកជាក្រុមដំនុំទាំងអស់; នោះខ្ញុំក៏តាំងព្យាយាមតាមនិត្យរឿងនេះជាថ្មីឡើងវិញ ក្រយហើយប្រគេនមកលោកតាមការ, ដើម្បីនឹងឡើងកាន់ពុម្ព

ជ្រាយឲ្យជាប្រយោជន៍ដូចៅដល់សិក្ខាកាមកុលបុត្រតាំងឱ្យយកគ្រូការមើលរៀនទៅទៀត ។

ទៅទីបំផុតនេះ, សូមជ្រាយកុសលដ៏ខ្ពង់ខ្ពស់ដែលហូរចេញមកអំពីកំលាំងព្យាយាមប្រឹងប្រែងនេះ ជូនដល់បុព្វបុរសត្រង់ជាន់ត្រង់ថ្នាក់ទំនងពួកឥស្សរជនត្រង់ដំណែង, សូមឲ្យបានសោយទីវង្គមនុញ្ញផលតាមសមគួរដល់អធ្យាស្រ័យតទៅ ។

វត្តលង្កា ឃុំលេខ ៤ ក្រុងភ្នំពេញ
ថ្ងៃសៅរ៍ ១៤កោដទែមិតសារ ឆ្នាំខមីបញ្ចស័ក ព. ស. ២៤៨៥
ក្រុមដំនុំប្រែព្រះត្រៃបិដកក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ
ព្រះគ្រូញាណសំវរៈ ញាណ-ឈឺ

លោកធម្មសូត្រ

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការថ្វាយចង្គំ ចំពោះព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គ
នោះ ។

មុននឹងពណ៌នាសេចក្តីក្នុងលោកធម្មសូត្រនេះ, ខ្ញុំសូមដំណល
សេចក្តីជាបុព្វយោគទេសនា, ឲ្យមានចំនងស្រួលបន្តិចបន្តួចជាងដើម
សិន សន្សឹមរៀបរៀងសូត្រនេះតាមលំដាប់តទៅ ។

សេចក្តីថា: ចំពោះមនុស្សយើងក្នុងលោកសន្និវាសតាំងមូល រមែង
មានសន្ដានចិត្តរពើតរពើង, ខ្លះឆាប់ ខ្លះយូរ ខ្លះឆាប់ខ្លះយូរ
តាមចំនងដែលបានដួចប្រទះនឹងលោកធម៌នោះៗមកប៉ះពាល់ ម្ល៉ោះហើយ
សន្ដានចិត្តរបស់យើងមិនងាយនឹងឈប់នៅនឹងបានឡើយ, គួរនាដូចរូប
ខ្វែង, តែងតែនឹងងាកវេរតាមចំនងៗល់បក់មកត្រូវដួចោះដែរ ។

មួយទៀត, មនុស្សយើងបើនឹងចែកចេញជាជាន់ ជាថ្នាក់ៗ ទៅ
បាន ៣ ថ្នាក់ គឺថ្នាក់ជាន់ខាង, ជាន់មធ្យម, ជាន់ខ្ពស់ ។

ថ្នាក់ជាន់ខាង, បានដល់ពួកមនុស្សដែលមានចិត្តស្រាល មិនធ្ងន់
ធ្ងរមានសន្ដានឧកក់មិនដែរ ទាំងតែចៀសក៏ស្រាល ក្រែងខឹងក៏ងាយ
ស្ងៀមក៏ងាយ, ជាក៏ងាយ អាក៏ងាយ ភ័យក៏ងាយ; មនុស្សក្រុមនេះ
គួរនាដូចជាតំឈើស្រាយសុទ្ធមានដើមតរ, រកាជាដើម មានឫសកក់,

ឈើទាំងនេះមិនមួនតាំសោះ ខន្ធដែតត្រូវឲ្យលាងដឹងអាសរលើងរលាំមួយ រំពេចមិនយឺតយូរឡើយ, ទាំងសាច់ឈើក៏ប្រែការមិនជាប់ស្អិតស្អារដែរ ។

ថ្នាក់ជាន់មធ្យម, ចាន់ជាតិពួកមនុស្សដែលមានចិត្តមិនស្រាល-មិនធ្ងន់តេក មានសន្តានមិនពាក់មិនព្រៃតេក ទាំងត្រចៀកក៏មិនស្រាលតេក កណ្តាល។ មានការពិនិត្យវែងឆ្ងាយគ្រាន់បើ មិនខ្លីឯ, មិនជា, មិនដាច់, មិនអារ, មិនក័យឆាយ។ មនុស្សក្រែមនេះ គួរនាដូចជាតិឈើមានខ្លឹមខាងក្រៅ គឺដើមឫស្សីដើមស្វាដូនភ្នែតជាដើម, ឈើទាំងនោះមានឫសមិនព្រៃមិនពាក់ គ្រាន់តែសាញប្រជាញចាក់ស្រែះទៅលើគ្នាប៉ុណ្ណោះ ជាន់ក្រាំនឹងឲ្យលាងឮបានខ្លះ មិនឆាយនឹងរលើងរលាំទៅក្តាម។ ឡើយ, ទាំងសាច់ឈើក៏ប្រែការបានសម្រេចប្រយោជន៍ ប្រហែលឈើស្រាយសុខ្លីក៏មាន ជាប់ជាងក៏មាន ។

ថ្នាក់ជាន់ខ្ពស់, ចាន់ជាតិពួកមនុស្សដែលមានសន្តានធ្ងន់ធ្ង ទឹងនួនមិនរតើតរតើងឡើងៗ ចុះៗ ច្រើងៗ ផតៗ ដោរៗ នាបៗ ដោយឆាយឡើយ សឹងមានគំនិតថ្លឹងរំពឹងមើលរកហេតុផលគួរមិនគួរ ទឹងសេចក្តីចំរើន វិនាស, លុះយល់ច្បាស់លាស់តិតៗមែនៗ ទើបអនុវត្តទៅតាមចំនងនោះៗ; មនុស្សក្រែមនេះ គួរនាដូចជាតិឈើមានខ្លឹមខាងក្នុង គឺ: តន្តីរ ផ្ចឹក, ពិងក្តាដើម មានឫសត្រៃ មានសាច់ជាប់ ឈើទាំងនេះ

ប្រែការបានច្រើនយ៉ាង អ្នកប្រាជ្ញសែងតែងកង់កាន់ តែងប្រាថ្នាគ្រប់ៗគ្នា ហើយមិនឆ្ងាយនឹងរលើងរលំដោយឧប្បាទវ័យឡើយ: មនុស្សយើងក្នុងលោកសន្និវាសនេះ ប្រៀបដូចជាដើមឈើតាំង ๓ ពួក, លោកធម៌ប្រៀបដូចឧប្បាទបក់មកប៉ះពាល់ដូច្នោះឯង ។ តាំងនោះសោតលោកធម៌គួរនាដូចជាថ្មាំពុល តែងធ្វើមនុស្សឲ្យពុលគ្រប់ជាន់គ្រប់ថ្នាក់មិនថាថ្នាក់ណាឡើយ ។

ទើបព្រះសុគតជាម្ចាស់ ទ្រង់គ្រាស់សំដែងលោកធម្មសូត្រនេះដោយមានពុទ្ធអធ្យាស្រ័យ ដើម្បីនឹងធ្វើសត្តនិកាយដែលទៅក្នុងពុទ្ធគុណ. ខេត្តរបស់ព្រះអង្គឲ្យចេះពាស់-ថ្នឹង-ពស់ សូនឹងទៅតាមគួរនឹងទម្ងន់ដំរៅនៃលោកធម៌, នៅវេលាដែលចុងដួចប្រទះហើយនោះ ។ ដូចនឹងរៀបរៀងតទៅនេះ ។

លោកធម្មសូត្រ. ត. អដ្ឋកនិបាត.

អដ្ឋិមេ ភិក្ខវេ លោកធម្មា លោកំ អនុបរិវត្តន្តិ លោកោ ច អដ្ឋលោកធម្មេ អនុបរិវត្តតិ ។ ល ។

សេចក្តីថា: "ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំងឡាយ៨ប្រការនេះរមែងជាប់ជិតដោយតាមសត្វលោក ឯសត្វលោកក៏រមែងជាប់ជិតដោយតាមលោកធម៌ទាំង ๘ប្រការ (នេះ) ទំនងគេចវេះមិនផុតរត់មិនរួចឡើយ" ។

ប្រាំបីប្រការតើម្តេចទៅ គឺមានលាភ ១ អលាភ ១ មានយស ១ អយស ១ គេនិន្ទា ១ គេសរសើរ ១ សេចក្តីសុខ ១ សេចក្តីទុក្ខ ១ រួមគ្នាជា ៨ ប្រការដូច្នេះ ។ លុះទ្រង់សំដែងជាកថេតុកាម្យតាបុច្ឆា (១) ដល់ពួកឯសូត្រអង្គឯង ដោះសាចំពោះព្រះអង្គឯងរួចហើយ ទើបទ្រង់ភិញ្ញគាថាដូច្នេះថា:

លាភោ អលាភោ ច យសាយសោ ច
និន្ទា បសំសា ច សុខំ ទុក្ខំ ច
ឯតេ អនិច្ចា មនុជេសុ ធម្មា
អស្សស្សតោ វិបរិណាមធម្មា
ឯតេ ច ញត្វា សតិមា សុមេធោ
អវេក្ខតិ វិបរិណាមធម្មេ

១— បុច្ឆាមាន ៣ គឺអទិដ្ឋជោតនាបុច្ឆា ១ ទិដ្ឋសំសន្ទនាបុច្ឆា ១ វិមតិច្ឆេទនាបុច្ឆា ១ ។ ៣ ដៃរទៀតគឺមទុស្សុបុច្ឆា ១ អមតុស្សុបុច្ឆា ១ តិម្មិតបុច្ឆា ១ ។ ៥ យ៉ាងនៃទៀតគឺ អទិដ្ឋជោតនាបុច្ឆា សួរដើម្បីប៉ះពាល់សេចក្តីដែលខ្លួនមិនទាន់ដឹងមិនទាន់ឃើញ ឲ្យច្បាស់លាស់ឡើង ១, ទិដ្ឋសំសន្ទនាបុច្ឆា សួរតាមដែលបានដឹងបានឃើញ ដើម្បីនឹងប្រៀបធៀបដោយអ្នកប្រាជ្ញដទៃ ១, វិមតិច្ឆេទនាបុច្ឆា សួរដើម្បីនឹងវិនិច្ឆ័យនូវសេចក្តីសង្ស័យ ១, អតុមតិបុច្ឆា សួរស្រែបបណ្តោយតាមដើយ ១ ស្រែបបណ្តោយតាមសួរ, ដូចសួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់ថារូបទៀងឬមិនទៀង?", ដើយថា "មិនទៀងទេព្រះអង្គដ៏ចំរើន ១, កថេតុកាម្យតាបុច្ឆា សួរដើម្បីសំដែងចំពោះព្រះអង្គឯង, ក្នុងពាក្យថា "ម្នាលភិក្ខុទាំងឡាយសតិបដ្ឋានមាន ៤ យ៉ាង ។ នោះតើដូចម្តេច? ដូចដើម ១ ។

๕๘ สุขา ธมฺมา ฯ ปาเฏกฺกํ จิตฺตํ
อนิฏฺฐโต โน ปฏิฆาตเมติ
ตสฺสาวุโภ นิจฺจา อปฺปฏิโฆ
วิญฺญาตา อตฺถกตา ฯ สนฺติ
ปฏฺฐา ภิกฺขา ทิฏฺฐ อเสกฺขา
สมฺมปฺปญฺญาวิมุตฺติ ภาวิตฺถ ฯ

เสจกฺถา: โลกธมฺมาทิ๘ฝ่ายเหล่านี้ มีอยู่แก่โลก๑ อโลก๑ มีอายตนะ๑ อนายตนะ๑ เนกขัมมะ๑ เสขเปสิ๑ เสจกถาสุข๑ เสจกถาทุกข์๑ เป็นธรรมไม่เที่ยงแท้ ไม่ตั้งอยู่ เกิดขึ้นแล้วดับไป (ชั่วขณะสั้นๆ) เหมือนกับมนุษย์ทั้งหลายเป็นต้น. ผู้ใดรู้ชัดซึ่งโลกธรรมทั้ง๘นี้ ผู้นั้นชื่อว่ารู้จักโลก (โลก) ทั้งรู้จักโลกธรรมทั้ง๘นี้ด้วย; (อีก) ธรรมทั้งหลายเป็นที่ชอบใจของจิต (ของโลก) ไม่มีเลย, โลกไม่ได้ยินดีในเสจกถาที่ไม่เป็นประโยชน์ เพราะธรรมไม่เป็นที่ชอบใจ, โลกปฏิเสธเสจกถาที่ไม่เป็นประโยชน์ ทั้งปฏิเสธเสจกถาที่ทำให้จิตขุ่นมัว ทั้งทำให้ปราศจากความยินดีในเสจกถาที่ไม่เป็นประโยชน์, โลกรู้ชัดซึ่งปรมัตถธรรมทั้งหลายโดยชอบ ด้วยปัญญาอันชอบ, ไม่มีเสจกถาที่โลกยังไม่ได้ยินได้ฟัง ยังไม่ได้ทราบ ยังไม่ได้ทำให้แจ้ง ยังไม่ได้ทำให้ถึงพร้อม ยังไม่ได้ทำให้เจริญ ยังไม่ได้ทำให้มาก.

កាលដែលខ្ញុំសំដែងទិដ្ឋតាថានេះចប់ស្រេចហើយ ទើបខ្ញុំប្រាថនាទិតមវចនៈ សំដែងជូនថែមទៀត សេចក្តីដ៏ដែលខ្លះ មានពីស្តារជាដំបូងខ្លះ ។

ឯសេចក្តីពីស្តារថា ម្នាលកិកូតាំងឡាយ លោកធម៌ទាំង ៨ ប្រការ គឺ មានលាភ ឥតលាភជាដើម តែងកើតឡើងដល់បុគ្គលជាបុថុជ្ជនអ្នកមិនចេះ-ដឹងផង, តែងកើតឡើងដល់អរិយសាវកអ្នកចេះ-ដឹងផង មិនចៀសចាកផលនៃបុគ្គលណាមួយឡើយ, ហេតុដូច្នេះ ខ្ញុំចោទដល្លាំងនូវកិកូ-សេយ្យ ដើម្បីបំភ្លឺសេចក្តីតទៅទៀតថា ម្នាលកិកូតាំងឡាយបុនត្រង់អរិយ-សាវកអ្នកចេះ-ដឹង នឹងបុថុជ្ជនអ្នកមិនចេះដឹងមានសេចក្តីផ្សេងគ្នា, លើសខ្វះគ្នា, ខ្ពស់ទាបជាងគ្នាដូចម្តេចវិញ? កិកូតាំងឡាយក្រាបបង្គំទូលថា "បពិត្រព្រះលោកនាថជាម្ចាស់ដ៏ចំរើន ខ្ញុំព្រះអង្គទាំងអម្បាលនេះ ជាន ព្រះអង្គជាប្រធាន ជានព្រះអង្គជាអ្នកដឹកនាំ ជានព្រះអង្គជារឹតជាងផ្នែក, ឥឡូវណេះ សូមជានតាកជនាព្រះអង្គទ្រង់បំភ្លឺសេចក្តីនៃភាសិត (នេះ) ជានតួកខ្ញុំព្រះអង្គជាកិកូតាំងនុសង្គា លុះជានស្តាប់ភាសិតរបស់ព្រះអង្គ ហើយរឭកជានចាំទុកតរៅ" ។

ព្រះភ្នំព្រះអង្គទ្រង់ត្រាស់ថា "ម្នាលកិកូតាំងឡាយ បើដូច្នេះអ្នកទាំង-ឡាយចូរប្រុងស្តាប់, ចូរធ្វើទុកក្នុងចិត្តឲ្យប្រសើរចុះ តថាគតនឹងសំដែងឲ្យស្តាប់" ។ កិកូតាំងនោះទូលព្រះភ្នំព្រះអង្គដីកាថា "ព្រះករុណា ព្រះអង្គ" ។

ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ លោក
រមែងកើតឡើងដល់បុថុជ្ជនអ្នកមិនចេះដឹង, បុថុជ្ជននោះមិនចេះពិចារណា
មិនដឹងច្បាស់តាមពិតថា លោកនេះកើតឡើងដល់អាត្មាអញពិតហើយ
តែលោកនោះជាវេទស់មិនឲ្យឆ្ងាយជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា,
ឥតលោក, មានយស, ឥតយស, តេនិទ្ធា តេសរាសើរ, សេចក្តីសុខ,
សេចក្តីទុក្ខ រមែងកើតឡើងដល់បុថុជ្ជនអ្នកមិនចេះដឹង, បុថុជ្ជននោះមិន
ចេះពិចារណា មិនដឹងច្បាស់តាមពិតថា សេចក្តីទុក្ខនេះកើតឡើងដល់
អាត្មាអញពិតហើយ តែសេចក្តីទុក្ខនេះជាវេទស់មិនឲ្យឆ្ងាយ ជាទុក្ខ មាន
សេចក្តីប្រែប្រួលជាធម្មតា; ទើបជាន លោកក្តី ឥតលោកក្តី មានយសក្តី
ឥតយសក្តី តេនិទ្ធាក្តី តេសរាសើរក្តី សេចក្តីសុខក្តី សេចក្តីទុក្ខក្តី រមែង
គ្របសង្កត់ចិត្តរបស់បុថុជ្ជននោះ។ តែឯត្រកអរនឹងលាភដែលកើតឡើង
តែងថ្នាំងថ្នាក់គួចចិត្តកង់ឥតលាភ, តែឯត្រកអរនឹងយសដែលកើតឡើង
តែងថ្នាំងថ្នាក់គួចចិត្តកង់ឥតយស, តែឯត្រកអរនឹងពាក្យសរសើរដែល
កើតឡើង តែងថ្នាំងថ្នាក់គួចចិត្តកង់ពាក្យនិន្ទា, តែឯត្រកអរនឹងសេចក្តី
សុខដែលកើតឡើង តែងថ្នាំងថ្នាក់គួចចិត្តកង់សេចក្តីទុក្ខ; បុថុជ្ជននោះ
ខ្ជួលត្រង់ឯយកសេចក្តីត្រកអរ នឹងសេចក្តីថ្នាំងថ្នាក់គួចចិត្ត ដូចពាណិ-
ជាមកហើយយ៉ាងនេះ នឹងមិនរួចផុតចាកជាតិជរាមរណៈ សេចក្តីសោក

ទុក្ខេ ទុក្ខហេតុស្ស សេចក្តីចង្អៀតចង្អល់ចាំងឡាយទៀយ, តថា-
គតេហិ/ថា ជុំជួនខ្លះនោះមិនរួចពីកុក្កុច្ចទេ" ។

ម្នាលភិក្ខុទាំងឡាយ ក៏ឯលោកធម៌ទាំង ៨ ប្រការនេះ មានលោកជា
ដើម រមែងកើតឡើងដល់អរិយសាវកអ្នកបះ-ដំណឹង (ដូច្នោះដែរ), ក៏អរិយ-
សាវកនោះ (លោក) បេះពិចារណា (លោក) ដឹងតាមពិតថា លោកនេះ
កើតឡើងដល់គាត្មាអញពិតមែនហើយ តែលោកនោះ ជារបស់មិនទៀង
ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា: ឥតលាភ មានយស ឥតយស
វាក្យសរសើរ ពាក្យនិន្ទា សេចក្តីសុខ សេចក្តីទុក្ខ រមែងកើតឡើង
ដល់អរិយសាវកនោះ។ លោកបេះពិចារណា លោកដឹងច្បាស់តាមពិត
ថា សេចក្តីទុក្ខនេះ កើតឡើងដល់គាត្មាអញពិតមែនហើយ តែសេចក្តី
ទុក្ខនោះជារបស់មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា, ទើប
មានលាភជាដើមក្តី រមែងមិនត្រូវសង្កត់ចិត្តរបស់អរិយសាវកនោះជាន
ទៀយ: គាំងអរិយសាវកនោះរសាត់ទៀត លោកក៏មិនត្រេកអរនឹងលាភ
ដែលកើតឡើង មិនថ្នាំងថ្នាក់តូចចិត្តក្នុងឥតលាភ, មិនត្រេកអរនឹងយស
ដែលកើតឡើង មិនថ្នាំងថ្នាក់តូចចិត្តក្នុងឥតយស, មិនត្រេកអរនឹងវាក្យ-
សរសើរដែលកើតឡើង មិនថ្នាំងថ្នាក់តូចចិត្តក្នុងពាក្យនិន្ទា, មិនត្រេក
អរនឹងសេចក្តីសុខដែលកើតឡើង មិនថ្នាំងថ្នាក់តូចចិត្តក្នុងសេចក្តីទុក្ខ,

អរិយសាវកនោះ លោកលះចោលសេចក្តីត្រេកអរនឹងសេចក្តីថ្នាំងថ្នាក់ក្តួចចំពុក, ដូចពាណិជមកហើយយ៉ាងនេះ ដើម្បីរួចចាកជាតិ ជរា មរណៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ គោមនស្ស សេចក្តីចង្អៀតចង្អល់ចាំងឡាយ ហ្មាន, តថាគតហៅថា អរិយសាវកនោះរួចចាកទុក្ខមែន ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង ទើបបុថុជ្ជនអ្នកមិនចេះដឹង, មានសេចក្តីប្លែកគ្នា លើសខ្វះពីគ្នា ខ្ពស់ទាបដាច់គ្នាដូច្នេះឯង ។

(អស់សេចក្តីក្នុងដំណើរតែប៉ុណ្ណេះ)

ទើបអធិប្បាយតាមន័យក្នុងព្រះសូត្រនេះដូចមានតទៅនេះ សេចក្តីថា: លោកធម៌ទាំង ៨ ប្រការនេះ បែកចេញជា ២ ផ្នែក គឺខាងគុណ ១ ផ្នែក ខាងទោស ១ ផ្នែក ។

ផ្នែកខាងគុណ (ខ្ពស់) ចាន់ដល់លោកធម៌ ៤ យ៉ាង គឺខាងលាភ ១ យស ១ សាក្យសរសើរ ១ សេចក្តីសុខ ១ រួមជា ៤ យ៉ាង ។

លាភៈ ចាន់ដល់របស់ដែលមានវិញ្ញាណ ទើបតវិញ្ញាណ ដូចបុត្រប្រុស- ស្រី- ខ្ញុំកំដរ- សំពត់ស្នួត- ដណ្តប់- គោជនាហារជាដើម ដែលចាន់មកដោយកំឡាំងព្យាយាមខ្លះ ដោយគុណវិជ្ជាសិល្បសាស្ត្រខ្លះ ដោយបុណ្យវាសនាពីព្រៃងនាយខ្លះ របស់ដែលចាន់មកនោះ ហៅថាលាភ ។ (មានត)

បំពេញបៀវត្សអតីតការិយាធិបតីក្រុងសង្កែ

ដែលទើបតាំងថ្មីក្នុងខែស្នូរយោត-អូត ឆ្នាំ ១៩៤៣

១ - សញ្ញាប័ត្រលេខ ៥៣ ចុះថ្ងៃ ៨-៧-៤៣ តាំងគ្រូសូត្រ តន់-តឹក កើតឆ្នាំច គាយុ ៤៦ វស្សា ២៦ នាមធាយោ ពុទ្ធសរ ជាចៅអធិការ វត្តដំស្បូកកំផ្លីយ៍ ឃុំកំពង់ចឡត ស្រុកកំដួល (ស្វាយរៀង) ។

២ - សញ្ញាប័ត្រលេខ ៥៤ ចុះថ្ងៃ ២៩-៧-៤៣ តាំងគ្រូសូត្រ សុក-ឆុក កើតឆ្នាំវោះ គាយុ ៥៣ វស្សា ៣២ នាមធាយោ សុវណ្ណជោត ជាចៅអធិការ វត្តតាបាន់ ឃុំកំពង់គ្រាច ស្រុកអមាសមែក ។

៣ - សញ្ញាប័ត្រលេខ ៥៥ ចុះថ្ងៃ ២៩-៧-៤៣ តាំងគ្រូសូត្រ កុំ-ដួន កើតឆ្នាំកេរ គាយុ ៥២ វស្សា ៥ នាមធាយោ ជនត្តេរ ជាចៅអធិការ វត្តដងកំកម ឃុំប៉ុនកៃស ស្រុកប៉ុនកៃស (ស្ទឹងត្រែង) ។

៤ - សញ្ញាប័ត្រលេខ ៥៦ ចុះថ្ងៃ ២៩-៧-៤៣ តាំងគ្រូសូត្រ ព៉-ស៊ីតែ កើតឆ្នាំមមែ គាយុ ៣៧ វស្សា ១៥ នាមធាយោ បញ្ញាសុវ័យ ជាចៅអធិការ វត្តគោកសំរៅ ឃុំល្វា ស្រុកកំពង់ត្របែក (ព្រៃវែង) ។

៥ - សញ្ញាប័ត្រលេខ ៥៧ ចុះថ្ងៃ ៣០-៧-៤៣ តាំងគ្រូសូត្រ ញាណ-ឃុន កើតឆ្នាំមមែ គាយុ ៣៧ វស្សា ១៦ នាមធាយោ ស៊ីលសំវរៈ ជាចៅអធិការ វត្តពោធិ៍សុវណ្ណកំផ្លីយ៍ ឃុំផ្សារត្រែកាម (ពោធិ៍សាត់) ។

៦ - សញ្ញាប័ត្រលេខ ៥៨ ចុះថ្ងៃ ៣០-៧-៤៣ តាំងគ្រូសូត្រ

ខ្ទុប-មុត កើតឆ្នាំច អាយុ ៤៤ វស្សា ២៥ នាមធាយា សុមនត្ថេរ ជាចៅ-អធិការ វត្តជា ឃុំជា ស្រុកកំពង់លែង (កំពង់ឆ្នាំង) ។

៧ - សញ្ញាប័ត្រលេខ ៥៨ ចុះថ្ងៃ ៣០-៧-៤៣ តាំងគ្រូសូត្រ គឹម-ជា កើតឆ្នាំឆ្លូវ អាយុ ៥៥ វស្សា ៣៥ នាមធាយា សុវណ្ណជោត ជាចៅអធិការ វត្តឥន្ទ្រកោសិយ ឃុំគោះដាច់ ស្រុកមុខកំពូល (កណ្តាល) ។

៨ - សញ្ញាប័ត្រលេខ ៦០ ចុះថ្ងៃ ២-៨-៤៣ តាំងគ្រូសូត្រ ស.ឡាយ កើតឆ្នាំរកា អាយុ ៥៨ វស្សា ៣៦ នាមធាយា សុវណ្ណប្បញ្ញា ជាចៅអធិការ វត្តគុំ ឃុំរកា ស្រុកត្រាំង (វៃតែតាកែវ) ។

៩ - សញ្ញាប័ត្រលេខ ៦១ ចុះថ្ងៃ ២-៨-៤៣ តាំងគ្រូសូត្រ ឡាយ-ហ៊ុន កើតឆ្នាំកុរ អាយុ ៤៧ វស្សា ២៥ នាមធាយ៉ា ធម្មត្ថេរ ជាចៅអធិការ វត្តសូរត៍ ឃុំកណ្តឹង ស្រុកបាទី (តាកែវ) ។

១០ - សញ្ញាប័ត្រលេខ ៦២ ចុះថ្ងៃ ២-៨-៤៣ តាំងគ្រូសូត្រ ស៊ុំ-សន កើតឆ្នាំថោះ អាយុ ២៩ វស្សា ៨ នាមធាយា ធម្មសុវណ្ណ ជាចៅអធិការ វត្តដំណាក់ពងជា ឃុំប្រាំម៉ាំ ស្រុកត្រាំង (តាកែវ) ។

១១ - សញ្ញាប័ត្រលេខ ៦៣ ចុះថ្ងៃ ២-៨-៤៣ តាំងគ្រូសូត្រ សោម-អ៊ុត កើតឆ្នាំកុរ អាយុ ៤៥ វស្សា ២៤ នាមធាយា ធម្មសារ ជាចៅ-អធិការ វត្តសំណាម ឃុំព្រ៉ុងញ៉ែង ស្រុកត្រាំតត់ (តាកែវ) ។

១២ - សញ្ញាប័ត្រលេខ ៦៤ ចុះថ្ងៃ ៣-៨-៤៣ តាំងគ្រូសូត្រ

តំម-ច្រែក កើតឆ្នាំរកា អាយុ ២៣ វស្សា ១ នាមធាយា សុន្ធរត្ថេរ ជាចៅអធិការ វត្តកុល ឃុំដូង ស្រុកគងពីសី (កំពង់ស្ពឺ) ។

១៣ - សញ្ញាប័ត្រ លេខ ៦៥ ចុះថ្ងៃ ៣-៨-៤៣ តាំងគ្រូសូត្រ ញ៉ឹក-ភ័ន កើតឆ្នាំកុរ អាយុ ៣២ វស្សា ១២ នាមធាយា ឥន្ទរត្ថេរ ជាចៅអធិការ វត្តច្រកម្ទេស ឃុំច្រកម្ទេស ស្រុកស្វាយចាប (ស្វាយរៀង) ។

១៤ - សញ្ញាប័ត្រលេខ ៣ ចុះថ្ងៃ ៦-៨-៤៣ តាំងគ្រូសូត្រ ប៉ាល់-ធន កើតឆ្នាំថ្លៅ អាយុ ៣១ វស្សា ៨ នាមធាយា សោរត្ថ ជាចៅអធិការ វត្តលលកស ឃុំលលកស ស្រុកចុកាន (តេាធ៌សាត់) (គណធម្មយុត្តិ) ។

១៥ - សញ្ញាប័ត្រលេខ ៦៦ ចុះថ្ងៃ ៤-៨-៤៣ តាំងគ្រូសូត្រ ម៉ែន-ជួរ កើតឆ្នាំកុរ អាយុ ៣២ វស្សា ១១ នាមធាយា ធុនត្ថេរ ជាចៅអធិការ វត្តរំដែហ្លួត្ថៅ ឃុំវាលរ ស្រុកគងពីសី (កំពង់ស្ពឺ) ។

១៦ - សញ្ញាប័ត្រលេខ ៦៧ ចុះថ្ងៃ ៤-៨-៤៣ តាំងគ្រូសូត្រ ភៅ ខន់ កើតឆ្នាំថ្លៅ អាយុ ៥៥ វស្សា ៣៥ នាមធាយា ធម្មរង្សត ជាចៅអធិការ វត្តអង្គរវៀន ឃុំទឹកល្អក់ ស្រុកគងពីសី (កំពង់ស្ពឺ) ។

១៧ - សញ្ញាប័ត្រលេខ ៦៨ ចុះថ្ងៃ ១២-៨-៤៣ តាំងគ្រូសូត្រ កោញ-ពេជ្រ កើតឆ្នាំថ្លៅ អាយុ ៤៣ វស្សា ១៨ នាមធាយា ពុទ្ធត្ថេរ ជាចៅអធិការ វត្តសំរោង ឃុំដំដុប ស្រុកចុកាំ (ព្រៃវែង) ។

អក្ខរសិទ្ធិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ជោះពុទ្ធផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនធិតន្ធមន្ត្រី ញ៉ឹក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ ភៅ-សុំម អ្នកត្រួតត្រា
សិស្សនៅសាលាថាលីជាន់ខ្ពស់

បញ្ជីរឿង

ផ្នែកអក្សរសាស្ត្រ		*ទំព័រ*
. . . . .	មាយើង (ពាក្យពាក្យ)	៦០៣
. . . . .	រឿងព្រៃងខ្មែរ: "រឿងម្តាយពិត អាពុកពិត ស្រីពិត"	៦១៦
អ្នកអាចារ្យ ពិម-អាន	រឿងព្រៃរបាទអសោក (តទៅ)	៦៣២
ផ្នែកសាសនា		
លោកអាចារ្យ ម៉ុញ-ណាត្រ	សុជាតាជាតក	៦៥៣

ឆ្នាំគំរប់ទី ១៥ — លេខ ១១ ខែកញ្ញាមិថុនា ១៩៤៣ — ជំនៀងជាវ: ១ ឆ្នាំ ៦០ រៀល ។

KAMBUJASURIYĀ

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire : Khun Nibandhamantri Nhok-Thĕm, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse : Vénérable Kao-Sim, Surveillant général de l'Ecole Supérieure de Pāli.

TABLE DES MATIÈRES

Partie littéraire

		Pages
.....	Meayŏng, poème ancien.....	607
.....	Conte populaire cambodgien «Rŭong Mdaypĭt Apăkpĭt Sreipĭt»	616
Par l'achar Kim-Ann	Légende de l'Empereur d'Açoka de l'Inde antique (suite)	632

Partie religieuse

Vénérable Achar Mĕnh-Nakri.....	Sujātajātaka.....	657

បទភាពគតិ

អញ្ជុំក្រញ្ជាគាប សិរសាស្រែំតាប លុតលើតហត្ថា តាំងទស-
គូលី អតិវន្ទា នៃព្រះអង្គជា ឥសូរតតគ្រែ ។ ព្រះអង្គខត្តម លើសលើ
ឥន្ទ្រព្រហ្ម មូលមកតំក្តី ប្រកបប្រការ សម្ភារៈខ្ញុំ បរិបូណ៌ជាមិ
ពិសេសរៀងក្តាន ។ បង្គំព្រះធម៌ ពិសេសមានអាថ៌ ផ្លែភាន់ប្រមាណ
ស្មោះស្មើតេគ្រា ថ្លៃថ្លាមែនមាន បវរទេវញ្ញាណ ផ្ទឹមផ្គុំសព្វសត្វ ។
បង្គំព្រះសង្ឃ ប្រសើរខេត្តុង្គ ខត្តមពេកក្លាត់ អាចនាំសត្វធ្វង វិលឆ់ល
វង្គ ដល់ស្ថានអម្រឹត- បុរីនាយណា ។ ទើបខ្ញុំបង្គំ ចំពូរខេតខត្តម សោ-
ឡសសួគ៌ា សូមសុខសួស្តី សិទ្ធិទីយោ- យុយឺនសុទសោ-ប្បាយបរិបូណ៌
បុណ្យ ។ ស្រែចំខ្ញុំទូរថ្ងៃ ដំណើរដំណែង ដំណាលតាំមុន មានក្សត្រ
មួយថ្ងៃ ប្រពៃលើសលន់ គ្រប់គ្រងមហាជន ក្រុងពាពណសី ។ ព្រះ
នាមព្រះបាទ ព្រហ្មទត្តនរោត្ត លើសលើលោកិយ ប្រកបដាយ អាវ្យ
អត្តមហោស្ថ តបតលាណ រូបវត្តសោភា ។ ព្រះស្ងួសៅដៃ ពិសេស
ច្រើនពៃត្រែ សម្រាប់ក្សត្រា តង់តាល់សព្វថ្ងៃ ក្រាស់ត្រែតណា ប្រដូច
តាព- តរៀបរៀងកយ ។ ឧទ្ទិយោជា ស្រមណ៌ព្រាហ្មណ៌គណា- ចារ្យ
បេះគ្រែដ្ឋប្តាយ សម្រាប់មហាក្សត្រ ព្រហ្មទត្តខ្ញុំសាយ ពលពាលតាំង-
ឡាយ អានេតសំរេយ្យា ។ ស្តេចសោយពស្ត្រស្តល់ ឥតកោលាហល

រដ្ឋក្រុងប្រាំ ទ្រង់ទស្សតាំងពាក្យ ឯងអាចអាសារ អាសូរគុណា
ចិញ្ចឹមរៀមរៃ ។ ក្សត្រីកក្សាន្តសោយពាក្យ ភ្លើងព្រះអំណាច ឯងឥត
ផ្តឹមឆន ស្តេចផ្តាញ់សត្រូវ មិត្តទុស្តច្រើសយ្ងន ពុំអាចប្រឡង សុះ
សល់លើសលន់ ។ កាលនោះមានមា. ណពរៀភាព ក្សត្រីថ្លៃមាន
បុណ្យ ជាអ្នកខុគិត ក្សិណខ្សត់ទ្រព្យធន ជាអ្នកខុជិន និត្យនៅសព្វ
ថ្ងៃ ។ តរៃយោនោះណា កបកលសោកា សត្តិសមល្មមល្មៃ តែចិត្ត
នោះមិញ កំណាញ់ពេកពៃ្រ ព្រៃងលានទីពៃ គេពុំចូលចិត្ត ។
មានកាលមួយថ្ងៃ ចៅមាណពនៃ ទៅកេជញ្ជាត់ ទឹងតរៃយាប្រាណ
តាមដោយកំសត់ ពិបាកពេកក្តាត់ ខុគិតក្រៃក្រ ។ តញ្ជើសោតធ្លុះ
ដាចដាច់លុះ ដោយមុមនោះនៃ រឹងតរៃយា ឥតអស្យាស្រ័យ ពុំគន់រំពៃ
ថៃទាំឡើយហោង ។ ប្តីតែងជញ្ជាត់ ដាក់ទៅផ្ទុះចាត់ ដោយមុមនោះ
ឯង ឥតសព្វឥតសារ ឥតការជាម្ចាង់ ហេតុឥតចិត្តចង់ រំពឹងរំពា ។
ជញ្ជាត់រៀងទៅ ដួចដល់សំពៅ ជាធំមហិមា រីនាយសំពៅ និត្យនៅ
តរៃយា មើលតីកេត្រា យល់តញ្ជើធ្លុះ ។ នាងអ្នកនាក់ ស្រដីទៅថា
នាងជញ្ជាត់នោះ ម្តេចពុំគិតធ្វើ ករញ្ជើនាងធ្លុះ យកអ្វីបុកបុះ សោះរ៉ា
លេចបាន ។ ក្សិណនាយសំពៅ ត្រែាងរៃកថាទៅ ទឹងតរៃយាប្រាណ
ម៉ើចេះដូច្នោះ មិនបុះទៅថ្លាន ការ់ករញ្ជើបាន ជាប្រពន្ធក់ ។ អញទឹង
ផ្តាស់យក ប្រពន្ធក់មក នៅលើភ្នែត្រា ជាប្រពន្ធអញ រឹងរៃញ្ជោងណា

ដ្បិតលោកជាធំជា បង្អាប់ដូនថៃ ។ នាងស្តាប់ប្តីថា ខ្លីដូនតាយោង
ឯងឲ្យទៅនេះ ដោយភាក្យពុំស្រួល តាំងតួរបើដេរ ត្រូវគ្នានោះសោះ
ដេរចង់ទោសា ។ ទើបនាងធ្វើយទៅ កាន់តាយសំពៅ ដាច្តីភាក្យ
ពាក្យខ្ញុំថាស់ខុស លើសលោះត្រង់ណា កំដល់អ្នកជា ប្តីពុំបួលចិត្ត ។
ខ្លីឯយកខ្ញុំទៅ ដូរមាណពទៅ កាន់ណ្ហាឯជញ្ជាត់ បើអ្នកខ្លីឯដូរ ខ្ញុំទៅ
ខ្លីឯតាត់ ខ្ញុំសោកគ្មានចិត្ត ប្រពៃកុថាខ្លី ។ ទើបនាយសំពៅ ស្រែក
ស្រែកហៅទៅ បុរសនោះឮ ថាហៅហ៊ានដូរ ប្រពន្ធឬអ្វី មកតាយស្រែដ
ឲ្យជាក់ខ្លីឯគ្នា ។ មាណពជញ្ជាត់ ក្តុកគ្រែតាត់ ស្តីដូរកេរ៉ាយោ ខ្លាចខ្លួន
ពុំហ៊ាន ទៅឆ្ងាយកន្លែង នាយនោះវែងឆ្ងាយ ហៅខ្លាច់ ។ ទៅ ។ ទើប
មាណពនោះ ខន្ធាឋចូលស្មោះ ឡើងលើសំពៅ តាំងប្តីប្រពន្ធ អង្គុយ
ខ្ចិត្យទៅ ទើបនាយសំពៅ ស្រែដាវៀតថា ។ ចៅអើយឥឡូវ មកយើង
ខ្លីឯប្តូរ ប្រពន្ធផងគ្នា អញឲ្យប្រពន្ធ អញទៅចៅណា ចៅឲ្យកេរ៉ាយោ
ចៅមកអញហោង ។ មាណពកំសត់ ស្តាប់យល់ពាក្យចម ពុំហ៊ាន
សាសង នាយនោះវែងរួច វែងផ្លូវច្រែនជង ថាហើយថាធង ដាច្រែន
កាសា ។ ទើបមាណពនោះ ថាតាមបំពោះ ចិត្តអកហោកណា ប្តូរ
អ្នកហោច ត្រូវមោចកំត្រា ឥតបើខ្លីឯថា ខាស់ខែង សាកក្តី ។ នាយសំ-
ពៅស្តាប់ អស់អាថិសាវសព្ទ ត្រែកតរះចត៌ កៀមកក្បាលតន្ទឹង ដល់ភ្នំឯ
ឃ្លាតខ្លី ថាហៃហ្អូនស្រី ឯណោះសោតហោង ។ ជានាងក្អូនស្ងួ

មាសមិត្រចូលចិត្ត ព្រមមូលនឹងបង ឬមួយពុំមូល ពុំចូលចិត្តបង ចូរ
ទៅសាសង ឥឡូវនេះណា ។ ឯមេកញ្ជើ ឮអស្រលេី បង់នាយនាង
សើចហើយញញឹម មើលចុងនេត្រា ទន់ហើយទើបថា បុពណាឯង
ហោង ។ ឯនាងកវយា ទៅនាយកេត្រា ស្តែងស្តាប់សាសង ប្តីប្តូរ
ផ្តែផ្តាំ ពាក្យពេចន៍ជាម្តង នាងចរចុះផ្តង ពីលេីកេត្រា ។ តែសៀ
ទៅត នាងដេីរចុះមក កាន់ប្តីកំព្រា ទ្រព្យធនពុំយក ដឹតដោយ
គាត្មា នាងឈោងប្រាក់ កញ្ជើកាន់ទៅ ។ ចោចបានសម្រាម មកបុក
ដឹតក្តាម ពិតពុំឲ្យសៅ នាងកាន់តាមប្តី ដញ្ជាត់តាមស្មៅ បានស្រែច
ទើបទៅ ហានប្តីនោះណា ។ លុះដល់លំទៅ នាងដណ្តើងទៅ កាន់ប្តី
នាងថា អ្នកអើយអស់ផ្ទះ រៀងខាងនេះណា ជាញាតិកា សន្តានដៅ
ពណាំ ។ ឬជារៀងលាន ដ្បិតខ្ញុំពុំមាន ដឹងញាតិនិមិល បេីអ្នកឯណា
ជាញាតិបវរ រៀងលានស្មោះសរ អ្នកច្រាបខ្ញុំភ្លាំ ។ ប្តីឆ្ងេីយរឹងទៅ
នាងអើយញាតិដៅ បងគ្មានទេណា សឹងតែរៀងលាន នៅឋានទៀប
គ្នា សត្វថៃថ្ងៃកំព្រា គ្មានបងប្អូនឡើយ ។ នាងភ្ញាប្តីថា ឥតញាតិរឹង្ស
កំព្រាច្រេះហើយ ហេតុនាងសប្បុរស យេកគេជារឿយ នាងពុំតែងឡើយ
អំសត់កេត្តា ។ នាងយកគ្រឿនោះ ឲ្យប្តីនាងស្មោះ ដូនចែកគ្រប់គ្នា តិច។
គ្រប់មុខ អ្នកស្រុកនៅនា រៀងលានស្គាល់ក្បា ទេត្តភាងំលំទៅ ។ ប្តី
សោតទៅស្មោះ ដោយប្រពន្ធនោះ បង្គាប់ប្រៃដៅ កាលនោះរៀងលាន

ខាងហ្នលំនៅ សឹងតិតថាហៅ នេះដែលឯណា ។ សប្បុរសដូច្នេះ
ផ្តើលអ្វីម្តងណោះ ដូនយើងគ្រប់គ្នា សព្វជនកំណាញ់ កន្ទ្រឹសឫស្យា
ឥឡូវម្តេចជា សប្បុរសពេកក្រៃ ។ អ្នកឯងតិតហើយ ពិតពុំលង់ខ្លួយ
មានកាលមួយថ្ងៃ គេដើរទៅលេង ទឹងមាណពនៃ យល់នាងប្រពៃ
មានរូបសោភា ។ ទើបគេតិតក្នែ ថាហៅនេះនៃ តាត់ចាន់តរំយោ ខ្មែតទើប
សប្បុរស ពុំដូចសព្វគ្រា នាងនេះលក្ខណា មានយោធហ្មត់ហ្មង ។
មានកាលមួយថ្ងៃ មាណពទៅព្រៃ រកកាច់ឧសចង ចាប់បានរែកមក
ដូចកាលសព្វជន រែឈើនោះផង ពុំឈើខ្លួនា ។ សឹងឈើប្រពៃ
មែនមានដំឡៃ ភ្ញាំពាក់ក្រឹស្នា នាងយល់ឧសប្តី ចានពីព្រឹក្សា សឹង
ឈើជាៗ មានៗដំឡៃ ។ នាងតិតឯងថា ប្តីអញនេះណា ចានឈើ
ប្រពៃ ពុំស្គាល់ជាឈើ នោះមានដំឡៃ យកមកសព្វថ្ងៃ ដុតដូច្នេះ
ណា ។ សមឈើនេះមាន ក្រាស់ក្រែនាហាន អាយឯងទើបជា
ឧសស្អុកផង ពុំស្គាល់ក្រឹស្នា ភ្ញាំពាក់យកជា ឧសឥតតិតឡើយ ។
ទើបនាងនារី ដណ្តឹងទៅប្តី ថាមែនអ្នកអើយ ឧសនាព្រៃអាយ អស់តែ
ម្ល៉ះហើយ ឬមួយនៅឡើយ អ្នកប្រាប់ខ្ញុំវ៉ា ។ ប្តីឆ្លើយវិលទៅ មាន
ច្រើនក្តាត់នៅ នាព្រៃព្រឹក្សា យកបានជាយ រនេះក្តីណា ពុំអស់ប្លែន
ភ្លា នាងនឹងតិតថ្លៃ ។ នាងឮថ្លោះណា អរវតគណនា សំណេះនឹងប្តី
ថ្លោះអ្នកទៅពេ យកមកខ្មែតឬ ឲ្យអស់អំពី ព្រៃនោះឯងហោង ។

ទំនិញដួលរលេះ ញាតិជិតនៅរនេះ ដឹកទុកជាម្ហូប ប្តីថានាងនឹង យកទៅសម្លាប់ ហើយស៊ីសាច់ឈាមគេឯងណា ។ ទើបនាងឆ្ងាស់ឆ្ងើយ ថាអ្នកស្តីអើយ លើនេះលើវា សឹងមានដាំឡូ ត្បាំពាក់ក្រឹស្នា អស់អ្នកតេគ្រា គេទិញយកទៅ ។ លើនេះខ្ញុំស្គាល់ ជាក់ឥតពីការ អស់អ្នកសំរេច គេទិញមិនលែង ឡើយដូចសំរេច គេទិញទាំងៅ ស្រុកចិនទាយណា ។ បើយើងបានហើយ យើងគិតអ្វីឡើយ ថ្លៃនៃថ្លៃក្រឹស្នា ត្បាំពាក់ប្រពៃ យកថ្លៃមកណា ខ្វៃនៃព្រៃការសា សម្តែងជាតិ ។ តាមតែចិត្តជ្រះ ចិត្តធំធ្លាស់រើស ប្រាក់មាសអ្វីៗ ដោយចិត្តស្រឡាញ់ យកតាមចិត្តក្តី អ្នកនៅៗ ខ្ញុំ ដោយពាក្យខ្ញុំថា ។ ប្តីឮពាក្យនៃ អរឯងភេតនៃត្រៃ ត្រៃតីត្រៃតា ជាន់ឥរមែកសរនៃត្រែក វែកទៅម្តងម្កា ដឹងកាំចិតព្រាតួលទៅកន្លែងនៃត្រៃ ។ កាត់តរពុកស្រែច ចងចោលជាជាប់ វែកមកតាំងថ្ងៃហើយប្រាប់តរយោ ប្អូនអើយ។សនៃ កាត់តរទៅនៃត្រៃ ច្រើនតៃត្រាត់ណា ។ វែកមកនេះហាន តាមកំឡាំងបាន ទើបនាងតរយោ រកដួលរលេះ ដឹកអស់ក្រឹស្នា ត្បាំពាក់ជា។ តាំងព្រៃនោះនៃ ។ តរពុកនាស្ថាន នោះហើយទើបមាន តាណាដូចនៃ មកទិញក្រឹស្នា ត្បាំពាក់ប្រពៃ ខាងថ្លៃតាតថ្លៃ ឥតរស្អែងឡើយណា ។ ហេតុនាងនារី ដឹងអស់តំពី តាលនាងនៅជា ប្រពន្ធនៃទៅ នាយតាតេគ្រា ឥតឈ្នួញនាខា បំរោតបានឡើយ ។ លុះឈ្នួញទិញបាន ពីនាងតាលក្សាណ

គេយកទៅហើយ នាងរៀបខុកខ្លៃ ផ្គូផ្គាប់ជារឿយ ពិតពុំលង់ ឡើយ រណ្តាប់គ្រឹះហាន ។ ចាយចាត់រៀបរក៍ លោះខ្ញុំកំដរ ប្រែកម ធនធាន អ្នកជង់ចេញចូល នាងសោតថ្កើងថ្កាន សម្បត្តិមូលមាន អនេក ខ្លៃ ។ ប្តីនាងនេះនៃ ស្គាល់អ្នកជនៃ ស្គាល់ព្រះស្គាល់ពញ្ញា អ្នកជង់កប់អាន ដ្បិតបានខ្លៃ កម្ចត់ទូរលក្ខណា នាងនោះប្រពៃ ។ ទើបនាងនារី ស្រដីនឹងប្តី អ្នកអើយសព្វថ្ងៃ ខ្ញុំចង់ឲ្យអ្នក រៀនវត់ឲ្យវៃ ឲ្យស្រួសនាប់ក្រៃ ដូចចិត្តចង់ឱ្យ ។ ប្តីសោតឆ្ងាស់ឆ្ងើយ ថាហៃនាងអើយ បងឥតបើថា តាមចិត្តប្តូនហោង អញបងបានជា មេ៉ះដ្បិតនរណា មិន ដ្បិតប្តូនស្រី ។ លុះថ្ងៃមួយណា នាងរៀបក្រយា សំណុំរបឱ្យ ទំក មួយបំពងី នាងផ្ញង់ឲ្យប្តី ពុនវែកវត់ខ្លួ សព្វៗវេលា ។ ដើមឡើយ វត់ហត់ ដង្ហើមផុតៗ ស្ទើរដាច់ខ្យល់ណា វត់វិលមកវិញ ប្រាប់ប្រពន្ធថា វាហត់ក្តាត់ណា ដូចនឹងស្លាប់ហោង ។ លុះដល់ពីរថ្ងៃ ទើបវត់ទៀតនៃ ដោយចិត្តចំណង់ ខឹងចង់ឲ្យបាន ដូចក្តីប៉ុនប៉ង ប្រាថ្នានោះហោង ចិត្ត បង់សង្ឃាត ។ វត់ទៀតដល់ទី ដើមកាលវត់ខ្លួ ដោយចិត្តខ្ជិលឃ្នាត ដ្បិត ប្រពន្ធថា បងចាំពុំឃ្លាត ទៃងទំសង្ឃាត ដូចក្តីប្រាថ្នា ។ លុះប្តីនាងវត់ វត់ស្រួសពុំហត់ ដោយចិត្តសោះសា ទើបនាងនារី ឃល់ប្តីអាត្មា ឋានបូណ៌ ហើយណា ទើបនាងនោះនៃ ។ ទៅថ្ពាន់មន្ត្រី ឲ្យគេថ្វាយប្តី ជាខ្ញុំក្សត្រ ថ្ងៃ មន្ត្រីនាំថ្វាយ ដូចចិត្តនាងនៃ បំរើសព្វថ្ងៃ ជាខ្ញុំពជា ។

ខ្ញុំដែលថ្លែងសំដែងចរចា ឯអគ្គព្រះមហា ព្រហ្មខត្តិយជាតិ ។ នាសម័យ
១ ថ្ងៃចក្រី ឲ្យជ្រាប់សេនី សេនាពលជន ។ ដ្បិតក្សត្រព្រហ្មខត្ត
ជាប្បធាន មានព្រះបំណង ប្រកាតព្រឹក្សា ។ ឲ្យរៀបប្រុងរៀបប្រាប
បណ្ណា- ការអបយសា- ពិភពស្តេចស្តែង ។ ភ្លាត់ដាវខ្លាន់ការតាត់
តែង រៀបគ្រប់ដំណែង ដំណើរក្សត្រា ។ ឯចៅនោះគៀងគឹហា
ច្រាយច្រាប់តរៃយោ នាងអើយឥឡូវ ។ ព្រះបាទនរោត្តមគួ ស្តេច
តែងពលក្សួហ៍ ប្រកាតព្រឹក្សា ។ ចូរចៅប្អូនគៀងតំណា ប្រដាប់ប្រដា
ឲ្យបង្ហាត់ ។ ខ្ញុំដែលចៅចៅបក្រែវត្តិ ព្រះបាទព្រហ្មខត្ត ឥស្សរសិរ-
សា ។ នាងស្តាប់សារសង្ឃប្តីថា នាងរៀបក្រយា ឲ្យប្តីស្នេហ៍ស្នាល ។
អគ្គរសោតល្អត្រគាល អប់ផ្កាត្រគាល ប្រហើរឈ្មុយឈ្ងប់ ។ អាហារ
ត្រគាលសាយសព្ទ ណ្ហាប់ត្រាន់ត្រប់ ឲ្យប្តីសង្ឃារ ។ រុំជាសំណុំ
ហើយណា ផ្តង់ជាក្រយោ ស្មោយមហាក្សត្រថ្លៃ ។ នាងដឹងដំណឹង
នោះនៃ ជាក្សត្រចៅថ្មៃ ខំឯត្រាត់ត្នាត្តិ ។ ខំឯឃ្លាតអាមាត្យមន្ត្រី
មានប៉ុន្មានប្តី នាងខំឯតាន់ចៅ ។ ឯមហាក្សត្រាចមចៅ ព្រឹកព្រាង
ច្រាលផ្លៅ ប្រដាប់ព្រះអង្គ ។ ខ្ញុំដែលត្រឿងរុងរឿងចម្ងាំង ព្រះពស្ត្រ
ឯឦទ្ធខ្ញុំ ចាំក់ផ្ងាក់មាលា ។ ខ្ញុំដែលស្រេចសម្តេចពជា ស្តេចស្តេចយា-
ត្រា ឡើងលើអស្សតរ ។ ចេញចៅដល់ក្រៅនគរ ព្រះអង្គបើកថវ

រ័តន៍ពជអស្សា ។ ភ្ញីឆ្កួសខ្ពង់ខ្ពស់សោភា ធ័ត្រៃរ័តន៍ជួរចា-ម៉ាសេស
រៀងពយ ។ អតិរម្យត្រសុំត្រសាច់ ត្រសែតរំគាយ រំគើយសាក់
សែង ។ សេនាយោធាខៈខែង កំភាន់លំពែង ហែៗច្រូងច្រាង ។
ដាវខែលត្រាស់ត្រៃលសង៍ខាង សេនាគាន់គាង ខួនចាំងចាមរ៉ ។
មហាក្សត្រត្រួតគ្នាខគ្គចក្រ ឯកឯងពិសី ពាលពេញពលា ។ ជល់
កងកំឡុងព្រឹក្សា ស្តេចបរអស្សពាហ៍ លឿនលន់កន្ទុង ។ សេនា
យោធាពលផង ខែងខំក្តាត់ហោង តុំគាន់ក្សត្រា ។ ជិតរជាយ
តាមត្រៃយអស្សពាហ៍ ប៉ុន្តែចៅមា- ណពនោះឯងហោង ។ ដ្បិត
តាត់រត់ស្ទាត់កន្ទុង ពាន់ក្សត្រច្បាស់ច្បង ចមចក្រពជា ។

(មានត)

រឿងម្ចាយពិតអាពុកពិតស្រីពិត

មានរឿងមួយថាស់ខុំនិយាយតមកថា :

កាលនោះមានប្រុសម្នាក់ជាអ្នកកំសត់ត្រកំព្រាក ម្ចាយអាពុកស្លាប់ចោលអំពីតូចនៅតែម្នាក់ឯងតែឯងគេស៊ីចិញ្ចឹមតាំងគ្រាន់តែធ្លុតពោះរស់ប្រចាំថ្ងៃគ្រាប្រុងប្រយ័ត្ន ដល់ប្រុសនោះចំរើនធំឡើងបានដឹងសេចក្តីក៏ចង់ដឹងថាកន្លងតរនោះនឹងមានស្រីពិត-ម្ចាយពិត-អាពុកពិតប្លែ ហើយមានថ្ងៃមួយ ស្តេចកន្លងតរនោះនឹងគិតធ្វើបុណ្យកំសាន្តសប្បាយ ។

ស្តេចមានព្រះបន្ទូលហៅនាម៉ឺនមួយឈ្មោះដែលជាធំ មកដល់ស្តេចទ្រង់បង្គាប់ឲ្យនាម៉ឺននោះចេញទៅធ្វើពេធសាលាបុណ្យនៅត្រើយស្ទឹងម្ខាងឯម៉ឺននោះមានស្ពានសួរួងរៅ នាម៉ឺននោះទៅធ្វើពេធសង់សាលារួចស្រេចវិលមកក្រាបទូលស្តេច ។ ទ្រង់ឲ្យរៀបក្តីផ្កាស្វាមូគ្រប់បរិពារជាណាត់បុណ្យ ហើយស្តេចយាងចេញចុងព្រះកដពេធដួចដុំមន្ទីរតូចធំហែស្តេចយាងចូលបុណ្យ ។

ឯប្រុសនោះឮថាស្តេចធ្វើបុណ្យដូច្នោះ ក៏មានសេចក្តីត្រេកអរជាយចង់ដឹងថាកន្លងតរស្តេចនោះជាមានស្រីពិត-ម្ចាយពិត-អាពុកពិតប្លែ ក៏ប្រុសនោះដើរទៅទៅក្រាមស្ពានធ្វើជាអង្គុយស្តួចត្រី ឯស្តេចនោះយាង

ទៅឯសាលាបុណ្យមុន នៅតែអស់អ្នកនឹងព្រះពាជបុត្រីស្តេច នោះដល់
វេលារសៀលមោ៉ងមួយ អស់អ្នកនឹងព្រះពាជបុត្រីស្តេចនោះរៀបខ្លួននឹង
ទៅចូលបុណ្យ ប៉ុន្តែព្រះពាជបុត្រីស្តេចនោះកំព្រាពុំមានព្រះមាតា ។
ក្រុយព្រះជន្មចោលនាងតាំងអំពីតូចទៅ ដល់អស់អ្នកនឹងពាជបុត្រីនឹង
ពួកស្រីស្នំក្រមារចេញទៅធ្វើស្ពានហួសអស់ទៅ នៅតែព្រះពាជបុត្រី
កំព្រាទៅជាគ្រោយគេ ដល់នាងយាងទៅដល់ស្ពាននាងឧតៈទៅគ្រាម
ស្ពានឃើញបុរសកំសត់អត្តុយស្លូបត្រីគ្រាមស្ពាន នាងឈប់ពុំហ៊ាន
យាងហួសទៅ អស់ពួកស្រី ។ កំណាន់សួរថា ម្ចាស់ដូចម្តេចក៏ឋានជា
ឈប់ ទើបនាងបន្ទូលប្រាប់ទៅអស់ពួកស្រីៗថា ឋានជាឈប់ដ្បិតមាន
បុរសប្រុសម្នាក់ទៅអត្តុយស្លូបត្រីគ្រាមស្ពានទៅដូចម្តេចនឹងឋាន អស់
ស្រីសៅឡឹកថាម្ចាស់យាងទៅមិនអ៊ាទេ ខ្លាចថ្វីមនុស្សកំសត់ដូចជាគេឆ្គួត
ហើយនាងធ្វើយឡើងថាកុំស្រីដូច្នោះមិនត្រូវទេ ធម្មតាគេជាប្រុសទុកជា
គេឆ្គួតព្រឹលល្ងង់ទៅដូចម្តេច គេជាប្រុសមិនត្រូវនឹងដើរលេងលើគេ ។
ឯអស់ពួកស្រីៗក៏ស្តីឲ្យថា នែអ្នកតំណេះ អត្តុយស្លូបត្រីគ្រាម
ស្ពានដើរចេញ ម្ចាស់ស្តេចនឹងយាងទៅធ្វើបុណ្យ ។ ឯបុរសនោះ ពួ
ស្រីស្រែដាថាដូចម្តេច ក៏មិនដើរចេញទ្រឹងជាមិនឮ ឯនាងជាបុត្រីស្តេចចង់
ដឹងក៏ស្រែដាឲ្យបុរសនោះថា នែអ្នកបុរសស្លូបត្រីអញ្ជើញចេញពីគ្រាម
ស្ពានចេញឲ្យខ្ញុំសុំផ្លូវទៅផង ។

បុរសនោះឮនាងជាបុត្រីស្តេចនិយាយដូច្នោះក៏ក្រោកដើរចេញគយ
គឺយទៅផ្ទះអាត្មាវិញ ឯនាងបុត្រីស្តេចឃើញទៅបុរសនោះដើរហួសទៅ
ខ្លួនឯងហ៊ានធ្វេងទៅធ្វើបុណ្យជាមួយនឹងស្តេចជាអាពុត ដល់ធ្វើរួច
ស្រេចបរិបូណ៌ស្តេចក៏វិលមកព្រះដំណាក់វិញ ។

លុះថ្ងៃក្រោយ បុរសនោះគិតក្នុងចិត្តនឹកចង់ចូលទៅគាល់ស្តេច
ក៏រៀបខ្លួនតាមដោយខ្លួនខ្លួនជាអ្នកកំសត់ពិបាក រៀបខ្លួនរួចចេញដើរតាមផ្លូវ
អាត្មា ទៅដល់មាត់ភ្លៅកំផែងនឹងចូលទៅបំណាងនឹងចូលគាល់ដល់ស្តេច
ឯពួកនាយហានចាំទ្វារកំផែងវាយឃាត់មិនឲ្យចូលថា ចៅបុរសឯងរូបក៏អាក្រក់
សំពត់ក៏ចាស់ដាច់រាបមិនគួរនឹងចូលក្នុងទីកំផែងស្តេចទេ ។

ក៏បុរសនោះមកគិតក្នុងចិត្តថា អញគិតធ្វើដូចម្តេច ឲ្យបានជាប
ដល់ស្តេចបន្តិចឲ្យហៅអញចូល ហើយនិយាយទៅនឹងពួកនាយហានចាំទ្វារ
ថា អ្នកកុំយាត់ខ្ញុំដ្បិតខ្ញុំឃើញក្នុងនគរស្តេចនេះឥតមានស្រីពិតអាពុកពិត
ម្លាយពិតទេ ចៅបុរសនិយាយតែប៉ុណ្ណោះអង្គុយស្ងៀមនៅនឹងមាត់ទ្វារ
នោះទៅពុំនិយាយស្តីនឹងអ្នកឯណាទៀតឡើយ ដល់ស្តេចចេញចុងព្រះ
កដកពេងអស់នាម៉ឺនធំតូចក៏មកជួបជុំគាល់ស្តេច ។

ឯនាយពាហានចាំទ្វារសង្ស័យណាស់ក៏ចូលទៅគាល់ស្តេចក្រាប
ទូលថាមានចៅបុរសកំសត់ម្នាក់មកពីណាមិនដឹងនឹងចង់ចូលមកគាល់
នោះទូលបង្គំដាខ្ញុំឃាត់មិនឲ្យចូល ដ្បិតបុរសនោះស្ងៀកសំពត់ដាច់ដាច

លេចមុខលេចក្រោយ ហើយចៅបុរសនោះនិយាយនឹងខ្លួនឯងថា ខ្ញុំជាអ្នកឯងមិនត្រូវឃាត់ខ្ញុំទេ ដ្បិតខ្ញុំឃើញក្នុងនគរនេះគ្មានស្រីពិតប្រាកដពិតម្ដាយពិតទេ ចៅបុរសនោះនិយាយតែប៉ុណ្ណោះក៏ស្ងៀមទៅ ។

ស្តេចទ្រង់ជ្រាបដូច្នោះហើយ ស្តេចទ្រង់សួរទៅនាយពាហានថា ចុះឥឡូវចៅបុរសនោះនៅឯណា ? នាយពាហានក្រាបទូលថា នៅឯមាត់ទ្វារវាំង ទើបស្តេចមានបន្ទូលថា បើដូច្នោះអាមាត្យឯងទៅហៅវាមកមើល អាមាត្យក៏ទៅហៅចៅបុរសអង្គុយនៅមាត់ទ្វារជ្រាប់ថា ចៅបុរសស្តេចមានបន្ទូលឲ្យចៅបុរសឯងចូលទៅ ទើបចៅបុរសនិយាយសួរទៅអាមាត្យថា ស្តេចឲ្យហៅទៅធ្វើអ្វី អាមាត្យឆ្លើយថាមិនដឹងជាឲ្យហៅធ្វើអ្វីទេ ឲ្យតែមកហៅចៅបុរសឯងទៅ ចៅបុរសនោះក៏ដើរទៅជាមួយនឹងអាមាត្យទៅដល់ហើយ ក្រាបថ្វាយបង្គំគាល់ស្តេចដោយថ្នូរទន់សមគួរ ។

ស្តេចទតឃើញអាមាត្យនាំចៅបុរសនោះមកដល់ ស្តេចមានបន្ទូលថា ចៅបុរសឯងនិយាយថាក្នុងនគរអញនេះគ្មានស្រីពិតម្ដាយពិតអាពុកពិត ចៅបុរសឯងថាដូច្នោះមែនឬដូចម្ដេច ទើបចៅបុរសក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ឯក្នុងទីព្រៃនគរបស់ល្អងនេះ ទូលបង្គំជាខ្ញុំថាមែន ក្នុងទីព្រៃកជវាំងមានតែញីទូលបង្គំថាមែន ម្ដាយពិតរកពុកពតគ្មាន ទូលបង្គំជាខ្ញុំថាមែនហើយ ចៅបុរសទូលតបទៅនឹងស្តេចទៀតថា សូមទ្រង់ព្រះមេត្តា

ត្រាស ឯស្រីពិតមានតែមួយដែលជាព្រះពុទ្ធបុត្រីរៀបរបស់ខ្ញុំ
ព្រះករុណាពិសេសនេះទើបហៅស្រីតថនលើកឡើងជាក់ជាស្រីពិត ។

ស្តេចខ្ញុំជាបយល់ដូចរៀបរុសនោះថាមែន ទើបមានព្រះបន្ទូល
សួរថា រៀបរុស ដូចម្តេចហៅស្រីពិត ដូចម្តេចហៅម្ចាយពិតអាពុក
ពិត ទើបរៀបរុសក្រាបទូលស្តេចថា សូមខ្ញុំព្រះមេត្តាត្រាស ឯ
ស្រីពិតម្ចាយពិតអាពុកពិតនោះមានតែល្អង់ធូលីព្រះបាទព្រះអង្គយាង
ចេញពីនគរៀរស៊ើបរកទើបបាន បើល្អង់ធូលីព្រះបាទរកបាននៅទីណា
ស្រុកណាភូមិណា សូមល្អង់ធូលីព្រះបាទខ្ញុំធ្វើតាមសព្វព្រះពុទ្ធហ្ងឹយ
ខ្ញុំតិតឃើញដូចម្តេច ខ្ញុំពិសោធត្រាប់ជំពូករៀហើយពុំមានម៉ាអ្វី
ទើបហៅពេញជាស្រីពិតម្ចាយពិតអាពុកពិត ។

ស្តេចខ្ញុំជាបត្រាប់ប្រការខ្ញុំទីកក្នុងព្រះចិត្តាថា រៀបរុសនេះ
និយាយថាត្រូវច្បាកដ ហើយស្តេចព្រះពុទ្ធជានមាសច្បាក់សំពត់អាវឲ្យ
រៀបរុសហើយខ្ញុំឆ្លាំថារៀបរុសឯងនុ៎ះរៀរណានៅចាំអញ បើអញរក
ស្រីពិតម្ចាយពិតអាពុកពិតបាន ហើយអញលែមកវិញថ្ងៃណាអញនឹង
ឲ្យរៀបរុសឯងធ្វើជាធំលើសគេចាំងពួង ហើយស្តេចខ្ញុំបង្គាប់ឲ្យនា-
ម៉ឺនមួយដែលជាធំឲ្យធ្វើដូរមួយឲ្យរៀបរុសនោះនៅហើយស្តេចឆ្លាំឲ្យនា-
ម៉ឺនរៀបរៀបចំលៀងរៀបរុសនោះតរៀងៗ ដល់ស្តេចនឹងយាងចេញចាត
ព្រះនគរៀរកស្រីពិតម្ចាយពិតអាពុកពិតនោះ ស្តេចមានបន្ទូលហៅ

តាម៉ឺនមួយជាធំដែលជាអ្នកសម្រែចពជការក្នុងព្រះនគរ ឲ្យមើលរក្សាទីព្រះពជរាំងដ្បិតស្តេចនឹងយាងចេញរកស្រីពិតម្តាយពិតអាពុកពិត ហើយស្តេចរៀបព្រះដំណើរតៀសព្រះអង្គជាបុរសកំសត់ម្នាក់ ហើយយាងចេញទៅនៅវេលាយប់ស្ងាត់ពុំឲ្យនរណាដឹងដល់មួយឡើយ ឲ្យដឹងតែបុត្រីដែលជាធំនឹងចៅបុរសនោះ ហើយស្តេចយាងទៅធ្វើជាអ្នកកំសត់ពិបាកពុំឲ្យអ្នកណាស្គាល់ជាស្តេចឡើយ ។

ស្តេចយាងទៅដល់ស្រុកមួយជាព្រំព្រះនគរឃើញតាចាស់យាយចាស់ប្តីនឹងប្រពន្ធ ក៏ស្តេចចូលទៅសុំសំណាក់អាស្រ័យ ឯជូនតានោះក៏ព្រមឲ្យទៅ ដល់នៅយូរបន្តិចទៅឃើញកូនគេក្នុងស្រុកនោះមានរូបឆោមល្អក៏មានចិត្តគិតចង់បាន ទើបនិយាយនឹងតាយាយថា តាយាយអើយ អញ្ជើញចៅឃើញកូនគេមួយ រូបឆោមរលោមពណ៌សមជាប្រពន្ធខ្ញុំជូចុះយាយតាទៅដណ្តឹងកូនគេឲ្យខ្ញុំ យាយតាធ្វើយថា ទុចៅអើយ ខ្លួនយាយតាសព្វថ្ងៃនេះ ជាអ្នកកំសត់អត់ឃ្លានពិបាកណាស់ នឹងទៅដណ្តឹងកូនគេតើនរណាគេនឹងឲ្យ ទើបស្តេចធ្វើយទៅវិញថា យាយទៅដណ្តឹងគេចុះ ថ្កាប់ថាខ្ញុំឲ្យមកសុំដណ្តឹង គេមិនថាអីទេ តាយាយនោះក៏ទៅដណ្តឹងកូនក្រមុំគេតាមពាក្យចៅប្រៃ ។

យាយតាទៅដល់ផ្ទះអ្នកដែលមានកូនក្រមុំនោះ ក៏ឡើងទៅអង្គុយលើឆ្នុះ អ្នកផ្ទះនោះសួរថា យាយមកពីណា យាយថាស់ធ្វើយថាខ្ញុំមក

សូមដំកឋអ្នកលាក់ជាំងគ័ន្ធនឹងអ្នក ទៅខ្ញុំឲ្យមកសុំដណ្តឹងកូនក្រមុំអ្នក ឯ
ម្ចាយអាតុកនាងក្រមុំនោះនឹកក្នុងចិត្តថា យាយនេះម្តេចក៏គាត់ហ៊ានដណ្តឹងកូនអញឲ្យទៅនាត់ ហើយអ្នកដែលមានកូនក្រមុំនោះនិយាយទៅនឹងយាយចាស់នោះថា យាយខ្ញុំឲ្យ ប៉ុន្តែយាយឯងនាំទៅកំណែ្តះយាយឯងមកឲ្យយើងមើលថែលួសមនឹងកូនយើង។ ឲ្យមិនថាអីទេ ។

តាយាយលាគេវិលមកផ្ទះវិញនិយាយប្រាប់ថា ទៅឯងលួសមនឹងកូនគេ។ ឲ្យហើយប៉ុន្តែគេឲ្យទៅឯងទៅឲ្យគេមើលរូបសិន បើសមនឹងកូនគេ។ មិនថាអីទេ ឯស្តេចឮយាយចាស់ប្រាប់ដូច្នោះ ហើយមានចិត្តត្រេកអរស្ទាវទៅយាយចាស់នោះថា បុះឲ្យខ្ញុំទៅថ្ងៃណាយាយ។ នោះធ្វើយថាព្រឹកស្អែកយើងទៅ លុះដល់ព្រឹកឡើងយាយនឹងស្តេចទៅទៅដល់ផ្ទះអ្នកដែលមានកូនក្រមុំនោះ ក៏ឡើងទៅអង្គុយសំពះគេហើយថយមកអង្គុយដោយខ្នូវដ៏សមគួរ អ្នកផ្ទះនោះក៏មានចិត្តស្រឡាញ់ស្តេចជាកូនប្រសានោះ ប៉ុន្តែមិនដឹងជាស្តេចក្លែងកេទតិតស្មានជាមនុស្សទាំងផ្លាស។

ឯស្តេចទៅចំរើម្តាយក្មេកអាពុកក្មេកតែសព្វថ្ងៃទៅ រំលោចលួសដេកម្តាយក្មេកប្រាប់កូនស្រីក្រមុំនោះថា អ្នកមាសម្តាយឯងមិនសិតទឹកជាក់ចុងដើងប្តីបៀកស្វា ៥ ម៉ាត់ជាក់ឲ្យប្តី ក្រែងចួនយប់ក្រោកឡើងរកស៊ីស្វាទឹកទឹកក៏ឲ្យមានស្រាប់ កូននោះក៏ព្រមធ្វើតាមភាក្យម្តាយប្រើ ចួនក៏ពុំធ្វើតាម ដល់ថ្ងៃមួយស្តេចធ្វើជាសុំតទឹកម្តាយក៏ប្រាប់កូនក្រមុំថា នាងឯង

មិនយកផ្តិលទៅតាមប្តីឯងទេឬ ឯនាងជាកូនក្រមុំនោះក៏ពុំទៅតាមពាក្យ
ម្តាយទេ ស្តេចនោះទៅយូរបន្តិចក៏វិលមកវិញ ។

ដល់វេលាល្ងាចស្តេចធ្វើយ៉ាងអ្នកជំនាញ ស្រែងអ្នកក្បែរផ្ទះ
ខ្លួននៀលពេញពាសស្មៅផ្ទះពុំដឹងខ្លួន ឯម្តាយក្មេកយល់ឃើញកូន
ប្រសាស្រែង ក៏ស្តីប្រាប់ទៅកូនក្រមុំថា នាងឯងមិនយកទឹកទៅលាង
តំអូត កូនក្រមុំឆ្លើយថាទេមនុស្សអ៊ីចឹមក៏ស្មាដូច្នោះ ស្តេចឮដូច្នោះ
ព្រឺកខ្លឹងស្តេចលាម្តាយក្មេកនឹងអាពុកក្មេកទៅផ្ទះយាយថាស់តាថាស់
ប្រាប់យាយតាថាពីដំណើរកូនក្រមុំគេដែលយាយតាទៅដណ្តឹងឲ្យខ្ញុំនោះ
យាយតាអើយសំណាងនាងនោះនឹងខ្ញុំមិនចង់ជាគូព្រងនឹងគ្នាទេឲ្យ
យាយតាប្រគល់កូនទៅគេវិញចុះ ។

យាយតាក៏ទៅជូនសំណាងកូនគេតាមពាក្យទៅប្រុស ទៅលើផ្ទះ
និយាយថា ខ្ញុំសុំជូនព្រងសំណាងកូនអ្នកផង ដ្បិតទៅខ្ញុំថាពុំមាន
ព្រងនឹងកូនអ្នកទេ រួចយាយតាក៏លាគេមកផ្ទះអាតាវិញ លុះព្រឹកឡើង
ស្តេចលាយាយចាស់តាចាស់ដើរទៅទៀត ដល់ស្រុកមួយជាចុងស្រុក
ទេគួរក្រៅក៏ទៅសុំសំណាក់នឹងផ្ទះជូនចាស់តាចាស់ ។ ក៏យល់ព្រមស្តេច
ក៏ទៅធ្វើការរកស៊ីនឹងយាយតាតែសព្វថ្ងៃរៀងទៅ ។

កន្លងសម័យថ្ងៃ ១ ស្តេចដើរទៅលេងឃើញកូនក្រមុំអ្នកស្រុកនោះ
ហើយជាអ្នកមានផង កូនស្រុកនោះពុំមានអ្នកឯណានឹងមានស្មើនឹងគេ

ទ្បើយ ប៉ុន្តែអ្នកនោះមានកូនស្រី ១ កូនប្រុស ១ ទាំង ២ នាក់ មិនទាន់
មានប្តីប្រពន្ធទេក៏ស្តេចនោះដើរទៅលេងបានឃើញមានចិត្តគិតចង់បាន
រៀមកផ្ទះអាត្មាវិញហើយនិយាយប្រាប់តាយាយថា យាយខ្ញុំចង់បាន
កូនគេ ដែលមានកូនប្រុសមួយស្រីមួយ សុំឲ្យយាយទៅដណ្តឹងកូនគេ
ឲ្យខ្ញុំផង យាយថាស់ទ្បើយថា ចៅអើយខ្លួនយាយក្រមុំរតើ នរណាគេ
នឹងឲ្យកូនគេមកចៅ ឯស្តេចឮយាយនិយាយដូច្នោះក៏មានបន្ទូលទៅនឹង
យាយថា យាយទៅដណ្តឹងកូនគេចុះថាខ្ញុំឲ្យមកដណ្តឹងគេមិនថាអីទេ
យាយថាស់នោះក៏ត្រមទៅតាមពាក្យចៅប្រើ ប៉ុន្តែយាយតាពុំដឹងជាចៅ
នោះជាស្តេចទ្បើយ គិតស្មានថាជាមនុស្សពាំនាំផ្លាសដាំទៀក៏ទៅដណ្តឹង
កូនគេ។ ក៏ត្រមឲ្យ ស្តេចនោះក៏ទៅបម្រើម្តាយក្មេកតែសព្វថ្ងៃរៀងទៅ ។

ឯនាងជាប្រពន្ធនោះក៏ប្រតិបត្តិប្តី ល្អចជាក់ទឹកចុងជើងបៀកស្ងោ
៥ ម៉ាត់ជាក់ទៅដំណេកប្តីតែសព្វថ្ងៃរៀងទៅ រៀលស្តេចទៅឆ្ងូតទឹកនាង
កាន់ដួលនឹងសំពត់ឆ្ងូតតាមទៅឆ្ងូតទឹក បើស្តេចឆ្ងូតទឹកនាងនោះដុះក្អែល
ឲ្យប្តី។ ផ្ងាស់សំពត់ឆ្ងូត នាងទទួលយកសំពត់ឆ្ងូតរួចដងទឹកជាក់ដួលកាន់
ដើរតាមប្តីទៅដល់ផ្ទះលាងរដើងប្តី ដល់រៀលថ្ងៃមួយ ស្តេចធ្វើជាឈឺ
ម្តាយក្មេកអាពុកក្មេកយើញកូនប្រសាឈឺ ក៏មានចិត្តនោះកំតក់យ្រសដី
ទៅនឹងកូនក្រមុំថា កូនមកមើលគក់ច្រកាច់ឲ្យប្តី នាងនោះកំគក់ច្រកាច់
ឲ្យប្តី ប៉ុន្តែស្តេចនឹងនាងពុំទាន់បានរៀបការនៅទ្បើយទេ ឯអាពុកក្មេក

ម្តាយក្មេកក៏ពុំដឹងជាអ្វីដែរ តែតស្មានជាមនុស្សប្រុសស្តីចាំងផ្ការស ដល់នៅយូរបន្តិចទៀបានពេលល្ងាច ក៏ម្តាយក្មេកអាពុកក្មេកនោះចេញប្រាក់រថស់ខ្លួនរៀបការកូនក្រមុំនឹងកូនប្រសា ហៅអស់ញាតិដឹតធ្វើយមករៀបការ ស៊ីផឹកជាសុរេចស្តេចនឹងនាងក៏រួមសុខទុក្ខនៅជាមួយគ្នាតាំងអំពីនោះរៀងមក ។

ដល់នៅយូរបន្តិចទៀបស្តេចចង់ពិសោធចិត្តប្រពន្ធ នឹងចិត្តម្តាយក្មេកអាពុកក្មេងឲ្យឃើញពិតឬពុំពិត ក៏ស្តេចធ្វើជាដឹកស្រាលេងរៀងជាញឹកញាប់ៗ មកជារៀងនឹងរកប្រាក់ឲ្យចំនគ្មាន ម្តាយអាពុកនោះក៏ចេញប្រាក់ឲ្យចំនតែសព្វថ្ងៃបាត់តែអស់ប្រាក់ជាប់ខ្លួនជាអ្នកក្រ ម្តាយក្មេកអាពុកក្មេកប្រពន្ធនោះពុំមានស្តីថាអ្វី អស់ញាតិសន្តានទៅជិតខាងគេស្រដីថា ឲ្យផ្តាច់ទៀកុំឲ្យកូនអាចវៃរ៉ាមិនគិតធ្វើការរកស៊ីដូចគេចាំនឹងពួន រាល់តែរៀងផឹកស្រាដូច្នេះតើ នឹងខុកវាថ្លៃគេស្តីប៉ុនគេផ្តប់ ម្តាយអាពុកនោះក៏មិនឮមាត់អ៊ីះ ។

ឯស្តេចនោះ យល់ឃើញជាម្តាយក្មេកអាពុកក្មេងគ្រលំបាកអស់សម្បត្តិមានតែខ្លួនហើយក៏ឈប់លែងលេង ចេះតែរកមិនមានតិតរកស៊ីអ្វី ប្រើតែប្រពន្ធឲ្យធ្វើនំលក់គ្រាន់តែផ្តែតនោះ ឯម្តាយអាពុកក្មេងនឹងប្រពន្ធនឹងមានស្រដីអ្វីឲ្យធ្ងន់ពាក្យតូចចិត្តកូនប្រសាក៏គ្មាន ហើយស្តេចនោះនឹកកត់ព្រះចិត្តថា តើចៅប្រុសនេះមានប្រាជ្ញាយល់ការដែរឬថា

ឲ្យអញកេម្ពាយពិតគាពុកពិតច្រៀតន្ធជាស្រែពិតនេះហៅតេញជាគ្រែ ៥. ឲ្យវែអញកេបានហើយល្មមអញតែងព្រះបន្ទូលច្រាប់ទៅសេនាបតីឲ្យរៀបកងយានខ្លួរពលេច្បើរដើង តាមមុខងារដើរសេះកងរថទន្ទេញលអញចុះក៏ស្តេចតែងព្រះបន្ទូលច្រាប់ទៅសេនាបតីសេចក្តីថា ឲ្យរៀបដើរសេះរទេះកងយានពលេច្បើរដើងទៅទន្ទេញលស្តេច ដ្បិតស្តេចកេច្រៀតន្ធជាស្រែពិតជាម្ពាយពិតគាពុកពិតបានហើយ។ ឲ្យយកគ្រឿងឥស្សរិយយសនាំទៅថ្វាយជាទាប់, មួយទៀត បើចំរើនាំព្រះបន្ទូលមកដល់ឲ្យរៀបទន្ទេញជប់លៀងតាមដោយទ្រង់គួរជាបងថ្លៃស្តេច ។ តែឆ្លុះស្រែចស្តេចជាតំកូនចំពង់ចិទ្ធមាត់ចំពង់ជិតពុំឲ្យបងថ្លៃនោះដើងសេចក្តី ហើយស្តេចហៅបងថ្លៃថា អ្នកបងអើយអញ្ជើញមកអាយ ខ្ញុំបងនឹងឲ្យអ្នកបងនាំសំបុត្រខ្ញុំទៅឲ្យនាម៉ឺនដែលជាធំទៅកងកំងហ្នឹងនោះ តើអ្នកបងឯហានទៅឬទេ បងថ្លៃឮដូច្នោះក៏ព្រមទៅតាម ហើយចេញដើរទៅសួរគេតែតាមផ្លូវទៅដល់ស្រុកមួយសួរគេថា អ្នកអើយផ្លូវណាទៅកំងស្តេច អ្នកស្រុកនោះច្រាប់ថា ផ្លូវនេះហើយទៅកំងស្តេច បងថ្លៃស្តេចនោះក៏ចេះតែដើរសួរគេតែរៀងទៅ ។

លុះដល់ទៅមាត់ភ្នំកំងក៏សួរនាយគាហានយាមភ្នំថា អ្នកហ្នឹងហើយឬដែលគេហៅកំងហ្នឹង នាយគាហានក៏ច្រាប់ថាហ្នឹងហើយ ឯនាយគាហានសង្ស័យក៏សួរថា អ្នកឯងមកពីណា ចាន់ដាមកសួរកេកំងហ្នឹង បងថ្លៃស្តេចទ្វើយថា ខ្ញុំនាំសំបុត្រគ្លួនខ្ញុំមកឲ្យនាម៉ឺនធំដែលទៅកងកំងនេះ

គ្រានោះកម្មពីអតីតជាតិ ក៏ជួនជាត្រូវឲ្យផលសម្រេចមួយរំពេច នោះ ក៏ស្រាប់តែមានមនុស្សម្នាក់ មានសណ្ឋានមុខប្រកបដោយកែលវែង ១៨ អន្លើ ចូលមកសួរនឹងព្រះនេត្រព្រះថេរកុនាលៈ លុះព្រះកុនាលឆន្ទៈបានឧស្សាហការហើយ ក្នុងខណៈនោះស្តេចទ្រង់លើកដល់ពាក្យព្រះយសត្ថេរ ដែលថាក្អែកជាធម្មជាតិមិនខឿន ហើយទ្រង់ព្រះដម្រែនេះថា "លោកបានឃើញឬស្តាប់ថា អញនឹងត្រូវអន្តរាយក្អែកដែលជារាជ្ជាន់នៃផលកម្មរបស់អញ ព្រោះដូច្នោះលោកទើបបានសំដែងពាក្យនោះ លោកជាកល្យាណមិត្តនឹងអញពិតប្រាកដ ។ ព្រោះគុណគឺសេចក្តីមេត្តាចំពោះមកខ្លួនអញ ទើបលោកបានប្រាសចេញនូវទុក្ខរបស់លោកដល់អញ លោកប្រាថ្នានឹងឲ្យអញដឹងខ្លួន ក្នុងពេលដែលអញបានឮលាន់ជ្ជាន់នៃផលកម្មរបស់អញនេះ ចិត្តអញមិនបានរំភើបញាប់ញ័រទេ ។ មួយទៀតក្នុងកាលមុននោះ ព្រះថេរៈបានបង្រៀនវិជ្ជានេះដល់អញថា ពួកសត្វតាំង ៣ ពួក[1] ក៏មិនខឿនខាត់ទេ មិនមែនជារបស់រឹងប៉ឹងទេ តែងតែប្រែប្រួលទៅជាធម្មតា គ្រាន់តែស្រមើស្រមៃបញ្ឆោតចិត្តឥតអំពើតាំងតែពីយូរយារណាស់មកហើយ អញបានឃើញខ្លួនឯងជាក់ច្បាស់ហើយថា "នឹងត្រូវខ្លួចខាតបង់ក្នុងប្រសាទជាលក្ខណៈ ចូរខ្លួនឯងចំប្រឹងសម្រឹងខ្លួនទៅក្នុងព្រះធម៌ថ្ងៃ" ។

---

១ ពួកសត្វតាំង ៣ ពួក: ពាមភព រូបភព អរូបភព ។

គ្រានោះ ព្រះកុនាលភជទេវសេ គ្រាស់ទីឆ្ងីមនុស្សប្រុសកែលនោះថា "ចូរឯងឆ្ពៀលកែ្នកអញម្ខាងទៀតមកកន្ទឹងជ្រុតដៃអញសិន" ។

ខណៈនោះមនុស្សប្រុសកែលនោះ ស្ទុះស្ទាវចូលទៅជិតព្រះកុនាលភជទេវសេ ដោយសេចក្តីប៉ុនប៉ងនឹងឆ្ពៀលព្រះនេត្រព្រះអង្គ ហើយឆ្ពៀលព្រះនេត្រម្ខាងទៀតមកកន្ទឹងព្រះបាទ្តព្រះអង្គ ក៏ពួកអ្នកឈរមើលទាំងអស់កែ្រសកតឹកតឹងខ្លាំងអីងអាប់ដោយស្ញប់ស្ញែងគ្រែញ៉ខ្លួនថា "ទុច្ចំឡែកអស្ចារ្យណាស់ហ្ន៎ ! ។

"ទុកម្មអកុសល ! លោតែព្រះចន្ទដ៏ចរិសុទ្ធមានរស្មីភ្លឺត្រចះ ភ្ញាក់ស្រែសចុះមកហើយ ផ្តាំឈូកដ៏រីកស្រែស់ល្អត្រកាលកេយរុះទៅហើយ តំពួកមនុស្សទាំងសែនកោដិ មិនអាចនឹងខប់ខល់សេចក្តីសោកស្តាយបាន ស្រែកយំអឺងកងគ្រប់ៗគ្នា" ។

ព្រះកុនាលភជទេវសេ បានពិចារណាមើលវង់ចក្ខុដែលទៅកន្ទឹងព្រះហស្តដោយព្រះដម្រិះនេះថា "ឈិះ ! កែ្នកនេះនែ ! ហេតុអ្វីបានជាឥឡូវនេះឯងមើលរូបភាពមិនឃើញសោះ ពីដើមគេថាឯងហ្នឹងល្អណាស់ ឥឡូវនេះឯងគ្រាន់តែងាប់ជាក់ថោកទាបឥតគេកប់សោះទេតើ ឯងហ្នឹងហើយធ្វើឲ្យវារំកិចត្តពួកមនុស្សល្ងង់ខ្លៅ គេថាគ្រែតែឯងហ្នឹង ទើបបណ្តាលចិត្តអញឲ្យមានសេចក្តីស្នេហាឈ្លក់នៅពុំសូវបែបបទ ឯខ្លួនឯងៗ គ្រាន់តែធ្វើបញ្ឆោវឲ្យស្តុងចិត្ត ដោយហេតុទាំងពាន់ទាំងហ្នឹង និងយ

ដោយពិតមែនថា មិនមានក្អែកក៏មិនជាអ្វីដែរ ក្អែកឯងដូចពពុះដែល
អណ្តែតនៅលើទឹកដែរ អ្នកដែលពិចារណាឃើញថា ឯងហ្នឹងជារបស់
ទើបប្តឹងពិតជ្រាកជាតបន្ទុះបន្ទួយ អ្នកនោះឈ្មោះថា ជាទាសៈនៃជំរៃ
ហើយទើបសេចក្តីស្លាប់" ។

ពេលដែលព្រះអង្គពិចារណាដូច្នេះ ទ្រង់ក៏ជ្រាបសេចក្តីសោតា-
បត្តិផល ហើយទ្រង់ជ្រាបឃើញនូវអរិយសច្ចដោយជាអច្ឆរិយៈក្នុងពេល
នោះ ។

ត្រាព្រះអង្គជ្រាបឃើញអរិយសច្ចហើយ ទើបត្រាស់ទៅនឹងមនុស្ស
ប្រុសកែលវិការនោះថា "ចូរឯងឆ្កឹលក្អែកម្ខាងទៀត" ។

មនុស្សនោះគោរពតាមពាក្យបង្គាប់ ជ្រាបឆ្កឹលព្រះទេតនោះ
ហើយ ដាក់ទៅក្នុងព្រះហស្ត ។

ព្រះចៅកុនាលជ្រាបពិចារណាមើលក្អែកនោះហើយ ទ្រង់ជ្រាបស្រេច
ដល់ សកិទាគាមី ព្រោះតែព្រះអង្គនិទ្ទោសមិនបានហើយ ទ្រង់ត្រឡប់
ជ្រាបបញ្ញាចក្ខុដ៏បរិសុទ្ធឡើងវិញ ទើបទ្រង់ត្រាស់ព្រះវាចានេះថា "មំស-
ចក្ខុតាំងឡាយរបស់អញនេះក្តៀលបេញអស់ហើយ តែអញជ្រាបហើយ
នូវចក្ខុតិជ្ជាជ្ញ បើព្រះបិតារបស់អញបោះបង់ចោលបុត្រក្នុងសង្ការវដ្តហើយ
អញតប្បីជាទុរសេរបស់ព្រះពុទ្ធជាព្រះធម្មជាវិញ បើខុកជាអញ

វិនាសហើយចាកពីជសម្បត្តិ អញក៏ជាធម្មសម្បត្តិក្នុងគ្រានេះដែរ អញ
ជានរួចផុតចេញស្រឡះហើយ ចាកសេចក្តីគាមរងស្ស នឹងសេចក្តីទុក្ខ
ព្រួយ" ។

លំដាប់តមក ព្រះកុមារាលកជទេវសេ ទ្រង់ជ្រាបថា ព្រះពោធិសារបុត-
ហ្មាយកែងមកអំពីព្រះនាងតិស្សរក្សិតា មិនមែនជាការសម្រេចមកអំពី
ពោធិប្បញ្ញាត្តិទេ ។ ខណៈនោះ ព្រះអង្គតាំងសេចក្តីជ្ញាថា "សូមឲ្យព្រះ
ពោធិនីតិស្សរក្សិតា ទ្រង់សម្រាន្តព្រះជន្មនៅជាសុខ ឲ្យជានយូរលង់ទៅ
ហើយកុំឲ្យវិតក្កអាជ្ញុកក្នុងព្រះអង្គឡើយ ។ ព្រោះហេតុអ្វី ? ព្រោះថា
ព្រះនាងជាគ្រឿងប្រដាប់ ជាហេតុធ្វើឲ្យវិនាសដល់ខ្ញុំ ហើយធ្វើខ្ញុំឲ្យ
ជានសម្រេចគុណធម៌ជាជល" ។

គ្រានោះនាងកាញ្ចនមាលា ជាព្រះជាយាព្រះកុមារាលជានជ្រាប
ដំណឹងថា ព្រះស្វាមីត្រូវគេធ្លាក់ព្រះនេត្រទាំងពីរហើយ នាងក៏សុំ
ម្ចាស់ទៅជិតព្រះស្វាមី លុះជានឃើញព្រះហ្វាមីមានព្រះកាយប្រឡាក់
ដោយព្រះលោហិត ដែលហូរស្រោចអំពីព្រះនេត្រាមក នាងវិលស្រកយំ
ភ័យខ្លាចតក្កមាពេញទៅដោយសេចក្តីសង្វេគសុតចិត្ត ហើយដួលដេក
សន្ធប់ជាប់ស្មារតីទៅលើដែនដី អ្នកទៅជិតនាងជានយកទឹកប្រសិទ្ធិ
ស្រោចព្រះកាយ នាងជានដឹងអាត្មាឡើងវិញ ទាំងខ្លួនក្តី ហើយវិលវល

ទូលថា "ឧត្តមព្រះទេវតាដ៏បរិសុទ្ធហើយ ល្អបំផុតពៃត្រកូតនេះ ជារបស់នៃសត្វទាំងពួងដ៏ឧត្តមវិសេសធំធីតែម្តងទៀតហើយ" ។

ព្រះកុនាលកជាឧបាសក មានចិត្តជ្រះថ្លាជ្រាលជ្រៅដោយនាង ទើបត្រាស់ទូន្មានគាថានេះថា:

"អំពើទុច្ចរិតដែលបងធ្វើហើយ ឥឡូវនេះបងត្រូវទទួលផ្តន្ទាអំពីអំពើទុច្ចរិតនោះវិញ សេចក្តីទុក្ខដ៏ធំបំផុតរបស់សត្វសត្វទាំងឡាយក្នុងលោកគឺការត្រាត់ច្បាស់ថាកម្មត្រូវស្ងួតហាជាធម្មតា ប្អូនឯងមិនបន្ទោបង់សេចក្តីទុក្ខសោកឲ្យផុតឆ្ងាយពីខ្លួនទៅណានាង ប្រយោជន៍អ្វីនឹងការយំសោកនេះ" ។

ពួកអ្នកនគរបានឃើញដូច្នោះហើយ ទើបនាំគ្នាបំបរបង់ព្រះកុនាលព្រមទាំងព្រះជាយា បង្ខំឲ្យស្តេចចេញចាកដែនទៅ ។

ចាប់ដើមតាំងអំពីកំណើតមក ក៏អ្នកទាំងពីរព្រះស្វាមីនឹងព្រះជាយាក្តាប់បានទ្រង់នូវព្រះជន្មនៅដោយការសោយសុខសម្បូរជាសុខុមាលជាតិស្តេចមិនដែលប្រកបការងារឲ្យនឿយហត់ដល់ព្រះកាយពាលទេ មិនដែលវិសេសវិសាលដ៏ធ្ងន់ទេ សូម្បីការងារអ្វីតិចតួចក៏មិនដែលធ្វើដែរ ទ្រង់ក៏ត្រឡប់ទៅជាថោកទាបស្តេចយាងសូមទានគេដោយព្រះឫទ្ធិ ។ ទ្រង់ដើរញាត់ញាណហើយដៃស្តាំក្តាប់ដៃ ។ តាមតម្បន់ផ្សារ ។ សូមទានអាហារដើម្បីចិញ្ចឹមជីវិតព្រះអង្គព្រមទាំងព្រះជាយាផង ។ នាងគាញ្ចន-

មាលាដ៏ក្រៃហស្តក្រៃស្ងាម ស្តេចទ្រង់ព្រះដំណើរត្រឡប់មកតាម
មាគ៌ាដែលចូលទៅកាន់ក្រុងចាដលិបុត្រ កាលដល់ទ្វារព្រះបរមកដ៏ង
ហើយទ្រង់ថ្វាយចង្ចំចូលទៅខាងក្នុងព្រះកដដំណាក់ព្រះចិតា តែនាយ
ទ្វារបាលឃាត់មិនឲ្យស្តេចចូលទៅ ។ វេលានោះព្រះកុនាលកដនុះស
ទ្រង់ផ្ទំនៅក្នុងកោនដំរីទៀបទ្វារព្រះកដ៏ងនោះអស់មួយភក្តិ លុះត្រលឹម
ស្រាងឡើងទ្រង់ដេញពិណរហើយច្រៀងរៀបរាប់ទៅតាមសំឡេងពិណ
អំពីគ្រាជាធំ ហើយទង្វើងគ្រាអកត្ញូរបស់ព្រះអង្គ ព្រមទាំងបរិយាយ
អំពីហេតុដែលបានសម្រេចមគ្គផល ព្រោះតេជៈព្រះនេត្រាបស់
ព្រះអង្គ ។ ពួកអ្នកដែលបិតនៅដិតទ្វារ បានស្តាប់ទំនុកច្រៀងនោះហើយ
ក៏បានតិចារណាដោយខ្លួនឯង អំពីរូបភាពដែលប្រមូលរួមចូលទៅក្នុង
ខន្ធទាំងឡាយ អ្នកទាំងអស់នោះក៏បានរួចចាកជាតិទុក្ខ ដែលប្រព្រឹត្ត
ទៅក្នុងវដ្តសង្សារបានត្រង់គ្នា ។

ព្រះបាទអសោក កាលទ្រង់ព្រះសណ្តាប់សំឡេងច្រៀងទំនងសំ
ឡេងពិណនោះ ព្រះអង្គទំកក្តកដល់ព្រះកុនាលកដនុះស ហើយទ្រង់
ត្រាស់ថា, "សូរសំឡេងពិណនោះ ដូចជាសូរសំឡេងរបស់កុនាលៈកូន
អញ ទំនុកច្រៀងពាប់រៀបអំពីសំណាងវាសនា អាក្រក់ទំងស្លនោះជា
ទំនុកច្រៀងអ្នកណាមួយ ក្នុងគ្រាដែលវាបានធ្លាជាធំ ។ ព្រះអង្គទើប
ចាត់ភដបំរើឲ្យទៅពិនិត្យមើល លុះភដបំរើបានទៅមើលឃើញព្រះ

កុនាលកជទេសេក្សាសថាគព្រះនេត្រតាំងសងខាង មានព្រះកាយស្តួម
កំព្រឹង ហើយកើតចែងថ្ងៃខុះ ព្រោះហេតុនោះទើបចំណាំ ព្រះគង្គមិន
បាន ក៏ត្រឡប់ទៅក្រាបទូលព្រះរាជាថា "តឹអ្នកស្តេចម្ចាក់ ខ្ញុំកំព្រឹកព-
ពើឥមានខ្លួនស្តួមកំព្រឹងហើយកើតចែងថ្ងៃខុះ ប្រពន្ធក៏បិតនៅផ្ទាប់ខាង
ខ្លួនក៏នោះ" ។

ព្រះរាជា កាលទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទ្រង់មានព្រះ
ដំម្រិះថា "កាលពីមុនអញយល់សុបិនយើញថា កុនាលកូនអញបាន
អន្តរជាន ក្នែកតាំងពីរៅ ក្រែងឥហ្នឹងហើយដឹង? អញត្រូវឲ្យគេដល់កូនអញ
ភ្លាន ស្រាកចិត្តមួយស្រេចក់សោះ នែអាមាត្យទាប់ឡើង! ឲ្យគេទៅហៅ
ក់មក ។ ខណៈនោះស្តេចត្រាស់ប្រើឲ្យពួកជំទប់រើទៅហៅមនុស្សខ្វាក់នោះ
ពីកេងដំរី លុះដល់ហើយគេសួរមនុស្សខ្វាក់នោះថា "អ្នកជាអ្វី? អ្នក
ជាកូនចៅនរណា?"

មនុស្សខ្វាក់តបថា "បិតាខ្ញុំជាស្តេចឈ្មោះអរសោក ព្រះអង្គជា
ម្ចាស់នៃជម្ពូទ្វីប ទ្រង់ជាអស្សរះលើមនុស្សតាំងអស់ ខ្ញុំជាឧសោបេស់ព្រះ
អង្គនោះ ខ្ញុំឈ្មោះកុនាល តែខ្ញុំមានបិតាមួយផ្សេងទៀត ព្រះអង្គជា
ជម្ចិកមហាកប់ ដែលគេជាប់ហៅថាព្រះតុខ្នោះ" ។

ខណៈនោះតួកជំទប់រើ បាននាំមនុស្សខ្វាក់ ត្រមតាំងតរយោទៅ
ឆាល់ព្រះមហាក្សត្រ ។

កាលព្រះមហាក្សត្រខេតរយើញព្រះកុនាលកជទុរស ថ្ងៃសចាក
ព្រះនេត្រ មានព្រះកាយស្គមកំព្រឹង លេចចែងថ្ងៃខុះ មានសំលៀក
បំពាក់ដ៏គ្រាំគ្រាចាស់រយើករយោកធ្លុះរហុយ ព្រោះហេតុនោះ ទើបទ្រង់
ចំណាំព្រះទុរសពុំបាន លុះទ្រង់បានយើញមនុស្សកំសត់ខុគ្គិត មាន
ទំនង់អាការរស់នៅដោយលំបាកដូច្នោះ ទើបត្រាស់សួរថា "ឯងជា
ចៅកុនាលមែនឬទេ?"

ព្រះកជទុរសទូលតបថា "ទូលព្រះបង្គំហ្នឹងហើយព្រះអង្គ" ។

ព្រះកជា កាលទ្រង់ព្រះសណ្តាប់ពាក្យនោះ ព្រះរាយោកំរើក
ភ្នាំងសង្រែងសង្រៃ ស្រយុតព្រះហ្ឫទ័យដោយសេចក្តីក្តួរក្តួយ ស្តេច
ដួលទៅលើផែនដី ពួកកជបរិពារបានយកទំកប្រស់ព្រំស្រប់ព្រះកក្តាំ
ព្រះអង្គបានដ៏ងព្រះស្មារតីគើនឡើង ទ្រង់លើកត្រកងបីព្រះកុនាល
ជាក់លើព្រះឧរូ ទ្រង់ក្សត្រព្រះនេត្រាទ័ងព្រះហស្ត ហើយទ្រង់ព្រះ
តន្ទៃដ៏ងថា "ត្រាតីមុននេត្រាឯងដូចជាក្មែកបក្សីកុនាល ព្រោះដូច្នោះ
បានជាគេហៅកូនឯងដោយនាមនេះ ឥឡូវនេះកូនឯងវិនាសសាបសូន្យ
ចាកនេត្រាទៅហើយ តើទ័ងហៅកូនឯងដូចម្តេចវិញ? ទុមាស
អាពុក, ច្បាប់ហ្នឹងចូរចុះ អ្នកណាបានឆ្លៀលក្មែកកូនឯង ធ្វើឲ្យដូចជាដៃ
មេឃ ច្បាសចាកដួងព្រះចន្ទ្រទ័ងតារាដូច្នោះ? មនុស្សមានចិត្តឥត
មេត្តាប្រណី វាបានធ្វើឲ្យសាបសូន្យក្មែកកូនឯងនោះតើមនុស្សដូចម្តេច?

អ្នកណាបានធ្វើកែកកូនឯងឲ្យដាស់ប្រជានៃការឈឺចាប់ ទៅជាប់រហូតមកដល់ថ្ងៃនេះ ? កុនាលកូនអាពុកអើយ ! អ្នកណាធ្វើកែកកូនឯងឲ្យរំលែកការមែបនេះ ?

ចូរច្បាប់គាពុកមកឲ្យឆាប់ចុះ ! អាពុកយើញកូនឯងពេលនេះ អាពុកខន់អស់ចាំងកាយ ឈឺចាប់ជាខ្លាំង ភ្លើងតំសេចក្តីសោកស្តាយនេះ សាយសព្វខ្លួន រហូតដល់ដួងប្អូនទំយប់តាហើយ ធ្វើឲ្យអាពុកបានសេចក្តីនៅសុសាចស្លូន្យ ដូចជាគេត្រូវកាំអសនី ។

ព្រះកុនាលកដឧស ឧនចុះទៀបច្រៀបច្រាទព្រះពជបិតាហើយក្រាបទូលថា " ព្រះអង្គកុំសោយសោកជាទុក្ខជាអុកអ្វី កុំគ្រែវគ្រែងដល់ហេតុការណ៍ដែលបត្តិហួសទៅហើយ ។ ឧព្រះវរបិតាព្រះអង្គមិនធ្លាប់ជាមនុស្សទេឬ សូម្បីព្រះពុទ្ធចាំងខ្លាយក៏គង់ព្រះអង្គត្រូវទទួលផ្ទាន់ជាមតិកនៃផលកម្ម របស់ព្រះអង្គដែរ ។ (ព្រះបាច្ចេកពុទ្ធ) ព្រះសាវកពុទ្ធព្រមចាំងសាមញ្ញជនចាំងអស់ ក៏ត្រូវតែទទួលផ្ទាន់ជាមតិកនៃផលកម្មរបស់ខ្លួន ។ មិនមានអ្នកឯណាមួយ គេចឲ្យផុតអំពីវិបាកនៃកម្មរបស់ខ្លួនទៅរួយ ។ កម្មចាំងខ្លាយជាកុសលឬអកុសល មិនដែលបាត់ទៅទេ គ្រាន់តែដូច្នោះមិនគួរនឹងជាញាប់ជាលដល់អ្នកដទៃ គ្រាន់តែអំពើកម្មដែលខ្ញុំព្រះអង្គធ្វើហើយ ដោយខ្លួនឯងនោះ តែមិនមែនជាជាវដែលសម្រាប់តាមចាក់ មិនមែនខ្មេះ មិនមែនថ្នាំពុល មិនមែនអាសិរពិសទេ សេចក្តីទុក្ខ

លំបាកកើតមកអំពីហេតុទាំងអស់នោះមកយាយខ្លួនខ្ញុំព្រះអង្គក៏ដោយ គឺជាវិបាកនៃកម្មវេរបស់ខ្ញុំពីមុនមក ដែលខ្ញុំព្រះអង្គបានខ្ជះខ្ជួលផលកងគ្រានេះ ការធ្វើទោសអ្នកដទៃកងហេតុនេះ ទើងមិនមានយុត្តិធម៌សោះឡើយ; សត្វសត្វទាំងអស់ដែលមានអត្តភាពរស់នៅ ដូចជាវង់មួលមួយដែលគេចាញ់ត្រូវជាប់ព្រួញទាំងពាន់ច្រួនច្រាលយ៉ាងណាមិញ ក៏ខ្លួនខ្ញុំព្រះអង្គនេះ ត្រូវខ្ជះខ្ជួលវិបាកនៃកម្មដ៏អាក្រក់ទាំងពាន់ ដែលត្រូវបួបប្រទះកងពេលនេះដូច្នោះដែរ ។

ព្រះបាទអាសាកប៉ែកខាងជាបានទ្រង់ព្រះសណ្តាប់ពាក្យនុរសនោះក៏ព្រះអង្គនៅតែមានព្រះហ្ឫទ័យក្តៅនេះឆួលរងំដោយភ្លើង គឺសេចក្តីសោកស្តាយ ទ្រង់គាស់ទីងព្រះពជនុរសទៀតថា "ចុះអ្នកណាកាត់តមេត្តីអ្វីម្ល៉ះ បានបំផ្លាញក្អែកកូនប្រុសអញចាំងនេះអេះ ?"

ព្រះកុនាលពជនុរសតបថា "បពិត្រព្រះវរបិតា គឺព្រះអង្គឯងបានតែងព្រះពជនុង្ការទៅឲ្យគេធ្វើលក្អែកខ្ញុំព្រះបង្គំជាខ្ញុំ បានជាគេហ៊ានធ្វើលមែបនេះព្រះអង្គ" ។

ព្រះបរមក្សត្រគាស់ថា "បើជាអញបានបង្គាប់ឲ្យអ្នកណាមួយទៅធ្វើលក្អែកកូនឯងមែន អញនឹងកាត់អណ្តាតអញចេញដោយខ្លួនឯង" ។

ព្រះកុមារកស្សបទូលតបថា "បពិត្រព្រះវរបិតា ព្រះកស្សបសារមានទាំងប្រថាប់ព្រះលៃព្ងកវរដោយព្រះខន្តីព្រះអគ្គដ៏ ហេតុដូចម្តេចបានជាខ្ញុំមិនស្រាប ?

ព្រះពជាត្រាស់ថា "បើអញ្ចឹងបានប្រថាប់ត្រា ព្រះកស្សបសារដោយធ្មេញអញមែន អញនឹងតាស់រំលេងធ្មេញអញដោយខ្លួនឯង បើក្អែកអញបានឃើញដង អញនឹងធ្វើលយកក្អែកអញចេញដោយខ្លួនឯង" ។

គ្រានោះព្រះពជាមិនតិស្សរក្សត្រា បានត្រាស់ហៅព្រះនាងបញ្ចាវតីមកខំហាយថា[1] "បួរនាងឯងធ្វើលក្អែកខ្ញុំឥឡូវនេះចុះខ្ញុំត្រមាំងកូនប្រុសនឹងដើរទៅសួមទានតេមកចិញ្ចឹមជីវិត" ។

ដំណឹងនោះជាហេតុបណ្តាល ទៅឲ្យជាបដល់ព្រះស្រោតស្តេចទើបខ្ចង់ព្រះដម្រិះថា "ឫកពជាតិស្សរក្សត្រាហើយ ធ្វើលក្អែកកូនប្រុសសំឡាញ់ទេស់អញ" ក្នុងមួយរំពេចនោះព្រះអគ្គមានព្រះទង្វើរឲ្យហៅព្រះពជាមិនតិស្សរក្សត្រាមក ហើយត្រាស់ប្រទេន្ធះថា "មេស្រីកាចបង្កែ ព្រោះហេតុអ្វីបានជាព្រះធរណីទ្រង់ខ្ចង់ហានឯងខុតមិនស្រួបខ្លួនហានឯងតទ្ធិចឲ្យហើយតែម្តងទៅ ? ហានឯងថាស្តីបំផ្លាញអាវ្យធមិ ពេលនេះតែងជាអញស្តីបន្តើមហានឯងណាស់ ហានឯងសំដែនខ្លួនហើយកល

---

๑ សៀវភៅពុទ្ធសាសនានៅស៊ីឡង់ ហ្ស៊ីណូវ៉ាំ នៃលោកមៅប្រែជាខ្មែរព្រះមាតានៃពុទ្ធសាសនាស៊ីឡង់ទៅ ទើបព្រះពជាត្រង់ខ្ចង់តិស្សរក្សត្រាឡើងជាអគ្គមហេសី ។

មាយា ធ្វើជាញាតិសាលោហិតដែលស្រឡាញ់អញស្ទួច តែតំនិត
ហនឯងឯងលាមកបំផុត!" ។

ព្រះមហាសត្វតែងតំរែតំរង់ធនេះកេលកលដោយក្តៅគឺសោស:
ទំនព្យាបាទដ៏ខ្លាំងក្លា ទ្រង់សម្ងឹងឆ្ពោះព្រះនាងតិស្សរក្សិតាមិនដាក់ព្រះ
នេត្រាហើយត្រាស់ថា:

" ហនឯងឯងចំលាយក្អែកកូនអញ, អញទំនវែកហួរខ្លួនហនឯង
ដោយត្រចកឥឡូវនេះ, អញទំនចាក់ហនឯងឯងទាំងរស់ដោយឈើអណ្តាត
ហើយលើកសួយឡើង ដាក់ទៅលើចុងឈើដ៏ខ្ពស់, អញទំនច្រែកខ្លួន
ហនឯង ដាចម្រែកៗដោយរណារ, អញទំនតាត់អណ្តាតហន ដោយ
កាំបិត, អញទំនក្រែបលង្ហិនហន ដោយភួរថ្មដ៏ធំខានមុខតាលគម្រឹល,
អញទំនចោះចោលខ្លួនហនទៅកន្លែងគុកភ្លើង; អញទំនបង្អកមាត់ហន
ដោយថ្នាំពិសពុលដ៏ក្លាច្រើនម៉ុង" ព្រះអង្គបុំនបំនទំនធ្វើអាឃាតព្យា-
បាទច្រើនបែបដូច្នេះ ។

ព្រះកុមារកាឝរាស ដាបហេតុនោះហើយ ទ្រង់មានព្រះហឫទ័យ
ពេញទៅដោយមេត្តាករុណា ព្រះអង្គក្រាបទូលព្រះវរបិតាថា "ព្រះនាង
តិស្សរក្សិតា បានប្រព្រឹត្តទុច្ចរិតធមិហើយ ព្រោះហេតុនោះបានជានាង
ធ្វើឫកពាដូច្នេះ, ឧព្រះពជា! ពេលនេះសូមព្រះអង្គទ្រង់អនុញ្ញាតព្រះ
អាជ្ញាដោយធមិ ព្រះអង្គមិនសមគួរទំនពិឃាតព្រះនាងឧះទេ សូមទ្រង់

កុំមានព្រះហឫទ័យក្រែងគាន ទើបការសំខ្ចីនឹងឆ្ពោះមកពួកកូនទើបពួកសត្វដែលឋោកគាបអាប់ឥតច្បាស្ប"(๑) ។

តែស្តេចមិនទ្រង់ស្តាប់តាក្យព្រះពជបុត្រ ទ្រង់ឲ្យចាត់ចែងកន្ទែងសម្រាប់តំរោត ហើយឲ្យនាំព្រះពជនីះទៅដុតក្តៅទាំងរស់ ព្រមទាំងអ្នកទតរកស្រីសិលា ដែលជាអ្នកចូលដៃក្នុងការប្រព័ត្តិបទល្មើស ដ៏ទៃក្តីនោះ ក៏ស្មាប់រំខាសជាមួយគ្នាក្នុងគ្រានោះទៅ ។

គ្រានោះកើតទាំងខ្លាយ បានឃើញហេតុអស្ចារ្យចំឡែកដូច្នោះ ក៏កើតសេចក្តីសង្ស័យឡើង ទើបនាំគ្នាសួរហេតុនេះចំពោះនឹងព្រះថេរៈបតុប្តថា "ព្រោះហេតុអ្វីក៏គេឆ្ងល់ព្រះខេត្តព្រះកុមារពជនុរសក្នុងបច្ចុប្បន្ននេះ?"

ព្រះថេរៈតបថា "អ្នកទាំងខ្លាយបួរតាំងសោតប្រសាទ្រុងស្តាប់ខ្ញុំ។ នឹងសំដែងប្រាប់ដល់ពួកអ្នក ក្នុងអតីតកាល មានព្រាន២ព្រួកម្នាក់ទៅក្រុងពារាណសី ព្រានទាំងនោះនៅជាមួយនឹងពួកមនុស្សតែក្នុងគិម្ហរដូវ

---

๑ ចំណែកខាងព្រះពុទ្ធសាសនា បានត្រាស់ទូលតាក្យសង្ស័យនេះដល់ព្រះពជាថា "សូមទេវៈ ខ្ញុំព្រះអង្គមិនបានដឹងថាមានសេចក្តីឈឺចាប់ទេ សូម្បីការទទួលទុក្ខលំបាកអត់ធន់ដោយយើងតិចតួចក៏មានក្នុងខ្លួនខ្ញុំព្រះអង្គដែរ ក្នុងចិត្តរបស់ខ្ញុំព្រះអង្គ មិនមានអ្វីក្រៅពីតម្កល់ចំពោះព្រះមាតា ដែលលោកបានធ្វើឲ្យទ្វាក់ភ្នែករបស់ខ្ញុំព្រះអង្គ ដើម្បីដាច់ផ្តាស់សម្លឹងឃើញជាក់ឱ្យស់នូវពាក្យស្ង័យនេះ សូមឲ្យភ្នែករបស់ខ្ញុំព្រះអង្គចូរត្រឡប់បានដោយសុទស្សនៈដូចដើមវិញ ។ ព្រាន់តែព្រាស់ចប់ភាន់ស្ទុះពីក្រោមទ្រូង ព្រះនេត្រាក៏កើតត្រចាងឡើងវិញត្រឹមដោយលំអទាំងអស់ដូចពីមុន ។

លុះដល់ហេមន្តរដូវ តែងតែទៅបរបាញ់សត្វក្នុងព្រៃកំពុង ដើរកុកនឹងខ្នាតសត្វចេកល្អកដងព្រៃរហូតដល់ហិមវន្តបរិភោគ ។ ពេលនោះបួនជាមានក្តៀងរំលោភអស្ចារ្យ ធ្លាក់ព្រិលសស្វាចដេរដាសពាសពេញផែនដី គឺពួកសត្វម្រឹគចាំង ៥០០ រត់ចូលតាមគ្នាត្រសុកទៅក្នុងរោងថ្មធំមួយ ព្រានព្រៃឃើញដូច្នោះហើយក៏គិតថា "បើអញសម្លាប់ម្រឹគចាំងអស់តែម្តងទៅសាច់វាធំធាត់ស្អុយរួច បើដូច្នេះអញនឹងធ្លៀលតែកក់ចេញហើយអញនឹងស៊ីម្រឹគចាំងនោះម្តងមួយ ១ កល់ថ្ងៃ ៧" ។

លុះគិតដូច្នោះហើយ ក៏ចាប់ធ្លៀលតែកម្រឹគចាំង ៥០០ ឲ្យខ្លាចាំងអស់គ្មានសល់ ។ ដល់មកឥឡូវនេះ ព្រោះតែអំពើនោះឯងបានជាត្រូវគេធ្លៀលតែក ។ ព្រានព្រៃកាលនោះ គឺព្រះកុនាលភជទាសនេះគាំងតែពីកាលនោះមករហូតដល់ថ្ងៃនេះ ព្រះកុនាលហ្នឹងឯងមានទោសត្រូវគេធ្លៀលតែកអស់ ៥០០ ជាតិមកហើយ" ។

គ្រូកាំងឮយ៉ាងនេះសួរទៀតថា "ព្រោះហេតុដូចម្តេច ក៏ព្រះកុនាលភជទាសបានកើតក្នុងកំណើតត្តិរច្ឆានកំណើតមានរូបរាងដ៏ល្អហើយបានត្រាស់ដឹងនូវអរិយសច្ចនឹងមគ្គផល ?' ។

ព្រះថេរៈឧបគុប្តតបថា "កាលអតីតកាល គ្រានោះពួកមនុស្សមានអាយុវែងដល់ប្លែនហ៊ីនឆ្នាំ មានព្រះពុទ្ធមួយព្រះអង្គ ឧប្បត្តិឡើង ព្រះនាម

ព្រះកកុសន្ធ កាលព្រះអគ្គទ្រង់បំពេញតុទ្ធកិច្ចស្រេចហើយ ស្តេចចូលកាន់បរិនិព្វានជាអនុបាទិសេសនិព្វានធាតុ គ្មានព្រះកជាមួយព្រះអគ្គទ្រង់ព្រះនាមសោភៈ(*) ទ្រង់គោរពចំពោះព្រះពុទ្ធអគ្គនោះ បានប្រោសឲ្យសាងព្រះស្តូបមួយ ប្រដាប់ដោយកែវដ៏ប្រសើរចាំង ៧ ប្រការ សុទ្ធសឹងតែមានដំឡៃ មានស្ថានផ្ទៃគ្រាមបួនផ្ទួង ក្នុងមួយផ្ទួងចំពាំ ៤០ លី (មួយយោជន៍) ។ តែកាលជាខាងក្រោយអំពីព្រះបាទសោភៈនោះទៅឆ្ងាតទៅ មានស្តេចមួយព្រះអង្គទៀតទ្រង់ព្រះនាមអសទ្ធម្មអត្ថមនដ្ឋីសាសនា ស្តេចអង្គនោះបានតាស់ឥតការ យកកែវដ៏ប្រសើរសុទ្ធសឹងតែមានដំឡៃអំពីព្រះស្តូបអស់លើងរេងៗ ទុកឲ្យនៅតែដីទំនងឈើប៉ុណ្ណោះ ។ អ្នកខនតាំងឡាយបានឃើញដូច្នោះក៏ប្រជុំគ្នាជាពួកជាកងនៅទីជិតព្រះស្តូប ទាំងគ្នាយំសោកស្តាយឆ្អែតចិត្តនឹកឱនតែសព្វខ្លួន កាលនោះមានកុលបុត្រម្នាក់ឃើញហេតុដូច្នោះទើបសួរថា "ដូចម្តេចក៏ខនតាំងអ្នកកាលំគ្នាយំ? អ្នកខនតាំងឡាយតបថា "ព្រះស្តូបនៃព្រះពុទ្ធជាម្ចាស់ដែលគេសាងដោយកែវដ៏ប្រសើរចាំង ៧ ប្រការ សុទ្ធសឹងតែមានដំឡៃដ៏រុងរឿង, ខេះនែអ្នកមើលចុះ គ្រាវគេចំណាយបង់ តាស់ឥតការយកកែវដ៏ប្រសើរចាំង ៧ ប្រការ សុទ្ធសឹងតែមានដំឡៃអស់រលីង

---

* ក្នុងទីក្រោយៗ ទ្រង់ត្រូវនាមតែសោភ តែមិនមែនព្រះបាទសោភដែលជាព្រះបិតារបស់ព្រះពុទ្ធសាក្យមុនីទេ គឺស្តេចអង្គសោភកាលពីព្រេងនាយទៅទៀត ។

ឆេងទុកឲ្យនៅតែដដែ. ទីឆ្ងាយប៉ុណ្ណោះ; ព្រោះដូច្នោះបានជាយើងយំ" ។
រីឯនោះកុលបុត្រនោះ ក៏បានកសាងជួសជុលព្រះស្តូបនោះ ដោយកែវ
ដ៏ប្រសើរចាំង ៧ ប្រការ សុទ្ធសឹងតែមានដំឡៃ ហើយស្អិតស្អាងដូច
ដើមឡើងវិញ ព្រមទាំងបានសាងព្រះពុទ្ធបដិមាករ មានព្រះបូបភាព
ដូចសុទ្ធសាធតៅទីឆ្ងាយព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះនាមតកុសន្ធអគ្គនោះ
ហើយបានតាំងសេចក្តីប្រាថ្នាក្នុងពេលនោះដូច្នេះថា "សូមអំណាច
កុសលនេះតទៅអនាគត ចូរបណ្តាលឲ្យខ្ញុំបានដូចព្រះពុទ្ធជាម្ចាស់អគ្គ·នេះ
ខ្ញុំសូមឲ្យបានត្រាស់ដឹងនូវធម៌ដ៏ប៉ិយវិសុទ្ធវិសេស គឺអមតមហានិព្វាន" ។
ក៏កុសលដែលព្រះកុនាលភជនុសេបានកសាងព្រះស្តូបដោយកែវដ៏ប្រ-
សើរក្នុងកាលណោះ ទើបនាំឲ្យបានកើតក្នុងត្រកូលដ៏ខ្ពង់ខ្ពស់ ហើយមាន
រិទ្ធិអំណាចក្នុងកាលបច្ចុប្បន្ននេះ ព្រោះតាលពីអតីតបានកសាងព្រះពុទ្ធ-
បដិមាករ ទើបមានព្រះបូបទោមល្អក្នុងបច្ចុប្បន្ននេះ សេចក្តីប្រាថ្នាដែល
ព្រះកុនាលភជនុសេ បានដាស់តុនហើយកាលពីអតីត ទើបបណ្តាល
ឲ្យបានត្រាស់ដឹងនូវផ្លូវនៃអរិយសច្ចក្នុងកាលឥឡូវនេះ ។

អានិសង្សនៃផ្លែកន្ធត្រៃមួយបំហៀង

កាលព្រះបានអនុមោទនាប្រសាទសទ្ធាដែរថា ក្នុងព្រះពុទ្ធ-
សាសនាហើយ ស្តេចទ្រង់ត្រាស់សួរព្រះថេរៈបគុប្តក្នុងហេតុនោះថា

"កន្លងជាន់ពុទ្ធកាល មានអ្នកណាជាពុទ្ធមាមក: បានបរិច្ចាគទានច្រើនជាងគេបំផុត ?

ព្រះថេរៈបត្តុប្បថ្វាយព្រះពរតបថា "ជាតិត្រមាកជ មានគហបតីម្នាក់ឈ្មោះសុទត្ត[1] បានបរិច្ចាគទានច្រើនជាងគេបំផុត" ។

ព្រះចាទអសោកត្រាស់សួរថា មានដែលគេបរិច្ចាគនោះជាចំនួនប៉ុន្មាន ?

ព្រះថេរៈបត្តុប្បថ្វាយព្រះពរថា "ចំនួនមាសមួយរយកោដិ" ។

ព្រះចាទអសោកទ្រង់ព្រះជម្រិះថា "គ្រាន់តែគហបតីគេអាចធ្វើទានអស់ទ្រព្យច្រើនម្ល៉ោះទៅហើយ ចំណង់បើខ្លួនអញ ឥឡូវបានសោយរាជ្យជាឥស្សរៈលើជម្ពូទ្វីបទាំងមូល, ម្តេចក៏បរិច្ចាគទានមិនបានជាន់ជល់នឹងគេ" ។

ទ្រង់ព្រះតំរិះដូច្នេះហើយ ព្រះអង្គបានបរិច្ចាគខ្លួនព្រះអង្គមូលព្រមទាំងព្រះកុនាលរាជទេវី ពួកសេនាបតីរបស់ព្រះអង្គនិងព្រះរាជទានធន

---

๑ ក្នុងអប្បៈដំណើរ គហបតីឈ្មោះអនាថបិណ្ឌិក ។ គេដឹងថាសុទត្តក្តី អនាថបិណ្ឌិកក្តី ទាំងពីរឈ្មោះនេះជាតាមទេសភាសាម្នាក់ ។ ក្នុងភាសាបាលីក៏ប្រាប់ថា "សុទត្ត:" ជាឈ្មោះដើម តែកាលពីដំបូងវាច្រើនថ្ងៃក្នុងពុទ្ធសាសនាហើយ បានបរិច្ចាគទានលើសលុបណាស់ ទើបបានគុណទេមិត្តតាមជាថ្មីថា "អនាថបិណ្ឌិក" ប្រែថាជាអ្នកឲ្យដុំបាយដល់មនុស្សអនាថា ឯភាសាថា "សុទត្ត:" ប្រែថា "ជាអ្នកឲ្យល្អ ឬឲ្យដោយងាយ" ឃើញបានសេចក្តីថាចិត្តខ្ពស់ដូចគ្នាដែរ ល្មមជាឈ្មោះហៅដំណូសគ្នាបាន ។

ដល់ព្រះអរិយសង្ឃ ខ្ញុំបានឲ្យសាងព្រះស្តូប ៨៤.០០០ ស្មុខ្ពស់ដំណែវត្តដ៏មានដំណៃ ព្រមទាំងព្រះស្តូបទាំងឡាយសម្រាប់ពួកព្រះអរហន្តជាសាវក ខ្ញុំបានឲ្យស្រោចដើមពោធិព្រឹក្ស បូករួមចំនួនព្រះពាជខ្ញុំឲ្យដែលព្រះអង្គបានព្រះពាជទានទាំងអស់ត្រូវជា មាស ៨៦ កោដិដំឡឹងគ្រានោះព្រះបាទអសោកខ្ញុំបែរឈ្លួនជាខ្មួន ព្រះអង្គបានជ្រាបថាខ្ញុំនឹងខ្ញុំនៅវង្គតដោយព្រះរោគនោះ ស្តេចជាទុក្ខព្រួយព្រះពាជហ្ឫទ័យជាខ្លាំង ទើបខ្ញុំព្រះករុណាសោកស្តាយក្រែងមិនបានសម្រេចដូចព្រះចិន្តា ។

អំពីអតីតកាល គ្រានៅដែលព្រះបាទអសោកបានធ្វើទានដោយដំមួយភ្លាប់នោះ ពាធគុប្តដែលជាសំឡាញ់ឋិតនៅដិតខាង បានជួយអនុមោទនាផង លុះដល់មកជាតិជាបច្ចុប្បន្ននេះ បានមកជាសេនាបតីមួយរបស់ព្រះបាទអសោកវិញ ក៏ពាធគុប្តឯកអគ្គមហាសេនា បានឃើញព្រះពាជាខ្ញុំជាទុក្ខព្រួយព្រះពាជហ្ឫទ័យដូច្នោះ ទើបប្រណម្យត្រពុំអញ្ជលីហើយទូលថា "បពិត្រមហាពាជ ឫទ្ធានុភាពនឹងអំណាចរបស់ព្រះអង្គត្រូចៅលើផែនដី ប្រៀបដូចជាវស្ស័នៃព្រះអាទិត្យ ពួកមនុស្សទាំងអស់ឥតមានអ្នកណាមួយហ៊ានក្រឡែកមើលចំព្រះភក្ត្រព្រះអង្គឡើយ" ។

ម្នាលព្រះពាជា ! មានតែពួកស្ត្រីទាំង ៩៤.០០០ ប៉ុណ្ណោះទើបហ៊ានមើលចំព្រះភក្ត្រព្រះអង្គ ការដែលខ្ញុំបែរឈ្លួននេះ ក៏ហាក់ដូចជា

ព្រះភិក្ខុទៀបនឹងអស្តង្គតទៅ ដូច្នោះលោកចាំង ៣ តែងតែប្រព្រឹត្ត
ប្រែប្រួលទៅជានិច្ច ពួកសត្វលោកត្រូវតែឈឺចាប់នឹងស្លាប់ជាធម្មតា
សូមទ្រង់ពិចារណាទូរអនិច្ចតាធម៌ ប្រយោជន៍អ្វីនឹងទ្រង់ជាទុក្ខព្រួយ
ព្រះកដហ្លួងយ៉ាងនោះ ។

ព្រះមហាក្សត្រត្រាស់តបថា "ខ្ញុំយំសោកពេលនេះ មិនមែន
ព្រោះភ្ញាក់រឭកនៃពាក្យសម្បែយយសទេ, ខ្ញុំជាអ្នកមានទុក្ខព្រួយនោះ មិន
មែនព្រោះតែត្រូវលះបង់ជីវិតនោះទេ ខ្ញុំខ្លាចខ្លួលំដួលចិត្តនោះ មិន
មែនព្រោះភ្ញាក់ឃ្លាតចាកមាតុត្រាមនឹងយ៉ាងព្រះកដទ្យរបស់ខ្ញុំទេ
ដោយសេចក្តីពិតនោះ ខ្ញុំមានសេចក្តីទុក្ខព្រួយនេះព្រោះនឹងត្រូវឃ្លាត
ចាកព្រះអរិយសង្ឃចាំងឡាយ ដែលខ្ញុំថ្វាយទានឲ្យគ្រប់
ចំនួនមាសមួយរយកោដិ ខ្ញុំបានឲ្យទានទៅហើយតែត្រឹម ៩៦ កោដិ
នៅខ្វះ ៤ កោដិទៀត ព្រោះដូច្នោះបានជាខ្ញុំកើតទុក្ខគានតឹងក្នុងចិត្ត" ។

ពលគុប្តឯកអគ្គមហាសេនាបតីក្រាបទូលថា "ឃ្លាំងព្រះកដទ្យ
ចាំងឡាយ របស់ព្រះអង្គនៅមានច្រើន គួរតែព្រះអង្គបំពេញទាន
នោះ ឲ្យគ្រប់ចំនួនទៅតាមសេចក្តីថ្វាយរបស់ព្រះអង្គ" ។

គ្រានោះស្តេចទ្រង់ព្រះកដទានមាស, ប្រាក់នឹងរបស់មានដទៃ
ឯទៀតៗ ជាច្រើនបញ្ជូនទៅដល់វត្តកុក្កុដារាម ។

កាលនោះព្រះសម្បទីជាឧរសនៃព្រះកុនាលកជបុត្រជាន់ដួងចាយាទ (អ្នកទទួលគ្រងមគធកក្នុងភពសម្បត្តិ) មានពួកសេនាបតីចំក្តុអាក្រក់ជាមិច្ឆាទិដ្ឋិ ជាន់ចូលទៅក្រាបទូលព្រះអង្គម្ចាស់សម្បទីថា "ព្រះបាទអស្សោកជិតអស់ព្រះជន្មហើយ សូមទ្រង់ទតមើលចុះ ន៎ុះហ្ន៎! ព្រះពជាទ្រង់បង្គិនព្រិះឃ្លាំង កំពុងតែឲ្យគេតើបខ្លះឆ្លាយនៅសព្រះពជទ្រព្យអស់ហើយ កាលបើព្រះអង្គនឹងជាន់ស្តេច គោង្គាគាត់ឲ្យព្រមទាំងព្រះពជទ្រព្យដ៏មានដំឡៃនោះឯង នឹងជាន់លើកដាក់ដំរកើនព្រះអង្គ ឲ្យជាស្តេចថ្កើងរុងរឿង ព្រោះដូច្នោះគួរតែទ្រង់បញ្ជាក្តុំឲ្យគេបង្គិនព្រះពជទ្រព្យនោះទាំងអស់" ។

ព្រះអង្គម្ចាស់សម្បទីលុះទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ក៏ទ្រង់យល់ព្រមតាមសេចក្តីពន្យល់របស់ពួកអាមាត្យ ក៏ទ្រង់ដកហូតយកព្រះពជទ្រព្យទាំងអស់របស់ព្រះពជា ដែលស្តេចកំពុងតែប្រឈួន ហើយមានព្រះហឫទ័យកំពុងជ្រះថ្លាយ៉ាងនោះ ទុកឲ្យនៅសល់តែភាជន៍មាសមួយនឹងភាជន៍ប្រាក់មួយប៉ុណ្ណោះ ដែលជាវត្ថុសម្រាប់ដាក់ព្រះក្រយាស្មោយព្រះពជាកាលទ្រង់ទទួលភាជន៍សោយស្រេចហើយ ក៏ទ្រង់បញ្ជូនភាជន៍ទាំងនោះ ព្រះពជាទៅវត្តកុក្កុដារាមវិញ ។ ខណៈនោះគេដាក់ព្រះក្រយាស្មោយក្នុងភាជន៍ដ៏ថ្លាយឲ្យទ្រង់សោយ ។ ក្នុងបច្ចុប្បន្នវារៈគេបានថ្លាយផ្លែកន្ទួតវិញមួយចំហៀងដល់ព្រះពជា ព្រះអង្គកាលបានទទួល

ផ្ទះឈើនោះហើយ ស្តេចឲ្យប្រជុំពួកអាមាត្យ ហើយត្រាស់នឹងវត្រះរាជា
ម្នាក់គួរឲ្យស្មុតចំគ្គថា អ្នកណាជាម្ចាស់នៃជម្ពូទ្វីបនេះ ? ។

ពួកអាមាត្យទូលតបថា "ទុព្រះរាជា! ព្រះអង្គតែមួយ ទ្រង់ជាម្ចាស់
នៃជម្ពូទ្វីបនេះ" ។

ព្រះរាជាជ្រាបដូច្នោះហើយ ទ្រង់ត្រាស់នឹងពួកអាមាត្យដោយព្រះ
នេត្រពោញទៅដោយអស្រុវលថា "អ្នកចាំងឡាយកាន់ប្រទូរទេ ដែល
ថាខ្លួនខ្ញុំជាម្ចាស់នោះ ខ្លួនខ្ញុំមិនមែនជាម្ចាស់ទេ ព្រោះហេតុអ្វី ព្រោះថា
ខ្ញុំជាកជាធិបតី ចុងតែត្រឹមលើផ្ទៃកន្ទុតតៃត្រមួយចំហៀងនោះឯង(១) ។
នុអនិច្ចាអើយ ទ្រព្យសម្បត្តិចាំងឡាយ ជាវេរស់ចោកចាបឥតប្រយោជន៍
គ្មានគេកប់ សូម្បីតែខ្លួនឯងជាឥស្សរលើមនុស្សចាំងឡាយ គង់ភ្លាត់
ខ្លួនទៅជាអ្នកខ្សត់ខ្សោតផុតចាកអំណាចទៅវិញបាន ពេលនេះខ្ញុំនៅ
មានត្រឹមតែផ្ទៃកន្ទុតតៃត្រមួយចំហៀងនេះ ប្រៀបដូចជាទន្ទេដែលមានខ្សែ
ទឹកជំនន់ភ្លាំងភ្លា កំពុងតែហូរភ្លាត់ជ្រុលបុះមកគគុកគគាក់ហើយត្រឡប់ទៅ
ជាឈប់នៅនឹងថ្កល់ ក្នុងកាលដែលផ្ទប់ស្ទុះនឹងគ្គំណាមួយដូច្នោះ" ខណៈ
នោះទ្រង់ត្រាស់នឹងវត្រះគាថាចាំងឡាយតទៅនេះថា:

---

១ វិស្មុទ្ធិមគ្គ: ព្រះបាទអសោកនោះ ទ្រង់សោយឥស្សរភាពលើផែនដីចាំងមូល · បាន
បរិភោគចាន់ចាំងរយកោដិ ព្រះអង្គធ្លាប់បានទទួលសេចក្តីសុខ លុះដល់ដិតទីវិនិត្តទ្រង់ជាធំបាន
តែត្រឹមផ្ទៃកន្ទុតតៃត្រមួយចំហៀងប៉ុណ្ណោះ កាលបើព្រះអង្គអស់បុណ្យហើយ ក៏ត្រឡប់ទៅជា
សោយសោក ព្រោះតែចំណង់រូបតែពាងកាយ ពីរោងសម្បត្តិនោះឯង ។

"ព្រះវាចាដ៏ឆ្ងាយរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ជាពាក្យត្រូវពិតប្រាកដណាស់ ក្នុងព្រះវាចាដ៏ឆ្ងាយរបស់ព្រះអង្គនោះ មិនមានពាក្យត្រង់ណាមួយដែលមិនពិតទេ ព្រះអង្គបានត្រាស់ព្រះពុទ្ធដីកាហើយថា "ពួកអ្នកដែលស្រឡាញ់ពុកចិត្តគ្នា ជាហេតុនាំមកនូវសេចក្តីក្តៅក្រហាយគ្នាជាទីបំផុត" ។

កាលពីដើមគែកាលណាខ្ញុំចេញប្រតាស់ប្រញាក្តុតៅលើកិច្ចអ្វីនីមួយ ហើយឥតមានអ្នកណាមួយខឹងឥតអាជ្ញាទេ ឥឡូវនេះខ្លួនខ្ញុំដូចជាខ្សែតដ៏ខ្លាំងក្លា តំពូនតែហូរធ្លាក់ជ្រលុះមកតគុកតគាក់ ស្រាប់តែទៅជួបស្នេះទឹកក្តាណាមួយហើយតាំងនៅទឹងថ្កល់យ៉ាងណា ក៏ពាក្យសំដីរបស់ខ្ញុំតាំងប៉ុន្មាន ឥឡូវនេះតាំងនៅទឹងថ្កល់មិនសម្រេចប្រយោជន៍អ្វីដូច្នោះដែរ ។ កាលពីមុននៅលើប្រថព័មណ្ឌលនេះ ខ្លួនខ្ញុំជាខ័ពិងទឹងជាម្ចាស់របស់មនុស្សតាំងអស់ ពួកស្តេចណាជាសត្រូវ មានចិត្តព្រហើនកាចរឹងរឹងរូស ខ្ញុំអាចបង្ក្រាបពួកស្តេចតាំងអស់នោះឲ្យនៅត្រាមអំណាចបាន ពួកមនុស្សណាជាអ្នកខ្សត់ទុគ៌តទន់ជាអ្នកទុព្វលភាព ខ្ញុំអាចជួយទំនុកបំរុងពួកមនុស្សតាំងអស់នោះបាន ។ កន្លងកាលមុន ខ្លួនខ្ញុំជាខ័ពិងនៃពួកមនុស្សឯទៀតជាច្រើន ឥឡូវនេះអំណាចរបស់ខ្ញុំ គេជាត់ជាត់ចោលអស់ហើយ ខ្លួនខ្ញុំប្រៀបដូចជារនេះមួយ ដែលគេរុះរើចេញអស់ទុកឲ្យនៅសល់តែទ្រពន់ ពុំនោះសោតដូចជាអសោកព្រឹក្សា កាលបើឫស

ពាន់ឆ្នាយរបស់ក់ស្តួតហើយ មែកពាន់ឆ្នាយក៏គេកាប់អស់បេញហើយ ឯផ្លា, ផ្លែ, មែកនឹងស្ទឹតពាន់អស់នោះ គេចរៀណារួចមុខជានឹងស្ងួត ស្រពោនហួតហែងរៀមិនខាន ។ ខ្ញុំឮភាតចាកបង្គោលដែលជាបង្អែក សម្រាប់ពាំងផ្អែកអស់ហើយ ព្រះពជ្ឈារបស់ខ្ញុំពាំងប៉ុន្មាន ក៏សុទ្ធតែជាសំបុត្រស្ងាប់ឥតប្រយោជន៍ពាំងអស់" ។

លុះខ្ញុំគ្រាស់គាថានេះចប់ហើយ ព្រះអង្គគ្រាស់ហៅពជបុរសអ្នកតាល់ក្នុងខ័ណ្ឌព្រះអង្គមក ខ្ញុំប្រទានកន្ទុតព្រៃមួយចំហៀង ហើយថ្លែងព្រះធម្មាថា "ចូរឯងយកផ្លែឈើនេះរៀតាន់វត្តកុក្កដាគម ឯងប្រគេនដល់ព្រះសង្ឃក្នុងវត្តនោះ ហើយឯងនឹងបានឮព្រះធម៌ថា ទេយ្យវត្ថុនេះជាខាងកាន់ក្រោយបំផុតរបស់ស្តេចអសោក ពេលនេះព្រះអង្គនៅមានផ្លែកន្ទុតព្រៃមួយចំហៀងប៉ុណ្ណោះ ខ្ញុំនឹងសងពាក្យព្រះពជ្ឈព្យ ដែលមានពាំងប៉ុន្មាននោះអស់ហើយ សូមព្រះសង្ឃទទួលយកដោយមេត្តាចិត្ត ចំពោះបច្ចុប្បន្នរបស់ស្តេចកំសត់ទុគ៌តនេះ ដែលជាអ្នកចំណែកតែសាច់កុសលយកផលអំពីទាននេះតែប៉ុណ្ណោះ" ។

លុះពជបុរសយកទៅប្រគេនដល់ព្រះសង្ឃ ត្រមពាំងផ្លែឆ្នាយព្រះធម្មារ ដោយសព្វគ្រប់ គំព្រះយសត្ថេរបានប្រកាសប្រាប់ដល់ដំខុំសង្ឃថា "អ្នកពាំងឆ្នាយបានឃើញ បានស្គាល់ព្រះបាទអសោកច្បាស់លាស់ហើយ ខ្ញុំដូចប្រសព្វតែសេចក្តីសុខនឹងសេចក្តីសោមនស្សតែម្យ៉ាងខ្ញុំផ្សាយ

ឥស្សរភាពរបស់ព្រះអង្គទៅលើប្រថពីមណ្ឌល មានសមុទ្រជាព្រំប្រទល់ ឥឡូវនេះត្រូវពលបរិពាររបស់ព្រះអង្គរំបងាន់យកឫទ្ធិអំណាច ធ្វើឲ្យសាច សូន្យពីព្រះអង្គអស់ទៅ ជនហួតយកព្រះពលទ្រព្យរបស់ព្រះអង្គអស់ គ្មានសល់ ធ្វើឲ្យព្រះអង្គមានតែខ្លួនទេ នៅមានត្រឹមតែផ្ទៃកន្ទុតតែមួយ ចំហៀងនេះដែលទ្រង់បានព្រះពលពានមកដោយស្ម័គ្រព្រះពលហ្លួចយ ចំពោះដល់សង្ឃព្រះពលពានដល់ព្រះគ្រឹស្តសង្ឃក្នុងពេលនេះ ដោយទ្រង់ មានព្រះពលហ្លួចយធ្ងន់ផ្ទៃ ដើម្បីនឹងបញ្ជាចិត្តដល់ពួកពលបរិពាររបស់ ព្រះអង្គ ។ ទើបព្រះថេរៈបានចាត់ឲ្យតាយកម្នាក់បុកកំរេចផ្ទៃឈើនោះ ឲ្យល្អិតជាដង់ដាក់លាយទៅក្នុងបបរ ដើម្បីឲ្យគ្រឹស្តាំងអស់បានចំណែក ពាននោះគ្រប់ៗគ្នាហើយ ព្រះថេរៈបានប្រាប់គ្រឹស្តាំងឡាយថា "អ្នកទាំង-ឡាយគួរដឹងខ្លួនថា ហេតុនេះជាកិច្ចសម្រាប់ផ្លូវសង្ឃ ដែលជាធម្មជាតគួរ ខឿយណាយ ខ្ពើមរអើមឲ្យណាស់ ទ្រព្យសម្បត្តិទាំងឡាយតាមគុណទាំង-ឡាយរមែងអន្តរាយបាត់ទៅភ្លាមៗឈឹង! សង្ឃារវង្សនេះពេញជាគួរឲ្យ ខឿយណាយចិត្តពេកណាស់ ហើយជាធម្មជាតនាំមកនូវសេចក្តីទុក្ខព្រួយ ជាខ្លាំងបំផុត" ។

ប្រពៃណីនេះក្តីឲ្យយើងដឹងបានថា "ឋណ្ណាស្តេចទាំងឡាយដែល ជាតំណតព្រះវង្សមក ពួកស្តេចដែលមានឫទ្ធានុភាពបរិបូណ៌ដោយពល-សម្បត្តិទាំងអស់នោះ ក៏មិនស្ថិតនឹងព្រះពុទ្ធសាសនានេះឡើយ ល្អិតណា

ពួកពលអាមាត្យរបស់ព្រះអង្គដួយការពារយ៉ាងណា តំគង់តែនៅសល់ឯង កាលបើយើងនៅមានកម្លាំងកំហែង មិនខាន់ជាក់ស្តែងក្នុងសេចក្តីពុក្នុនៅឡើយទេ យើងគួរតែខំប្រឹងព្យាយាមឲ្យគេញាប់ខ្នុក ដើម្បីឲ្យបានសម្រេចកុសលជាសុខតទៅ" ។

កាលដែលទ្រង់ខ្សោយថយព្រះកាយពល ទៀបរលត់ទំនួហើយ ព្រះបាទអសោកបានត្រាស់ទំនឹងពជគុប្តសេនាបតីថា "ឥឡូវនេះអ្នកណាជាម្ចាស់ធំជាងគេបណ្តាចក្កដ្ឋដ្ឋទ្វីបនេះ" ។

ពជគុប្តសេនាបតីក្រាបចុះទៀបព្រះបាទាហើយ ទើបទូលតបព្រះមហាក្សត្រថា "បពិត្រព្រះករុណាជាម្ចាស់ដ៏វិសេសលើត្បូង ព្រះអង្គទ្រង់ជាម្ចាស់ធំជាងគេបណ្តាច ?" ។

លុះទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ស្តេចតើនឡើងបាតក្រឡាព្រះបន្ទំថ្ងៃណាម្សិលអញ្ចឹង ទ្រង់ទតមើលគ្រប់ទិសទាំង ๔ ហើយថ្លែងនូវពាក្យនេះថា "វៀរលែងតែឃ្លាំងខ្ញុំចេញ ខ្ញុំសូមថ្វាយប្រថពីមណ្ឌលទាំងមូលដែលមានមហាសមុទ្រទាំង ๔ ជាព្រំប្រទល់ដល់ព្រះពុទ្ធជាម្ចាស់ទំនឹងព្រះអរិយសង្ឃ ។ ដោយអំណាចបុញ្ញកុសលជាគ្រឿងដែលខ្ញុំបានបំពេញហើយនេះតទៅអនាគត ខ្ញុំមិនប្រាថ្នាចង់បានជាស្តេចចក្រពត្តិទេ មិនប្រាថ្នាជាព្រះឥន្ទ ជាព្រះព្រហ្ម ជាលោកាធិបតី ឬជាខេត្តាទេ តែខ្ញុំសូមតាំងដំកល់សេចក្តីប្រាថ្នាថា តទៅអនាគតកន្លងពេលដែលខ្ញុំនឹងបានទៅកើត

ក្នុងជាតិណា ។ ខ្ញុំសូមឲ្យបានត្រៃត្រង់ខ្លួនដោយអំណាចខ្លួនឯង ហើយ
ខ្ញុំសូមឲ្យបានសម្រេចព្រះអរហត្តផលឲ្យបានឆាប់រហ័ស" ។ ខណៈដែល
ទ្រង់ត្រាស់ប្រទានព្រះបណ្ដាំនេះ ព្រះអង្គឲ្យប្រថាប់ព្រះពាសនុស្ការនោះ
ដោយព្រះវិលញ្ជកវន៌ព្រះទន្តរបស់ព្រះអង្គ ទ្រង់ប្រគល់ឲ្យទៅពាធគុប្ត
សេនាបតី កាលព្រះអង្គបរិច្ចាគទាននេះដល់ព្រះសង្ឃរួចហើយ ក៏ព្រះ
ភ្លុយរបស់ព្រះអង្គស្រូតថយចុះទៅជាដកបហើយទ្រង់សោយព្រះទំវង្គត
ក្នុងពេលនោះទៅ ។

ពួកសេនាបតីនាំគ្នារៀបចំព្រះបរមសពទៅតាមរបៀបស្ដេចចក្ក-
ពត្តិពាធ ចាត់ឲ្យតាក់តែងគ្រឿងសំអាងគ្រប់ប្រដាប់ទៅតាម
ក្រសួង ដើម្បីជាទីគោរពដល់ព្រះបរមសព ហើយរុំសំពត់ស្នបជាក់
ដំកល់ក្នុងព្រះមឈូស បូជាបរមសពតាមទំនៀម ។

គ្រានោះពួកសេនាបតី ចានអតិសេកព្រះអង្គម្ចាស់សម្បទីឲ្យឡើង
គ្រងសោយរាជ្យជាដំណាងព្រះអង្គតមក ។

ពាធគុប្តសេនាបតីចានថ្វាយដំណឹងនោះដល់ពួកអាមាត្យថា "ព្រះ
ចាទអសោកចានព្រះពាសនប្រថព័ម្ភលចាំងមួល ដល់ព្រះសង្ឃ
ហើយ ព្រោះអ្វី? ព្រោះថាព្រះអង្គថ្វាយទីដំបូងការបរិច្ចាគឲ្យគ្រប់
ចំនួនមួយរយគោដិ ឲ្យបានដូចជាតហបតីឈ្មោះសុទត្ត តែព្រះអង្គចាន

បរិច្ចាគហើយ កាលដែលទ្រង់ព្រះជន្មនៅឡើយ បានត្រឹមតែ៩៦កោដិ យើងត្រូវលោះជម្ពូទ្វីបនេះមកវិញដោយដំឡៃប្លួនកោដិ ដើម្បីនឹងធ្វើឲ្យសមមែចសេចក្តីប្រាថ្នារបស់ព្រះបរមសពនោះ" ។

ពួកអាមាត្យទាំងអស់ដំនុំគ្រប់គ្រងគ្នាហើយ ទើបបានលោះជម្ពូទ្វីបដោយដំឡៃមាស ៤ កោដិ ហើយថ្វាយទៅព្រះបាទសម្បទិជាវេជ្ជ-ការ ។ ព្រះពជនុសោរបស់ព្រះបាទសម្បទិ ដែលបានសោយរាជ្យជាដំណព្រះវង្សត្រកូលទ្រង់ព្រះនាមគ្គហបតិ (គហបតិ) ព្រះពជនុសោរបស់ព្រះបាទគ្គហបតិ ។ ល ។ ទ្រង់ព្រះនាមបុស្សរ៉ែន ។ ព្រះពជនុសោរបស់ព្រះបាទបុស្សរ៉ែន ។ ល ។ ទ្រង់ព្រះនាមបុស្សមិត្រ[1] ។ ព្រះបាទបុស្ស-មិត្រ បានប្រឹក្សាជាមួយនឹងពួកសេនាបតីថា "យើងត្រូវធ្វើដូចម្តេចដែលអាចល្បីកេរ្តិ៍ឈ្មោះរបស់យើងឲ្យបានខ្ទរខ្ទាយទៅកន្លងលោកនេះបាន? ។

គ្រានោះ មានសេនាបតីម្នាក់ ក្រាបទូលថា "កន្លងកាលមុន មានស្តេចសោយរាជ្យដែលជាព្រះវង្សរបស់ព្រះអង្គដែរ ទ្រង់សាងព្រះស្តូប

---

๑ អាយុ–វង់–កិង: ពជនុសោរបស់ព្រះបាទសម្បទិទ្រង់ព្រះនាមឫហ្សត្តិ ព្រះពជ-នុសោរបស់ព្រះបាទឫហ្សត្តិទ្រង់ព្រះនាមវិសេន ។ ព្រះពជនុសោរបស់ព្រះបាទវិសេន ទ្រង់ព្រះនាមបុស្សរ៉ែន ។ ព្រះពជនុសោរបស់ព្រះបាទបុស្សរ៉ែន ទ្រង់ព្រះនាមបុស្សមិត្រ ។ ក្នុងទីប្រៀបធៀន: ស្តេចដែលសោយរាជ្យជាដំណពីព្រះបាទអសោកមហាធម្មិកនឹង អាយុ–វង់–កិង ប្លែកតែត្រង់ថាព្រះបាទបុស្សរ៉ែនទៅជាព្រះបាទបុស្សរ៉ែនទៅវិញ ។ ឯព្រះនាមព្រះបាទ វិសេន មិនមានក្នុងអាយុ–វង់–ប្លួនទេ ។

๘๔. ๐๐๐ ហើយបានបរិភោគទានជាមាសមួយរយគោដ៏ ព្រះអង្គបាន ប្រតិបត្តិតបតិបត្តិតាមព្រះធម៌របស់ព្រះពុទ្ធ ដែលមាននៅក្នុងលោកនេះ ជាយូរអង្វែងនាំ ព្រះនាមរបស់ព្រះអង្គនោះតាំងនៅឋិតឋេរហូតមកដល់ សព្វថ្ងៃនេះ" ។

"បើព្រះអង្គបានកសាងព្រះស្តូប ๘๔. ๐๐๐ ដូចយ៉ាងព្រះបាទ អសោកអង្គនោះ. ព្រះនាមរបស់ព្រះអង្គក៏តង់តាំងនៅក្នុងលោកនេះ អស់កាលយូរលង់ទៅដូច្នោះដែរ" ។

ព្រះបាទបុស្សមិត្តត្រាស់តបថា "កន្លងកាលមុនស្តេចសោយជាតិ ដែលជាព្រះរាជ្យរបស់ខ្ញុំនោះព្រះអង្គមានរាជានុភាពគួរនឹងធ្វើវត្តុតាំងនោះ ឲ្យសម្រេចបាន, ឯខ្ញុំដូចម្តេចនឹងធ្វើការងារធំដល់ម្ល៉ោះឲ្យសម្រេចបាន ក្រែងអ្នកមានទុបាយណាមួយដទៃទៀត ដែលស្មើគ្នានឹងព្រះបាទអសោកនោះមានដែរឬ?

ពេលនោះមានសេនាបតី មានសេចក្តីយល់ឃ្វាងផ្សេងគ្នានឹងសេចក្តីចំរើនក្រាបទូលថា ការដែលធ្វើល្អឬធ្វើអាក្រក់ក្នុងអំពើតាំងពីរនេះ គង់បានស្ងួតខ្ចីរកើឈ្មោះស្មើគាគ្នា ព្រោះព្រះពាជាជាន់មុនទ្រង់បានសាងព្រះស្តូប ๘๔. ๐๐๐ ហើយតិត្តិយសរបស់ស្តេច ឋិតនៅអស់កាលយូរអង្វែង ឬបើទោះបីព្រះអង្គធំលាយបង់ព្រះស្តូបតាំងអស់នោះវិញ ក៏គង់

ព្រះនាមរបស់មហាបតិត្រ ទំនឹតាំងនៅជាប់ជាដំណែរបៃណើរៀងក្នុង
អនាគតជាយូរអង្វែងដូចគ្នាដែរ" ។

ព្រះចាន់បុសម្រេចតែងយល់ព្រមតាមគំនិតនោះ ទើបគ្រាស់ឲ្យ
ប្រជុំពលចតុរង្គសេនាហើយស្តេចយាងទៅគាន់វត្តកុក្កដារាម ដោយព្រះ
បំណងនឹងបុកចំលាយបំបែកទ្វារវត្តនោះ តែពេលនោះស្រាប់តែឮសូរ
សីហនាទ (សម្រែកសីង្ហ) សន្ធាប់ខ្លរនៅត្រង់ទ្វារនោះ ព្រះពជ្រាតែងរន្ធត់
ស្បប់ស្បែងព្រោះភ្លាត់យល់មិនអាចហាន់យាងចូលទៅក្នុងវត្តនោះ តែង
លើករេហ៍ពលត្រឡប់មកវិញ ។ ព្រះអគ្គនឹងចូលយាងទៅដល់ប៉ុន្តែ តែ
មិនអាចនឹងចូលទៅបានដូច្នោះ ដល់គ្រាត្រាយបំផុត ព្រះអគ្គមានចាត់
ឲ្យនិមន្តកិកុតាំងឡាយមកហើយគ្រាស់ថា "ខ្ញុំបំណងនឹងលាយបំបាត់
ព្រះពុទ្ធសាសនាចេញ, ទុកកិកុតាំងឡាយពួកលោកតាប់ចិត្តឲ្យខ្ពុកព្រះស្លឹប
ឬឲ្យខ្ពុកដីសេនាសនៈរបស់សង្ឃ?" ។

កិកុតាំងឡាយថ្វាយព្រះពរតបថា "បតិត្រមហាភជ អាត្មាភាព
តាំងអស់គ្នា តាប់ចិត្តរក្សាខ្ពុកព្រះស្លឹប ។

លុះតែងព្រះសណ្តាប់ដូច្នោះហើយ ព្រះចាន់បុសម្រេចកំពាត
ពួកកិកុតាំងអស់នោះទៅ តែងឲ្យលាយបង់នូវដីសេនាសនៈរបស់សង្ឃ
តាំងនោះ ហើយព្រះអង្គខំញាយាមក្នុងកិច្ចបំផ្លាញនោះតាន់រៃ
ចំរើនធំឡើងហួតដល់ទៅដែនសាគល: តែងបានថ្វែងព្រះទន្លាវយោ

ព្រះពជសារៈថា "បើអ្នកណាមួយយកក្បាលសមណៈបានមួយមក ស្បៃយើង អ្នកនោះនឹងត្រូវបានរង្វាន់ជាមាសមួយដុំ" ។

សម័យនោះ ក្នុងប្រទេសនោះ មានព្រះស្តូបមួយធំ ជាទីគោរពស្រឡាញ់នៃព្រះអរហន្តមួយអង្គ(១) ព្រះថេរៈអង្គនោះនិមិត្តធ្វើជាក្បាលសមណៈជាច្រើនតាំង ហើយប្រាប់ឲ្យអ្នកស្រុកនាំយកទៅថ្វាយដល់ព្រះរាជា តាលស្តេចទ្រង់ជ្រាបហេតុនោះហើយ ព្រះរាជាទ្រង់ប្រទានថ្នូរសម្រាប់ព្រះអរហន្តអង្គនោះទៀត តែព្រះថេរៈលោកចូលគាន់អាកាសកសិណាទិមន្តហួសបាត់ទៅ ព្រះរាជាមិនអាចតាមឃាតលោកបាន ។

គ្រានោះព្រះមហាក្សត្រ ស្តេចយាងទៅគាន់ពជរាជធានីឯទៀត ដោយសេចក្តីចំណង់នឹងធ្វើព្រះពុទ្ធសាសនាឲ្យវិនាស នៅក្នុងពជរាជធានីនោះមានយក្សម្នាក់ជាអ្នកគ្រប់គ្រងរក្សាព្រះពុទ្ធសាសនាយក្សនោះគិតថា "អញខ្លួលស៊ីលព្រះសម្មាសម្ពុទ្ធម្ចាស់មិនគួរនឹងធ្វើបាបដល់អ្នកណាឡើយ ប៉ុន្តែអញធ្វើដូចម្តេច ទើបគ្រប់គ្រងព្រះពុទ្ធសាសនាបានហ្ន៎? កាលមុនមានយក្សឈ្មោះភ្លូមិសៈ បានមកសូមធ្វើតាអញតែអញមិនព្រមឲ្យ ព្រោះវាប្រព្រឹត្តខុសច្បាប់ តែឥឡូវនេះ គួរអញឲ្យធ្វើតាអញទៅវានោះបុះដើម្បីបានវាជួយរក្សាព្រះពុទ្ធសាសនាផង" ព្រោះហេតុនេះក្នុងប្រទេសនោះ ទើបពួកយក្សនៅមានអំណាចគ្រប់គ្រងរក្សាព្រះពុទ្ធសាសនា

---

๑ ក្នុងអាយុ. វង្ស. ពិង្ស. ព្រះអរហន្តនោះនៅក្នុងវត្តធម្មិកជា ។

ដោយព្រះបាទបុសរ្សមិត្រមិនហ៊ានទំលាយបង់ ។ ១ណ : នោះភ្លក
យក្សទំាងពួក ដែលរក្សាដើមពោធិព្រឹក្ស នាំគ្នាល្បួងលួងលោម
ភ្លក្ខកដបុរសនាំបណ្តើរត្រមាំងព្រះពុទ្ធជាជន យកទៅហូតដល់មហា-
សមុទ្រខាងត្បូង លុះដល់ទីនោះហើយក៏យក្សឈ្មោះភូមិសៈ លើកថ្មដា
មួយដុំធំមុខគួរសើ្មមអស្ចារ្យគប់បំបែកព្រះសិរព្រះពុទ្ធអង្គនោះស្លាប់ត្រម
ជាមួយគ្នា ទំាងពួកតាបសទាំងអស់ក្នុងទីនោះ ។

ព្រះពុទ្ធវង្សរបាក្យតែក្នុងដែនមគធ ក៏ផុតអស់តែមណោះទៅ(១) ។

ចប់រឿងព្រះបាទអរសោកមហាឥតែប៉ុណ្ណោះ ។

---

១ ក្នុងអាយុ-វង្ស-កំណៈ គតិនោះមក (ក្រុងភ្នំ) ស្តេចយាងចូលទៅទីឯទៀត ដល់ឯក
កោដ្ឋាការនោះមានយក្សម្នាក់ ជាអ្នកត្រួតត្រាក្សាព្រះបង្គុមនៃព្រះពុទ្ធ ឈ្មោះគិតថា
"ព្រះពុទ្ធសាសនាទំាងអស្តង្គនោនទៅ ព្រោះអញជាអ្នកទទួលការៈខាងការពារមិនហានសម្លាប់
សត្វមានពីរាង តែអញមានធីតាដែលយក្សពិសិសបានសូមដណ្តឹងម្តងពីកាលមុន អញមិន
ព្រមឲ្យព្រោះភ័យមិនឈប់ប្រែព្រឹត្តអំពើទុក្ខវិវែតតទៅមួយនេះទេ អញឲ្យធីតាអញទៅ ។ នោះបុះ ដើម្បី
ឲ្យជួយរក្សាព្រះពុទ្ធសាសនាជាង ។ មានយក្សម្នាក់ទៀតចិត្តកាចច្រៃនង់ ជាអ្នករក្សាទ្វារព្រះ
បាទបុសរ្សមិត្រដែរ ព្រោះតែគោយកំឡាំងឫទ្ធានុភាពរបស់យក្សនោះ ទើបមិនមានអ្នកណា
អួយហ៊ានប្រែទុស្តនឹងស្តេចនោះសោះ ។ ទៅភ្លាមអ្នករក្សាព្រះបង្គុមរបស់ព្រះពុទ្ធ ទើបល្បួងតាំ
យក្សនៃលជាអ្នកត្រួតត្រាក្សាស្តេចទៅហូតដល់មហាសមុទ្រខាងត្បូង ក្នុងវេលានោះយក្ស
ឈ្មោះគិលិសបានលើកភ្នំថ្មួយយ៉ាងធំ ចប់បំបែកព្រះបាទបុសរ្សមិត្រ កំទេចត្រមទាំងបតុងង្គ-
សេនា ស្លាប់ទៅជាមួយគ្នាក្នុងទីនោះ ។ ព្រះបាទបុសរ្សមិត្របានបំផ្លាញបង់នូវពួកព្រះពុទ្ធ
នៃលជាមើរ្យវង្សអស់តំរឹមនោះមក ។

គ្រានោះ ពួកមហាជនដក់ចិត្តដោយសម្លេងនោះ នាំគ្នាប្រណម្យ
អញ្ជលី ប្រូនប្រាងប្រុងត្រចៀកនើបមើលស្រែកអង្វរគេថា នែបក្សី
មានសំដីផ្អែមល្ហែមជាទីស្រឡាញ់ មានសំដីទន់ភ្លន់ អ្នកចូរបង្អុរសូរសេព
មកទៀត ព្រះពោធិសត្វបានជាបន្ទូលហេតុទាំងពីរប្រការនេះហើយគិត
ថា អាត្មាអញនឹងពន្យល់ព្រះមាតាឲ្យស្តាប់បាន ក្នុងកាលឥឡូវនេះ
ទើបទូលថា បពិត្រព្រះមេមានគុណធ្ងន់ ពួកមហាជនបានឮសូរសម្លេង
ត្រដេរវិច តណ្ហាលមតិ នាំគ្នាខ្ជប់ត្រចៀកស្រែកយាត់ថា កុំស្រែក…
ជវុសភាថា នាម ន ភសិស្សាមិ បិយា ធម្មាសំដីអាក្រក់ រមែង
មិនជាទីគាប់ចិត្តអ្នកណាមួយសោះឡើយ ក៏ហើយទើបពោលនូវគាថា
ត្រៅទៀតថា:

ន ហិ វណ្ណេន សម្បន្នា មញ្ជុកា បិយភាសិនី.
ទរថា ហិំសា ហោន្តិ អស្មឹ លោកេ បរម្ហិ ច
ឯតុ បស្សសិមំ ភាទ្បឿ សុវណ្ណាំ តំសភាមកំ
កោកិលំ សណ្ហវាចេន ពហូនំ ចាណិនំ បិយំ
តស្មា សចិលវាចស្ស មន្តភាណី អនុទ្ធតោ
អត្ថំ ធម្មញ្ច ទីបេតិ មធុរន្តស្ស ភាសិតន្តិ ។

អធិប្បាយថា: បពិត្រព្រះមាតា ពួកជនដែលមានរូបឆោមល្អ ពាក្យ
មានសម្លេងពីរោះ គ្រាន់តែក្រឡេកឃើញគួរឲ្យចាប់ចិត្ត តែបើមានសំដី

អត្រក់សោះកសោះ បែរទៅជាមិនជាទីពេញចិត្ត (របស់មហាជន) ក្នុងលោកនេះផង លោកខាងមុខផង ដូចជាសត្វត្រដេរវិញ ត្រង់ពាក់កណ្តាលផ្លូវ ។ អ្នកដែលមានរូបពន្លឺអាក្រក់ តែបែកចេញដោយក់ចាំផ្លែមល្អែម សំដីស្អាតពាក្យពេចិ៍សា រមែងជាទីស្រឡាញ់នៃអ្នកផង ហេតុនោះ ខ្ញុំសូមទូលព្រះមាតា ។ បានទតឃើញទេ សត្វតាវើសម្បុរខ្មៅអាក្រក់ទេ តែថាពុកណាជាយ៉ាងនោះក៏ដោយ . តង់ត្រឡប់ជាទីស្រឡាញ់របស់មហាជនដោយសារសំដីផ្អែមល្អែម ។

សត្វកន្លះលោកដែលមានសំដីអាក្រក់ សូម្បីតែមាតាបិតារបស់ខ្លួនបង្កើតក៏មិនពេញចិត្តផង ព្រោះហេតុនោះ បុគ្គលអ្នកប្រាថ្នាឲ្យអ្នកផងមានមេត្រីស្រឡាញ់កប់អាន គប្បីពោលពាក្យគួរស្រឡាញ់ផ្អែមល្អែម ពោលពាក្យស្អាតពាក្យខ្ចន់ភ្ងន់ ចេះលៃលកដោយប្រាជ្ញា ហើយសន្សឹមហាមាត់និយាយ ត្រូវវៀរពោលពាក្យកេយកាយ និយាយឲ្យសមគួរតាមប្រមាណ បើមានអ្នកណាគន្លង់បំភ្លើតធម៌អាថ៌ គប្បីអាងយកភាសិតរបស់បុគ្គលនោះឯងមកជាហេតុ កុំធ្វើឲ្យអ្នកផងខែងាក់អន់ចិត្តបាន ។

ព្រះពោធិសត្វបានសំដែងធម៌ថ្វាយព្រះមាតា ញ៉ាំងព្រះនាងឲ្យយល់បាន ព្រះនាងក៏បរិមូណ៌ដោយបរិយោ មានយោគតរៀងមក ។ ព្រះពោធិសត្វបានញ៉ាំងព្រះមាតាឲ្យលែងយល់ខុសដោយទុក្ខតែម្តងហើយ ទៅតាមច្បាប់គម្ពី ។ ព្រះមាតាបានស្តាប់ នូវធម្មទេសនានេះចប់ ឯព្រះ

(តមក)

យស: បានដល់ឥស្សរិយយស, បុណ្យអំណាច, បរិវារ, អាយុ-វ័យជាដើម រមស់គ្រហស្ថឬបព្វជិត; ខាងបព្វជិតបានដល់សីលផ្ទះនិងគ្នាដែលបានឧបសម្ប៉ែហើយ ដូចលោកបួសថ្មីពីត្រឹម ៥ វស្សាចុះមកជានវកៈកុ, ពីត្រឹម ៥ វស្សាឡើងទៅទល់នឹង ៩ វស្សាជាមជ្ឈិមកៈកុ, ពីត្រឹម ១០ វស្សាឡើងទៅជាថេរ; ពាក្យ ៣ ន័យនេះ ហៅថា យស (ទីបនី) ។

សរសើរ បានដល់ពាក្យអំនួយដែលអ្នកស្រែកគេពេញចិត្តពេញអំនិត ដោយគុណរបស់ខ្លួនគុណណាមួយ ល្មមឲ្យគេអត់ធន់ទ្រាំពុំបានគេក៏ពោលអំនួយជួយជ្រោងឡើងតាមគុណនោះ។ ក្នុងទីចំពោះមុខខ្លះ កំបាំងមុខខ្លះ ហៅថា ពាក្យសរសើរ ។

សុខ: បានដល់សភាពដែលគួរឲ្យរីករាយ-ស្រស់ស្រាយ-ឈាមថ្លាមុខរីកញញឹមញញែម ដោយសមតាមចំណង់តាមប្រាថ្នា ដូចជេត-ដើរ-ឈរ- អង្គុយជាដើម មិនមានសេចក្តីលំបាកជាផលរបស់បុណ្យ ហៅថា សុខ ។

ពាក្យ ៤ ឃាំងនេះ បើប្រគល់ដល់ឲ្យដល់ជនចំពួកណា ហើយទំនងធ្វើជនចំពួកនោះ ឲ្យមានសេចក្តីត្រេកអរឡើងជាងោរ មានបុគ្គលក្នុងលោក

គួរជាខ្មែរគោតខ្ជាបដល់ជនឯទៀត ដោយមានលាភ-យស-ពាក្យសរសើរ-
សេចក្តីសុខខោះឯង ។

ផ្នែកខាងទោស (ពាយ) បានដល់លោកធម៌ ๔ យ៉ាង គឺ អតលាភ ๑
អតយស ๑ ពាក្យទន្ទោ ๑ សេចក្តីទុក្ខ ๑ ទាំង ๔ យ៉ាងនេះ បើប្រគល់
ផលទៅដល់ជនចំពួកណា ហើយ នឹងធ្វើជនចំពួកនោះឲ្យមានសេចក្តីអាក់
អន់តូចចិត្ត មានមុខក្រៀមក្រំខ្មីឆ្មាំ ឥតអំណាចតេជៈអ្វីតិច
តួចក្នុងខ្លួន ពាយក្រៃលែងពាយ ថោកក្រៃលែងថោក សាយក្រៃលែង
សាយ ដោយឥតមានទីសង្ឃឹមគុណណាមួយសោះ, ម្ល៉ោះហើយជនចំពួក
នោះទទួលវេទនាគ្រាន់ថាក់តែផ្នែកខាងទោសមិនដាយទំនងរៀស្រង់ខ្លីឯបាន
ព្រោះខុសបំណងខុសប្បាថ្នាគ្រប់អន្ទឹងទាំងអស់ ។

ផ្នែកទាំង ๒ ដូចបានថ្លែងមកហើយនេះ តែងជាស់ប្តូរវេនគ្នាវិលចុះ
វិលខ្មីឯជាដរាប, បានដាក្រែងពុទ្ធដីកាគ្រន់សំដែងថា: "អដ្ឋ លោក-
ធម្មា លោកំ អនុបរិវត្តន្តិ លោកធម្មាទាំង ๘ ប្រការតែងជាប់ដិត
ដោយតាមសត្វលោកគ្រប់ជាន់គ្រប់ថ្នាក់" ដូចរៀបរៀងមកហើយក្នុង
ប្រាលីនោះ ។

ជនចំពួកមួយ បានទទួលត្រង់តែបែកខាងគុណសុទ្ធ ស្ទើរតែ
ទំនិរហួតមួយជីវិតក៏មានខ្លះ តែដោយស្តួចស្តើងណាស់, ជនចំពួកមួយ

ខ្លួនត្រង់តែប៉ែកខាងទោសសុទ្ធ ស្មើតែនឹងហូតមួយដងតែពៅក៏សឹងមានដាយដែរ ។

បើចែកជាគូវិញមាន ៤ គូ លាយគាំងគុណគាំងទោស (ខ្ពស់ទាប) ច្របូកច្របល់គ្នា គឺមានលាភ អតលាភជាគូ ๑ មានយស អតយសជាគូ ๑ សរសើរ និន្ទាជាគូ ๑ សុខទុក្ខជាគូ ๑ សេចក្តីពិស្តារដូចបានរៀបរៀងមកហើយក្នុងខាងលើស្រាប់ ។

ន័យមួយទៀតក្នុងគម្ពីរខុទ្ទកនិកាយថាមង្គលសូត្រត្រង់គាថាទី ๑๐ សេចក្តីថា :

ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ
អសោកំ វិរជំ ខេមំ តមេវ មង្គលមុត្តមន្តិ ។

(ប្រែថា) ចិត្តរបស់បុគ្គលឯណាដែលលោកធម៌ទាំង ๘ ប្រការ ពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ๑ មិនមានសេចក្តីសោក ๑ មិនមានធុលី គឺកិលេស ๑ ជាចិត្តក្សេមក្សាន្ត ๑ ទាំង ๔ យ៉ាងនេះជាមង្គលដ៏ខ្ពង់ខ្ពស់ ។

តើឯចិត្តនេះ[๑] បើតាមលោកតាមឋាលីមាន ๖ យ៉ាងគឺ ចិត្តំ ចេតោ មនោ វិញ្ញាណំ មានឃំ មានសំ ជានាមធម៌ ๑ យ៉ាងក្លែងក្លាយ មិនមានត្រង់ត្រាយពាណ៌សម្បុរល្មមឲ្យឃើញ ចាប់ពាល់សំគាល់បានដោយ

---

๑. សូមស្រាវជ្រាវតាមព្រះអភិធម្ម ឬ វិសុទ្ធិមគ្គនោះចុះ ។

ដាយខ្លីយ គ្រាន់តែមានសភាពតិតនឹកវិញ្ញាណអារម្មណ៍ រក
ហេតុផ្សេង ។ ប៉ុណ្ណោះ ។

បើគោលតាមរូបសព្ទពាក្យវែកញែកដូចខ្លះគឺ:

๑- ធម្មជាតគិតនឹកអារម្មណ៍ ឬដឹងស្គាល់អារម្មណ៍ ឈ្មោះ
ថា ចិត្ត ។

๒- ធម្មជាតសន្សំអារម្មណ៍ ឬគ្រាប់ទៅតាមអារម្មណ៍ ឈ្មោះថា
វេទនា ។

๓-. ធម្មជាតដឹងអារម្មណ៍ ក់ស់ខ្ទមន់ ក់ស់ដំកៅ ថ្ងូង ស្ងួត
លៃលក ឬ អុំសួអារម្មណ៍ ឈ្មោះថា មនោ ។

๔-. ធម្មជាតិសម្រាប់ដឹង ស្គាល់អារម្មណ៍ដោយវិសេស ឈ្មោះ
ថា វិញ្ញាណ ។

๕-. ធម្មជាតសម្រាប់ខ្ជួលគ្រងរឹងអារម្មណ៍តីសេចក្តីលំបាក-ល្អ-
អាក្រក់-សុខ-ទុក្ខគ្រប់ប្រការ ឈ្មោះថា ហេយ ។

๖-. ធម្មជាតសម្រាប់ផ្តួចផ្តើម-ផ្តងគំនិត-បំណង-ប្រថ្នា ឈ្មោះ
ថា មានស:

រូបសព្ទទាំង ๖ យ៉ាងនេះ ផ្សេងគ្នាតែគ្រងំពាក្យវែក, ឯអត្ថសេចក្តី
នៅតែមួយដូចគ្នា គឺចិត្តនេះឯង; សមដូចពាក្យថា ចិត្តបុណ្យ, ចិត្ត
បាប, ចិត្តល្អ, ចិត្តអាក្រក់ ។ល។ បើគោលដោយកិច្ចរបស់ចិត្តវិញ

មាន ๓ យ៉ាង គឺសេចក្តីសំគាល់ចាំបានថា: ស, ខ្ញុំ, តែហម, ខ្ញុំជាដើម ជាកិច្ចវេទនាសញ្ញា[๑] ๑, សេចក្តីដឹងច្បាស់លាស់ថា: ស, ខ្ញុំ, តែហម, ខ្ញុំ រហូតដល់ដឹងវិតែលក្ខណញ្ញាណ គឺ: អនិច្ចំ ទុក្ខំ អនត្តា តែមិនអាចនឹងធ្វើដំណើរទៅឈានឯកមគ្គ-ផលបានឡើយ ជាកិច្ចវេទនាវិញ្ញាណ ๑, សេចក្តីដឹងវិសេសជាងសញ្ញានឹងវិញ្ញាណជាងពីរនេះផង អាចនឹងធ្វើដំណើរទៅឈានឯកមគ្គ.ផលព្រះនិព្វានបាន តាមទំនើងខ្លួនឯងផង ជាកិច្ចវេទនាបញ្ញា (សោតណាវេតសិក) ๑ ។ កិច្ចទាំង ๓ យ៉ាងនេះ មានគួរនាដូចជនទាំង ๓ ពួក គឺតាវតគួច ๑ មនុស្សធំដឹងក្តី ๑ នាយជាងមាស ๑ ។

ឯតាវតគួច ๑ បើប្រសិនជាបានឃើញរូបកហាបណៈថ្មីរូបមាសកក់ គ្រាន់តែដឹងថា វែង ខ្ចី ជ្រួង មូល ខ្ញុំ ស តែមប៉ុណ្ណោះក៏ផុតគំនិតទៅ មិនបានដឹងថាជារបស់អតដំខ្លៃមានដំខ្លៃ អ្នកប្រៈទេសគេតែងតបអានទុកជាគ្រឿងទេបគោត បរិគោតកំទេ ។

ចំណែកខាងមនុស្សធំដឹងក្តី ទើបបានដឹងថា រូបកហាបណៈថ្មមាសកនេះ ជារបស់ល្អវិចិត្រ វែង ខ្ចី ជ្រួង មូល ខ្ញុំ ស ត្រមាំងដឹងថារបស់នេះមានដំម្ល អ្នកប្រទេសគេតែងទិញមកបតអានទុកជាគ្រឿងទេបគោត

---

๑ សញ្ញាចិត្តហាឆារណាវេតសិកមាន ๔ គឺ: ផិសញ្ញា, វេទនា, សញ្ញា, វេតនា, ឯកគ្គតា, ជីវិតិន្ទ្រិយោ, មនសិការោ ។ អភិធម្ម ។

ចរិតគោតម្រីមប៉ុណ្ណោះក៏ផុតគំនិតរៀ នឹងបានដឹងថារូបកហាបណៈ ឬមាសកនេះមានទឹកខ្ពស់-ទាប មានសាច់ពេញលេញចរិសុទ្ធផ្លូវធំ ជាមាសក្រហម មាសសាយដោយទង់ដែង ឬលាយដោយជាតិដទៃក៏ទេដែរ ។

ចំណែកខាងឯនាយជាងមាសវិញ ទើបដឹងស្គាល់ហ្មត់ថារូបកហាបណៈឬមាសកនេះ មានទឹកខ្ពស់ មានសាច់ពេញលេញចរិសុទ្ធផ្លូវធំ ជាមាសក្រហមសុទ្ធ-សុទ្ធឥតលាយដោយទង់ដែង ឬលាយដោយជាតិដទៃទេ មានជម្ងៃត្រឹមប៉ុណ្ណោះ, កើតនៅលើក្តីកដ៏សមគួរ ផុតទុក្ខចប់ ដំបន់ឯណោះ។ មិនមានរឿងត្រូវនឹងគំនិតឡើយ ។

សញ្ញាប្រៀបគួរនាដូចជាកេតូច ។, រឿងណាដូចមនុស្សធំដឹងក្តីក៏ដើរ-ឆ្ងាំស្រាល,បញ្ជាដូចនាយជាងមាសស្គាល់ជាតិមាសមិនតាំងប្រឡំដូច្នោះឯង ។

មួយវិញទៀត ចិត្តនេះបើចាត់ដោយសណ្ឋានពីសវិញ ក៏ពីសណាស់ក្រៃលែងជាងសត្វពាន ឬក្រៃលែងជាងពាកេតូច ដែលនៅដេកផ្ងារមិនស្ងៀមស្ងាត់នៅក្នុងអារម្មណ៍មួយ។ ឡើយ ប្រហែលដូចសត្វមច្ចជាតិត្រីដែលប្តូរបស្រង់ឡើងជាក់លើគោក ហើយក៏រមែងទំនឹងស្ទុះស្ទួរធ្លាប់ទីនៃលទៅកេទឹកវិញ មិនងាយនឹងស្ងៀតនៅនឹងឡើយ, ហើយជាធម្មជាតិតែងអាស្រ័យនៅជាមួយនឹងរូបមនុស្ស - សត្វតិរច្ឆាន - ទេវតា

ដោយច្រើន, ដូចមានសេចក្តីកន្លងមកថ្មីថា នាម ១-រូប ១, រូបបានដល់រូបក្ខន្ធ, នាមបានដល់វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ, របស់ទាំងពីរនេះតែងជាប់ជិតដោយគាមន្តគ្រប់ ៦ ដំណាក់, បើនាមបែរមុខឈមទៅកាន់ដំណាក់ខាងសុគតិ រូបក៏ទៅតាម, បើនាមបែរមុខឈមទៅកាន់ដំណាក់ខាងទុគ្គតិ រូបក៏ទៅតាមដូចមូលនិធិរបស់ជូញ្ជាងឯង ។

តែកន្លងនេះ មានបំណងនឹងសំដែងតែអំពីចិត្ត ដែលមិនរំលើចញាប់ញ័រដោយលោភមិណាមួយមកប៉ះពាល់, ដែលពាក្យថាជាមង្គលប៉ុណ្ណោះ ព្រោះកន្លងបទគាថាទី ១០ នោះជាប់ទាក់ទងដោយមង្គល ៤ ប្រការដូចបានពណ៌នាមកហើយខាងលើស្រាប់ ។

ត្រង់ពាក្យថា: មង្គល បានដល់សេចក្តីល្អ សេចក្តីចំរើនសុខសាន្ត គ្រាណគ្រប់ជាន់គ្រប់ថ្នាក់ ទាំងលោកិយៈ លោកុត្តរៈ ហៅថា មង្គល ដូចគ្នានឹងពាក្យថា បុណ្យ-ផល កុសលានិសង្សនោះដែរ ។

ក៏ឯមង្គលទាំង ៤ ប្រការនោះ នឹងលើកមង្គល ៣ ខុទ. សូមរៀបរៀងចំពោះតែអកម្មកិតចិត្តមង្គល ១ ដូចមានតទៅនេះ ។

សេចក្តីថា: ចិត្តរបស់បុគ្គលដំនាន់ណាមួយ ទោះបីបុថុជ្ជនក្តី អរិយសាវកក្តី ដែលជាចិត្តមិនរំលើចញាប់ញ័រដោយលោភមិទាំង ៨ ប្រការសូម្បីលោភមិណាមួយ ចិត្តរបស់បុគ្គលនោះហៅថាមង្គល ដូចមានព្រះភាសិតថា: (មានត)

ចំណួនចៅអធិការធំៗមន្ត្រីសង្ឃ

នៃសេចក្តីបង្គាប់ឯកឧត្តម-អ៊ូត-សេបតម្ប្រ៊ី-ខាតូប្រ៊ី-ណូវ៉ែម្ប៊ី ឆ្នាំ ១៩៤៣

(តទៅ)

១៨ - សញ្ញាប័ត្រលេខ ៦៨ ចុះថ្ងៃ ១៩-៨-៤៣ តាំងគ្រូសូត្រ កើត-ឆេង កើតឆ្នាំកេង អាយុ ២៨ វស្សា ៧ នាមធាយ រ៉ៃយត្នោ ជាចៅអធិការ វត្តពោធិ៍មុនី ឃុំស្វាយចេក ស្រុកវាំងភ្លូ (ស្វាយរៀង) ។

១៩ - សញ្ញាប័ត្រលេខ ៧០ ចុះថ្ងៃ ១៩-៨-៤៣ តាំងគ្រូសូត្រ ខៀ-ញ៉ែវ កើតឆ្នាំខាល អាយុ ២៨ វស្សា ៦ នាមធាយ បញ្ញាសរ ជាចៅអធិការ វត្តតាយ៉ន ឃុំតាំងគក ស្រុកវាំងភ្លូ (ស្វាយរៀង) ។

២០ - សញ្ញាប័ត្រលេខ ៧១ ចុះថ្ងៃ ២៤-៨-៤៣ តាំងគ្រូសូត្រ ហៅ-ស៊ុត កើតឆ្នាំខាល អាយុ ៣០ វស្សា ១០ នាមធាយ ធម្មត្នោ ជាចៅអធិការ វត្តល្វា ឃុំសំរោប ស្រុកស្អាង (កំពង់ធំ) ។

២១ - សញ្ញាប័ត្រលេខ ៧២ ចុះថ្ងៃ ២៤-៨-៤៣ តាំងគ្រូសូត្រ ស-ម៉ម កើតឆ្នាំជូត អាយុ ៦៨ វស្សា ៤៩ នាមធាយ ធម្មប្បញ្ញា ជាចៅអធិការ វត្តពតេង ឃុំចុងជូរ ស្រុកបាកយណ៍ (កំពង់ធំ) ។

២២ - សញ្ញាប័ត្រលេខ ៧៣ ចុះថ្ងៃ ២៤-៨-៤៣ តាំងគ្រូសូត្រ ស៊ន-ប៊ិច កើតឆ្នាំច អាយុ ៧០ វស្សា ៤៩ នាមធាយ ព្រហ្មត្នោ ជាចៅអធិការ វត្តទ្រាំដូង ឃុំចុងជូរ ស្រុកបាកយណ៍ (កំពង់ធំ) ។

២៣ - សញ្ញាប័ត្រលេខ ៧៤ ចុះថ្ងៃ ២៤-៨-៤៣ តាំងគ្រូសូត្រ
ឧប-ណាំ កើតឆ្នាំទាល ៤៤ឆ្នាំ ៤៣ វស្សា ៣២ នាមនាយា សុវណ្ណគ្នេរ
ជាចៅអធិការ វត្តអារគ្រាច ឃុំព្រៃឈរ ស្រុកកំពង់ត្រែក (ព្រៃវែង) ។

២៤- សញ្ញាប័ត្រលេខ ៧៥ ចុះថ្ងៃ ១១-៨-៤៣ តាំងលោកគ្រូ
កែវ-ឡុង កើតឆ្នាំមមី អាយុ ៦៣ ឆ្នាំ វស្សា ២៦ នាមនាយា សុវណ្ណ-
ប្បញ្ញា ជាចៅអធិការ វត្តសំរោងសែន ឃុំសំរោងសែន ស្រុកកំពង់-
លែង (កំពង់ឆ្នាំង) ។

២៥- សញ្ញាប័ត្រលេខ ៧៦ ចុះថ្ងៃ ២៣-៨-៤៣ តាំងលោកគ្រូ
សុក-អាំ កើតឆ្នាំរកា អាយុ ៤៧ ឆ្នាំ វស្សា ២៣ នាមនាយា ជវនធម្ម
ជាចៅអធិការ វត្តខ្នុរ ឃុំត្រងិល ស្រុកកំពង់លែង (កំពង់ឆ្នាំង) ។

២៦- សញ្ញាប័ត្រលេខ ៧៧ ចុះថ្ងៃ ៤-១០-៤៣ តាំងលោកគ្រូ
មៀ-ខាន់ កើតឆ្នាំកុរ អាយុ ៣៣ ឆ្នាំ វស្សា ១៣ នាមនាយា សុវណ្ណធម្ម
ជាចៅអធិការ វត្តត្រពាំងប្រី ឃុំត្រពែក ស្រុកកំចាយមារ (ព្រៃវែង) ។

២៧- សញ្ញាប័ត្រលេខ ៧៨ ចុះថ្ងៃ ១៨-១០-៤៣ តាំងលោកគ្រូ
អឹម-ឃុន កើតឆ្នាំច អាយុ ២៦ ឆ្នាំ វស្សា ២ នាមនាយា យោសត្ថេរ ជា
ចៅអធិការ វត្តអូរគោខ្នុញ ឃុំប្រវែស ស្រុកសំរោងទង (កំពង់ស្ពឺ) ។

២៨- សញ្ញាប័ត្រលេខ ៧៩ ចុះថ្ងៃ ១៩-១០-៤៣ តាំងលោកគ្រូ
ងួន ប៊ុច កើតឆ្នាំរោង អាយុ ២៩ ឆ្នាំ វស្សា ៨ នាមនាយា មុនីបញ្ញា

ជាចៅអធិការ វត្តអន្លង់ថ្ម ឃុំត្រែងជាំងគង ស្រុកសំរោងទង (តំពង់ស្ពឺ) ។

២៩- សញ្ញាប័ត្រលេខ ៤ ចុះថ្ងៃ ១៣-១១-៤៣ តាំងលោកគ្រូ ម៉ៅ-ខួន កើតឆ្នាំកែ អាយុ ៣៦ ឆ្នាំ នាមឆាយា ឃុណ្ណោ ជាចៅអធិការ វត្តត្រែងពោន ឃុំចាម ស្រុកតំពង់ត្រែបែក (ត្រៃវែង) ឯណោះគម្រប់ត្តិ ។

៣០- សញ្ញាប័ត្រលេខ ៨១ ចុះថ្ងៃ ១៦-១១-៤៣ តាំងលោកគ្រូ ខេត-សំ កើតឆ្នាំកេរ អាយុ ៤១ ឆ្នាំ វស្សា ២១ នាមឆាយា សុវណ្ណវ័ន្ទ ជាចៅអធិការ វត្តថ្មាលាន់ ឃុំចាម ស្រុកតំពង់ត្រែបែក (ត្រៃវែង) ។

ខ្ញុំលោកផ្ញើនដែលបានកែឆ្នៃរឿងពិធីបុណ្យបវេណីតប្រចាំឆ្នាំ លោកនៅឆ្ងាយ ខ្ញុំមិនពិធីបុណ្យទំមន្តព្រះសង្ឃជាន់ខ្ពស់តាមបាន

ការតើខែស្នូរយេត ឆ្នាំ ១៩៤៣ កិរដ្ឋាំងខ្ញុំបង រួបរួមទំនៀមទម្លាប់ខ្មែរ បានយោសនាចុះក្នុងទស្សនាវដ្តីពុទ្ធសុរិយា សុំឲ្យអ្នកពេះនឹងចាំនួយ ពែងចាំកូនរឿងពិធីបុណ្យបវេណីតប្រចាំឆ្នាំ ពិយកទៅបាង ខ្ញុំងរឿងពិធីបុណ្យទំមន្តព្រះសង្ឃចុះទូកទៅជាន់ខ្ពស់តាមបាង ។ ពែងហើយបញ្ជូនទៅឲ្យក្រុមដំណុំងរួបរួមទំនៀមទម្លាប់ខ្មែរ នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ។

ដោះពាលតាំងថ្ងៃ ៤ បង្កំងវិ ឃរ ឆ្នាំ ១៩៤៤ ក្រុមដំណុំបានពិនិត្យទៅឃើញសេចក្តីពែងរបស់លោកគ្រូ ចិត-សាំង ចៅអធិការវត្តល្អ ឃុំកំរ ងំបង្ហាំង ស្រុកជីក្រែង ខែត្រសៀមរាប ល្អដាងគេ, សរម្រែចថាត្រូវឲ្យបានខ្ញុំងទៅទី ១ ជាសៀវភៅផ្សេង ៦ រួមជាងំខ្ញែ ១០,០០ នឹង លោក ឈឹម-ធី ស្មៀនសាលាខែត្រពោធិសាត់ បាន៖ភ្ញៀនទី ២ ជាសៀវភៅផ្សេង ៥ រួមជាងំខ្ញែ ៥,០០ ពេលឃើលោកខេះ ពែងរឿងពិធីបុណ្យទទួលព្រះសង្ឃជាន់ខ្ពស់តាមបាង ម៉ែងស្ងួលល្អ មិនសូវត្រូវ ។

អធិបតីក្រុមដំណុំ

សេចក្តីផ្តួងដំណឹង

អំពីទស្សនាវដ្តី កម្ពុជសុរិយា

ក្នុងឆ្នាំ ១៩៨៤ នេះ យើងសូមជំរាបជូនលោក-អ្នក មើលកម្ពុជសុរិយាថា ឆ្នាំថ្មីនេះយើងនឹងទំព្រឹងរៀបចំផ្សំរឿងភ័ន្តវែងកាន់តែពីរោះពិសាគ្រប់ទាំងសារពាជាតិ ដូចជា គោលបាំរកាងពង្សាវតារខ្មែរជាដើម ។

ន្លែករឿងប្រលោមលោកនឹងមានចុះផ្សាយជូនលោក-អ្នកមើលលេងកំសាន្តចិត្ត រួចហើយ យើងមានរឿងប្រលោមលោកមួយហើយ ហៅថា "កំពូលកំសត់" រឿងនេះ យើងហ៊ានអួតថា ជារឿងកំសត់មែនទៀ ដែលខ្មែរយើងចូលចិត្តមើលណាស់ទាំងសំនួនភេហារក៏ពីរោះពិសាគួរឲ្យចង់មើលចង់ស្តាប់ ... ។ ក្រៅអំពីនេះ យើងប្រុងនឹងរៀបចំឲ្យមានរឿងល្ខោនដោយឡែកថែមទៀត ដើម្បីជារង្វើងកំសាន្តចិត្តនឹងនាំឲ្យបានចំរើនពាក្យពេចន៍ដ៏ខ្មែរទំនើបថ្មីផង ។

មួយវិញទៀត គោលបាំរកាងពង្សាវតារនឹងក្លាយជាមិត្តរបស់ខាងប្រទេស បើមានក្រដាសល្មមនឹងចុះផ្សាយរឿងសំខាន់ៗ អស់ទេះបាន យើងក៏នឹងចុះផ្សាយជូនអស់លោក-អ្នកមើលកម្ពុជសុរិយារៀងរាល់ខែក្នុងឆ្នាំ ១៩៨៤ នឹងឆ្នាំតទៅ ។

រួមសេចក្តីថា ក្នុងន្លែកអក្សរសាស្ត្ររបស់យើងមានទាំងរឿងពែង រឿងប្រែ-ទាំងភាសាវាយ-ទាំងភាសាកាឡៃ ។

* *
*

ចំណែកខាងន្លែកសាសនារបស់យើង ក៏មានរឿងភ័ន្តល្អៗ ជាច្រើនដែលអស់លោកអ្នកគ្រាន់ខាងក្រែមដំនុំព្រះត្រៃបិដកបានរៀបរៀងមកចុះផ្សាយក្នុងកម្ពុជសុរិយាទេះ ក្រៅអំពីនេះ នៅមានដំណឹងតាំងពីអធិការ នឹងបុណ្យបញ្ចុះសីមា គ្រប់ទាំងបុណ្យខាងព្រះពុទ្ធសាសនាផ្សេងៗ ទៀតផង ។

ក្នុងទីបំផុតទេះ យើងសូមរំលឹកដល់ប្រជាជនជាតិខ្មែរជាពុទ្ធសាសនិកជនទាំងឡាយថា:

កិច្ចខំនុកបំរុងអក្សរសាស្ត្រខ្មែរនឹងព្រះពុទ្ធសាសនា ជាការយ៉ាងសំខាន់បំផុត ក្នុងការជួយស្រោចស្រង់ប្រទេសជាតិខ្មែរឲ្យបានគង់ធ្ងន់នៅនឹងឲ្យបានចំរើនលូតលាស់តទៅក្នុងអនាគតកាល ។

បណ្ណាធិការ